# ព្រះ
# ត្រៃបិដកបាលិ
## និង
## សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## មជ្ឈិមនិកាយ មូលបណ្ណាសក
## ទុតិយភាគ
# ២១

បោះពុម្ពលើកទី ៣

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០៥

# ឱបម្មវគ្គោ

## បឋមំ កកចូបមសុត្តំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា មោលិយផគ្គុនោ ភិក្ខុនីហិ សទ្ធឹ អតិវេលំ សំសដ្ឋោ វិហរតិ ។ ឯវំ សំសដ្ឋោ អាយស្មា មោលិយផគ្គុនោ ភិក្ខុនីហិ សទ្ធឹ វិហរតិ ។ សចេ កោចិ ភិក្ខុ អាយស្មតោ មោលិយផគ្គុនស្ស សម្មុខា តាសំ ភិក្ខុនីនំ អវណ្ណំ ភាសតិ តេនាយស្មា មោលិយផគ្គុនោ កុបិតោ អនត្តមនោ អធិករណម្បិ ករោតិ ។ សចេ បន កោចិ ភិក្ខុ តាសំ ភិក្ខុនីនំ សម្មុខា អាយស្មតោ មោលិយផគ្គុនស្ស អវណ្ណំ ភាសតិ តេន ភិក្ខុនិយោ កុបិតា អនត្តមនា អធិករណម្បិ ករោន្តិ ។ ឯវំ សំសដ្ឋោ អាយស្មា មោលិយផគ្គុនោ ភិក្ខុនីហិ សទ្ធឹ វិហរតិ ។

# ឱបម្មវគ្គ

## កកចូបមសូត្រ ទី ១

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គឺសម័យនោះឯង ព្រះមោលិយផគ្គុន មានអាយុ នៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនី ហួសវេលា ។ ព្រះមោលិយផគ្គុន មានអាយុ តែងនៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីយ៉ាងនេះ ។ បើមានភិក្ខុណាមួយ ពោលទោសពួកភិក្ខុនីទាំងនោះ ក្នុងទីចំពោះមុខព្រះមោលិយផគ្គុន មានអាយុ ព្រះមោលិយផគ្គុន មានអាយុ ក៏ខឹងតាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ ដោយហេតុនោះផង ។ បើមានភិក្ខុណាមួយពោលទោសព្រះមោលិយផគ្គុន មានអាយុ ក្នុងទីចំពោះមុខពួកភិក្ខុនីទាំងនោះ ពួកភិក្ខុនីក៏ខឹងតាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង ។ ព្រះមោលិយផគ្គុនមានអាយុ តែងនៅប្រឡូកប្រឡំ ដោយពួកភិក្ខុនី យ៉ាងនេះ ។

អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អាយស្មា ភន្តេ មោលិយផគ្គុនោ ភិក្ខុនីហិ សទ្ធឹ អតិវេលំ សំសដ្ឋោ វិហរតិ ឯវំ សំសដ្ឋោ ភន្តេ អាយស្មា មោលិយផគ្គុនោ ភិក្ខុនីហិ សទ្ធឹ វិហរតិ សចេ កោចិ ភិក្ខុ អាយស្មតោ មោលិយផគ្គុនស្ស សម្មុខា តាសំ ភិក្ខុនីនំ អវណ្ណំ ភាសតិ តេនាយស្មា មោលិយផគ្គុនោ កុបិតោ អនត្តមនោ អធិករណម្បិ ករោតិ សចេ បន កោចិ ភិក្ខុ តាសំ ភិក្ខុនីនំ សម្មុខា អាយស្មតោ មោលិយផគ្គុនស្ស អវណ្ណំ ភាសតិ តេន តា ភិក្ខុនិយោ កុបិតា អនត្តមនា អធិករណម្បិ ករោន្តិ ឯវំ សំសដ្ឋោ ភន្តេ អាយស្មា មោលិយផគ្គុនោ ភិក្ខុនីហិ សទ្ធឹ វិហរតីតិ ។



គ្រានោះ មានភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានបុណ្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុន មានអាយុ នៅច្រឡូកច្រឡំជាមួយនឹងពួកភិក្ខុនី ហួសវេលា បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុនមានអាយុ តែងនៅច្រឡូកច្រឡំ ជាមួយនឹងពួកភិក្ខុនីយ៉ាងនេះ បើមានភិក្ខុណាមួយពោលទោសភិក្ខុនីទាំងនោះ ក្នុងទីចំពោះមុខមោលិយផគ្គុន មានអាយុ មោលិយផគ្គុន មានអាយុ ក៏ទាស់អាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង បើមានភិក្ខុណាមួយ ពោលទោសមោលិយផគ្គុន មានអាយុ ក្នុងទីចំពោះមុខភិក្ខុនីទាំងនោះ ភិក្ខុនីទាំងអម្បាលនោះ ក៏ទាស់អាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុនមានអាយុ តែងនៅច្រឡូកច្រឡំជាមួយនឹងពួកភិក្ខុនី យ៉ាងនេះឯង ។

[៦] អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន មោលិយផគ្គុនំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ មោលិយផគ្គុន អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា មោលិយផគ្គុនោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មោលិយផគ្គុនំ ឯតទវោច សត្ថា តំ អាវុសោ មោលិយផគ្គុន អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ អាយស្មា មោលិយផគ្គុនោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ មោលិយផគ្គុនំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ ផគ្គុន ភិក្ខុនីហិ សទ្ធឹ អតិវេលំ សំសដ្ឋោ វិហរសិ ឯវំ សំសដ្ឋោ ត្វំ(១) ផគ្គុន ភិក្ខុនីហិ សទ្ធឹ វិហរសិ សចេ កោចិ ភិក្ខុ តុយ្ហំ សម្មុខា តាសំ ភិក្ខុនីនំ អវណ្ណំ ភាសតិ តេន ត្វំ កុបិតោ អនត្តមនោ អធិករណម្បិ ករោសិ

១ ឱ. ម. កិរ ត្វំ ។





[៦] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ១ រូប មកថា ម្នាលភិក្ខុ ចូរអ្នកមកកាយ អ្នកចូរទៅហៅមោលិយផគ្គុនភិក្ខុតាមពាក្យតថាគតថា ម្នាលអាវុសោមោលិយផគ្គុន ព្រះសាស្តា ទ្រង់ត្រាស់ហៅអ្នក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកមោលិយផគ្គុនមានអាយុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងព្រះមោលិយផគ្គុនមានអាយុថា ម្នាលអាវុសោមោលិយផគ្គុន ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ព្រះមោលិយផគ្គុន មានអាយុ ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមោលិយផគ្គុនមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ មានពុទ្ធតម្រាស់នេះថា ម្នាលផគ្គុន បានឮថា អ្នកនៅច្រឡូកច្រឡំជាមួយនឹងពួកភិក្ខុនីហួសវេលា ពិតមែនឬ ម្នាលផគ្គុន អ្នកនៅច្រឡូកច្រឡំជាមួយនឹងពួកភិក្ខុនីយ៉ាងនេះ បើមានភិក្ខុណាមួយពោលទោសពួកភិក្ខុនីនោះក្នុងទីចំពោះមុខអ្នក ៗក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង

សចេ បន កោចិ ភិក្ខុនីនំ(១) សម្មុខា តុយ្ហំ អវណ្ណំ ភាសតិ តេន តា ភិក្ខុនិយោ កុបិតា អនត្តមនា អធិ-ករណម្បិ ករោន្តិ ឯវំ សំសដ្ឋោ កិរ ត្វំ ផគ្គុន ភិក្ខុនីហិ សទ្ធឹ វិហរសីតិ ។ ឯវំ ភន្តេ ។ ននុ ត្វំ ផគ្គុន កុល-បុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោតិ ។ ឯវំ ភន្តេ ។ ន ខោ តេ ឯតំ ផគ្គុន បតិរូបំ កុល-បុត្តស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតស្ស យំ ត្វំ ភិក្ខុនីហិ សទ្ធឹ អតិវេលំ សំសដ្ឋោ វិហរេយ្យាសិ ។ តស្មាតិហ ផគ្គុន តវ ចេបិ កោចិ សម្មុខា តាសំ ភិក្ខុនីនំ អវណ្ណំ ភាសេយ្យ តត្រាបិ ត្វំ ផគ្គុន យេ គេហសិតា ឆន្ទា យេ គេហសិតា វិតក្កា តេ បជ-ហេយ្យាសិ តត្រាបិ(២) ផគ្គុន ឯវំ សិក្ខិតព្វំ ន ចេវ មេ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាមិ ហិតានុកម្បី ច វិហរិស្សាមិ

១ ឱ. ម. សចេ បន កោចិ ភិក្ខុ តាសំ ភិក្ខុនីនំ ។ ២. ឱ. ម. តត្រាបិ តេ ។



ពុំនោះសោត បើមានភិក្ខុណាមួយ ពោលទោសអ្នក ក្នុងទីចំពោះមុខពួកភិក្ខុនី ។ នោះក៏ខឹងតាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ ដោយហេតុនោះផង ម្នាលផគ្គុន បានឮថាអ្នកតែងនៅច្របូកច្របល់ជាមួយនឹងពួកភិក្ខុនីយ៉ាងនេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលផគ្គុន ចុះក្រែងអ្នកជាកុលបុត្រចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធា ។ ព្រះករុណាព្រះអង្គ ។ ម្នាលផគ្គុន អ្នកនៅច្របូកច្របល់ជាមួយនឹងពួកភិក្ខុនីហួសវេលា ដោយអំពើណា អំពើនុ៎ះមិនសមគួរដល់អ្នក ដែលជាកុល-បុត្រចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធាឡើយ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានភិក្ខុណាមួយ ពោលទោសពួកភិក្ខុនីនោះ ចំពោះមុខអ្នក ម្នាលផគ្គុន ឆន្ទៈណា ដែលអាស្រ័យនូវផ្ទះគឺបញ្ច-កាមគុណ វិតក្កៈណា ដែលអាស្រ័យនូវផ្ទះគឺបញ្ចកាមគុណ អ្នកគប្បីលះបង់ឆន្ទៈនិងវិតក្កៈទាំងនោះ ក្នុងការពោលទោសនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការពោលទោសនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញ នឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង អាត្មាអញនឹងជាអ្នកមានសេចក្តីអនុគ្រោះ ដោយប្រយោជន៍

មេត្តចិត្តោ ន ទោសន្តរោតិ ឯវញ្ហិ តេ ផគ្គុន សិក្ខិតព្វំ ។ តស្មាតិហ ផគ្គុន តវ ចេបិ កោចិ សម្មុខា តាសំ ភិក្ខុនីនំ បាណិនា បហារំ ទទេយ្យ លេឌ្ឌុនា បហារំ ទទេយ្យ ទណ្ឌេន បហារំ ទទេយ្យ សត្ថេន បហារំ ទទេយ្យ តត្រាបិ ត្វំ ផគ្គុន យេ គេហសិតា ឆន្ទា យេ គេហសិតា វិតក្កា តេ បជហេយ្យាសិ តត្រាបិ តេ ផគ្គុន ឯវំ សិក្ខិតព្វំ ន ចេវ មេ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាមិ ហិតានុកម្បី ច វិហរិស្សាមិ មេត្តចិត្តោ ន ទោសន្តរោតិ ឯវញ្ហិ តេ ផគ្គុន សិក្ខិតព្វំ ។ តស្មាតិហ ផគ្គុន តវ ចេបិ កោចិ សម្មុខា អវណ្ណំ ភាសេយ្យ តត្រាបិ ត្វំ ផគ្គុន យេ គេហសិតា ឆន្ទា យេ គេហសិតា វិតក្កា តេ បជហេយ្យាសិ តត្រាបិ តេ ផគ្គុន ឯវំ សិក្ខិតព្វំ ន ចេវ មេ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាមិ



ជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានភិក្ខុណាមួយ ឲ្យនូវការប្រហារដោយដៃ ឲ្យនូវការប្រហារដោយដុំដី ឲ្យនូវការប្រហារដោយដំបង ឲ្យនូវការប្រហារ ដោយគ្រឿងសស្ត្រា ដល់ពួកភិក្ខុនីនោះ ក្នុងទីចំពោះមុខអ្នក ម្នាលផគ្គុន ឆន្ទៈណា ដែលអាស្រ័យនូវផ្ទះគឺបញ្ចកាមគុណ វិតក្កៈណា ដែលអាស្រ័យនូវផ្ទះគឺបញ្ចកាមគុណ អ្នកគប្បីលះបង់នូវឆន្ទៈនិងវិតក្កៈទាំងនោះ ក្នុងការឲ្យនូវប្រហារនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការឲ្យនូវប្រហារនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញនឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង អាត្មាអញនឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលផគ្គុន ព្រោះហេតុនោះបើប្រសិនជាមានភិក្ខុណាមួយពោលទោសចំពោះមុខអ្នក ម្នាលផគ្គុន ឆន្ទៈណា ដែលអាស្រ័យនូវផ្ទះគឺបញ្ចកាមគុណ វិតក្កៈណាដែលអាស្រ័យនូវផ្ទះគឺបញ្ចកាមគុណ អ្នកគប្បីលះបង់នូវឆន្ទៈនិងវិតក្កៈទាំងនោះ ក្នុងការពោលទោសនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការពោលទោសនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញនឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង

ហិតានុកម្បី ច វិហរិស្សាមិ មេត្តចិត្តោ ន ទោសន្តរោតិ ឯវញ្ហិ តេ ផគ្គុន សិក្ខិតព្វំ ។ តស្មាតិហ ផគ្គុន តវ ចេបិ កោចិ បាណិនា បហារំ ទទេយ្យ លេឌ្ឌុនា បហារំ ទទេយ្យ ទណ្ឌេន បហារំ ទទេយ្យ សត្ថេន បហារំ ទទេយ្យ តត្រាបិ ត្វំ ផគ្គុន យេ គេហសិតា ឆន្ទា យេ គេហសិតា វិតក្កា តេ បជហេយ្យាសិ តត្រាបិ តេ ផគ្គុន ឯវំ សិក្ខិតព្វំ ន ចេវ មេ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាមិ ហិតានុកម្បី ច វិហរិស្សាមិ មេត្តចិត្តោ ន ទោសន្តរោតិ ឯវញ្ហិ តេ ផគ្គុន សិក្ខិតព្វន្តិ ។

(៣) អថខោ ភគវា ភិក្ខូ អាមន្តេសិ អារាធយឹសុ វត មេ ភិក្ខវេ ភិក្ខូ ឯកំ សមយំ ចិត្តំ ។ ឥធាហំ ភិក្ខវេ ភិក្ខូ អាមន្តេសឹ អហំ ខោ ភិក្ខវេ



អាត្មាអញនឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកមានចិត្តមេត្តា មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានភិក្ខុណាមួយ ឲ្យនូវការប្រហារដោយដៃ ឲ្យនូវការប្រហារដោយដុំដី ឲ្យនូវការប្រហារដោយដំបង ឲ្យនូវការប្រហារដោយគ្រឿងសស្ត្រា ចំពោះអ្នក ម្នាលផគ្គុន ឆន្ទៈណា ដែលអាស្រ័យនូវផ្ទះគឺបញ្ចកាមគុណ វិតក្កៈណា ដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ អ្នកគប្បីលះបង់ឆន្ទៈនិងវិតក្កៈទាំងនោះ ក្នុងការឲ្យនូវប្រហារនោះចេញ ម្នាលផគ្គុន មួយទៀតក្នុងការឲ្យនូវប្រហារនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញនឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង ជាអ្នកអនុគ្រោះដោយប្រយោជន៍ មានចិត្តមេត្តា មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

(៣) លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបានញុំាងចិត្តតថាគតឲ្យត្រេកអរ ក្នុងសម័យមួយហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រាប់ភិក្ខុទាំងឡាយ ក្នុងទីនេះថា ម្នាលភិក្ខុទាំងឡាយ តថាគត

ឯកាសនភោជនំ ភុញ្ជាមិ ឯកាសនភោជនំ ខោ អហំ ភិក្ខវេ ភុញ្ជមានោ អប្បាពាធតញ្ច សញ្ជានាមិ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច ។ ឯថ តុម្ហេបិ ភិក្ខវេ ឯកាសនភោជនំ ភុញ្ជថ ឯកាសនភោជនំ ខោ ភិក្ខវេ តុម្ហេបិ ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានិស្សថ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ចាតិ ។ ន មេ ភិក្ខវេ តេសុ ភិក្ខូសុ អនុសាសនី ករណីយា អហោសិ សតុប្បាទករណីយមេវ(១) ភិក្ខវេ តេសុ ភិក្ខូសុ អហោសិ ។ សេយ្យថាបិ ភិក្ខវេ សុភូមិយំ ចាតុម្មហាបថេ អាជញ្ញរថោ សុធន្តោ(២) យុត្តោ អស្ស ឋិតោ ឱធស្តបតោទោ តមេនំ ទក្ខោ យោគ្គាចរិយោ អស្សទម្មសារថិ អភិរុហិត្វា

១ ម. ម. ឯត្តកាយ មេតំ ទិស្សតិ ។ ២ ម. ម. សុទន្តោតិ ន ទិស្សតិ ។



ឆាន់ភោជនតែក្នុងអាសនៈមួយ ម្នាលភិក្ខុទាំងឡាយ កាលតថាគតឆាន់ ភោជនតែក្នុងអាសនៈមួយ តថាគត ក៏បានប្រសព្វនូវការមិនមានអាពាធ ផង មិនមានរោគផង ក្រោកទៅមកបានរហ័សរហួនផង កម្លាំងកាយ ផង ការនៅជាសុខសប្បាយផង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរមកអាយ អ្នកទាំងឡាយ ចូរបរិភោគភោជនតែក្នុងអាសនៈ មួយ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បរិភោគភោជនក្នុង អាសនៈមួយ អ្នកទាំងឡាយ នឹងបានប្រសព្វនូវការមិនមានអាពាធផង មិនមានរោគផង ក្រោកទៅមកបានរហ័សរហួនផង កម្លាំងកាយផង ការនៅជាសុខសប្បាយផង មិនខាន ។ ម្នាលភិក្ខុទាំងឡាយ តថា-គត មិនបានធ្វើនូវការប្រៀនប្រដៅភិក្ខុទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ តថាគត គ្រាន់តែដាស់ស្មារតីភិក្ខុទាំងឡាយនោះប៉ុណ្ណោះ ។ ម្នាលភិក្ខុ ទាំងឡាយ ដូចជារថទឹមសេះអាជានេយ្យ មានទាំងសេះដែលគេបង្ហឹក ល្អហើយ មានជន្លួញប្រុងប្រៀប ទឹមបញ្ឈរទុកត្រង់ផ្លូវបំបែកជា ៤ មានផែនដីរាបស្មើ បង្ហឹកខ្លួន គ្រូអ្នកបង្ហាត់ បានឡើងជិះរថនោះ

វាមេន ហត្ថេន រស្មិយោ គហេត្វា ទក្ខិណេន ហត្ថេន បតោទំ គហេត្វា យេនិច្ឆកំ យទិច្ឆកំ សារេយ្យាបិ បច្ចាសារេយ្យាបិ ឯវមេវ ខោ ភិក្ខវេ ន មេ តេសុ ភិក្ខូសុ អនុសាសនី ករណីយា អហោសិ សតុប្បាទករណីយមេវ ភិក្ខវេ តេសុ ភិក្ខូសុ អហោសិ ។ តស្មាតិហ ភិក្ខវេ តុម្ហេបិ(១) អកុសលំ បជហថ កុសលេសុ ធម្មេសុ អាយោគំ ករោថ ឯវញ្ហិ តុម្ហេបិ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជិស្សថ ។ សេយ្យថាបិ ភិក្ខវេ គាមស្ស វា និគមស្ស វា អវិទូរេ មហន្តំ សាលវនំ តញ្ចស្ស ឯឡណ្ឌេហិ សញ្ឆន្នំ តស្ស កោចិទេវ បុរិសោ ឧប្បជ្ជេយ្យ អត្ថកាមោ ហិតកាមោ យោគក្ខេមកាមោ សោ យា តា សាលលដ្ឋិយោ កុដិលា ឱជហរណីយោ(២) តា តច្ឆេត្វា

១ ម. បិសទ្ទោ ន ទិស្សតិ ។ ២ ម. ឱជាបហរណីយោ ។ ឱ. ឱជហរណីយោ ។



កាន់ខ្សែបង្ហៀរដោយដៃឆ្វេង កាន់ជន្លួញដោយដៃស្តាំបររទៅមុខខ្លះ បររៀបក្រឡប់ថយក្រោយខ្លះ តម្រង់ទៅរកផ្លូវដែលខ្លួនប្រាថ្នា និងបំណើរដែលខ្លួនប្រាថ្នា សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតមិនគួរធ្វើនូវការប្រៀបប្រដៅភិក្ខុទាំងឡាយនោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតគួរធ្វើតែត្រឹមការដាស់ស្មារតីភិក្ខុទាំងឡាយនោះប៉ុណ្ណោះ មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយចូរលះអកុសលចេញ ចូរធ្វើនូវសេចក្តីព្យាយាមក្នុងកុសលធម៌ទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយបានធ្វើយ៉ាងនេះ នឹងបានដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាព្រៃឈើធំនៅជិតស្រុកឬនិគម ព្រៃឈើនោះសឹងតែដេរដាសដោយល្វីងលណ្ឌ:(១) បុរសណាមួយប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីក្សេមក្សាន្ត ចាកគ្រឿងប្រឹកដល់ព្រៃឈើនោះ បុរសនោះកាត់កូនឈើដែលវៀច ១ មាននុជាសៅផែនដីជ្រួតជ្រាប

១ អដ្ឋកថា ថា ជាធល់វល្លិ៍ដែលប្រទូស្តដើមឈើ គឺរួបរឹតឡើងនោស ។

ពហិទ្ធា នីហរេយ្យ អន្តោវនំ សុសោធិតំ(១) វិសោ-ធេយ្យ យា បន តា សាលលដ្ឋិយោ ឧជុកា សុជា-តា(២) សម្មា បរិហរេយ្យ ឯវញ្ហិ តំ ភិក្ខវេ សាលវនំ អបរេន សមយេន វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ឯវមេវ ខោ ភិក្ខវេ តុម្ហេបិ អកុសលំ បជហថ កុសលេសុ ធម្មេសុ អាយោគំ ករោថ ឯវញ្ហិ តុម្ហេបិ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អា-បជ្ជថ(៣) ។

(៤) ភូតបុព្វំ ភិក្ខវេ ឥមិស្សាយេវ សាវត្ថិយា វេទេហិកា នាម គហបតានី អហោសិ ។ វេទេ-ហិកាយ ភិក្ខវេ គហបតានិយា ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សោរតា វេទេហិកា គហបតានី

១ ឱ. ម. សុវិសោធិតំ ។ ២ ឱ. ម. ឯត្ថន្តរេ តាតិ បាឋោ ទិស្សតិ ។ ៣ ឱ. ម. អាបជ្ជិស្សថ ។



ទៅផង ហើយនាំយកចេញទៅខាងក្រៅ ជម្រះទីខាងក្នុងព្រៃឲ្យស្អាតបាត ថ្នមថែរក្សាកូនឈើដែលដុះឡើងត្រង់ ៗ ម្នាលភិក្ខុទាំងឡាយ ក៏កាលបើបុរសនោះ បានធ្វើយ៉ាងនេះ ព្រៃឈើនោះឯង មុខជានឹងដល់នូវសេចក្ដីចម្រើន ដុះដាល ធំទូលាយ ក្នុងសម័យខាងក្រោយមកពុំខាន សេចក្ដីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយចូរលះបង់អកុសលចេញ ចូរធ្វើនូវសេចក្ដីព្យាយាមក្នុងកុសលធម៌ទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយ ធ្វើយ៉ាងនេះ នឹងដល់នូវសេចក្ដីចម្រើន ដុះដាល ធំទូលាយ ក្នុងធម្មវិន័យនេះពុំខាន មានឧបមេយ្យយ៉ាងនោះឯង ។

(៤) ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា មានគហ-បតានីម្នាក់ឈ្មោះនាងវេទេហិកា នៅក្នុងក្រុងសាវត្ថីនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិត្តិសព្ទដ៏ពីរោះ របស់នាងវេទេហិកាគហបតានីល្បីខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា នាងវេទេហិកាគហបតានី ជាស្ត្រីស្ងួត នាង

និវាតា វេទេហិកា គហបតានី ឧបសន្តា វេទេហិកា គហបតានីតិ ។ វេទេហិកាយ ខោ បន ភិក្ខវេ គហបតានិយា កាឡី នាម ទាសី អហោសិ ទក្ខា អនលសា សុសំវិហិតកម្មន្តា ។ អថខោ ភិក្ខវេ កាឡិយា ទាសិយា ឯតទហោសិ មយ្ហំ ខោ អយ្យាយ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សោរតា វេទេហិកា គហបតានី និវាតា វេទេហិកា គហបតានី ឧបសន្តា វេទេហិកា គហបតានីតិ កិន្នុខោ មេ អយ្យា សន្តំយេវ នុ ខោ អជ្ឈត្តំ កោបំ ន បាតុករោតិ ឧទាហុ អសន្តំ ឧទាហុ មយ្ហំវេត្ថ(១) កម្មន្តា សុសំវិហិតា យេន មេ អយ្យា សន្តំយេវ អជ្ឈត្តំ កោបំ ន បាតុករោតិ នោ អសន្តំ យន្នូនាហំ អយ្យំ វីមំសេយ្យន្តិ ។ អថខោ ភិក្ខវេ កាឡី ទាសី ទិវា ឧដ្ឋាសិ ។ អថខោ ភិក្ខវេ វេទេហិកា គហបតានី កាឡឹ ទាសឹ ឯតទវោច ហេ ជេ កាឡីតិ ។

១ ម. មយ្ហេវេត្ថ ។ ឱ. មយ្ហមេវេត្ថ ។



វេទេហិកាគហបតានី ជាស្ត្រីសភាពរាបទាប នាងវេទេហិកាគហបតានី ជាស្ត្រីស្រគត់ស្រគំ ។ ម្នាលភិក្ខុទាំងឡាយ ឯនាងវេទេហិកាគហបតានី មានទាសីម្នាក់ ឈ្មោះកាឡី ជាស្ត្រីឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកចាត់ចែងការងារល្អ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង នាងកាឡីទាសី មានសេចក្តីត្រិះរិះដូច្នេះថា នាងម្ចាស់របស់គ្នាអញ មានកិត្តិសព្ទដ៏ពីរោះល្បីខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា នាងវេទេហិកាគហបតានី ជាស្ត្រីស្លូត នាងវេទេហិកាគហបតានី ជាស្ត្រីសភាពរាបទាប នាងវេទេហិកាគហបតានី ជាស្ត្រីស្រគត់ស្រគំដូច្នេះ ចុះអ្នកស្រីជាម្ចាស់អញ មានកំហឹងខាងក្នុងដែរ តែមិនធ្វើឲ្យប្រាកដឬ ឬមិនមានកំហឹងខាងក្នុងទេ ឬក៏ដោយសារការងារទាំងនុ៎ះ ដែលអញបានចាត់ចែងត្រឹមត្រូវ បានជាអ្នកស្រីជាម្ចាស់អញមិនបញ្ចេញកំហឹងខាងក្នុងដែលមានដែរ មិនមែនជាមិនមានទេ បើដូច្នោះ មានតែអញល្បងអ្នកស្រីជាម្ចាស់លមើល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ នាងកាឡីទាសីក្រោកឡើង (ពីដំណេក) ក្នុងវេលាថ្ងៃពេក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពេលនោះ នាងវេទេហិកាគហបតានី បាននិយាយនឹងនាងកាឡីទាសីដូច្នេះថា នែមេកាឡី ។

កឹ អយ្យេតិ ។ កឹ ជេ ទិវា ឧដ្ឋាសីតិ ។ ន ខ្វយ្យេ កិញ្ចីតិ(១) ។ នោ វត រេ កិញ្ចិ បាបទាសិ(២) ទិវា ឧដ្ឋាសីតិ កុបិតា អនត្តមនា ភកុដិមកាសិ(៣) ។ អថខោ ភិក្ខវេ កាឡិយា ទាសិយា ឯតទហោសិ សន្តំយេវ(៤) មេ អយ្យា អជ្ឈត្តំ កោបំ ន បាតុករោតិ នោ អសន្តំ មយ្ហំ បនេតេ កម្មន្តា សុសំវិហិតា យេន មេ អយ្យា សន្តំយេវ អជ្ឈត្តំ កោបំ ន បាតុករោតិ នោ អសន្តំ យន្នូនាហំ ភិយ្យោសោ មត្តាយ អយ្យំ វីមំសេយ្យន្តិ ។ អថខោ ភិក្ខវេ កាឡី ទាសី ទិវតរំយេវ(៥) ឧដ្ឋាសិ ។ អថខោ ភិក្ខវេ វេទេហិកា គហបតានី កាឡឹ ទាសឹ ឯតទវោច ហេ ជេ កាឡីតិ ។ កឹ អយ្យេតិ ។ កឹ ជេ ទិវា ឧដ្ឋាសីតិ ។ ន ខ្វយ្យេ កិញ្ចីតិ ។

១ ម. ន ខោ អយ្យេ កិញ្ចិ ។ ២ ម. ឱ. បាបិ ទាសិ ។ ៣ ភមុកំ អកាសិ ។ ៤ ម. សន្តំយេវ នោ ។ ៥ ម. ទិវាតរំ ។



នាងកាឡីទាសីឆ្លើយតបថា អ្នកស្រីមានប្រសាសន៍ថាម៉េច ។ ចុះហេតុម្ដេចក៏ក្រោកពេលថ្ងៃម៉្លេះ ។ គ្មានអ្វីទេអ្នកស្រី ។ នាងវេទេហិកាគហបតានី ក៏ទឹងតក់អន់ចិត្ត ធ្វើមុខក្រញូវស្ដីថា ហើមេពាលទាសីអម្រក់ បើមិនមានអ្វីទេ ម្ដេចក៏ហ៊ានឯងក្រោកពេលថ្ងៃម៉្លេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ កាឡីទាសីមានសេចក្ដីត្រិះរិះដូច្នេះថា អ្នកស្រីជាម្ចាស់អញមានកំហឹងខាងក្នុងដែរ តែមិនធ្វើឲ្យប្រាកដ មិនមែនជាមិនមានទេ ដោយសារការងារទាំងនុ៎ះ គាត្មាអញបានចាត់ចែងត្រឹមត្រូវ បានជាអ្នកស្រីជាម្ចាស់អញ មិនបញ្ចេញកំហឹងខាងក្នុងដែលមានដែរ មិនមែនជាមិនមានទេ បើដូច្នោះគួរតែអញល្បងមើលម្ចាស់អញ ឲ្យលើសជាងនេះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ នាងកាឡីទាសីក្រោកឡើង (ពីដំណេក) រឹងរឹតតែពេលថ្ងៃជាងមុនទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ នាងវេទេហិកាគហបតានី បាននិយាយនឹងនាងកាឡីទាសីដូច្នេះថា នែមេកាឡី ។ កាឡីទាសី ឆ្លើយតបថា អ្នកស្រីមានប្រសាសន៍ថាម៉េច ។ ចុះហេតុម្ដេចក៏ក្រោកពេលថ្ងៃម៉្លេះ ។ គ្មានអ្វីទេ អ្នកស្រី ។ នាងវេទេហិ-

នោ វត រេ កិញ្ចិ បាបទាសិ ទិវា ឧដ្ឋាសីតិ កុបិតា អនត្តមនា អនត្តមនវាចំ និច្ឆារេតិ(១) ។ អថខោ ភិក្ខវេ កាឡិយា ទាសិយា ឯតទហោសិ សន្តំយេវ ខោ មេ អយ្យា អជ្ឈត្តំ កោបំ ន បាតុករោតិ នោ អសន្តំ មយ្ហមេវេតេ កម្មន្តា សុសំវិហិតា យេន មេ អយ្យា សន្តំយេវ អជ្ឈត្តំ កោបំ ន បាតុករោតិ នោ អសន្តំ យន្នូនាហំ ភិយ្យោសោមត្តាយ អយ្យំ វីមំសេយ្យន្តិ ។ អថខោ ភិក្ខវេ កាឡី ទាសី ទិវាតរំយេវ ឧដ្ឋាសិ ។ អថខោ ភិក្ខវេ វេទេហិកា គហបតានី កាឡឹ ទាសឹ ឯតទវោច ហេ ជេ កាឡីតិ ។ កឹ អយ្យេតិ ។ កឹ ជេ ទិវាតរំ ឧដ្ឋាសីតិ ។ ន ខ្វយ្យេ កិញ្ចីតិ ។ នោ វត រេ កិញ្ចិ បាបទាសិ ទិវាតរំ ឧដ្ឋាសីតិ កុបិតា អនត្តមនា អគ្គឡសូចឹ គហេត្វា សីសេ បហារំ អទាសិ សីសំ តេ ភិន្ទិស្សាមីតិ(២) ។

១ ម. និច្ឆារេសិ ។ ២ ម. សីសំ វោភិន្ទិ ។ ឱ. សីសំ ទ្វេធា ភិន្ទិ ។



គហបតានី ទឹងតក់អន់ចិត្ត ក៏បញ្ចេញវាចា ដោយសេចក្ដីតក់អន់ចិត្តថា ហ៎ើយនែនាងទាសីអប្រក់ បើមិនមានអ្វីទេ ម្ដេចក៏ហ៊ានក្រោកទាល់ថ្ងៃម្ល៉េះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ កាឡីទាសីមានសេចក្ដីត្រិះរិះដូច្នេះថា អ្នកស្រីជាម្ចាស់អញ មានកំហឹងខាងក្នុងដែរ តែមិនធ្វើឲ្យប្រាកដ មិនមែនជាមិនមានទេ ដោយសារការងារទាំងនុ៎ះ ដែលអញបានចាត់ចែងត្រឹមត្រូវ បានជាអ្នកស្រីជាម្ចាស់អញ មិនបញ្ចេញកំហឹងខាងក្នុង មិនមែនជាមិនមានទេ បើដូច្នេះ គួរតែអញល្បងមើលអ្នកស្រីជាម្ចាស់ឲ្យលើសជាងនេះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ កាឡីទាសីក្រោកឡើង (ពីដំណេក) រឹតតែទាល់ថ្ងៃជាងមុនទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ នាងវេទេហិកាគហបតានី បាននិយាយនឹងកាឡីទាសីដូច្នេះថា នែមេកាឡី ។ កាឡីទាសីឆ្លើយថា អ្នកស្រីមានប្រសាសន៍ថាម្ដេច ។ ចុះហេតុម្ដេចក៏ក្រោកទាល់ថ្ងៃម្ល៉េះ ។ គ្មានអ្វីទេអ្នកស្រី ។ នាងវេទេហិកាគហបតានីទឹងតក់អន់ចិត្ត និយាយថា ហ៎ើយនែនាងទាសីអប្រក់ បើមិនមានអ្វីទេ ម្ដេចក៏ហ៊ានក្រោកទាល់ថ្ងៃម្ល៉េះ ជាហើយ ក៏ចាប់ខ្នុកទ្វារយកទៅគោះក្បាលថា អញនឹងវាយបំបែកក្បាលឯង ។

អថខោ ភិក្ខវេ កាឡី ទាសី ភិន្នេន សីសេន លោហិតេន គឡន្តេន បដិវិស្សកានំ ឧជ្ឈាបេសិ បស្សថយ្យេ សោរតាយ កម្មំ បស្សថយ្យេ និវាតាយ កម្មំ បស្សថយ្យេ ឧបសន្តាយ កម្មំ កថំ ហិ នាម ឯកទាសិយា(១) ទិវា ឧដ្ឋាសីតិ កុបិតា អនត្តមនា អគ្គឡសូចឹ គហេត្វា សីសេ បហារំ ទស្សតិ សីសំ តេ ភិន្ទិស្សាមីតិ(២) ។ អថខោ ភិក្ខវេ វេទេហិកាយ គហបតានិយា អបរេន សមយេន ឯវំ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆិ ចណ្ឌី វេទេហិកា គហបតានី អនិភតា វេទេហិកា គហបតានី អនុបសន្តា វេទេហិកា គហបតានីតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ តាវទេវ សោរតសោរតោ ហោតិ និវាតនិវាតោ ហោតិ ឧបសន្តូបសន្តោ ហោតិ យាវ ន អមនាបា វចនបថា ផុសន្តិ យតោ ច ខោ(៣) ភិក្ខវេ

១ ឱ. ម. ឯកទាសិកាយ ។ ២ ឱ. ម. សីសំ ជា ភិន្ទិស្សតីតិ ។ ៣ ម. ខោ-សទ្ទោ នត្ថិ ។



ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង នាងកាឡីទាសី បែកក្បាលហូរឈាម ហើយ ក៏ពោលទោសប្រាប់ស្ត្រីអ្នកជិតខាងថា អ្នកស្រីជាម្ចាស់ ចូរមើលអំពើរបស់ស្ត្រីដែលស្លូតចុះ អ្នកស្រីជាម្ចាស់ ចូរមើលអំពើរបស់ស្ត្រីដែលសុភាពរាបទាបចុះ អ្នកស្រីជាម្ចាស់ ចូរមើលអំពើរបស់ស្ត្រីស្រគត់ស្រគំចុះ មិនសមបើអ្នកស្រីជាម្ចាស់ (ខឹង) ទឹងកាក់អន់ចិត្តនឹងទាសីម្នាក់ថា ហេតុឯងក្រោក (ពីដំណេក) ទាល់ថ្ងៃ ហើយចាប់ទុកក្លោះទ្វារសំពងចំក្បាលថា អញនឹងវាយបំបែកក្បាលហឹងដូច្នេះសោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ នាងវេទេហិកាគហបតានី ក៏មានកិត្តិសព្ទដ៏អាក្រក់ល្បីខ្ចរខ្ចាយសុសសាយក្នុងសម័យខាងក្រោយមកយ៉ាងនេះថា នាងវេទេហិកាគហបតានី ជាស្ត្រីកាច នាងវេទេហិកាគហបតានី ជាស្ត្រីមិនសុភាពរាបទាប នាងវេទេហិកាគហបតានី ជាស្ត្រីមិនស្រគត់ស្រគំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះក្នុងសាសនានេះក៏យ៉ាងនោះដែរ ជាអ្នកស្លូតណាស់ ជាអ្នកសុភាពរាបទាបណាស់ ជាអ្នកស្រគត់ស្រគំណាស់ ត្រាតែគន្លងពាក្យមិនជាទីគាប់ចិត្តមិនទាន់មកប៉ះពាល់ ម្នាលភិក្ខុទាំងឡាយ កាលណាបើ

ភិក្ខុំ អមនាបា វចនបថា ផុសន្តិ អថខោ ភិក្ខុ សោរតោតិ វេទិតព្វោ និវាតោតិ វេទិតព្វោ ឧបសន្តោតិ វេទិតព្វោ ។ នាហំ ភិក្ខវេ ភិក្ខុំ សុវចោតិ វទាមិ យោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សុវចោ ហោតិ សោវចស្សតំ អាបជ្ជតិ តំ កិស្ស ហេតុ តញ្ហិ(១) សោ ភិក្ខវេ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អលភមានោ ន សុវចោ ហោតិ ន សោវចស្សតំ អាបជ្ជតិ ។ យោ ច ខោ ភិក្ខវេ ភិក្ខុ ធម្មំយេវ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ(២) សុវចោ ហោតិ សោវចស្សតំ អាបជ្ជតិ តមហំ សុវចោតិ វទាមិ ។ តស្មាតិហ ភិក្ខវេ ធម្មំយេវ សក្ករោន្តា ធម្មំ គរុករោន្តា ធម្មំ អបចាយមានា សុវចា ភវិស្សាម សោវចស្សតំ អាបជ្ជិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

១ ឱ. ម. តំ ហិ ។ ២ ម. ធម្មំយេវ សក្ករោន្តោ ធម្មំយេវ គរុករោន្តោ ធម្មំយេវ មានេន្តោ បូជេន្តោ អបចាយមានោ ។



នូវពាក្យមិនគាប់ចិត្តមកប៉ះពាល់ភិក្ខុហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបគេដឹងថាជាអ្នកស្លូត ថាជាអ្នកសភាពរាបទាប ថាជាអ្នកស្រគត់ស្រគំ ក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកប្រដៅងាយ ដល់នូវភាពជាអ្នកប្រដៅងាយ ព្រោះតែចីវរ បិណ្ឌបាត សេនាសនៈគិលានប្បច្ច័យភេសជ្ជបរិក្ខារ តថាគតមិនបានហៅភិក្ខុនោះថា ជាអ្នកប្រដៅងាយទេឡើយ ព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុនោះ កាលបើមិនបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ក៏មិនមែនជាអ្នកប្រដៅងាយ មិនដល់នូវភាពជាអ្នកប្រដៅងាយទេឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែភិក្ខុណាមួយ ធ្វើសក្ការៈចំពោះធម៌ ធ្វើសេចក្តីគោរពធម៌ ប្រព្រឹត្តកោតក្រែងធម៌មែន ទើបពេញជាអ្នកប្រដៅងាយ ដល់នូវភាពជាអ្នកប្រដៅងាយ តថាគតហៅភិក្ខុនោះថាជាអ្នកប្រដៅងាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកភិក្ខុក្នុងសាសនានេះ ត្រូវតែគិតថា យើងទាំងឡាយ កាលធ្វើសក្ការៈចំពោះធម៌ ធ្វើសេចក្តីគោរពធម៌ ប្រព្រឹត្តកោតក្រែងធម៌ នឹងជាអ្នកប្រដៅងាយ ដល់នូវភាពជាអ្នកប្រដៅងាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(៥) បញ្ចិមេ ភិក្ខវេ វចនបថា យេហិ វោ បរេ វទមានា វទេយ្យុំ កាលេន វា អកាលេន វា ភូតេន វា អភូតេន វា សណ្ហេន វា ផរុសេន វា អត្ថសញ្ហិតេន វា អនត្ថសញ្ហិតេន វា មេត្តចិត្តា វា ទោសន្តរា វា ។ កាលេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អកាលេន វា ភូតេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អភូតេន វា សណ្ហេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ ផរុសេន វា អត្ថសញ្ហិតេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អនត្ថសញ្ហិតេន វា មេត្តចិត្តា វា ភិក្ខវេ បរេ វទមានា វទេយ្យុំ ទោសន្តរា វា ។ តត្រាបិ វោ[១] ភិក្ខវេ

១ ម. ភោ ។



(៥) ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយចំពោះអ្នកទាំង-ឡាយ គប្បីនិយាយ ដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនោះមាន ៥ ប្រការគឺ និយាយក្នុងកាលគួរឬមិនគួរ ១ និយាយដោយពាក្យពិតឬមិនពិត ១ និយាយដោយពាក្យល្អឬអាក្រក់ ១ និយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬ មិនប្រកបដោយប្រយោជន៍ ១ និយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬ ទោសចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយក្នុងកាលគួរឬមិនគួរខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យពិត ឬពាក្យមិនពិតខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យល្អ ឬពាក្យអាក្រក់ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយមេត្តា-ចិត្ត ឬប្រកបដោយទោសចិត្តខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

ឯវំ សិក្ខិតព្វំ ន ចេវ នោ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាម ហិតានុកម្បី ច វិហរិស្សាម មេត្តចិត្តា ន ទោសន្តរា តញ្ច បុគ្គលំ មេត្តាសហគតេន ចេតសា ផរិត្វា វិហរិស្សាម តទារម្មណញ្ច សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

(៦) សេយ្យថាបិ ភិក្ខវេ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ សោ ឯវំ វទេយ្យ អហំ ឥមំ មហាបឋវឹ អបឋវឹ ករិស្សាមីតិ ។ សោ តត្រ តត្រ ខណេយ្យ តត្រ តត្រ វិកិរេយ្យ តត្រ តត្រ ឱដ្ឋុភេយ្យ តត្រ តត្រ ឱមុត្តេយ្យ អបឋវី ភវសិ អបឋវី ភវសីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ ឥមំ មហាបឋវឹ អបឋវឹ ករេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ អយញ្ហិ ភន្តេ



គប្បីសិក្សាក្នុងសូត្រនេះយ៉ាងនេះថា ចិត្តរបស់យើងនឹងមិនប្រែ-ប្រួលផង យើង នឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តដ៏ទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(៦) ម្នាលភិក្ខុទាំងឡាយ ដូចបុរសកាន់ចបនិងល្អីដើរមក បុរសនោះនិយាយយ៉ាងនេះថា អញនឹងធ្វើផែនដីធំនេះ ឲ្យមិនមែនជាផែនដី ។ បុរសនោះ ជីកដីត្រង់ទីនោះៗ បាចសាចទៅក្នុងទីនោះ ៗ ស្តោះទឹកមាត់ទៅក្នុងទីនោះ ៗ បន្ទោបង់នូវមូត្រក្នុងទីនោះ ៗ ដោយគិតថា ទីនេះមិនមែនជាផែនដី ទីនេះមិនមែនជាផែនដី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះជាដូចម្តេច បុរសនោះអាចនឹងធ្វើផែនដីធំនេះ ឲ្យមិនមែនជាផែនដីបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនបានទេ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា

មហាបថវី គម្ភីរា អប្បមេយ្យា សា ន សុករា អបថវី(១) កាតុំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ វចនបថា យេហិ វោ បរេ វទមានា វទេយ្យុំ កាលេន វា អកាលេន វា ភូតេន វា អភូតេន វា សណ្ហេន វា ផរុសេន វា អត្ថសញ្ហិតេន វា អនត្ថសញ្ហិតេន វា មេត្តចិត្តា វា ទោសន្តរា វា ។ កាលេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អកាលេន វា ភូតេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អភូតេន វា សណ្ហេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ ផរុសេន វា អត្ថសញ្ហិតេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ

១ ម. ឆ. អបឋវី ។



ផែនដីធំនេះ ជ្រាលជ្រៅរកប្រមាណមិនបាន ផែនដីធំនោះ មិនងាយនឹងធ្វើឲ្យទៅជាមិនមែនផែនដីបានឡើយ តែបុរសនោះ គ្រាន់តែបានចំណែកសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯងហើយ ដំណើរនោះដូចគ្នានឹងពួកជនដទៃ កាលនិយាយ ចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះ មាន ៥ ប្រការ គឺ និយាយក្នុងកាលគួរឬមិនគួរ ១ និយាយដោយពាក្យពិតឬមិនពិត ១ និយាយដោយពាក្យល្អឬពាក្យអាក្រក់ ១ និយាយដោយពាក្យប្រកបដោយប្រយោជន៍ឬមិនប្រកបដោយប្រយោជន៍ ១ និយាយដោយពាក្យប្រកបដោយមេត្តាចិត្តឬប្រកបដោយទោសចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយ ក្នុងកាលគួរឬកាលមិនគួរខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យពិត ឬពាក្យមិនពិតខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យល្អឬពាក្យអាក្រក់ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយ

អនត្ថសញ្ហិតេន វា មេត្តចិត្តា វា ភិក្ខវេ បរេ វទមានា វទេយ្យុំ ទោសន្តរា វា ។ តត្រាបិ វោ(១) ភិក្ខវេ ឯវំ សិក្ខិតព្វំ ន ចេវ នោ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាម ហិតានុកម្បី ច វិហរិស្សាម មេត្តចិត្តា ន ទោសន្តរា តញ្ច បុគ្គលំ មេត្តាសហគតេន ចេតសា ផរិត្វា វិហរិស្សាម តទារម្មណញ្ច សព្វាវន្តំ លោកំ បឋវិសមេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

(៨) សេយ្យថាបិ ភិក្ខវេ បុរិសោ អាគច្ឆេយ្យ លាខំ វា ហលិទ្ទិំ វា នីលំ វា មញ្ជដ្ឋំ វា អាទាយ សោ ឯវំ វទេយ្យ អហំ ឥមស្មឹ អាកាសេ រូបានិ លិខិស្សាមិ រូបបាតុភាវំ(២) ករិស្សាមីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ

១ ឱ. ភោ ។ ២ ម. រូបំ ។



ប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្តខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងគន្លងនៃពាក្យទាំងនោះ យ៉ាងនេះថា ចិត្តរបស់យើង នឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង នឹងមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តស្មើដោយផែនដី ជាចិត្តធំទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ហើយផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(៨) ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកទឹកល័ខក្តី ទឹករមៀតក្តី វត្ថុមានពណ៌ខៀវក្តី ពណ៌ហង្សបាទក្តី ដើរមក បុរសនោះនិយាយយ៉ាងនេះថា អាត្មាអញនឹងគូររូបទាំងឡាយ ធ្វើឲ្យមានរូបភាពប្រាកដឡើងក្នុងអាកាសនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់

អបិ នុ សោ បុរិសោ ឥមស្មឹ អាកាសេ រូបានិ(១) លិខេយ្យ រូបបាតុភាវំ ករេយ្យាតិ ។ នោ ហេតំ ភន្តេ តំ កិស្ស ហេតុ អយញ្ហិ ភន្តេ អាកាសោ អរូបី អនិទស្សនោ តត្ថ ន សុករំ រូបំ លិខិតុំ រូបបាតុភាវំ កាតុំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ វចនបថា យេហិ វោ បរេ វទមានា វទេយ្យុំ កាលេន វា អកាលេន វា ។ បេ ។ តទារម្មណញ្ច សព្វាវន្តំ លោកំ អាកាសសមេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

១ ម. ម. រូបំ ។



សេចក្ដីនោះជា ដូចម្ដេច បុរសនោះ អាចគូររូបទាំងឡាយ ធ្វើឲ្យមានរូប-ភាព ប្រាកដឡើងក្នុងអាកាសនេះបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះធ្វើមិនបានទេ ព្រោះហេតុដូចម្ដេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាអាកាសនេះមិនមានរូប មិនជាទីឃើញរូប មិនងាយនឹងគូររូប មិនងាយនឹងធ្វើរូបភាពឲ្យមានប្រាកដ ក្នុងអាកាសនេះបានឡើយ ក៏ឯបុរសនោះ គ្រាន់តែបានចំណែកសេចក្ដីលំបាកកាយ និងសេចក្ដីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះមែនហើយ សេចក្ដីនោះដូចគ្នានឹងពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះ មាន ៥ ប្រការ គឺ និយាយក្នុងកាលគួរ ឬកាលមិនគួរ ១ ។ បេ ។ ជាអ្នកមានចិត្តស្មើដោយអាកាស ជាចិត្តដ៏ទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(៨) សេយ្យថាបិ ភិក្ខវេ បុរិសោ អាគច្ឆេយ្យ អាទិត្តំ តិណុក្កំ អាទាយ សោ ឯវំ វទេយ្យ អហំ ឥមាយ អាទិត្តាយ តិណុក្កាយ គង្គំ នទឹ សន្តាបេស្សាមិ សម្បរិតាបេស្សាមីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ អាទិត្តាយ តិណុក្កាយ គង្គំ នទឹ សន្តាបេយ្យ សម្បរិតាបេយ្យាតិ ។ នោ ហេតំ ភន្តេ តំ កិស្ស ហេតុ គង្គា ហិ ភន្តេ នទី គម្ភីរា អប្បមេយ្យា សា ន សុករា អាទិត្តាយ តិណុក្កាយ សន្តាបេតុំ សម្បរិតាបេតុំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ វចនបថា យេហិ វោ បរេ វទមានា វទេយ្យុំ កាលេន វា អកាលេន វា ។បេ។ តទារម្មណញ្ច សព្វាវន្តំ លោកំ គង្គាសមេន ចេតសា



(៨) ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសកាន់គប់ភ្លើង ដែលឆេះឆ្នោលដើរមក បុរសនោះនិយាយយ៉ាងនេះថា អាត្មាអញនឹងកំដៅទន្លេគង្គាឲ្យក្តៅសព្វ ដោយគប់ស្មៅដែលឆេះឆ្នោលនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះថាដូចម្តេច បុរសនោះគាប់កំដៅទន្លេគង្គាឲ្យក្តៅសព្វ ដោយគប់ស្មៅដែលឆេះឆ្នោល បានឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះ ធ្វើមិនបានទេ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាទន្លេគង្គាមានជំរៅកប់មិនបាន(១) ទន្លេគង្គានោះ បុគ្គលមិនងាយនឹងកំដៅឲ្យក្តៅសព្វ ដោយគប់ស្មៅដែលឆេះឆ្នោលបានឡើយ ក៏ឯបុរសនោះគ្រាន់តែបានចំណែកសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមាដូចម្តេច មានឧបមេយ្យដូចពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះមាន ៥ ប្រការ គឺ និយាយក្នុងកាលគួរ ឬ កាលមិនគួរ ១ ។បេ។ នឹងជាអ្នកមានចិត្តស្មើដោយទន្លេគង្គា ជាចិត្ត

១ ជម្រៅរបស់ទន្លេគង្គានេះកម្រាស់ ១ គាវុតខ្លះ កន្លះយោជន៍ខ្លះ ឯបណ្តោយចំនួនប្រាំរយយោជន៍ ។ អដ្ឋកថា ។

វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

(៤) សេយ្យថាបិ ភិក្ខវេ វិឡារភស្តា(១) មទ្ទិតា សុមទ្ទិតា សុបរិមទ្ទិតា មុទុកា តូលិនី ឆិន្នសស្សរា ឆិន្នបព្ភរា អថ បុរិសោ អាគច្ឆេយ្យ កដ្ឋំ វា កឋលំ វា អាទាយ សោ ឯវំ វទេយ្យ អហំ ឥមំ វិឡារភស្តំ មទ្ទិតំ សុមទ្ទិតំ សុបរិមទ្ទិតំ មុទុកំ តូលិនឹ ឆិន្នសស្សរំ ឆិន្នបព្ភរំ កដ្ឋេន វា កឋលេន វា សរសរំ ការិស្សាមិ ភរភរំ ការិស្សាមីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ ឥមំ វិឡារភស្តំ មទ្ទិតំ សុមទ្ទិតំ សុបរិមទ្ទិតំ មុទុកំ តូលិនឹ ឆិន្នសស្សរំ ឆិន្នបព្ភរំ កដ្ឋេន វា កឋលេន វា សរសរំ ការេយ្យ ភរភរំ ការេយ្យាតិ ។ នោ ហេតំ ភន្តេ

១ ម. ឆ. ពិឡារភស្តា ។



ធំទូលាយដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(៤) ម្នាលភិក្ខុទាំងឡាយ ដូចជាសម្លៀកស្បែកខ្លាត្រី ដែលបុគ្គលជំប្រដាប់ សម្លាប់ឲ្យទន់ ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងរណាន បើបុរសកាន់យកឈើឬអំបែងក្បឿងដើរមក បុរសនោះនិយាយយ៉ាងនេះថា គ្នាអញនឹងយកឈើឬអំបែងក្បឿង (នេះ) ទៅគោះសម្លៀកស្បែកខ្លាត្រី ដែលបុគ្គលជំប្រដាប់ សម្លាប់ឲ្យទន់ ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងរណាននេះ ធ្វើឲ្យមានសំឡេងស្រួយ ឲ្យមានសំឡេងរណានឡើងវិញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះ ជាដូចម្ដេច បុរសនោះ អាចយកកំណាត់ឈើឬអំបែងក្បឿង ទៅគោះសម្លៀកស្បែកខ្លាត្រី ដែលបុគ្គលជំប្រដាប់សម្លាប់ឲ្យទន់ ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងរណាននេះ ធ្វើឲ្យមានសំឡេងស្រួយ ឲ្យមានសំឡេងរណានឡើងវិញបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ធ្វើមិនបានទេ

តំ កិស្ស ហេតុ អយញ្ហិ(១) ភន្តេ ពិឡារភស្តា មទ្ទិតា សុមទ្ទិតា សុបរិមទ្ទិតា មុទុកា តូលិនី ឆិន្នសស្សរា ឆិន្នភព្ភរា សា ន សុករា កដ្ឋេន វា កឋលេន វា សសរំ កាតុំ ភព្ភរំ កាតុំ យាវទេវ ច បន សោ(២) បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ វចនបថា យេហិ វោ បរេ វទមានា វទេយ្យុំ កាលេន វា អកាលេន វា ភូតេន វា អភូតេន វា សណ្ហេន វា ផរុសេន វា អត្ថសញ្ហិតេន វា អនត្ថសញ្ហិតេន វា មេត្តចិត្តា វា ទោសន្តរា វា ។ កាលេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អកាលេន វា ។ ភូតេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អភូតេន វា

១ ម. អសុ ហិ ។ ឱ. អមុ ហិ ។ ២ ម. ឱ. សោ បុរិសោ ។



ព្រោះហេតុដូចម្ដេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាស្បៀតស្បែកឆ្មាក្រីនេះដែលបុគ្គលដំប្រដាប់ សម្លាប់ឲ្យទន់ ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងណែន ស្បៀតស្បែកឆ្មាក្រីនោះ បុគ្គលមិនងាយនឹងធ្វើនោះឲ្យមានសំឡេងស្រួយ ឲ្យមានសំឡេងណែន ដោយឈើឬអំបែងក្បឿងបានឡើយ ក៏ឯបុរសនោះ គ្រាន់តែបានចំណែកសេចក្ដីលំបាកកាយ និងសេចក្ដីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះមានឧបមាដូចម្ដេច មានឧបមេយ្យដូចពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះ មាន ៥ ប្រការ គឺ និយាយក្នុងកាលគួរឬកាលមិនគួរ ១ និយាយដោយពាក្យពិតឬពាក្យមិនពិត ១ និយាយដោយពាក្យល្អឬពាក្យអាក្រក់ ១ និយាយដោយពាក្យប្រកបដោយប្រយោជន៍ឬមិនប្រកបដោយប្រយោជន៍ ១ និយាយដោយពាក្យប្រកបដោយមេត្តាចិត្តឬប្រកបដោយទោសចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយក្នុងកាលគួរឬកាលមិនគួរខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យពិត ឬពាក្យមិនពិតខ្លះ

សណ្ហេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ ផរុសេន វា អត្ថសញ្ហិតេន វា ភិក្ខវេ បរេ វទមានា វទេយ្យុំ អនត្ថសញ្ហិតេន វា មេត្តចិត្តា វា ភិក្ខវេ បរេ វទមានា វទេយ្យុំ ទោសន្តរា វា ។ តត្រាបិ វោ ភិក្ខវេ ឯវំ សិក្ខិតព្វំ ន ចេវ នោ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាម ហិតានុកម្បី ច វិហរិស្សាម មេត្តចិត្តា ន ទោសន្តរា តញ្ច បុគ្គលំ មេត្តាសហគតេន ចេតសា ផរិត្វា វិហរិស្សាម តទារម្មណញ្ច សព្វាវន្តំ លោកំ ពិឡារភស្តសមេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។





ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យល្អ ឬពាក្យអាក្រក់ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្តខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងគន្លងនៃពាក្យទាំងឡាយនោះយ៉ាងនេះថា ចិត្តរបស់យើងនឹងមិនបានប្រែប្រួលផង យើងនឹងមិនបញ្ចេញពាក្យអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកប្រកបដោយមេត្តាចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តស្មើដោយសម្លៀកស្បែកខ្លាត្រី ជាចិត្តដ៏ទូលាយ ដល់នូវសភាពធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំង-អស់ ធ្វើឲ្យជាអារម្មណ៍ របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(១០) ឧភតោ ទណ្ឌកេនបិ ចេ(១) ភិក្ខវេ កកចេន ចោរា ឱចរកា(២) អង្គមង្គានិ ឱកន្តេយ្យុំ តត្រាបិ យោ មនោ បទូសេយ្យ ន មេ សោ តេន សាសនករោ ។ តត្រាបិ វោ ភិក្ខវេ សិក្ខិតព្វំ ន ចេវ នោ ចិត្តំ វិបរិណតំ ភវិស្សតិ ន ច បាបិកំ វាចំ និច្ឆារេស្សាម ហិតានុកម្បី ច វិហរិស្សាម មេត្តចិត្តា ន ទោសន្តរា តញ្ច បុគ្គលំ មេត្តាសហគតេន ចេតសា ផរិត្វា វិហរិស្សាម តទារម្មណញ្ច សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

(១១) ឥមញ្ច តុម្ហេ ភិក្ខវេ កកចូបមំ ឱវាទំ អភិក្ខណំ មនសិករេយ្យាថ បស្សថ នោ តុម្ហេ ភិក្ខវេ តញ្ច វចនបថំ អណុំ វា ថូលំ វា យំ

១ ឱ-ម. ឧភតោ ទណ្ឌកេន ចេបិ ។ ២ ឱ. ម. ចោរកា ។



(១០) ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់ នាំគ្នាកាត់អវយវៈតូចធំរបស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញ៉ាំងចិត្តឲ្យប្រទូស្តចំពោះពួកចោរទាំងអម្បាលនោះ ភិក្ខុនោះមិនឈ្មោះថាជាអ្នកធ្វើតាមសាសនារបស់តថាគត ដោយការមិនអត់សង្កត់នោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាក្នុងការបៀតបៀនរបស់ចោរនោះថា ចិត្តរបស់យើង នឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

(១១) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីធ្វើទុកក្នុងចិត្តចំពោះឱវាទដែលប្រៀបដោយរណារនេះឯង ឲ្យរឿយៗចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនឃើញនូវនៃពាក្យតូច ឬ ធំនោះ ដែល

តុម្ហេ នាធិវាសេយ្យាថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហ ភិក្ខវេ ឥមំ កកចូបមំ ឱវាទំ អភិក្ខណំ មនសិករោថ តំ វោ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កកចូបមសុត្តំ បឋមំ និដ្ឋិតំ ។

---



នាំឲ្យអ្នកទាំងឡាយអត់សង្កត់ មិនបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនឃើញនូវពាក្យនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើទុកក្នុងចិត្ត ចំពោះឱវាទដែលប្រៀបដោយរណារនេះឯង ឲ្យរឿយ ៗ ចុះ ការធ្វើទុកក្នុងចិត្តនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។ លុះព្រះមានព្រះភាគ ត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិត របស់ព្រះមានបុណ្យ ។

ចប់ កកចូបមសូត្រ ទី ១ ។

---

# ទុតិយំ អលគទ្ទូបមសុត្តំ

(១២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អរិដ្ឋស្ស នាម ភិក្ខុនោ គទ្ធពាធិបុព្វស្ស(១) ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ អរិដ្ឋស្ស កិរ នាម ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អថ ខោ តេ ភិក្ខូ

១ ឱ. គទ្ធាធិបុព្វស្ស ។ ម. គទ្ធពាធិបុព្វស្ស ។

# អលគទ្ទូបមសូត្រ ទី ២

(១២) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុឈ្មោះអរិដ្ឋៈ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត(១) មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ ពួកភិក្ខុច្រើនរូបបានឮដំណឹងថា អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ គ្រានោះឯង ភិក្ខុទាំងនោះក៏

១ ពាក្យថា បុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ បានសេចក្តីថា ជាកូនចៅត្រកូលអ្នកសម្លាប់ត្មាត ។

យេន អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតទវោចុំ សច្ចំ កិរ តេ អាវុសោ អរិដ្ឋ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អថខោ តេ ភិក្ខូ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុកាមា សមនុយុញ្ជន្តិ សមនុគ្គាហន្តិ សមនុភាសន្តិ មា ហេវំ អាវុសោ អរិដ្ឋ អវច មា ភគវន្តំ អព្ភាចិក្ខ(១) ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ

១ ឱ. ម. អព្ភាចិក្ខិ ។



ចូលទៅរកអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតនោះ លុះចូលទៅដល់ហើយ បានសួរថាណើនុ៎ះ ឱអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋៈ បានឮថាអ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា តែងធ្វើនូវសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនគួរធ្វើនូវសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ មែនឬ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សំដែងថា តែងធ្វើនូវសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនគួរធ្វើនូវសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ យ៉ាងហ្នឹងមែន ។ គ្រានោះឯង ភិក្ខុទាំងនោះ មានប្រាថ្នាដើម្បីធ្វើអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត ឲ្យវៀរចាកទិដ្ឋិអាក្រក់នោះ ក៏សាកសួរ ដេញដោលសួររកហេតុថា ឱអាវុសោអរិដ្ឋៈ អ្នកកុំពោលយ៉ាងហ្នឹងឡើយ អ្នកកុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ការពោលបង្កាច់ ព្រះមានព្រះភាគមិនល្អទេ ព្រោះថា ព្រះមានព្រះភាគ មិនបានត្រាស់យ៉ាងហ្នឹងឡើយ

អនេកបរិយាយេន អាវុសោ(១) អរិដ្ឋ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ មំសបេសូបមា កាមា វុត្តា ភគវតា ។ តិណុក្កូបមា កាមា វុត្តា ភគវតា...។ អង្គារកាសូបមា កាមា វុត្តា ភគវតា...។ សុបិនកូបមា កាមា វុត្តា ភគវតា ...។ យាចិតកូប-មា កាមា វុត្តា ភគវតា...។ រុក្ខផលូបមា កាមា វុត្តា ភគវតា... ។ អសិសូនូបមា កាមា វុត្តា ភគ-វតា ... ។ សត្តិសូលូបមា កាមា វុត្តា ភគវតា ... ។

១ ឱ. អនេកបរិយាយេន ហាវុសោ ។ ម. អនេកបរិយាយេនាវុសោ ។





នែអាវុសោអរិដ្ឋៈ ធម៌ទាំងឡាយដែលធ្វើនូវសេចក្តីអន្តរាយ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើន ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយ មានឧបមាដូចឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃលែង ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចដុំសាច់...។ ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចគប់ស្មៅ...។ ព្រះមានព្រះភាគទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចរណ្តៅរងើកភ្លើង...។ ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចការយល់សប្តិ...។ ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចរបស់ខ្ចីគេ...។ ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចផ្លែឈើ... ។ ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមាដូចកាំបិតនិងជ្រញ់...។ ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយ មានឧបមាដូចលំពែងនិងដែកស្រួច...។

សប្បសិរូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ ឯវម្បិ ខោ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេហិ ភិក្ខូហិ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ តទេវ បាបកំ ទិដ្ឋិគតំ ថាមសា បរាមាសា(១) អភិនិវិស្ស វោហរតិ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។

(១៣) យតោ ខោ តេ ភិក្ខូ នាសក្ខឹសុ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ អថ តេ ភិក្ខូ(២) យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ

១ បរាមស្សាតិបិ បាឋោ ។ ២ ម. តេ ភិក្ខូតិ ន ទិស្សតិ ។



ព្រះមានព្រះភាគ ទ្រង់សំដែងថា កាមទាំងឡាយមានឧបមេយ្យដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ចិត្តច្រើន ទោសក្នុងកាមទាំងឡាយនោះ មានច្រើនក្រៃលែង ។ អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ទុកជាភិក្ខុទាំងឡាយនោះសាកសួរ ដេញដោល សួររកហេតុយ៉ាងនេះហើយ ក៏នៅតែនិយាយប្រកាន់ដោយព្រោះកម្លាំងនៃទិដ្ឋិ ព្រោះការស្ទាបអង្អែលដោយទិដ្ឋិថា ម្នាលអាវុសោ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយយ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សំដែងថា តែងធ្វើនូវសេចក្ដីអន្តរាយ ធម៌ទាំងនោះ មិនអាចធ្វើនូវសេចក្ដីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ។

(១៣) ភិក្ខុទាំងឡាយនោះ មិនអាចធ្វើភិក្ខុឈ្មោះអរិដ្ឋៈ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ឲ្យវៀរចាកទិដ្ឋិអាក្រក់នុ៎ះបាន ក្នុងកាលណា ភិក្ខុទាំងឡាយនោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងកាលនោះ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ភិក្ខុទាំងឡាយនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយក៏

ភគវន្តំ ឯតទវោចុំ អរិដ្ឋស្ស នាម ភន្តេ ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ អស្សុម្ហា ខោ មយំ ភន្តេ អរិដ្ឋស្ស កិរ នាម ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ អថ ខោ មយំ ភន្តេ យេន អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេនុបសង្កមិម្ហា ឧបសង្កមិត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតទវោចុម្ហា សច្ចំ កិរ តេ អាវុសោ អរិដ្ឋ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ



ក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះអរិដ្ឋៈ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញ ដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ បានឮដំណឹងថា ភិក្ខុឈ្មោះអរិដ្ឋៈ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញ ដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង យើងខ្ញុំទាំងឡាយក៏ចូលទៅរកអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត លុះចូលទៅដល់ហើយ ក៏បានសួរដំណើរនោះនឹងអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋៈ បានឮថាអ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ

យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ឯវំ វុត្តេ(១) អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ អម្ហេ ឯតទវោច ឯវំ ព្យាខោ អហំ អាវុសោ ភគវតា ធម្មំ ទេ-សិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរា-យាយាតិ អថខោ មយំ ភន្តេ អរិដ្ឋំ ភិក្ខុំ គទ្ធពា-ធិបុព្វំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុកាមា សមនុយុញ្ជិម្ហា សមនុគ្គាហិម្ហា សមនុភាសិម្ហា មា ហេវំ(២) អាវុសោ អរិដ្ឋ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ អរិដ្ឋ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ

១ ឱ. ម. ឯវំ វុត្តេ ភន្តេ ។ ២ ឱ. មា ឯវំ ។



ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា ធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ឯខ្ញុំ កាលដែលយើងខ្ញុំទាំងឡាយ សួរយ៉ាងនោះហើយ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត ក៏និយាយមកនឹងយើងខ្ញុំទាំងឡាយវិញដូច្នេះថា នែអាវុសោទាំងឡាយ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ យ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា ធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះឯង យើងខ្ញុំទាំងឡាយ មានប្រាថ្នានឹងធ្វើអរិដ្ឋភិក្ខុ ឲ្យបែរចាកទិដ្ឋិអាក្រក់នុ៎ះ ទើបយើងខ្ញុំទាំងឡាយសាកសួរដេញដោលសួររកហេតុថា ម្នាលអាវុសោអរិដ្ឋ អ្នកកុំពោលយ៉ាងហ្នឹង អ្នកកុំពោលបង្កាច់ នូវព្រះមានព្រះភាគឡើយ ការពោលបង្កាច់ព្រះមានព្រះភាគមិនល្អទេ ព្រោះថាព្រះមានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ នែអាវុសោអរិដ្ឋ ធម៌ទាំងឡាយ ដែលធ្វើនូវសេចក្តីអន្តរាយ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ

បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។បេ។ សប្បសិរូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវម្បិ ខោ ភន្តេ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ អម្ហេហិ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ តទេវ បាបកំ ទិដ្ឋិគតំ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ យតោ ខោ មយំ ភន្តេ



អាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោស ក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចកងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ។បេ។ ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក បពិត្រព្រះអង្គដ៏ចម្រើន អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ទុកជាយើងខ្ញុំទាំងឡាយសាកសួរដេញដោល សួររកហេតុ ក៏នៅតែនិយាយប្រកាន់ខាប់ ព្រោះកម្លាំងនៃទិដ្ឋិ ព្រោះការស្ទាបអង្អែលដោយទិដ្ឋិថា ម្នាលអាវុសោទាំងឡាយ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ យ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះតែយើងខ្ញុំទាំងឡាយ

នាសក្ខិម្ហា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ អថ មយំ ឯតមត្ថំ ភគវតោ អារោចេមាតិ ។

(១៤) អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ អាមន្តេហិ សត្ថា តំ អាវុសោ អរិដ្ឋ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេន អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេនុបសង្កមិ ឧបសង្កមិត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតទវោច សត្ថា តំ អាវុសោ អរិដ្ឋ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ភគវា ឯតទវោច





មិនអាចធ្វើភិក្ខុឈ្មោះអរិដ្ឋ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ឲ្យបែរចាក ទិដ្ឋិអាក្រក់នុ៎ះ បានទើបយើងខ្ញុំទាំងឡាយ សូមក្រាបបង្គំទូលហេតុនុ៎ះ ចំពោះព្រះមានព្រះភាគ ។

(១៤) គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូប ថា ម្នាលភិក្ខុ ចូរអ្នកមកអាយ អ្នកចូរទៅហៅអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត តាមពាក្យតថាគតថា ម្នាលអាវុសោអរិដ្ឋ ព្រះសាស្តា ទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត លុះចូលទៅដល់ហើយ ក៏និយាយនឹងអរិដ្ឋភិក្ខុ មានបុព្វ-បុរសជាអ្នកសម្លាប់ត្មាត ដូច្នេះថា ម្នាលអាវុសោអរិដ្ឋ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ក៏ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះអរិដ្ឋភិក្ខុមានបុព្វបុរស ជាអ្នកសម្លាប់ត្មាត អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា

សច្ចំ កិរ តេ អរិដ្ឋ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិ-សេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ កស្ស ខោ នាម ត្វំ មោឃបុរិស មយា ឯវំ ធម្មំ ទេសិតំ អាជានាសិ ។ ននុ មយា មោឃបុរិស អនេ-កបរិយាយេន អន្តរាយិកា ធម្មា វុត្តា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទី-នវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា មយា ... ។ មំសបេសូបមា កាមា វុត្តា មយា ... ។



ម្នាលអរិដ្ឋ បានឮថា អ្នកមានទិដ្ឋិដ៏អាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា តែងធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចនឹងធ្វើនូវសេចក្ដីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ដូច្នេះមែនឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ យ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា តែងធ្វើនូវសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ នែមោឃបុរស អ្នកដឹងច្បាស់ធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ អំពីសម្នាក់អ្នកណា ។ ម្នាលមោឃបុរស ធម៌ធ្វើនូវសេចក្ដីអន្តរាយ តថាគតសំដែងហើយ ដោយអនេកបរិយាយ ក៏ឯធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្ដីអន្តរាយ ដល់បុគ្គលអ្នកសេពដោយពិត តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក តថាគតសំដែងហើយថា កាមទាំងឡាយ មានឧបមាដូចកងឆ្អឹង...។ តថាគត សំដែងហើយថា កាមទាំងឡាយ មានឧបមាដូចដុំសាច់...។

តិណុក្កូបមា កាមា វុត្តា មយា ... ។ អង្គារកាសូបមា កាមា វុត្តា មយា ... ។ សុបិនកូបមា កាមា វុត្តា មយា ... ។ យាចិតកូបមា កាមា វុត្តា មយា ... ។ រុក្ខផលូបមា កាមា វុត្តា មយា ... ។ អសិសូនូបមា កាមា វុត្តា មយា ... ។ សត្តិសូលូបមា កាមា វុត្តា មយា ... ។ សប្បសិរូបមា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អថ ច បន(១) មោឃបុរិស អត្តនា ទុគ្គហិតេន អម្ហេ ចេវ អព្ភាចិក្ខសិ អត្តានញ្ច ខនសិ ពហុញ្ច អបុញ្ញំ បសវសិ តញ្ហិ តេ មោឃបុរិស ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ

១ ម. ឆ. ឯត្តកេ ឧត្តិ ទិស្សតិ ។



តថាគតសម្ដែងហើយថា កាមទាំងឡាយ មានឧបមាដូចគប់ស្មៅ...។ តថាគតសម្ដែងហើយថា កាមទាំងឡាយ មានឧបមាដូចរណ្ដៅរងើកភ្លើង...។ តថាគតសម្ដែងហើយថា កាមទាំងឡាយមានឧបមាដូចការយល់សប្ដិ...។ តថាគតសម្ដែងហើយថាកាមទាំងឡាយមានឧបមាដូចរបស់ដែលខ្ចីគេ...។ តថាគតសម្ដែងហើយថា កាមទាំងឡាយ មានឧបមាដូចផ្លែឈើ...។ តថាគតសម្ដែងហើយថា កាមទាំងឡាយ មានឧបមាដូចកាំបិតនិងជ្រញ់...។ តថាគតសម្ដែងហើយថា កាមទាំងឡាយ មានឧបមាដូចលំពែងនិងដែកស្រួច...។ តថាគតសម្ដែងហើយថា កាមទាំងឡាយ មានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក នែមោឃបុរស កាលបើហេតុមានទំនងយ៉ាងនេះ អ្នកឈ្មោះថា ពោលបង្កាច់តថាគតផង ឈ្មោះថាគាស់រំលើងនូវខ្លួនឯងផង ឈ្មោះថា ទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនប្រកាន់អាក្រក់ ម្នាលមោឃបុរស ព្រោះថា អំពើអាក្រក់នោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខដល់អ្នកអស់កាលយូរអង្វែង ។ គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់សួរភិក្ខុ

តំ កឹ មញ្ញថ ភិក្ខវេ អបិ នាយំ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ ឧស្មីកតោបិ ឥមស្មឹ ធម្មវិនយេតិ ។ កិញ្ហិ(១) សិយា ភន្តេ នោ ហេតំ ភន្តេតិ ។ ឯវំ វុត្តេ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។

(១៨) អថខោ ភគវា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតទវោច បញ្ញាយិស្សសិ ខោ ត្វំ មោឃបុរិស ឯតេន សកេន បាបកេន ទិដ្ឋិគតេន ឥធាហំ ភិក្ខូ បដិបុច្ឆិស្សាមីតិ ។ អថខោ ភគវា

១ ឱ. ម. កឹ ហិ ។



ទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះថា ដូចម្តេច អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ ឈ្មោះថាមានចំហាយកម្តៅភ្លើងគឺញាណ ក្នុងធម្មវិន័យនេះ បានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ចំហាយកម្តៅភ្លើងនោះនឹងមានដូចម្តេចបាន បពិត្រព្រះអង្គដ៏ចម្រើន ចំហាយកម្តៅភ្លើងនោះមិនមានឡើយ ។ កាលដែលពួកភិក្ខុក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះហើយ អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ក៏អង្គុយនៅស្ងៀម អៀនខ្មាស ដាក់កសំយុងចុះ ឱនមុខចុះ សញ្ជប់សញ្ជឹង មិនភ្លៀវភ្លា ។

(១៨) គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបថា អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត អង្គុយនៅស្ងៀម អៀនខ្មាស ដាក់កសំយុងចុះ ឱនមុខចុះ សញ្ជប់សញ្ជឹងមិនភ្លៀវភ្លាហើយ មានព្រះបន្ទូលទៅនឹងអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាតដូច្នេះថា ម្នាលមោឃបុរស អ្នកនឹងប្រាកដ ដោយទិដ្ឋិអាក្រក់ ជារបស់ខ្លួននេះ តែតថាគតនឹងសាកសួរភិក្ខុទាំងឡាយក្នុងសេចក្តីនេះ ។ គ្រានោះឯង ព្រះមានព្រះភាគ

ភិក្ខូ អាមន្តេសិ តុម្ហេបិ មេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ យថាយំ អរិដ្ឋោ ភិក្ខុ គទ្ធពាធបុព្វោ អត្តនា ទុគ្គហិតេន អម្ហេ ចេវ អព្ភាចិក្ខតិ អត្តានញ្ច ខណតិ ពហុញ្ច អបុញ្ញំ បសវតីតិ ។ នោ ហេតំ ភន្តេ អនេកបរិយាយេន ហិ នោ ភន្តេ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ បេ ។ សប្បសិរូបមា កាមា វុត្តា ភគវតា



ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ ពោលបង្កាច់ តថាគតផង ជីកគាស់រំលើងនូវខ្លួនឯងផង ទទួល នូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនកាន់យកអាក្រក់ ដោយប្រការណា ព្រោះអ្នកទាំងឡាយដឹងច្បាស់នូវធម៌ ដែលតថាគតសម្តែងហើយ ដោយប្រការដូច្នោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ មិនបានដឹងច្បាស់នូវធម៌នុ៎ះទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ធម៌ធ្វើនូវសេចក្តីអន្តរាយ ព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ដល់យើងខ្ញុំទាំងឡាយ ដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយមានឧបមាដូចជាកង្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ។ បេ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចក្បាលពស់

ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ សាធុ(១) ខោ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ អនេកបរិយាយេន ហិ វោ ភិក្ខវេ អន្តរាយិកា ធម្មា វុត្តា មយា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។បេ។ សប្បសិរូបមា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អថ ច បនាយំ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ អត្តនា ទុគ្គហិតេន អម្ហេ ចេវ អព្ភាចិក្ខតិ អត្តានញ្ច ខនតិ ពហុញ្ច អបុញ្ញំ បសវតិ តញ្ហិ

១ ម. សាធុ ភិក្ខវេ ។



មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃពេក ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដឹងច្បាស់នូវធម៌ដែលតថាគតសម្តែងហើយ យ៉ាងនេះ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ ព្រោះថាធម៌ធ្វើនូវសេចក្តីអន្តរាយ តថាគតសម្តែងហើយ ដល់អ្នកទាំងឡាយដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ តែងធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពពិតមែន តថាគតសម្តែងហើយថា កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃពេក តថាគតសម្តែងហើយថា កាមទាំងឡាយ ឧបមាដូចជាកង់ឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ។បេ។ តថាគតសម្តែងហើយថា កាមទាំងឡាយមានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោស ក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក កាលបើហេតុមានទំនងយ៉ាងនេះ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ ឈ្មោះថា ពោលបង្កាច់តថាគតផង ឈ្មោះថាគាស់រំលើងនូវខ្លួនឯងផង តែងទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនប្រកាន់អាក្រក់ ព្រោះថាអំពើនោះ នឹងប្រព្រឹត្តទៅ

តស្ស មោឃបុរិស ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ សោ វត ភិក្ខវេ អញ្ញត្រេវ កាមេហិ អញ្ញត្រ កាមសញ្ញាយ អញ្ញត្រ កាមវិតក្កេហិ កាមេ បដិសេវិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

(១៦) ឥធ ភិក្ខវេ ឯកច្ចេ មោឃបុរិសា ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ



ដើម្បីមិនជាប្រយោជន៍ ជាទុក្ខ ដល់មោឃបុរសនោះ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ វៀរលែងតែកាមទាំងឡាយ វៀរលែងតែសេចក្តីសម្គាល់ក្នុងកាមទាំងឡាយ វៀរលែងតែកាមវិតក្កៈទាំងឡាយហើយ ត្រឡប់សេពនូវកាមទាំងឡាយវិញ នេះមិនមែនជាឋានៈឡើយ ។

(១៦) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានមោឃបុរសពួកខ្លះរៀនធម៌គឺ សុត្តៈ[១] គេយ្យៈ[២] វេយ្យាករណៈ[៣] គាថា[៤] ឧទាន[៥]

---

១ បានខាងឧភតោវិភង្គ គឺភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ និងនិទ្ទេសគឺបទភាជនីយ៍របស់ឧភតោវិភង្គនោះ និងខន្ធកៈទាំង ២២ មានបព្វជ្ជាខន្ធកៈជាដើម និងបរិវារៈ និងមង្គលសូត្រ រតនសូត្រ នាឡកសូត្រ តុវដ្ដកសូត្រ ដែលមានក្នុងគម្ពីរសុត្តនិបាត និងសូត្រដទៃ ៗ ដែលជាពាក្យរបស់ព្រះតថាគត ។ ២ បានខាងសូត្រទាំងអស់ដែលមានគាថា និងសគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយ ។ ៣ បានខាងអភិធម្មបិដកទាំងអស់និងសូត្រដែលគ្មានគាថា និងពុទ្ធវចនៈឯទៀត ៗ ដែលមិនបានសង្គ្រោះដោយអង្គ ៨ ។ ៤ បានខាងធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធមិនបានឈ្មោះថាសុត្ត ក្នុងគម្ពីរសុត្តនិបាត ។ ៥ បានខាងព្រះសូត្រទាំង ៨២ ប្រកបដោយគាថាដែលសម្រេចមកអំពីសោមនស្សញ្ញាណ ។

ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តេ តំ ធម្មំ បរិយាបុណិត្វា តេសំ ធម្មានំ បញ្ញាយ អត្ថំ ន ឧបបរិក្ខន្តិ តេសំ តេ ធម្មា បញ្ញាយ អត្ថំ អនុបបរិក្ខតំ ន និជ្ឈានំ ខមន្តិ តេ ឧបារម្ភានិសំសា ចេវ ធម្មំ បរិយាបុណន្តិ ឥតិវាទប្បមោក្ខានិសំសា ច យស្សត្ថាយ(១) ធម្មំ បរិយាបុណន្តិ តញ្ចស្ស អត្ថំ នានុភោន្តិ តេសំ

១ ឱ. ម. យស្ស ចត្ថាយ ។



ឥតិវុត្តកៈ(១) ជាតកៈ(២) អព្ភុតធម្មៈ(៣) វេទល្លៈ(៤) លុះពួកបុរសទាំងនោះ បានរៀនធម៌នោះហើយ ក៏មិនបានពិចារណានូវសេចក្តីនៃធម៌ទាំងឡាយនោះ ដោយប្រាជ្ញា ធម៌ទាំងនោះ ដែលមោឃបុរសទាំងនោះមិនបានពិចារណានូវសេចក្តីដោយប្រាជ្ញាហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្ត មោឃបុរសទាំងនោះ រៀនធម៌ដោយមានបំណងនឹងរកខាងលើកទោសគេផង ដោយមានបំណងនឹងដោះស្រាយពាក្យដូច្នេះដូច្នោះផង កុលបុត្រទាំងឡាយ រៀនធម៌ដើម្បីប្រយោជន៍ណា (៥) ពួកមោឃបុរសនោះ មិនបាននូវប្រយោជន៍នោះ របស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះដែល

១ បានខាងព្រះសូត្រទាំង ១១០ សូត្រ មានពាក្យថា វុត្តមិទំ ភគវតា ជាដើម ។ ២ បានខាងជាតក ៥៥០ មានអបណ្ណកជាតកជាដើម ។ ៣ បានខាងសូត្រទាំងអស់ដែលសម្តែងអំពីសេចក្តីអស្ចារ្យ មានពាក្យថា ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ជាដើម ។ ៤ បានខាងសូត្រទាំងឡាយមានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រជាដើម និងសូត្រទាំងពួងដែលអ្នកសួរបានសេចក្តីត្រេកអរហើយដេញដោលសួរតទៅ ។ ៥ សំដៅយកមគ្គផល ។

តេ ធម្មា ទុគ្គហិតា ទីឃរត្តំ អហិតាយ ទុក្ខាយ សំវត្តន្តិ តំ កិស្ស ហេតុ ទុគ្គហិតត្តា ភិក្ខវេ ធម្មានំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ អលគទ្ទត្ថិកោ អលគទ្ទគវេសី អលគទ្ទបរិយេសនំ ចរមានោ សោ បស្សេយ្យ មហន្តំ អលគទ្ទំ តមេនំ ភោគេ វា នង្គុដ្ឋេ វា គណ្ហេយ្យ តស្ស សោ អលគទ្ទោ បដិនិវត្តិត្វា ហត្ថេ វា ពាហាយ វា អញ្ញតរស្មឹ វា អង្គបច្ចង្គេ ឌំសេយ្យ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ តំ កិស្ស ហេតុ ទុគ្គហិតត្តា ភិក្ខវេ អលគទ្ទស្ស ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចេ មោឃបុរិសា ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តេ តំ ធម្មំ បរិយាបុណិត្វា តេសំ ធម្មានំ បញ្ញាយ អត្ថំ ន ឧបបរិក្ខន្តិ តេសំ តេ ធម្មា បញ្ញាយ អត្ថំ អនុបបរិក្ខតំ ន និជ្ឈានំ ខមន្តិ តេ ឧបារម្ភានិសំសា ចេវ ធម្មំ បរិយាបុណន្តិ



មោឃបុរសទាំងនោះ រៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលយូរអង្វែង ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាធម៌ទាំងឡាយ មោឃបុរសទាំងនោះរៀនមិនល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ក៏ត្រាច់ទៅស្វែងរកពស់វែក បុរសនោះបានឃើញពស់វែក ១ យ៉ាងធំ ហើយក៏ចាប់ពស់វែកនោះត្រង់ខ្លួនឬកន្ទុយ ពស់វែកនោះក៏ងាកមកចឹកបុរសនោះ ត្រង់ដៃឬដើមដៃឬអវយវៈតូចធំណាមួយ បុរសនោះក៏ដល់នូវសេចក្ដីស្លាប់ឬដល់នូវសេចក្ដីទុក្ខជិតនៃទីស្លាប់ មានពស់វែកនោះជាហេតុ ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាពស់វែក បុរសនោះចាប់មិនស្រួល ម្នាលភិក្ខុទាំងឡាយ មានមោឃបុរសពួកខ្លះ ក្នុងសាសនានេះ រៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ លុះមោឃបុរសទាំងនោះរៀនធម៌នោះហើយ មិនបានពិចារណានូវសេចក្ដីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងឡាយនោះដែលមោឃបុរសទាំងនោះមិនបានពិចារណានូវសេចក្ដីដោយប្រាជ្ញាហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្ត មោឃបុរសទាំងនោះ រៀនធម៌ដោយមានបំណងតែខាង

ឥតិវាទប្បមោក្ខានិសំសា ច យស្សត្ថាយ ធម្មំ បរិយាបុណន្តិ តញ្ចស្ស អត្ថំ នានុភោន្តិ តេសំ តេ ធម្មា ទុគ្គហិតា ទីឃរត្តំ អហិតាយ ទុក្ខាយ សំវត្តន្តិ តំ កិស្ស ហេតុ ទុគ្គហិតត្តា ភិក្ខវេ ធម្មានំ ។

(១៧) ឥធ បន ភិក្ខវេ ឯកច្ចេ កុលបុត្តា ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តេ តំ ធម្មំ បរិយាបុណិត្វា តេសំ ធម្មានំ បញ្ញាយ អត្ថំ ឧបបរិក្ខន្តិ តេសំ តេ ធម្មា បញ្ញាយ អត្ថំ ឧបបរិក្ខតំ និជ្ឈានំ ខមន្តិ តេ ន ចេវ ឧបារម្ភានិសំសា ធម្មំ បរិយាបុណន្តិ ន ឥតិវាទប្បមោក្ខានិសំសា ច យស្ស-ត្ថាយ ធម្មំ បរិយាបុណន្តិ តញ្ចស្ស អត្ថំ អនុភោន្តិ



លើកទោសគេផង ដោយមានបំណងតែខាងដោះស្រាយក្តីវាទៈ ដូច្នេះ ដូច្នោះផង កុលបុត្រទាំងឡាយរៀនធម៌ ដើម្បីប្រយោជន៍ណា ពួកមោឃបុរសនោះក៏មិនបាននូវប្រយោជន៍នោះ របស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះរៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះជាធម៌ទាំងឡាយ ដែលមោឃបុរស រៀនមិនល្អហើយ យ៉ាងនេះឯង ។

(១៧) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះរៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ កុលបុត្រទាំងនោះ លុះរៀនធម៌នោះហើយ ក៏ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយនោះដោយប្រាជ្ញា ធម៌ទាំងនោះ លុះកុលបុត្រទាំងនោះពិចារណានូវសេចក្តីដោយប្រាជ្ញាហើយ ក៏ប្រាកដច្បាស់ក្នុងចិត្ត កុលបុត្រទាំងនោះមិនមែនរៀនធម៌ ដោយមានបំណងតែខាងលើកទោសគេផង មិនមែនរៀនធម៌ដោយមានបំណងតែខាងដោះស្រាយក្តីវាទៈដូច្នេះដូច្នោះផង កុលបុត្រឯទៀតរៀនធម៌ ដើម្បីប្រយោជន៍ណា កុលបុត្រទាំងនោះ ក៏បាននូវប្រយោជន៍នោះ របស់ធម៌នោះ

តេសំ តេ ធម្មា សុគហិតា ទីឃរត្តំ ហិតាយ សុខាយ សំវត្តន្តិ តំ កិស្ស ហេតុ សុគហិតត្តា ភិក្ខវេ ធម្មានំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ អលគទ្ទត្ថិកោ អលគទ្ទគវេសី អលគទ្ទបរិយេសនំ ចរមានោ សោ បស្សេយ្យ មហន្តំ អលគទ្ទំ តមេនំ អជបទេន ទណ្ឌេន សុនិគ្គហិតំ និគ្គណ្ហេយ្យ អជប-ទេន ទណ្ឌេន សុនិគ្គហិតំ និគ្គហេត្វា គីវាយំ សុគហិតំ គណ្ហេយ្យ កិញ្ចាបិ សោ ភិក្ខវេ អលគទ្ទោ តស្ស បុរិសស្ស ហត្ថំ វា ពាហំ វា អញ្ញតរំ វា អង្គបច្ចង្គំ ភោគេហិ បលិវេឋេយ្យ អថខោ សោ នេវ តតោនិ-ទានំ មរណំ វា និគ្គច្ឆេយ្យ មរណមត្តំ វា ទុក្ខំ តំ កិស្ស ហេតុ សុគហិតត្តា ភិក្ខវេ អលគទ្ទស្ស ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចេ កុលបុត្តា ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ





ធម៌ទាំងនោះដែលកុលបុត្រពួកនោះរៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ទាំងឡាយដែលកុលបុត្រទាំងនោះ បានរៀនដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ត្រាច់ទៅស្វែងរកពស់វែក បុរសនោះបានឃើញពស់វែក ១ យ៉ាងធំ ក៏សង្កត់ពស់វែកនោះដោយដំបងដូចជាជើងពពែ ដោយស្រួលបួល លុះសង្កត់ដោយដំបងដូចជាជើងពពែ យ៉ាងស្រួលហើយ ក៏ចាប់ត្រង់កយ៉ាងមាំ ម្នាលភិក្ខុទាំងឡាយ ពស់វែកនោះរុំព័ទ្ធដៃឬដើមដៃឬអវយវៈតូចធំណាមួយនៃបុរសនោះ ដោយរាងទាំងឡាយក៏មែនហើយ តែបើទុកជាដូច្នោះ បុរសនោះក៏មិនដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ មានពស់វែកនោះជាហេតុទេ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាពស់វែកបុរសនោះចាប់ត្រូវទំនង ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះ រៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា

ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភូតធម្មំ វេទល្លំ តេ ធម្មំ បរិយាបុណិត្វា តេសំ ធម្មានំ បញ្ញាយ អត្ថំ ឧបបរិក្ខន្តិ តេសំ តេ ធម្មា បញ្ញាយ អត្ថំ ឧបបរិក្ខតំ និជ្ឈានំ ខមន្តិ តេ ន ចេវ ឧបារម្ភានិសំសា ធម្មំ បរិយាបុណន្តិ ន ឥតិវាទប្បមោក្ខានិសំសា ច យស្សត្ថាយ ធម្មំ បរិយាបុណន្តិ តញ្ចស្ស អត្ថំ អនុភោន្តិ តេសំ តេ ធម្មា សុគ្គហិតា ទីឃរត្តំ ហិតាយ សុខាយ សំវត្តន្តិ តំ កិស្ស ហេតុ សុគ្គហិតត្តា ភិក្ខវេ ធម្មានំ ។ តស្មាតិហ ភិក្ខវេ យស្ស មេ ភាសិតស្ស អត្ថំ អាជានេយ្យាថ តថា នំ ធារេយ្យាថ យស្ស ច បន មេ ភាសិតស្ស អត្ថំ ន អាជានេយ្យាថ អហំ វោ តត្ថ(១) បដិបុច្ឆិតព្វោ យេ វា បនស្សុ វិយត្តា ភិក្ខូ កុល្លូបមំ វោ ភិក្ខវេ ធម្មំ ទេសេស្សាមិ

១ ម. តត្ថ ។



ឧទាន: ឥតិវុត្តក: ជាតក: អព្ភូតធម្ម: វេទល្ល: កុលបុត្រ ទាំងនោះ លុះបានរៀនធម៌នោះហើយ ក៏ពិចារណា នូវសេចក្តីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងនោះ លុះកុលបុត្រពួកនោះបានពិចារណា នូវសេចក្តីដោយប្រាជ្ញា ក៏ប្រាកដច្បាស់ក្នុងចិត្ត កុលបុត្រទាំងនោះមិនមែនរៀនធម៌ ដោយមានចំណង់តែទាំងលើកទោសគេផង មិនមែនរៀនធម៌ ដោយមានចំណង់តែទាំងដោះស្រាយវាទៈជួបុះជួបោះផង កុលបុត្រឯទៀតរៀនធម៌ដើម្បីប្រយោជន៍ណា កុលបុត្រទាំងនោះ ក៏បាននូវប្រយោជន៍នោះរបស់ធម៌នោះ ធម៌ទាំងឡាយនោះ ដែលកុលបុត្រទាំងនោះរៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ទាំងឡាយដែលកុលបុត្រទាំងនោះរៀនដោយល្អ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីដឹងច្បាស់ នូវសេចក្តីនៃភាសិតណា របស់តថាគត គប្បីចាំទុកនូវសេចក្តីនៃភាសិតនោះយ៉ាងនោះចុះ មួយវិញទៀត អ្នកទាំងឡាយមិនអាចដឹងច្បាស់នូវសេចក្តីនៃភាសិតណា របស់តថាគត អ្នកទាំងឡាយគប្បីសាកសួរតថាគតក្នុងអត្ថនៃភាសិតនោះចុះ ឬគប្បីសួរចំពោះភិក្ខុណាដែលឈ្លាសវៃចុះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ មានឧបមាដូចក្បូន ដល់អ្នកទាំងឡាយ

និត្ថរណត្ថាយ នោ គហណត្ថាយ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៨) ភគវា ឯតទវោច សេយ្យថាបិ ភិក្ខវេ បុរិសោ អទ្ធានមគ្គប្បដិបន្នោ សោ បស្សេយ្យ មហន្តំ ឧទកណ្ណវំ ឱរិមតីរំ(១) សាសង្កំ សប្បដិភយំ បារិមតីរំ ខេមំ អប្បដិភយំ ន ចស្ស នាវា សន្តារណី ឧត្តរសេតុ វា អបារា បារំ គមនាយ តស្ស ឯវមស្ស អយំ ខោ មហា ឧទកណ្ណវោ ឱរិមតីរំ(២) សាសង្កំ សប្បដិភយំ បារិមតីរំ ខេមំ អប្បដិភយំ នត្ថិ ច នាវា សន្តារណី ឧត្តរសេតុ វា អបារា បារំ គមនាយ យន្នូនាហំ តិណកដ្ឋសាខាបលាសំ សង្កឌ្ឍិត្វា កុល្លំ ពន្ធិត្វា

១ ម. ឱរិមន្តីរំ ។ ឧ. ឱរិមំ តីរំ ។ ២ ម. ឱរិមញ្ញ តីរំ ។ ឧ. ឱរិមំ តីរំ ។



ដើម្បីឲ្យរលាស់ខ្លួនចេញ មិនមែនដើម្បីឲ្យទៅប្រកាន់ទេឡើយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវសេចក្តីនោះ ចូរទុំយកចិត្តទុកដាក់ឲ្យប្រពៃ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(១៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកដើរផ្លូវឆ្ងាយ បុរសនោះឃើញ នូវអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ តែថាទូក ក្បូន ឬស្ពានសម្រាប់ឆ្លងពីត្រើយអាយ ទៅត្រើយនាយ នៃបុរសនោះមិនមានឡើយ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អន្លង់ទឹកដ៏ធំនេះ មានត្រើយខាងអាយប្រកបដោយសេចក្តីរង្កៀសនិងភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ ទូក ក្បូនឬស្ពានសម្រាប់ឆ្លងពីត្រើយខាងអាយទៅត្រើយខាងនាយក៏គ្មាន បើដូច្នោះ មានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើ មែកឈើ និងចំបើង យកមកចងធ្វើជាក្បូន ហើយ

តំ កុល្លំ និស្សាយ ហត្ថេហិ ច បាទេហិ ច វាយមមានោ សោត្ថិនា បារំ ឧត្តរេយ្យន្តិ ។ អថខោ សោ ភិក្ខវេ បុរិសោ តិណកដ្ឋសាខាបលាសំ សង្កឌ្ឍិត្វា កុល្លំ ពន្ធិត្វា តំ កុល្លំ និស្សាយ ហត្ថេហិ ច បាទេហិ ច វាយមមានោ សោត្ថិនា បារំ ឧត្តរេយ្យ តស្ស ឧត្តិណ្ណស្ស បារគតស្ស(១) ឯវមស្ស ពហុការោ ខោ មេ អយំ កុល្លោ ឥមាហំ កុល្លំ និស្សាយ ហត្ថេហិ ច បាទេហិ ច វាយមមានោ សោត្ថិនា បារំ ឧត្តិណ្ណោ យន្នូនាហំ ឥមំ កុល្លំ សីសេ វា អារោបេត្វា ខន្ធេ វា បច្ចារោបេត្វា(២) យេនកាមំ បក្កមេយ្យន្តិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ ឯវំការី តស្មឹ កុល្លេ កិច្ចការី អស្សាតិ ។ នោ ហេតំ ភន្តេ ។ កថំការី ច សោ ភិក្ខវេ បុរិសោ តស្មឹ កុល្លេ កិច្ចការី អស្ស ។ ឥធ ភិក្ខវេ តស្ស បុរិសស្ស បារគតស្ស(៣) ឯវមស្ស ពហុការោ ខោ មេ អយំ កុល្លោ

១ ឱ. តស្ស តិណ្ណស្ស បារំ គតស្ស ។ ម. តស្ស បុរិសស្ស តិណ្ណស្ស បារំ គតស្ស ។ ២ ឱ. ឧច្ចារេត្វា ។ ៣ ឱ. ម. តិណ្ណស្ស បារំ គតស្ស ។



អាស្រ័យនូវក្បូននោះ ព្យាយាមដោយដៃនិងជើង ឆ្លងទៅកាន់ត្រើយខាងនាយដោយសួស្តីបាន ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះក៏ប្រមូលស្មៅ កំណាត់ឈើ មែកឈើ និងចំបើង មកចងជាក្បូន ហើយបានអាស្រ័យក្បូននោះ ព្យាយាមដោយដៃនិងជើង ឆ្លងទៅកាន់ត្រើយខាងនាយបានដោយសួស្តី កាលបុរសនោះឆ្លងទៅដល់ត្រើយខាងនាយហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញ ។ បានអាស្រ័យក្បូននេះ ព្យាយាមដោយដៃនិងជើង ឆ្លងមកដល់ត្រើយដោយសួស្តីបាន បើដូច្នោះមានតែអាត្មាអញលើកក្បូននេះទូលលើក្បាលឬលីនឹងក ដើរចេញទៅកាន់ទីគួរតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះធ្វើយ៉ាងនេះ បានឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនមែនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសនោះ ធ្វើដូចម្តេច ទើបបានឈ្មោះថាធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះឆ្លងដល់ត្រើយខាងនាយក្នុងទីឯនោះ គួរតែត្រិះរិះយ៉ាងនេះថា ក្បូននេះមានឧបការៈច្រើន ដល់អាត្មាអញ ។

ឥមាហំ កុល្លំ និស្សាយ ហត្ថេហិ ច បាទេហិ ច វាយមានោ សោត្ថិនា បារំ ឧត្តិណ្ណោ យន្នូនាហំ ឥមំ កុល្លំ ថលេ វា ឧស្សាទេត្វា(១) ឧទកេ វា ឱបិលាបេត្វា យេនកាមំ បក្កមេយ្យន្តិ ។ ឯវំការី ខោ សោ ភិក្ខវេ បុរិសោ តស្មឹ កុល្លេ កិច្ចការី អស្ស ។ ឯវមេវ ខោ ភិក្ខវេ កុល្លូបមោ មយា ធម្មោ ទេសិតោ និត្ថរណត្ថាយ នោ គហណត្ថាយ ។ កុល្លូបមំ វោ ភិក្ខវេ ធម្មំ ទេសិតំ(២) អាជានន្តេហិ ធម្មាបិ វោ បហាតព្វា បគេវ អធម្មា ។

(១៩) ឆយិមានិ ភិក្ខវេ ទិដ្ឋិដ្ឋានានិ ។ កតមានិ ឆ ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ

១ ម. ឧស្សារេត្វា ។ យ. ឧស្សាបេត្វា ។ ២ ម. ធម្មំ ទេសិតំ ន ទិស្សតិ ។



បានអាស្រ័យនូវក្បូននេះហើយ ព្យាយាមដោយដៃនិងជើង ក៏ឆ្លងដល់ត្រើយខាងនាយបានដោយសួស្តី បើដូច្នោះមានតែអាត្មាអញលើកក្បូននេះ ដាក់លើគោក ឬពន្លិចក្នុងទឹក ហើយដើរចេញទៅកាន់ទីគួរតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះ ដែលធ្វើយ៉ាងនេះបាន ឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មានឧបមាដូចជាក្បូន ដែលតថាគតសម្តែងហើយ ដើម្បីឲ្យរលាស់ខ្លួនចេញ មិនមែនដើម្បីឲ្យនៅប្រកាន់ឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ដឹងច្បាស់នូវធម៌ មានឧបមាដូចក្បូន ដែលតថាគតសម្តែងហើយ គប្បីលះបង់ធម៌(១) ទាំងឡាយចេញ នឹងចាំបាច់ពោលទៅថ្វីដល់អកុសលធម៌ ។

(១៩) ម្នាលភិក្ខុទាំងឡាយ ហេតុជាទីតាំង នៃទិដ្ឋិទាំងឡាយនេះ មាន ៦ ។ ហេតុជាទីតាំង នៃទិដ្ឋិទាំង ៦ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនឃើញនូវពួកអរិយបុគ្គល មិនឈ្លាសក្នុងអរិយធម៌ មិនសិក្សាក្នុងអរិយធម៌

១ អដ្ឋកថា ថា បានដល់សមថៈ និងវិបស្សនា ។ ដែលព្រះសាស្តាឲ្យលះនោះ គឺឲ្យលះឆន្ទរាគក្នុងសមថៈ និងវិបស្សនានោះឯង ។

សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ វេទនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ សញ្ញំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ សង្ខារេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ យម្បិទំ ទិដ្ឋិដ្ឋានំ សោ លោកោ សោ អត្តា សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សាមីតិ តម្បិ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ



មិនឃើញពួកសប្បុរស មិនឈ្លាសក្នុងសប្បុរសធម៌ មិនសិក្សាក្នុងសប្បុរសធម៌ ពិចារណាឃើញរូបថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ពិចារណាឃើញនូវវេទនាថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ពិចារណាឃើញនូវសញ្ញាថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ពិចារណាឃើញនូវសង្ខារទាំងឡាយថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះ ១ អារម្មណ៍ណាដែលបានឃើញបានឮ បានពាល់ត្រូវ បានដឹងច្បាស់ មកដល់ បានស្វែងរក បានពិចារណាហើយ ។ ដោយចិត្ត ក៏ពិចារណាឃើញអារម្មណ៍នោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះ ១ ហេតុជាទីតាំងនៃទិដ្ឋិណាថា នោះជាសត្វលោក នោះជាខ្លួនអាត្មាអញ អាត្មាអញនោះទៅកាន់បរលោកនឹងជាអ្នកទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតិវត្ថុ(១) ដូច្នោះឯង ក៏ពិចារណាឃើញហេតុជាទីតាំងនៃទិដ្ឋិនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួននៃអាត្មាអញដូច្នេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ឯអរិយសាវ័កដែលចេះដឹង

---

១ អដ្ឋកថា ថា បានដល់ភ្នំសិនេរុ ផែនដី និងមហាសមុទ្រជាដើម ។

អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ វេទនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ សញ្ញំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ សង្ខារេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ យម្បិទំ ទិដ្ឋិដ្ឋានំ សោ លោកោ



បានឃើញពួកអរិយៈ ជាអ្នកឈ្លាសក្នុងអរិយធម៌ បានសិក្សាដោយប្រពៃក្នុងអរិយធម៌ បានឃើញពួកសប្បុរស ជាអ្នកឈ្លាសក្នុងសប្បុរិសធម៌ បានសិក្សាដោយប្រពៃក្នុងសប្បុរិសធម៌ ពិចារណាឃើញនូវរូបថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ពិចារណាឃើញនូវវេទនាថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ពិចារណាឃើញនូវសញ្ញាថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ពិចារណាឃើញនូវសង្ខារទាំងឡាយថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ អារម្មណ៍ណាដែលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយៗ ដោយចិត្ត ក៏ពិចារណាឃើញនូវអារម្មណ៍នោះថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ហេតុជាទីតាំងនៃទិដ្ឋិណាថា នោះជាសត្វលោក

សោ អត្តា សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សាមីតិ តម្បិ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ សោ ឯវំ សមនុបស្សន្តោ អសតិ ន បរិតស្សតីតិ ។

(២០) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច សិយា នុ ខោ ភន្តេ ពហិទ្ធា អសតិ បរិតស្សនាតិ ។ សិយា ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ ឯកច្ចស្ស ឯវំ ហោតិ អហុ វត មេ តំ វត មេ នត្ថិ សិយា វត មេ, តំ វតាហំ ន លភាមីតិ សោ



នោះជាខ្លួន នោះជាលោក លុះទៅកាន់លោកខាងមុខ គឺជាបុគ្គលទៀងទាត់ ឋិតថេរមិនប្រែប្រួល មិនប្រែប្រួលជាសស្សតិក្ដី ដូច្នោះឯង ក៏ពិចារណាឃើញនូវហេតុជាទីតាំងនៃទិដ្ឋិនោះថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ អរិយសាវ័កនោះ កាលពិចារណាឃើញច្បាស់យ៉ាងនេះ កាលបើវត្ថុនោះមិនមាន គឺថា វិនាសទៅ ក៏មិនតក់ស្លុតឡើយ ។

(២០) លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុ ១ រូប បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បើវត្ថុខាងក្រៅមិនមាន គឺថាវិនាសទៅ សេចក្ដីតក់ស្លុតមានដែរឬ ។ ព្រះមានព្រះភាគទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយក្នុងលោកនេះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ទ្រព្យរបស់អាត្មាអញមានហើយ តែឥឡូវ ទ្រព្យរបស់អាត្មាអញនោះ ត្រឡប់ទៅជាគ្មានវិញ(១) ទ្រព្យណា ដែលអាត្មាអញគួរបាន ឥឡូវអាត្មាអញ មិនបានទ្រព្យនោះឡើយ បុគ្គលនោះ

---

១ ខូចខាតទៅដោយស្ដេចរឹបជាន់ ចោរលួច ភ្លើងឆេះ ទឹកលិច ឬអស់ទៅដោយប្រើប្រាស់ ។ អដ្ឋកថា ។

សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ឯវំ ខោ ភិក្ខុ ពហិទ្ធា អសតិ បរិតស្សនា ហោតីតិ ។ សិយា បន ភន្តេ ពហិទ្ធា អសតិ អបរិតស្សនាតិ ។ សិយា ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ ឯកច្ចស្ស ន ឯវំ ហោតិ អហុ វត មេ តំ វត មេ នត្ថិ សិយា វត មេ តំ វតាហំ ន លភាមីតិ សោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ឯវំ ខោ ភិក្ខុ ពហិទ្ធា អសតិ អបរិតស្សនា ហោតីតិ ។ សិយា នុ ខោ ភន្តេ អជ្ឈត្តំ អសតិ បរិតស្សនាតិ ។ សិយា ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ ឯកច្ចស្ស ឯវំ ទិដ្ឋិ ហោតិ



ក៏សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេងភ្លេច ម្នាលភិក្ខុ កាលបើបរិក្ខារខាងក្រៅមិនមានហើយ សេចក្ដីតក់ស្លុត រមែងមាន យ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបើបរិក្ខារខាងក្រៅ មិនមានហើយ សេចក្ដីមិនតក់ស្លុតមានដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយ ក្នុងលោកនេះ មិនមានសេចក្ដីត្រិះរិះ យ៉ាងនេះថា ទ្រព្យរបស់អាត្មាអញមានហើយ តែឥឡូវទ្រព្យរបស់អាត្មាអញនោះ ត្រឡប់ទៅជាគ្មានវិញ ទ្រព្យណា ដែលអាត្មាអញគួរបាន ឥឡូវអាត្មាអញមិនបានទ្រព្យនោះឡើយ បុគ្គលនោះមិនសោកសៅ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេងភ្លេច ម្នាលភិក្ខុ កាលបើបរិក្ខារខាងក្រៅមិនមានហើយ សេចក្ដីមិនតក់ស្លុត រមែងមាន យ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបើគ្រឿងខាងក្នុងមិនមានហើយ សេចក្ដីតក់ស្លុត មានឬទេ ។ ព្រះមានព្រះភាគ ទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយ ក្នុងលោកនេះ មានសេចក្ដីយល់

សោ លោកោ សោ អត្តា សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សាមីតិ សោ សុណាតិ តថាគតស្ស វា តថាគតសាវកស្ស វា សព្វេសំ ទិដ្ឋិដ្ឋានាធិដ្ឋានបរិយុដ្ឋានាភិនិវេសានុសយានំ សមុគ្ឃាតាយ សព្វសង្ខារសមថាយ សព្វូបធិប្បដិនិស្សគ្គាយ តណ្ហាក្ខយាយ វិរាគាយ និរោធាយ និព្វានាយ ធម្មំ ទេសេន្តស្ស ។ តស្ស(១) ហោតិ ឧច្ឆិជ្ជិស្សាមិ នាមស្សុ វិនស្សិស្សាមិ នាមស្សុ នស្សុ នាម ភវិស្សាមីតិ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ

១ ឱ. តស្ស ឯវំ ។



ហើយខ្ញុំនឹងជាលោកនោះ លោកនោះជាអាត្មាអញ លោកនោះជាខ្ញុំ អាត្មាអញនោះ ទៅកើតក្នុងបរលោក គឺជាបុគ្គលទៀងទាត់ថិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតវត្ថុយ៉ាងនោះឯង បុគ្គលនោះបានស្តាប់ពាក្យរបស់តថាគតក្តី របស់សាវ័កនៃតថាគតក្តី ដែលសម្តែងធម៌ដើម្បីគាស់រំលើងនូវទិដ្ឋិនិងហេតុនៃទិដ្ឋិ(១) និងទីតាំងកន្សោមនៃទិដ្ឋិ និងសេចក្តីគ្របសង្កត់នៃទិដ្ឋិនិងអនុស័យដែលតាំងនៅក្នុងសន្តាន ដើម្បីរម្ងាប់នូវសង្ខារទាំងពួង ដើម្បីលះបង់នូវឧបធិ(២) ទាំងពួង ដើម្បីអស់ទៅនៃតណ្ហា ដើម្បីប្រាសចាករាគៈ ដើម្បីរលត់នៃកងទុក្ខ ដើម្បីព្រះនិព្វាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងសូន្យទៅ មិនកើតទៀតឡើយ អាត្មាអញនឹងវិនាសទៅ មិនកើតទៀតឡើយ អាត្មាអញមុខជានឹងមិនកើតទៀតឡើយ បុគ្គលនោះក៏សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ

១ ហេតុនៃទិដ្ឋិមាន ៨ គឺ ខន្ធ ១ អវិជ្ជា ១ ផស្សៈ ១ សញ្ញា ១ វិតក្កៈ (សេចក្តីត្រិះរិះ) ១ អយោនិសោមនសិការៈ(ការធ្វើទុកក្នុងចិត្តដោយខុសទំនង) ១ បាបមិត្ត(មិត្រអាក្រក់) ១ បរតោឃោសៈ សំឡេងគឺពាក្យអំពីសម្នាក់ជនដទៃ ១ ។ ២ ឧបធិមាន ៤ គឺ ខន្ធូបធិ ១ កិលេសូបធិ ១ អភិសង្ខារូបធិ ១ បញ្ចកាមគុណូបធិ ១ ។ អដ្ឋកថា ។

សម្មោហំ អាបជ្ជតិ ឯវំ ខោ ភិក្ខុ អជ្ឈត្តំ អសតិ បរិតស្សនា ហោតីតិ ។ សិយា បន ភន្តេ អជ្ឈត្តំ អសតិ អបរិតស្សនាតិ ។ សិយា ភិក្ខូតិ ភគវា អវោច ។ ឥធ ភិក្ខុ ឯកច្ចស្ស ន ឯវំ ទិដ្ឋិ ហោតិ សោ លោកោ សោ អត្តា សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សាមីតិ សោ សុណាតិ តថាគតស្ស វា តថាគតសាវកស្ស វា សព្វេសំ ទិដ្ឋិដ្ឋានាធិដ្ឋានបរិយុដ្ឋានាភិនិវេសានុសយានំ សមុគ្ឃាតាយ សព្វសង្ខារសមថាយ សព្វូបធិបដិនិស្សគ្គាយ តណ្ហាក្ខយាយ វិរាគាយ និរោធាយ និព្វានាយ ធម្មំ ទេសេន្តស្ស ។ តស្ស ន ឯវំ ហោតិ ឧច្ឆិជ្ជិស្សាមិ



ដល់នូវសេចក្ដីវង្វេងវង្វាន់ ម្នាលភិក្ខុ កាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្ដីតក់ស្លុត រមែងមានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះកាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្ដីមិនតក់ស្លុត គប្បីមានដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់តបថា ម្នាលភិក្ខុ មាន ។ ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយ ក្នុងលោកនេះ មិនមានសេចក្ដីយល់ឃើញយ៉ាងនេះថា នោះជាសត្វលោក នោះជាខ្លួន អាត្មាអញនោះទៅក្នុងបរលោក នឹងជាបុគ្គលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅបីដូចជាសស្សតវត្ថុដូច្នោះឯង បុគ្គលនោះ រមែងស្ដាប់ពាក្យនៃតថាគតក្ដី សាវ័កនៃតថាគតក្ដី ដែលសំដែងធម៌ ដើម្បីគាស់រំលើងនូវទិដ្ឋិ និងហេតុនៃទិដ្ឋិ និងទីតាំងអាស្រ័យនៃទិដ្ឋិ និងសេចក្ដីគ្របសង្កត់នៃទិដ្ឋិ និងអនុស័យដែលតាំងនៅមាំក្នុងសន្ដាន ដើម្បីរម្ងាប់នូវសង្ខារទាំងពួង ដើម្បីលះបង់នូវឧបធិទាំងពួង ដើម្បីអស់ទៅនៃតណ្ហា ដើម្បីប្រាសចាករាគៈ ដើម្បីរលត់នៃកងទុក្ខ ដើម្បីព្រះនិព្វាន ។ បុគ្គលនោះមិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងសូន្យទៅ មិនកើតទៀតឡើយ អាត្មា

នាមសុ វិនស្សិស្សាមិ នាមសុ ន សុ នាម ភវិស្សាមីតិ សោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តា-ឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ឯវំ ខោ ភិក្ខុ អជ្ឈត្តំ អសតិ អបរិតស្សនា ហោតីតិ ។

(៤១) តំ(១) ភិក្ខវេ បរិគ្គហំ បរិគ្គណ្ហេយ្យាថ យ្វាស្ស បរិគ្គហោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ តិដ្ឋេយ្យ បស្សថ នោ តុម្ហេ ភិក្ខវេ តំ បរិគ្គហំ យ្វាស្ស បរិគ្គហោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ តិដ្ឋេយ្យាតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ អហម្បិ ខោ តំ ភិក្ខវេ បរិគ្គហំ ន សមនុបស្សាមិ យ្វាស្ស បរិគ្គហោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ តិដ្ឋេយ្យ ។ តំ(២) ភិក្ខវេ អត្តវាទុបាទានំ ឧបាទិ-យេថ យំស(៣) អត្តវាទុបាទានំ ឧបាទិយតោ ន ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសា

១ ម. តញ្ច ។ ២ ម. តំ ហិ ។ ៣ ម. យំ អស្ស ។



អញនឹងវិនាសទៅ ពិតណាស់ហើយអញ អាត្មាអញប្រាកដជានឹងមិនកើតទៀតឡើយ បុគ្គលនោះមិនសោកសៅ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង គគ្រក់គគ្រេញ មិនដល់នូវសេចក្តីវង្វេងវង្វាន់ ម្នាលភិក្ខុ កាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្តីមិនតក់ស្លុត រមែងមានយ៉ាងនេះ ។

(៤១) ម្នាលភិក្ខុទាំងឡាយ ទ្រព្យរបស់ណា ដែលទៀងទាត់ ឋិត-ថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតវត្ថុដូច្នោះឯង អ្នកទាំងឡាយគប្បីកាន់យកនូវទ្រព្យរបស់នោះចុះ ម្នាលភិក្ខុទាំងឡាយ ទ្រព្យរបស់ណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សត-វត្ថុដូច្នោះឯង តើអ្នកទាំងឡាយឃើញនូវទ្រព្យរបស់នោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទ្រព្យរបស់ណាដែលទៀងទាត់ ឋិត-ថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតវត្ថុដូច្នោះឯង សូម្បីតថាគតក៏មិនឃើញនូវទ្រព្យរបស់នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតដល់បុគ្គលអ្នកប្រកាន់ នូវអត្តវាទុបាទានណា(១) អ្នកទាំងឡាយប្រកាន់ នូវអត្តវាទុបាទាននោះ ម្នាលភិក្ខុទាំងឡាយ សេចក្តី

១ ភាវៈនិងសេចក្តីប្រកាន់ថាខ្លួនដូច្នេះ ។ អដ្ឋកថា ។

បស្សថ នោ តុម្ហេ ភិក្ខវេ តំ អត្តវាទុបាទានំ យស្ស អត្តវាទុបាទានំ ឧបាទិយតោ ន ឧប្បជ្ជេយ្យុំ សោក-បរិទេវទុក្ខទោមនស្សុបាយាសាតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ អហម្បិ ខោ តំ ភិក្ខវេ អត្តវាទុបាទានំ ន សមនុបស្សាមិ យស្ស អត្តវាទុបាទានំ ឧបាទិយតោ ន ឧប្បជ្ជេយ្យុំ សោក-បរិទេវទុក្ខទោមនស្សុបាយាសា ។ តំ ភិក្ខវេ ទិដ្ឋិ-និស្សយំ និស្សយេថ យស្ស ទិដ្ឋិនិស្សយំ និស្សយតោ ន ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោ-មនស្សុបាយាសា បស្សថ នោ តុម្ហេ ភិក្ខវេ តំ ទិដ្ឋិនិស្សយំ យស្ស ទិដ្ឋិនិស្សយំ និស្សយតោ ន ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយា-សាតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ



សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើង ដល់បុគ្គលអ្នកប្រកាន់នូវអត្តវាទុបាទានណា អ្នកទាំងឡាយបានឃើញនូវអត្តវាទុបាទាននោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនឃើញនូវអត្តវាទុបាទាននុ៎ះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់បុគ្គលអ្នកប្រកាន់នូវអត្តវាទុបា-ទានណា សូម្បីតថាគត ក៏មិនឃើញ នូវអត្តវាទុបាទាននោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់បុគ្គលអាស្រ័យនូវទិដ្ឋិនិស្ស័យណា អ្នកទាំងឡាយអាស្រ័យ នូវទិដ្ឋិនិស្ស័យនោះ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់បុគ្គលអាស្រ័យនូវទិដ្ឋិនិស្ស័យណា អ្នកទាំង-ឡាយឃើញនូវទិដ្ឋិនិស្ស័យនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនឃើញ នូវទិដ្ឋិនិស្ស័យនោះទេ ។ ម្នាលភិក្ខុទាំងឡាយ

អហម្បិ ខោ តំ ភិក្ខវេ ទិដ្ឋិនិស្សយំ ន សមនុបស្សាមិ យស្ស ទិដ្ឋិនិស្សយំ និស្សយតោ ន ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។

(២២) អត្តនិ វា ភិក្ខវេ សតិ អត្តនិយំ មេតិ អស្សាតិ ។ ឯវំ ភន្តេ ។ អត្តនិយេ វា ភិក្ខវេ សតិ អត្តា មេតិ អស្សាតិ ។ ឯវំ ភន្តេ ។ អត្តនិ ច ភិក្ខវេ អត្តនិយេ ច សច្ចតោ ថេតតោ អនុបលព្ភមានេ(1) យម្បិទំ ទិដ្ឋិដ្ឋានំ សោ លោកោ សោ អត្តា សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សាមីតិ ននាយំ ភិក្ខវេ កេវលោ បរិបូរោ ពាលធម្មោតិ ។ កិញ្ហិ នោ សិយា ភន្តេ កេវលោ ហិ(2) ភន្តេ(3) បរិបូរោ ពាលធម្មោតិ ។

១ ឱ. ម. អនុបលព្ភមានេ ។ ២-៣ ឱ. អយំ ពាលោ ធត្តិ ។



ក្រៃហើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់បុគ្គល ការស្រ័យនូវទិដ្ឋិនិស្ស័យណា សូម្បីតថាគតក៏មិនឃើញនូវទិដ្ឋិនិស្ស័យនោះដែរ ។

(២២) ម្នាលភិក្ខុទាំងឡាយ កាលបើខ្លួនមានហើយ សេចក្តីត្រិះរិះថា នេះជាបរិក្ខាររបស់ខ្លួនអញដូច្នេះ មានឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបរិក្ខាររបស់ខ្លួនមានហើយ សេចក្តីត្រិះរិះថា នេះជាខ្លួនរបស់អញដូច្នេះ មានដែរឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបើខ្លួនក្តី បរិក្ខាររបស់ខ្លួនក្តី ដែលបុគ្គលមិនបាន ដោយពិត ដោយឋិតថេរ ហេតុជាទីតាំងនៃទិដ្ឋិណាថា នោះជាសត្វលោក នោះជាខ្លួន អាត្មាអញនោះទៅកាន់បរលោក នឹងជាបុគ្គលទៀងទាត់ ឋិតថេរ មិនប្រែប្រួល នឹងឋិតនៅដូចជាសស្សតវត្ថុដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ នេះ ជាពាលធម៌បរិបូណ៌ទាំងអស់ មានពិត ឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ពាលធម៌មានបរិបូណ៌ទាំងអស់ ពិតមែន ។

តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភិក្ខវេ វេទនា ។ បេ ។ សញ្ញា ... សង្ខារា ... វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហ ភិក្ខវេ យង្កិញ្ចិ រូបំ



ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះជាដូចម្តេច រូបជាធម្មជាតទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចំរើន មិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចំរើន ជាទុក្ខ ។ របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសភាពប្រែប្រួលជាធម្មតា គួរនឹងពិចារណាឃើញនូវរបស់នោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះឬ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនោះមិនគួរនឹងយល់ឃើញដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះជាដូចម្តេច វេទនា ។ បេ ។ សញ្ញា... សង្ខារទាំងឡាយ... វិញ្ញាណជារបស់ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចំរើន មិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចំរើន ជាទុក្ខ ។ របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសភាពប្រែប្រួលជាធម្មតា គួរនឹងពិចារណាឃើញនូវរបស់នុ៎ះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះឬ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះមិនគួរនឹងយល់ឃើញដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបណានីមួយ

អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា ។ បេ ។ យា កាចិ សញ្ញា ... យេ កេចិ សង្ខារា ... យំ កិញ្ចិ វិញ្ញាណំ អតីតា-នាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោ-ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។

(២៣) ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្ពិន្ទតិ វេទនាយបិ និព្ពិន្ទតិ សញ្ញាយបិ និព្ពិន្ទតិ សង្ខារេសុបិ និព្ពិន្ទតិ វិញ្ញាណស្មឹបិ[១] និព្ពិន្ទតិ និព្ពិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមុត្តស្មឹ

១ ម. បញ្ចសុ ឋានេសុ បិសទ្ទោ ន ទិស្សតិ ។



ជាអតីត ជាអនាគត ជាបច្ចុប្បន្ន ខាងក្នុងឬខាងក្រៅ គ្រោតគ្រាតឬល្អិត ថោកទាបឬឧត្តម រូបណាដែលមានក្នុងទីឆ្ងាយឬក្នុងទីជិត អ្នកទាំងឡាយ គប្បីឃើញរូបទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ វេទនាណាមួយ ។ បេ ។ សញ្ញាណាមួយ ... សង្ខារទាំងឡាយណាមួយ ... វិញ្ញាណណាមួយ ជាអតីត ជាអនាគត ជាបច្ចុប្បន្ន ខាងក្នុងឬខាងក្រៅ គ្រោតគ្រាតឬល្អិត ថោកទាបឬឧត្តម វិញ្ញាណណា ដែលមានក្នុងទីឆ្ងាយឬក្នុងទីជិត អ្នកទាំង-ឡាយ គប្បីឃើញនូវវិញ្ញាណទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។

(២៣) ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើបានឃើញយ៉ាងនេះហើយ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយហើយ ក៏លែងត្រេកអរ កាលបើលែងត្រេកអរហើយ ចិត្តក៏ផុតស្រឡះ កាលបើចិត្តផុត

វិមុត្តមិតិ(១) ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្ម-
ចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។
អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ឥតិបិ
សង្កិណ្ណបរិក្ខោ(២) ឥតិបិ អព្ពូឡ្ហេសិកោ ឥតិបិ
និរគ្គឡោ ឥតិបិ អរិយោ បន្នទ្ធជោ បន្នភារោ វិសំ-
យុត្តោ ឥតិបិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឧក្ខិត្តប-
លិឃោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អវិជ្ជា
បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភា-
វង្កតា អាយតិំ អនុប្បាទធម្មា ។ ឯវំ ខោ ភិក្ខវេ
ភិក្ខុ ឧក្ខិត្តបលិឃោ ហោតិ ។ កថញ្ច ភិក្ខវេ
ភិក្ខុ សង្កិណ្ណបរិក្ខោ ហោតិ ។ ឥធ ភិក្ខវេ

១ ម. វិមុត្តម្ហីតិ ។ ២ សង្កិណ្ណបរិខោតិប្បត្តិ ។



ស្រឡះហើយ ញាណដឹងថា ចិត្តរួចផុតស្រឡះហើយដូច្នេះ ក៏កើត
មានឡើង ហើយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អញ
បាននៅរួចហើយ កិច្ចដែលគួរធ្វើ អញបានធ្វើហើយ កិច្ចដទៃ
ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុ
ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា អ្នកមានសន្ទះទ្វារកន្លាស់(១) លើក
ឡើងហើយផង មានគូរំលុបរំលាយហើយផង មានសសរគោលដក
ឡើងហើយផង មិនមានសន្ទះទ្វារផង ជាអរិយៈមានទង់ជ័យ ដាក់ចុះ
ហើយ មានភារៈដាក់ចុះហើយ ប្រាសចាកយោគៈផង ។ ម្នាលភិក្ខុ
ទាំងឡាយ ភិក្ខុជាអ្នកមានសន្ទះទ្វារកន្លាស់លើកឡើង តើដោយប្រការ
ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ បាន
លះបង់នូវអវិជ្ជា តាំងពីមានគល់ផ្តាច់ផ្តិលចោល ធ្វើឲ្យដូចជាដើមត្នោតកំបុត
ក ធ្វើឲ្យលែងមានប្រភព ឲ្យលែងកើតទៅខាងមុខទៀត ជាធម្មតា
ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសន្ទះទ្វារកន្លាស់ លើកឡើងហើយ
ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានគូ
រំលុបរំលាយនោះ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ

១ សន្ទះទ្វារកន្លាស់ឬសន្ទះទ្វាររនឹងគុលដែលធ្វើសម្រាប់ទូលបេញចូលបិទបើកទ្វារស្រុក ទ្វារនគរជាដើម ។

ភិក្ខុនោ ពោនោព្ភវិកោ ជាតិសង្សារោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯវំ ខោ ភិក្ខវេ ភិក្ខុ សង្កិណ្ណបរិក្ខោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អព្ពូឡ្ហេសិកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ តណ្ហា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ឯវំ ខោ ភិក្ខវេ ភិក្ខុ អព្ពូឡ្ហេសិកោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ និរគ្គឡោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ



ភិក្ខុក្នុងសាសនានេះ បានលះបង់នូវជាតិសង្សារ(១) ជាសភាវៈឲ្យនូវភពថ្មី ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព ឲ្យលែងកើតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានគូលុបលាយហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ជាអ្នកមានសសរគោលដកឡើងហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវតណ្ហា ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព ឲ្យលែងកើតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសសរគោលដកឡើងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានសន្ទះទ្វារ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវសញ្ញោជនៈជាចំណែកខាង

១ បានដល់អភិសង្ខារ គឺកម្មជាបច្ច័យក្នុងភពថ្មី តាមទំនងដែលញុំាងសត្វឲ្យកើតឲ្យព្រាត់ រង្គាត់ទៅក្នុងជាតិទាំងឡាយ ។

ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវង្កតានិ អាយតឹ អនុប្បាទធម្មានិ ឯវំ ខោ ភិក្ខវេ ភិក្ខុ និរគ្គឡោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុ-កតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ហោតិ ។

(៤៤) ឯវំ វិមុត្តចិត្តំ ខោ ភិក្ខវេ ភិក្ខុំ សឥន្ទា ទេវា សព្រហ្មា សបជាបតិកា អន្វេសន្តា(១) នាធិ-គច្ឆន្តិ ឥទំ និស្សិតំ តថាគតស្ស វិញ្ញាណន្តិ តំ កិស្ស ហេតុ ទិដ្ឋេវាហំ ភិក្ខវេ ធម្មេ តថាគតំ អននុវេជ្ជោតិ(២) វទាមិ ។ ឯវំវាទឹ ខោ មំ ភិក្ខវេ

---

១ ម. ឆ. អន្វេសំ ។ ២ ម. អននុវេជ្ជោតិ ។ អននុវិជ្ជោតិ ។



ក្រោម ៥ ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុត-ក លែងមានបែបភាព ឲ្យលែងកើតតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ជាអ្នកមិនមានសន្ទះទ្វារ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ជាអរិយៈមានទង់ជ័យដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកមានះ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ បានលះ-បង់ នូវអស្មិមានះ ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុត-ក ឲ្យលែងមានបែបភាព ឲ្យលែងកើតតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអរិយៈ មានទង់ជ័យដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកមានះ ដោយប្រការដូច្នេះឯង ។

(៤៤) ម្នាលភិក្ខុទាំងឡាយ ពួកទេវតា ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម និងបជាបតិទេវបុត្រ នាំគ្នាតាមស្វែងរកភិក្ខុ ដែលមានចិត្តរួចស្រឡះយ៉ាងនេះ ក៏មិនបានប្រទះថា វិញ្ញាណរបស់សត្វអាស្រ័យហើយនូវអារម្មណ៍នេះ សេចក្តីនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសត្វថាមិនមានក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ តែមាន

ឯវមក្ខាយឹ ឯកេ សមណព្រាហ្មណា អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខន្តិ វេនយិកោ សមណោ គោតមោ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេតីតិ ។ យថា ចាហំ ភិក្ខវេ ន យថា ចាហំ ន វទាមិ តថា មំ តេ ភោន្តោ សមណព្រាហ្មណា អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខន្តិ វេនយិកោ សមណោ គោតមោ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេតីតិ ។ បុព្វេ ចាហំ ភិក្ខវេ ឯតរហិ ច ទុក្ខញ្ចេវ បញ្ញាបេមិ ទុក្ខស្ស ច និរោធំ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ ឃដ្ដេន្តិ[១] តត្រ ភិក្ខវេ

១ ម. វិហេសេន្តិ ឃដ្ដេន្តីតិ បទទ្វយំ ន ទិស្សតិ ។



សមណព្រាហ្មណ៍មួយពួក បានពោលបង្កាច់តថាគតដែលមានវាទៈយ៉ាងនេះ ដែលបានពោលយ៉ាងនេះ ដោយពាក្យមិនទៀង ដោយពាក្យទទេ ដោយពាក្យកុហក ដោយពាក្យមិនពិត ដូច្នេះថា ព្រះសមណគោតម ជាអ្នកបំផ្លាញសត្វ តែងបញ្ញត្តនូវសេចក្តីដាច់សូន្យ សេចក្តីវិនាស សេចក្តីមិនកើតទៀត របស់សត្វដែលមាននៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោល ដោយប្រការណាផង ដោយប្រការណាផង សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះពោលបង្កាច់តថាគតដោយប្រការដូច្នោះៗ ដោយពាក្យមិនទៀង ដោយពាក្យទទេ ដោយពាក្យកុហក ដោយពាក្យមិនពិត ដូច្នេះថា ព្រះសមណគោតម ជាអ្នកបំផ្លាញសត្វ តែងបញ្ញត្តនូវសេចក្តីដាច់សូន្យ សេចក្តីវិនាស សេចក្តីមិនកើតទៀត របស់សត្វដែលមាននៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវក្តី តថាគត តែងបញ្ញត្តនូវទុក្ខ[១] ផង នូវសេចក្តីរលត់នៃទុក្ខ[២] ផង ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃ ជេរ តម្រាម ប្រទូស្ត បៀតបៀន ធ្វើបាបតថាគតក្នុងការប្រកាសសច្ចៈទាំង ៤ នោះ ម្នាលភិក្ខុ

១ ពាក្យថា ទុក្ខ នេះ សង្គ្រោះយកសមុទ័យចូលផង ។ ២ ពាក្យថា រលត់នៃទុក្ខ នេះ សង្គ្រោះយកមគ្គចូលផង ។

តថាគតស្ស ន ហោតិ អាឃាតោ ន អប្បច្ចយោ ន ចេតសោ អនភិរទ្ធិ(១) ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ តត្រ ភិក្ខវេ តថាគតស្ស ន ហោតិ អានន្ទោ ន សោមនស្សំ ន ចេតសោ ឧព្ពិលាវិតត្តំ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ តត្រ ភិក្ខវេ តថាគតស្ស ឯវំ ហោតិ យំ ខោ ឥទំ បុព្វេ បរិញ្ញាតំ តត្ថ មេ ឯវរូបា ការា ករីយន្តីតិ ។

(៤៥) តស្មាតិហ ភិក្ខវេ តុម្ហេ ចេបិ បរេ អក្កោសេយ្យុំ បរិភាសេយ្យុំ រោសេយ្យុំ វិហេសេយ្យុំ ឃដ្ដេយ្យុំ(២) តត្រ តុម្ហេហិ ន អាឃាតោ ន អប្បច្ចយោ ន ចេតសោ អនភិរទ្ធិ ករណីយា ។

១ ម. ឱ. អនភិរទ្ធិ ។ ២ ម. ឱ. ឃដ្ដេយ្យុន្តិ បាឋោ ន ទិស្សតិ ។



ទាំងឡាយ តថាគតមិនមានសេចក្ដីក្រោធ មិនមានសេចក្ដីមិនត្រេកអរ គឺទោមនស្ស មិនមានសេចក្ដីមិនរីករាយនៃចិត្ត ក្នុងហេតុមានជេរ ជាដើមនោះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតក្នុងការប្រកាសសច្ចៈនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនមានសេចក្ដីត្រេកអរ មិនមានសេចក្ដីសោមនស្ស មិនមានសេចក្ដីប៉ោងចិត្ត ក្នុងសក្ការៈជាដើមនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃ ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតក្នុងការប្រកាសសច្ចៈនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្ដីត្រិះរិះក្នុងសក្ការៈជាដើមនោះយ៉ាងនេះថា ខន្ធបញ្ចកៈណា ដែលតថាគតបានកំណត់ដឹងក្នុងកាលមុនរួចហើយ សក្ការៈមានសភាពយ៉ាងនេះ គឺពួកជនដទៃធ្វើដល់តថាគត គឺចំពោះខន្ធបញ្ចកៈនោះ ។

(៤៥) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បើពួកជនដទៃជេរ តិកម ប្រទូស្ត បៀតបៀន ធ្វើដល់អ្នកទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើសេចក្ដីក្រោធ មិនត្រូវធ្វើសេចក្ដីមិនត្រេកអរ គឺទោមនស្ស មិនត្រូវធ្វើសេចក្ដីមិនរីករាយនៃចិត្ត ក្នុងពាក្យជេរជាដើមនោះឡើយ ។

តស្មាតិហ ភិក្ខវេ តុម្ហេ ចេបិ បរេ សក្ការេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ តត្រ តុម្ហេហិ ន អានន្ទោ ន សោមនស្សំ ន ចេតសោ ឧព្ពិលាវិតត្តំ ករណីយំ ។ តស្មាតិហ ភិក្ខវេ តុម្ហេ ចេបិ បរេ សក្ការេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ តត្រ តុម្ហាកំ ឯវមស្ស យំ ខោ ឥទំ បុព្វេ បរិញ្ញាតំ តត្ថ មេ ឯវរូបា ការា ករីយន្តីតិ ។ តស្មាតិហ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ



ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បើពួកជនដទៃធ្វើសក្ការៈ គោរព រាប់អាន បូជាអ្នកទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើសេចក្ដីត្រេកអរ មិនត្រូវធ្វើសេចក្ដីសោមនស្ស មិនត្រូវធ្វើសេចក្ដីប៉ោងចិត្ត ក្នុងសក្ការៈជាដើមនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បើពួកជនដទៃធ្វើសក្ការៈ គោរព រាប់អាន បូជាអ្នកទាំងឡាយ អ្នកទាំងឡាយត្រូវត្រិះរិះ ក្នុងសក្ការៈជាដើមនោះយ៉ាងនេះថា ខន្ធបញ្ចកៈណា ដែលអាត្មាអញបានកំណត់ដឹងរួចហើយ ក្នុងកាលមុន សក្ការៈមានសភាពបែបនេះ គឺពួកជនដទៃធ្វើដល់យើងទាំងឡាយ ក៏ចំពោះខន្ធបញ្ចកៈនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ វត្ថុណា ដែលមិនមែនរបស់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយលះបង់វត្ថុនោះចេញ វត្ថុដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្ដីសុខអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ តើអ្វីៗ មិនមែនរបស់អ្នកទាំងឡាយដែរ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់រូបនោះចេញ រូបដែលអ្នកទាំងឡាយលះបង់ហើយនោះ

ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។ វេទនា ភិក្ខវេ ន តុម្ហាកំ តំ បជហថ សា វោ បហីនា ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។ សញ្ញា ភិក្ខវេ ន តុម្ហាកំ តំ បជហថ សា វោ បហីនា ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។ សង្ខារា ភិក្ខវេ ន តុម្ហាកំ តេ បជហថ តេ វោ បហីនា ទីឃរត្តំ ហិតាយ សុខាយ ភវិស្សន្តិ ។ វិញ្ញាណំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ



នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្ដីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ វេទនាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់ នូវវេទនានោះចេញ វេទនាដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នូវសញ្ញានោះចេញ សញ្ញាដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់ នូវសង្ខារទាំងឡាយនោះចេញ សង្ខារទាំងឡាយដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវវិញ្ញាណនោះចេញ វិញ្ញាណដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍

សុខាយ ភវិស្សតិ ។ តំ កឹ មញ្ញថ ភិក្ខវេ យំ ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ តំ ជនោ ហរេយ្យ វា ឌហេយ្យ វា យថាបច្ចយំ វា ករេយ្យ អបិ នុ តុម្ហាកំ ឯវមស្ស អម្ហេ ជនោ ហរតិ វា ឌហតិ វា យថាបច្ចយំ វា ករោតីតិ ។ នោ ហេតំ ភន្តេ តំ កិស្ស ហេតុ ន ហិ នោ ឯតំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ



និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះដូចម្តេច ស្មៅ កំណាត់ឈើ មែកឈើ និងស្លឹកឈើណា ដែលមានក្នុងវត្តជេតពននេះ បើអ្នកផងនាំយកទៅក្តី ដុតចោលក្តី ធ្វើឲ្យសមគួរតាមបច្ច័យក្តី នូវវត្ថុមានស្មៅជាដើមនោះ តើអ្នកទាំងឡាយគួរមានសេចក្តីត្រិះរិះយ៉ាងនេះថា អ្នកផងនាំយកទៅក្តី ដុតចោលក្តី ធ្វើឲ្យសមគួរតាមបច្ច័យក្តី នូវយើងទាំងឡាយ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរគិតយ៉ាងនេះទេ ដំណើរនោះ តើព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាវត្ថុមានស្មៅជាដើមនុ៎ះ មិនមែនជាខ្លួន ឬមិនមែនជាទ្រព្យរបស់ខ្លួននៃយើងខ្ញុំទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងហើយ វត្ថុណា ដែលមិនមែនរបស់អ្នកទាំងឡាយទេ ចូរអ្នកទាំងឡាយលះបង់នូវវត្ថុនោះចេញ វត្ថុដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ តោះអ្វី ។ គឺមិនមែនរបស់អ្នកទាំងឡាយដែរ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ

តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។ វេទនា ភិក្ខវេ ។ បេ ។ សញ្ញា ភិក្ខវេ ។ បេ ។ សង្ខារា ភិក្ខវេ ។ បេ ។ វិញ្ញាណំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ ។

[២៦] ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ឯវំ ស្វាក្ខាតេ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ យេ តេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា



ចូរអ្នកទាំងឡាយលះបង់នូវរូបនោះចេញ រូបដែលអ្នកទាំងឡាយលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ វេទនា ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ សញ្ញា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ ចូរអ្នកទាំងឡាយលះបង់វិញ្ញាណនោះចេញ វិញ្ញាណដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។

[២៦] ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណាជាព្រះអរហន្តខីណា-ស្រព មានព្រហ្មចារ្យនៅចប់ហើយ មានកិច្ចៈធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ(១)បានសម្រេចប្រយោជន៍របស់ខ្លួនហើយ មានកិលេសជា

១ កិលេស ១០ យ៉ាង និងខន្ធ ៥ ជាដើម ឈ្មោះថា ភារៈគ្រឿងធ្ងន់ ដែលហៅថាភារៈដាក់ចុះហើយ គឺអស់រវល់ដោយកិលេសនិងខន្ធ ៥ ជាដើមនោះតទៅទៀតហើយ ។

សម្មទញ្ញាវិមុត្តា វដ្ដំ តេសំ នត្ថិ បញ្ញាបនាយ ។ ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ឯវំ ស្វាក្ខាតេ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ យេសំ ភិក្ខូនំ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ សព្វេ តេ ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា ។ ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ឯវំ ស្វាក្ខាតេ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ យេសំ ភិក្ខូនំ តីណិ សញ្ញោជនានិ បហីនានិ ។ រាគទោសមោហា តនុភូតា សព្វេ តេ



គ្រឿងប្រកបក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ វដ្តរបស់ភិក្ខុទាំងនោះ មិនមានតាមបញ្ញត្តិ គឺជាវិនាសសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយ យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយ យ៉ាងនេះ ភិក្ខុទាំងឡាយណា បានលះបង់នូវសំយោជនៈជាចំណែកខាងក្រោម ៥ យ៉ាង ភិក្ខុទាំងអស់នោះជាឱបបាតិកទេវតា នឹងបរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់ពីលោកនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា បានលះបង់នូវសំយោជនៈទាំង ៣ យ៉ាង ស្រឡះហើយ តែនៅមានរាគៈ ទោសៈ មោហៈ ដែលស្រាលស្តើង ភិក្ខុទាំងអស់នោះ ជាសកទាគាមិបុគ្គល

សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ ។ ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ឯវំ ស្វាក្ខាតេ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ យេសំ ភិក្ខូនំ តីណិ សញ្ញោជនានិ បហីនានិ សព្វេ តេ សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនា ។ ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ឯវំ ស្វាក្ខាតេ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ យេ តេ ភិក្ខូ ធម្មានុសារិនោ សទ្ធានុសារិនោ សព្វេ តេ



នឹងត្រឡប់មកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា បានលះបង់នូវសំយោជនៈ ៣ យ៉ាងស្រឡះហើយ ភិក្ខុទាំងអស់នោះ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ(១) ជាអ្នកទៀងនឹងបានត្រាស់ដឹងក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា ជាធម្មានុសារីបុគ្គល(២) និងជាសទ្ធានុសារីបុគ្គល(៣) ភិក្ខុទាំងអស់នោះ

---

១ អភិ. មិនកើតជាអសុរកាយ ។ ២ បុគ្គលរលឹកតាមធម៌គឺបញ្ញា បានដល់បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានបញ្ញិន្ទ្រិយដ៏ក្លៀវក្លា ចម្រើននូវអរិយមគ្គមានបញ្ញាជាប្រធាន ។ ៣ បុគ្គលរលឹកតាមសទ្ធា បានដល់បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល តែមានសទ្ធិន្ទ្រិយដ៏ក្លៀវក្លា... ។

សម្ពោធិបរាយណា ។ ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ឯវំ ស្វាក្ខាតេ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ យេសំ មយិ សទ្ធាមត្តំ បេមមត្តំ សព្វេ តេ សគ្គបរាយណាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

អលគទ្ទូបមសុត្តំ ទុតិយំ និដ្ឋិតំ ។

---



នឹងបានត្រាស់ដឹងក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្ងារហើយ បើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសំដែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា គ្រាន់តែមានសទ្ធា គ្រាន់តែមានសេចក្ដីស្រឡាញ់ចំពោះតថាគត ភិក្ខុទាំងពួងនោះ ទៅខាងមុខ នឹងបានឋានសួគ៌ ។ ព្រះមានព្រះភាគ ទ្រង់បានសំដែងនូវសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយហើយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចប់ អលគទ្ទូបមសូត្រ ទី ២ ។

---

## តតិយំ វម្មិកសុត្តំ

(៤៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា កុមារកស្សបោ អន្ធវនេ វិហរតិ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ អន្ធវនំ ឱភាសេត្វា យេនាយស្មា កុមារកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា អាយស្មន្តំ កុមារកស្សបំ ឯតទវោច ភិក្ខុ ភិក្ខុ អយំ វម្មិកោ រត្តិំ ធូមាយតិ ទិវា បជ្ជលតិ ព្រាហ្មណោ ឯវមាហ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស បលិង្គិំ បលិង្គី ភទន្តេតិ(១) ។ ព្រាហ្មណោ ឯវមាហ ឧក្ខិប បលិង្គិំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស ឧទ្ធុមាយិកំ ឧទ្ធុមាយិកា ភទន្តេតិ ។

១ ម. លង្គិំ លង្គី ភទ្ទន្តេតិ ។

## វម្មិកសូត្រ ទី ៣

(៤៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះកុមារកស្សបមានអាយុ នៅក្នុងអន្ធវ័ន (ព្រៃជាទីនៅនៃពួកចោរខ្វាក់ភ្នែក) ។ គ្រានោះឯង ទេវតាមួយអង្គ មានសម្បុរល្អ (មក) ក្នុងវេលារាត្រីនឹងបឋមយាមកន្លងទៅហើយ បញ្ចេញរស្មីឲ្យភ្លឺក្នុងអន្ធវ័នទាំងអស់ ក៏ចូលទៅរកព្រះកុមារកស្សបមានអាយុ លុះចូលទៅដល់ហើយ ទើបឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះកុមារកស្សបមានអាយុថា ភិក្ខុ ភិក្ខុ ដំបូកនេះហុយផ្សែងក្នុងវេលាយប់ ឆេះក្នុងវេលាថ្ងៃ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ ចូរអ្នកយកសស្ត្រាមកជីកដំបូកនេះមើល ។ សុមេធ យកសស្ត្រាមកជីក ជីកទៅក៏បានឃើញសន្ទះទ្វារគន់ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សន្ទះទ្វារគន់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ ចូរអ្នកលើកសន្ទះទ្វារគន់ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធ យកសស្ត្រាជីកទៅ ក៏បានឃើញសត្វអ៊ឹង ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សត្វអ៊ឹង ។

ព្រាហ្មណោ ឯវមាហ ឧក្ខិប ឧទ្ធុមាយិកំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស ទ្វិធាបថំ ទ្វិធាបថោ ភន្តេតិ ។ ព្រាហ្មណោ ឯវមាហ ឧក្ខិប ទ្វិធាបថំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស ចង្គវារំ(១) ចង្គវារោ ភន្តេតិ ។ ព្រាហ្មណោ ឯវមាហ ឧក្ខិប ចង្គវារំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស កុម្មំ កុម្មោ ភន្តេតិ ។ ព្រាហ្មណោ ឯវមាហ ឧក្ខិប កុម្មំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស អសិសូនំ អសិសូនា ភន្តេតិ ។ ព្រាហ្មណោ ឯវមាហ ឧក្ខិប អសិសូនំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុ-មេធោ សត្ថំ អាទាយ អទ្ទស មំសបេសឹ

---

១ ម. ចង្កវារំ ។



ព្រាហ្មណ៍ បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកសត្វប៉ុងចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញផ្លូវបែកជា ២ ហើយក្រាបថា បពិត្រអ្នកដ៏ចម្រើន ផ្លូវបែកជា ២ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ ចូរអ្នកលើកផ្លូវបែកជា ២ ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញសំពត់តម្រងក្បួន ហើយក្រាបថា បពិត្រអ្នកដ៏ចម្រើន សំពត់តម្រងក្បួន ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកសំពត់តម្រងក្បួនចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញអណ្តើក ហើយក្រាបថា បពិត្រអ្នកដ៏ចម្រើន អណ្តើក ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកអណ្តើកចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញកាំបិតនិងជ្រញ់ ហើយក្រាបថា បពិត្រអ្នកដ៏ចម្រើន កាំបិតនិងជ្រញ់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកកាំបិតនិងជ្រញ់ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញដុំសាច់

មំសបេសិំ គណ្ហតិ ។ ព្រាហ្មណោ ឯវមាហ ឧក្ខិប មំសបេសិំ អតិក្ខិប សុមេធ សត្ថំ អាណាយាតិ ។ អតិក្ខិ-ធន្តោ សុមេធោ សត្ថំ អាណាយ អទ្ទស ជាតំ នាគោ កណ្ហតិ ។ ព្រាហ្មណោ ឯវមាហ តិដ្ឋតុ នាគោ មា ជាតំ យន្តេសិ នមោ គោភោហិ នាគស្សាតិ ។ អថ ខោ តំ ភិក្ខុ បណ្ណរស បញ្ហា គតវន្តំ ឧបសង្កមិត្វា បុច្ឆេយ្យាសិ យថា តេ គតវា ព្យាករោតិ តថា នំ ធារេយ្យាសិ ។ នាហន្តំ ភិក្ខុ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្ម-ណិយា បជាយ សទេវមនុស្សាយ យោ ឥមេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វាតិ ។ ឥទមវោច សា ទេវតា ឥទំ វត្វា តត្ថេវ អន្តរធាយិ ។





ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន ដុំសាច់ ។ ព្រាហ្មណ៍បានពោល យ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកដុំសាច់ចេញ ហើយយកសស្ត្រា ជីកទៀត ។ សុមេធ យកសស្ត្រាជីកទៅ ក៏បានឃើញនាគ ហើយ ប្រាប់ថា បពិត្រអ្នកដ៏ចម្រើន នាគ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា នាគនុកឲ្យនៅចុះ អ្នកកុំបៀតបៀននាគឡើយ អ្នកចូរថ្វាយបង្គំនាគចុះ ។ នែភិក្ខុ លោកចូរនាំយកប្រស្នាទាំង ១៥ នេះ ទៅក្រាបទូលសួរព្រះមាន ព្រះភាគ ព្រះមានព្រះភាគទ្រង់ព្យាករប្រាប់លោក យ៉ាងណា លោកត្រូវ កំណត់ចាំទុកនូវសេចក្ដីនោះ យ៉ាងនោះ ។ នែភិក្ខុ ក្នុងលោក ព្រមទាំង ទេវតា ព្រមទាំងមារ ព្រមទាំងព្រហ្ម ក្នុងពួកសត្វ ព្រមទាំងសមណ-ព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស យើងមិន ដែលឃើញអ្នកណាមួយ ឆ្លើយប្រស្នាទាំងនេះគ្រាប់ចិត្តបានឡើយ វៀរ លែងតែព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ឬក៏អ្នកដែលស្ដាប់អំពី សម្នាក់នៃព្រះតថាគតនេះ ។ ទេវតានោះបានពោល នូវពាក្យនេះ លុះពោលនូវពាក្យនេះហើយ ក៏បាត់អំពីទីនោះទៅ ។

(៤៨) អថខោ អាយស្មា កុមារកស្សបោ តស្សា រត្តិយា អច្ចយេន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា កុមារកស្សបោ ភគវន្តំ ឯតទវោច ឥមំ ភន្តេ រត្តឹ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ អន្ធវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ ភន្តេ សា ទេវតា មំ ឯតទវោច ភិក្ខុ ភិក្ខុ អយំ វម្មិកោ រត្តឹ ធូមាយតិ ទិវា បជ្ជលតិ ព្រាហ្មណោ ឯវមាហ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស បលិង្គំ បលិង្គា ភន្តេតិ ។ ព្រាហ្មណោ ឯវមាហ





(៤៨) លុះកន្លងរាត្រីនោះហើយ ព្រលះថ្ងៃ ព្រះកុមារកស្សប មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក្រាបបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះកុមារកស្សប មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យប់មិញនេះ មានទេវតាមួយអង្គ មានសម្បុរល្អ(មក)ក្នុងវេលាកន្លងបឋមយាមកន្លងទៅហើយ បញ្ចេញរស្មីឲ្យភ្លឺក្នុងអន្ធវនទាំងអស់ ចូលមកកៀកព្រះអង្គ លុះចូលមកដល់ហើយ ឋិតនៅក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះទេវតានោះឋិតនៅក្នុងទីដ៏សមគួរហើយ បាននិយាយពាក្យនេះនឹងខ្ញុំព្រះអង្គដូច្នេះថា ភិក្ខុ ភិក្ខុ ដំបូកនេះហុយផ្សែងក្នុងពេលយប់ ឆេះក្នុងពេលថ្ងៃ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរយកសស្ត្រាមកជីក ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញសន្ទះទ្វារគន់ ហើយក្រាបថា បពិត្រអ្នកដ៏ចម្រើន សន្ទះទ្វារគន់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា

ឧក្ខិប បលិឃំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ ។ អភិក្ខណន្តោ សុមេធោ សត្ថំ អាទាយ អទ្ទស ឧទ្ធុមា-យិកំ ឧទ្ធុមាយិកា កន្ទតិ ។ បេ ។ អទ្ទស នាគំ នាគោ កន្ទតិ ។ ព្រាហ្មណោ ឯវមាហ តិដ្ឋតុ នា-គោ មា នាគំ ឃដ្ដេសិ នមោ ករោហិ នាគស្សា-តិ ។ ឥមេ ខោ ត្វំ ភិក្ខុ បណ្ណរស បញ្ហេ ភគវន្តំ ឧបសង្កមិត្វា បុច្ឆេយ្យាសិ យថា តេ ភគវា ព្យាករេ-តិ តថា នំ ធារេយ្យាសិ ។ នាហន្តំ ភិក្ខុ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណ-ព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ ឥ-មេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វាតិ ។ ឥទមវោច ភន្តេ សា ទេវតា ឥទំ វត្វា





ម្នាលសុមេធ អ្នកចូរលើកសន្លុះទ្វារកេង់ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏ឃើញសត្វហ៊ឹង ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សត្វហ៊ឹង ។ បេ ។ បានឃើញនាគ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន នាគ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា នាគទុកឲ្យនៅចុះ អ្នកកុំបៀតបៀននាគឡើយ ចូរធ្វើការនមស្ការនាគចុះ ។ នែភិក្ខុ លោកគប្បីចូលទៅរកព្រះមានព្រះភាគ ហើយសួរប្រស្នាទាំង ១៥ នេះឯង ព្រះមានព្រះភាគទ្រង់ព្យាករប្រាប់លោកយ៉ាងណា លោកគប្បីចាំទុកនូវប្រស្នានោះ យ៉ាងនោះចុះ ។ នែភិក្ខុ ក្នុងលោក ព្រមទាំងទេវតា ព្រមទាំងមារ ព្រមទាំងព្រហ្ម ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស យើងមិនដែលឃើញអ្នកណាមួយ ឆ្លើយប្រស្នាទាំងនេះឲ្យត្រូវចិត្តបានឡើយ វៀរលែងតែព្រះតថាគត ឬ សាវ័កបស់ព្រះតថាគត ឬក៏អ្នកដែលបានស្តាប់អំពីសំណាក់នៃព្រះមានព្រះភាគនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ទេវតានោះបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ

តត្ថេវ អន្តរធាយិ ៗ កោ នុ ខោ ភន្តេ វម្មិកោ កា រត្តិំ ធូមាយនា កា ទិវា បជ្ជលនា កោ ព្រាហ្មណោ កោ សុមេធោ កឹ សត្ថំ កា អភិក្ខណា(១) កា បលិង្គី កា ឧទ្ធុមាយិកា កោ ទ្វិធាបថោ កឹ ចង្គវារំ កោ កុម្មោ កា អសិសូនា កា មំសបេសិ កោ នាគោតិ ៗ

(២៨) វម្មិកោតិ ខោ ភិក្ខុ ឥមស្សេតំ ចាតុម្មហា-ភូតិកស្ស កាយស្ស អធិវចនំ មាតាបេត្តិកសម្ភវស្ស ឱទនកុម្មាសូបចយស្ស អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំ-សនធម្មស្ស ៗ កា រត្តិំ ធូមាយនាតិ យំ ខោ ភិក្ខុ ទិវា កម្មន្តេ អារព្ភ រត្តិំ អនុវិតក្កេតិ អនុវិចារេតិ អយំ រត្តិំ ធូមាយនា ៗ កា ទិវា បជ្ជល-នាតិ យំ ខោ ភិក្ខុ រត្តិំ អនុវិតក្កេត្វា អនុវិចា-រេត្វា ទិវា កម្មន្តេ បយោជេតិ កាយេន វាចាយ

១ ម. ឆ. ក៏ អភិក្ខណន្តិ ទិស្សតិ ៗ



ក៏បាត់អំពីទីនោះទៅ ៗ បពិត្រព្រះអង្គដ៏ចំរើន អ្វីហ្ន៎ ហៅថាដំបូក អ្វីហុយផ្សែងក្នុងពេលយប់ អ្វីឆេះក្នុងពេលថ្ងៃ អ្នកណាជាព្រាហ្មណ៍ អ្នកណាជាសុមេធ អ្វីជាសស្ត្រា អ្វីជាការជីក អ្វីជាសន្ទះទ្វារកន់ អ្វីជាសត្វហ៊ឹង អ្វីជាផ្លូវបែកជាពីរ អ្វីជាសំពត់តម្រងក្បួន អ្វីជាអណ្ដើក អ្វីជាកាំបិតនិងជ្រញ់ អ្វីជាដុំសាច់ អ្វីជានាគ ៗ

(២៨) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា ដំបូក នេះជាឈ្មោះរបស់កាយនេះ ដែលប្រកបដោយមហាភូតរូប ៤ កើតព្រមព្រោះទឹកសុក្កៈរបស់មាតានិងបិតា ចម្រើនដោយសារបាយនិងនំ មានសភាវៈមិនទៀង មានការដុសខាត់បំបាត់ក្លិនអាក្រក់និងគក់ច្របាច់និងកិរិយាបែកធ្លាយខ្ចាត់ខ្ចាយជាធម្មតា ៗ ម្នាលភិក្ខុ ត្រង់ប្រស្នាថា អ្វីហុយផ្សែងក្នុងពេលយប់ សេចក្ដីថា បុគ្គលប្រារព្ធការងារក្នុងពេលថ្ងៃ ហើយដល់ពេលយប់ ត្រិះរិះពិចារណារឿយ ៗ ដោយហេតុណា ហេតុនេះ ហៅថា ហុយផ្សែងក្នុងពេលយប់ ៗ ម្នាលភិក្ខុ ត្រង់ប្រស្នាថា អ្វីឆេះក្នុងពេលថ្ងៃ សេចក្ដីថា បុគ្គលត្រិះរិះពិចារណារឿយ ៗ ក្នុងវេលាយប់ ហើយដល់វេលាថ្ងៃ ក៏ប្រកបការងារដោយកាយក្ដី ដោយហេតុណា

អយំ ទិវា បជ្ជលនា ។ ព្រាហ្មណោតិ ខោ ភិក្ខុ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ សុមេធោតិ ខោ ភិក្ខុ សេក្ខស្សេតំ ភិក្ខុនោ អធិវចនំ ។ សត្ថន្តិ ខោ ភិក្ខុ អរិយាយេតំ បញ្ញាយ អធិវចនំ ។ អភិក្ខណន្តិ ខោ ភិក្ខុ វីរិយារម្ភស្សេតំ អធិវចនំ ។ បលិង្គីតិ ខោ ភិក្ខុ អវិជ្ជាយេតំ អធិវចនំ ។ ឧក្ខិប បលិង្គី បជហ អវិជ្ជំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ អយមេតស្ស អត្ថោ ។ ឧទ្ធុមាយិកាតិ ខោ ភិក្ខុ កោធុបាយាសស្សេតំ អធិវចនំ ។ ឧក្ខិប ឧទ្ធុមាយិកំ បជហ កោធុបាយាសំ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ អយមេតស្ស អត្ថោ ។ ទ្វិធាបថោតិ ខោ ភិក្ខុ វិចិកិច្ឆាយេតំ អធិវចនំ ។ ឧក្ខិប ទ្វិធាបថំ បជហ វិចិកិច្ឆំ អភិក្ខណ សុមេធ





ហេតុនេះហៅថា ផេះភ្លើងវេលាថ្ងៃ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ព្រាហ្មណ៍ នេះ ជាឈ្មោះរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សុមេធ នេះជាឈ្មោះរបស់ភិក្ខុជាសេក្ខបុគ្គល ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សស្ត្រា នេះ ជាឈ្មោះរបស់ប្រាជ្ញាដ៏ប្រសើរ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ជីក នេះ ជាឈ្មោះរបស់ការប្រារព្ធព្យាយាម ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សន្ទះទ្វារគន់ នេះជាឈ្មោះរបស់អវិជ្ជា ។ ម្នាលសុមេធ អ្នកចូរលើកសន្ទះទ្វារគន់ចេញ គឺជាអ្នកចូរលះបង់អវិជ្ជាចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សត្វហ៊ឹង នេះ ជាឈ្មោះរបស់សេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត ។ ម្នាលសុមេធ អ្នកចូរលើកហ៊ឹងចេញ គឺជាអ្នកចូរលះបង់សេចក្តីក្រោធនិងសេចក្តីចង្អៀតចង្អល់ចិត្តចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ផ្លូវបែកជាពីរ នេះជាឈ្មោះរបស់វិចិកិច្ឆា ។ ម្នាលសុមេធ អ្នកចូរលើកនូវផ្លូវបែកជាពីរចេញ គឺជាអ្នកចូរលះបង់វិចិកិច្ឆា

សត្ថំ អាទាយាតិ អយមេតស្ស អត្ថោ ។ ចង្គវារន្តិ ខោ ភិក្ខុ បញ្ចន្នេតំ នីវរណានំ អធិវចនំ កាមច្ឆន្ទនីវរណស្ស ព្យាបាទនីវរណស្ស ថីនមិទ្ធនីវរណស្ស ឧទ្ធច្ចកុក្កុច្ចនីវរណស្ស វិចិកិច្ឆានីវរណស្ស ។ ឧក្ខិប ចង្គវារំ បជហ បញ្ច នីវរណេ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ អយមេតស្ស អត្ថោ ។ កុម្មោតិ ខោ ភិក្ខុ បញ្ចន្នេតំ ឧបាទានក្ខន្ធានំ អធិវចនំ សេយ្យថីទំ រូបូបាទានក្ខន្ធស្ស វេទនូបាទានក្ខន្ធស្ស សញ្ញូបាទានក្ខន្ធស្ស សង្ខារូបាទានក្ខន្ធស្ស វិញ្ញាណូបាទានក្ខន្ធស្ស ។ ឧក្ខិប កុម្មំ បជហ បញ្ចុបាទានក្ខន្ធេ អភិក្ខណ សុមេធ សត្ថំ អាទាយាតិ អយមេតស្ស អត្ថោ ។ អសិសូនាតិ ខោ ភិក្ខុ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ចក្ខុវិញ្ញេយ្យានំ រូបានំ ឥដ្ឋានំ កន្តានំ មនាបានំ បិយរូបានំ កាមូបសញ្ហិតានំ រជនីយានំ សោតវិញ្ញេយ្យានំ សទ្ទានំ ... ឃានវិញ្ញេយ្យានំ គន្ធានំ ... ជិវ្ហាវិញ្ញេយ្យានំ រសានំ ...



ចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សំពត់តម្រងក្បង់ នេះជាឈ្មោះរបស់នីវរណធម៌ទាំង ៥ គឺ កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ម្នាលសុមេធ អ្នកចូរលើកសំពត់តម្រងក្បង់ចេញ គឺថាអ្នកចូរលះបង់នីវរណធម៌ទាំង ៥ ចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយ នៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា អណ្តើក នេះ ជាឈ្មោះរបស់ឧបាទានក្ខន្ធទាំង៥ ឧបាទានក្ខន្ធទាំង ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលសុមេធ អ្នកចូរលើកអណ្តើកចេញ គឺថា អ្នកចូរលះបង់ឧបាទានក្ខន្ធទាំង ៥ ចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា កាំបិតនិងជ្រញ់ នេះជាឈ្មោះរបស់កាមគុណទាំង៥ គឺរូបដែលបុគ្គលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាមជាទីតាំងនៃតម្រេក ១ សំឡេងដែលបុគ្គលគប្បីដឹងដោយត្រចៀក...១ ក្លិនដែលបុគ្គលគប្បីដឹងដោយច្រមុះ...១ រសដែលបុគ្គលគប្បីដឹងដោយអណ្តាត...១

កាយវិញ្ញេយ្យានំ ផោដ្ឋព្វានំ ឥដ្ឋានំ កន្តានំ មនា-
បានំ បិយរូបានំ កាមូបសញ្ហិតានំ រជនីយានំ ។
ឧក្ខិប អសិសូនំ បជហ បញ្ច កាមគុណេ អ-
ភិក្ខន សុមេធ សត្ថំ អាទាយាតិ អយមេតស្ស
អត្ថោ ។ មំសបេសីតិ ខោ ភិក្ខុ នន្ទិរាគស្សេតំ
អធិវចនំ ។ ឧក្ខិប មំសបេសឹ បជហ នន្ទិរាគំ
អភិក្ខន សុមេធ សត្ថំ អាទាយាតិ អយមេតស្ស
អត្ថោ ។ នាគោតិ ខោ ភិក្ខុ ខីណាសវស្សេតំ
ភិក្ខុនោ អធិវចនំ ។ តិដ្ឋតុ នាគោ មា នាគំ
ឃដ្ដេសិ នមោ ករោហិ នាគស្សាតិ អយមេតស្ស
អត្ថោតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា
កុមារកស្សបោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

វម្មិកសុត្តំ តតិយំ និដ្ឋិតំ ។

---



ផ្សព្វដែលបុគ្គលគប្បីដឹងច្បាស់ ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ
ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃតម្រេក ១ ។
ម្នាលសុមេធ អ្នកចូរលើកកាំបិតនិងជ្រញ់ចេញ គឺជាអ្នកចូរលះបង់កាម-
គុណទាំង ៥ ចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយ
នៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ដុំសាច់ នេះជាឈ្មោះរបស់
នន្ទិរាគ (សេចក្តីត្រេកត្រអាល) ។ ម្នាលសុមេធ អ្នកចូរលើកដុំសាច់
ចេញ គឺថា អ្នកចូរលះបង់នន្ទិរាគចេញ ហើយយកសស្ត្រាជីកទៀត
នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា នាគ នេះ
ជាឈ្មោះរបស់ភិក្ខុដែលជាព្រះខីណាស្រព ។ នាគចូរឋិតនៅចុះ អ្នកកុំ
បៀតបៀននាគឡើយ អ្នកចូរធ្វើនូវការនមស្ការនាគចុះ នេះជាសេចក្តី
អធិប្បាយនៃពាក្យនុ៎ះ ។ ព្រះមានព្រះភាគ ទ្រង់បានសំដែងនូវសូត្រនេះ
ចប់ហើយ ព្រះកុមារកស្សបមានអាយុ ក៏មានចិត្តត្រេកអរ រីករាយហើយ
ចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចប់ វម្មិកសូត្រ ទី ៣ ។

## ចតុត្ថំ រថវិនីតសុត្តំ

(៣០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ សម្ពហុលា ជាតិភូមិកា(១) ភិក្ខូ ជាតិភូមិយំ វស្សំ វុត្ថា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច កោ នុ ខោ ភិក្ខវេ ជាតិភូមិយំ ជាតិភូមិកានំ ភិក្ខូនំ សព្រហ្មចារីនំ ឯវំ សម្ភាវិតោ អត្តនា ច អប្បិច្ឆោ អប្បិច្ឆកថញ្ច ភិក្ខូនំ

១ ឱ. ម. ជាតិភូមកា ។

## រថវិនីតសូត្រ ទី ៤

(៣០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប អ្នកនៅក្នុងជាតិភូមិ (១) នៅចាំវស្សាក្នុងជាតិភូមិហើយ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បណ្តាជាតិភូមិកភិក្ខុទាំងឡាយ ជាសព្រហ្មចារីដែលនៅក្នុងជាតិភូមិ ភិក្ខុណាខ្លះ ដែលមានគេសរសើរយ៉ាងនេះថា ជាអ្នកមិនមានសេចក្តីប្រាថ្នាដោយខ្លួនឯងផង សំដែងនូវកថាមិនមានសេចក្តីប្រាថ្នា (២) ដល់ពួកភិក្ខុផង ជាអ្នក

១ អដ្ឋកថាថា ស្រុកកំណើតរបស់ខ្លួន គឺស្រុកជាមួយនឹងសព្វញ្ញុពោធិសត្វ ។ ២ និយាយអំពីការមិនមានប្រាថ្នា ៤ យ៉ាង គឺមិនប្រាថ្នានូវបច្ច័យបួន ១ មិនប្រាថ្នាឲ្យគេស្គាល់ថាជាអ្នកកាន់ធុតង្គ ១ មិនប្រាថ្នាឲ្យគេស្គាល់ថាខ្លួនជាពហុស្សូត ១ មិនប្រាថ្នាឲ្យគេស្គាល់ថាខ្លួនបាននូវគុណមានសោតាបត្តិផលជាដើម ១ ។

កត្តា អត្តនា ច សន្តុដ្ឋោ សន្តុដ្ឋិកថញ្ច កិត្តកំ កត្តា អត្តនា ច បវិវិត្តោ វិវេកកថញ្ច កិត្តកំ(១) កត្តា អត្តនា ច អសំសដ្ឋោ អសំសគ្គកថញ្ច កិត្តកំ កត្តា អត្តនា ច អារទ្ធវីរិយោ វីរិយារម្ភកថញ្ច កិត្តកំ កត្តា អត្តនា ច សីលសម្បន្នោ សីលសម្បទាកថញ្ច កិត្តកំ កត្តា អត្តនា ច សមាធិសម្បន្នោ សមាធិសម្បទា-កថញ្ច កិត្តកំ កត្តា អត្តនា ច បញ្ញាសម្បន្នោ

១ ឱ. ឱ. បវិវេកកថញ្ច ។



ជាអ្នកសន្តោសដោយខ្លួនឯងផង សំដែងពីការសន្តោស(១) ដល់ពួកភិក្ខុផង ជាអ្នកស្ងប់ស្ងាត់ដោយខ្លួនឯងផង សំដែងពីការស្ងប់ស្ងាត់(២) ដល់ពួកភិក្ខុផង ជាអ្នកមិនច្រឡូកច្រឡំដោយខ្លួនឯងផង សំដែងពីការមិនច្រឡូកច្រឡំ(៣) ដល់ពួកភិក្ខុផង ជាអ្នកប្រារព្ធសេចក្ដីព្យាយាម ដោយខ្លួនឯងផង សំដែងពីការប្រារព្ធព្យាយាម(៤)ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយសីល ចំពោះខ្លួនឯងផង សំដែងពីការបរិបូណ៌ដោយសីល(៥)ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយសមាធិចំពោះខ្លួនឯងផង សំដែងពីការបរិបូណ៌ដោយសមាធិ(៦)ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយបញ្ញា ចំពោះខ្លួនឯងផង

១ និយាយអំពីសន្តោស ១២ យ៉ាង គឺ ចីវរសន្តោស មាន ៣ គឺត្រេកអរតាមបាន ១ ត្រេកអរតាមកម្លាំង ១ ត្រេកអរតាមសមគួរ ១ ឯក្នុងបិណ្ឌបាតសន្តោស សេនាសនសន្តោសនិងគិលានប្បច្ចយសន្តោស មានបីដូចគ្នា រួមជា ១២ ។ ២ និយាយអំពីសេចក្ដីស្ងប់ស្ងាត់ ៣ យ៉ាង គឺ ស្ងាត់កាយ ១ ស្ងាត់ចិត្តគឺសមាបត្តិប្រាំបី ១ ស្ងាត់ឧបធិវិវេក គឺព្រះនិព្វាន ១ ។ ៣ និយាយអំពីការមិនច្រឡូកច្រឡំមាន ៥ យ៉ាង គឺ មិនច្រឡូកច្រឡំដោយឮសំឡេង ១ មិនច្រឡូកច្រឡំដោយឃើញរូប ១ មិនច្រឡូកច្រឡំដោយពាក្យនិយាយឆ្លើយឆ្លង ១ មិនច្រឡូកច្រឡំដោយការប្រើប្រាស់ជាមួយគ្នា ១ មិនច្រឡូកច្រឡំដោយការប៉ះពាល់កាយ ១ ។ ៤ និយាយអំពីការប្រារព្ធព្យាយាមនៃសេចក្ដីព្យាយាមបរិបូណ៌ក្នុងកាយនិងចិត្តគ្រប់ឥរិយាបថទាំង ៤ ។ ៥ បរិបូណ៌ដោយសីល គឺជាផលនៃចតុប្បារិសុទ្ធិសីល ។ ៦ សមាធិក្នុងទីនេះបានដល់វិបស្សនា ដែលមានសមាបត្តិ ៨ ជាគ្រឿងទ្រ ។ អដ្ឋកថា ។

បញ្ញាសម្បទាកថញ្ច ភិក្ខូនំ កត្តា អត្តនា ច វិមុត្តិសម្បន្នោ វិមុត្តិសម្បទាកថញ្ច ភិក្ខូនំ កត្តា អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ វិមុត្តិញាណ-ទស្សនសម្បទាកថញ្ច ភិក្ខូនំ កត្តា ឱវាទកោ វិញ្ញាបកោ សន្ទស្សកោ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនន្តិ ។ បុណ្ណោ នាម ភន្តេ អាយស្មា មន្តាណីបុត្តោ ជាតិភូមិយំ ជាតិភូមកានំ ភិក្ខូនំ សព្រហ្មចារីនំ ឯវំ សម្ភាវិតោ អត្តនា ច អប្បិច្ឆោ





*សំដែងនូវកថាបរិបូណ៌ដោយបញ្ញា ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ដោយខ្លួនឯងផង សំដែងនូវកថាបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញាណ-ទស្សនៈ(១)ដោយខ្លួនឯងផង សំដែងនូវកថាបរិបូណ៌ដោយវិមុត្តិញាណ-ទស្សនៈដល់ពួកភិក្ខុផង ជាអ្នកឲ្យឱវាទ ចង្អុលឲ្យដឹងច្បាស់ ណែនាំ បបួលធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយ ដល់ពួកសព្រហ្មចារីផង ។ ភិក្ខុទាំង-ឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បណ្ដាជាតិភូមកភិក្ខុទាំងឡាយ ជាសព្រហ្មចារី ដែលនៅក្នុងជាតិភូមិ មានតែបុណ្ណៈដ៏មានអាយុ ជាមន្តាណីបុត្ត (កូនស្រីព្រាហ្មណ៍ឈ្មោះមន្តាណី)នេះ ទើបគេតែងសរសើរគុណ យ៉ាងនេះថា ជាអ្នកមិនប្រាថ្នា ដោយខ្លួនឯងផង*

---

១ វិមុត្តិញាណទស្សនៈក្នុងទីនេះ បានដល់បច្ចវេក្ខណញ្ញាណទាំង ១៩ គឺអនុបស្សនា ៣ អនុបស្សនា ៧ វិបស្សនាញាណ ៩ ឯអនុបស្សនា ៣ គឺ អនិច្ចានុបស្សនា ១ ទុក្ខានុបស្សនា ១ អនត្តានុបស្សនា ១ អនុបស្សនា ៧ គឺ ១-២-៣ ខ្ទង់ខាងដើម និងនិព្វិទានុបស្សនា ១ វិរាគា-នុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គានុបស្សនា ១ ។ វិបស្សនាញាណ ៩ គឺ ឧទយព្វ-យញ្ញាណ ១ ភង្គញ្ញាណ ១ ភយតូបដ្ឋានញ្ញាណ ១ អាទីនវញ្ញាណ ១ និព្វិទាញាណ ១ មុញ្ចិតុកម្យតាញាណ១ បដិសង្ខាញាណ ១ សង្ខារុបេក្ខាញាណ ១ សច្ចានុលោមិកញ្ញាណ ១ ។ អដ្ឋកថាសូត្រនេះ និងវិសុទ្ធិមគ្គបញ្ញានិទ្ទេស ។

អប្បិច្ឆកថញ្ច កិត្តយំ កត្តា អត្តនា ច សន្តុដ្ឋោ ។ បេ ។ អត្តនា ច បវិវិត្តោ ... អត្តនា ច អសំសដ្ឋោ ... អត្តនា ច អារទ្ធវីរិយោ ... អត្តនា ច សីលសម្បន្នោ ... អត្តនា ច សមាធិសម្បន្នោ ... អត្តនា ច បញ្ញា-សម្បន្នោ ... អត្តនា ច វិមុត្តិសម្បន្នោ .. អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ វិមុត្តិញាណទស្សន-សម្បទាកថញ្ច កិត្តយំ កត្តា ឱវាទកោ វិញ្ញាបកោ សន្ទស្សកោ សមាទបកោ សមុត្តេជកោ សម្បហំ-សកោ សព្រហ្មចារីនន្តិ ។

(៣១) តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថ-ខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ លាភា អាយស្មតោ បុណ្ណស្ស មន្តាណីបុត្តស្ស សុលទ្ធំ អាយស្មតោ បុណ្ណស្ស មន្តាណីបុត្តស្ស យស្ស



សម្តែងនីតិកថាមិនមានប្រាថ្នាដល់ពួកភិក្ខុផង ជាអ្នកសន្តោសដោយខ្លួនឯងផង ។ បេ ។ ជាអ្នកស្ងប់ស្ងាត់ ដោយខ្លួនឯងផង ... ជាអ្នកមិនច្រឡូកច្រឡំដោយខ្លួនឯងផង ... ជាអ្នកមានសេចក្តីព្យាយាមដោយខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយសីលចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយសមាធិចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយបញ្ញា ចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយវិមុត្តិចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយវិមុត្តិញាណទស្សនៈចំពោះខ្លួនឯងផង សម្តែងនីតិកថាបរិបូណ៌ដោយវិមុត្តិញាណទស្សនៈដល់ពួកភិក្ខុផង ជាអ្នកឲ្យឱវាទ ចង្អុលប្រាប់ ពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយដល់ពួកសព្រហ្មចារីផង ។

(៣១) សម័យនោះឯង ព្រះសារីបុត្តមានអាយុ អង្គុយក្បែរព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា បុណ្ណមន្តាណីបុត្តមានអាយុហៅពេញជាមានលាភ បាន អត្តភាពជាមនុស្ស ក៏បុណ្ណមន្តាណីបុត្តបានហើយដោយប្រពៃ (ព្រោះ)

វិញ្ញូ សព្រហ្មចារី សត្ថុ សម្មុខា អនុមស្ស អនុមស្ស វណ្ណំ ភាសន្តិ តញ្ច សត្ថា អព្ភនុមោទតិ អប្បេវ នាម មយម្បិ(១) កទាចិ ករហចិ អាយស្មតា បុណ្ណេន មន្តាណីបុត្តេន សទ្ធឹ សមាគមំ គច្ឆេយ្យាម(២) អប្បេវ នាម សិយា កោចិទេវ កថាសល្លាបោតិ ។

(៣២) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកញ្ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អស្សោសិ ខោ អាយស្មា បុណ្ណោ មន្តាណីបុត្តោ ភគវា កិរ សាវត្ថឹ អនុប្បត្តោ ។ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេតិ ។ អថខោ អាយស្មា បុណ្ណោ មន្តាណីបុត្តោ សេនាសនំ សំសាមេត្វា បត្តចីវរំ អាទាយ យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកញ្ចរមានោ

១ ម. អប្បេវ ច នាម មយម្បិ ។ អប្បេវ នាម មយំបិ ។ ២ ម. សមាគច្ឆេយ្យាម ។





ពួកសព្រហ្មចារីក៏ដែលជាអ្នកប្រាជ្ញពិចារណាហើយៗ តែងពោលសរសើរ សរសើរគុណចំពោះព្រះភក្ត្រព្រះសាស្តា ព្រះសាស្តាក៏ទ្រង់ត្រេកអរ ចំពោះបុណ្ណមន្តាណីបុត្តនោះ ធ្វើដូចម្តេចហ្ន៎ យើងទាំងឡាយនឹងបានជួបប្រជុំ ជាមួយនឹងព្រះបុណ្ណមន្តាណីបុត្ត មានអាយុនោះ ធ្វើដូចម្តេចហ្ន៎ នឹងបាននិយាយពាក្យចរចាជាមួយនឹងលោក ។

(៣២) គ្រានោះឯង ព្រះតថាគតគង់ ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមគួរដល់អធ្យាស្រ័យហើយ ទ្រង់ស្តេចទៅកាន់ចារិកឆ្ពោះក្រុងសាវត្ថី លុះស្តេចទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់ក្រុងសាវត្ថីនោះ ។ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ ។ ព្រះបុណ្ណមន្តាណីបុត្ត មានអាយុ បានឮដំណឹងដូច្នេះថា ព្រះមានព្រះភាគ យាងមកដល់ក្រុងសាវត្ថីហើយ ទ្រង់គង់ក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ លំដាប់នោះ ឯព្រះបុណ្ណមន្តាណីបុត្តមានអាយុ រៀបចំសេនាសនៈហើយប្រដាប់បាត្រចីវរ ទៅកាន់ចារិកក្នុងក្រុងសាវត្ថីនោះដែរ លុះត្រាច់ទៅកាន់ចារិក

យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ បុណ្ណំ មន្តាណីបុត្តំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ អាយស្មា បុណ្ណោ មន្តាណីបុត្តោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន អន្ធវនំ តេនុបសង្កមិ ទិវាវិហារាយ ។

(៣៣) អថខោ អញ្ញតរោ ភិក្ខុ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច យស្ស ខោ ត្វំ អាវុសោ សារីបុត្ត បុណ្ណស្ស នាម ភិក្ខុនោ មន្តាណីបុត្តស្ស អភិណ្ហំ កិត្តយមានោ អហោសិ សោ ភគវតា





តាមផ្លូវណា ក៏ចូលទៅកាន់ព្រះមានព្រះភាគ ដែលគង់នៅក្នុង វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ លុះចូលទៅ ដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះបុណ្ណមន្តាណីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមាន ព្រះភាគទ្រង់ពន្យល់ ដឹកនាំ ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ។ គ្រានោះ បុណ្ណមន្តាណីបុត្ត មានអាយុ កាលបើព្រះមានព្រះភាគ ទ្រង់ពន្យល់ ដឹកនាំ ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ ត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោក អំពីអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចូល ទៅកាន់អន្ធវ័ន(ព្រៃងងឹត) ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។

(៣៣) គ្រានោះឯង មានភិក្ខុ ១ រូប ចូលទៅរកព្រះសារីបុត្តមាន អាយុ លុះចូលទៅដល់ហើយ បាននោលពាក្យដូច្នេះនឹងព្រះសារីបុត្ត មានអាយុថា អាវុសោសារីបុត្ត អ្នកសម្តែងសេចក្តីសរសើររឿយៗ នូវភិក្ខុ បុណ្ណមន្តាណីបុត្ត ឯភិក្ខុបុណ្ណមន្តាណីបុត្តនោះ ដែលព្រះមានព្រះភាគ

ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន អន្ធវនំ តេន បក្កាមិ ទិវាវិហារាយ ។ អថខោ អាយស្មា សារីបុត្តោ តរមានរូបោ និសីទនំ អាទាយ អាយស្មន្តំ បុណ្ណំ មន្តាណីបុត្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ សីសានុលោកី ។ អថខោ អាយស្មា បុណ្ណោ មន្តាណីបុត្តោ អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ អាយស្មាបិ ខោ សារីបុត្តោ អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

(៣៤) អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា បុណ្ណោ មន្តាណីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា បុណ្ណេន មន្តាណីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ



ទ្រង់ពន្យល់ណែនាំឲ្យក្លាហាន ឲ្យរីករាយដោយធម្មីកថា លោកត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកពីអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចហើយ ចេញទៅកាន់អន្ធវ័នតោះ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ លំដាប់នោះឯង ព្រះសារីបុត្តមានអាយុ មានសេចក្តីប្រញាប់កាន់និសីទនៈ ដើរតាមក្រោយ ៗ នៃភិក្ខុបុណ្ណមន្តាណីបុត្តមានអាយុ ហើយមើលទៅសីសៈនៃបុណ្ណមន្តាណីបុត្ត ។ គ្រានោះឯង បុណ្ណមន្តាណីបុត្តមានអាយុ ដើរចូលទៅកាន់អន្ធវ័នហើយ អង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបម្លប់ឈើមួយ ចំណែកខាងព្រះសារីបុត្តមានអាយុ ក៏ចូលទៅកាន់អន្ធវ័នហើយអង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបម្លប់ឈើមួយដែរ ។

(៣៤) គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីទីពួនក្នុងសាយណ្ហសម័យ ហើយចូលទៅរកបុណ្ណមន្តាណីបុត្ត មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល មួយអន្លើដោយបុណ្ណមន្តាណីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និង

សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ បុណ្ណំ មន្តាណីបុត្តំ ឯតទវោច ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតីតិ ។ ឯវមាវុសោតិ ។ កិន្នុ ខោ អាវុសោ សីលវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ ចិត្តវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ ទិដ្ឋិវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។



ពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនុ៎ះ នឹងបុណ្ណមន្តាណីបុត្តមានអាយុថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគរបស់យើងដែរឬ ។ បុណ្ណមន្តាណីបុត្តមានអាយុ តបថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ ។ ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធនៃសីល(១)ឬ ។ ម្នាលអាវុសោ ការប្រព្រឹត្តនេះ មិនមែនត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធនៃចិត្ត(២)ឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ដើម្បីបរិសុទ្ធនៃទិដ្ឋិ(៣)ឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។

---

១ បរិសុទ្ធិនៃសីលក្នុងទីនេះ បានដល់ កថាវត្ថុ ៤ យ៉ាងគឺ អប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ អសំសគ្គកថា ១ សីលកថា ១ ។ ២ បរិសុទ្ធិនៃចិត្តក្នុងទីនេះ បានដល់ កថាវត្ថុ ៣ យ៉ាងគឺ បវិវេកកថា ១ វិរិយារម្ភកថា ១ សមាធិកថា ១ ។ ៣ បរិសុទ្ធិទាំង ៣ ក្នុងទីនេះ បានដល់បញ្ញាកថា តែមួយប៉ុណ្ណោះ ។

កឹ បនាវុសោ កង្ខាវិតរណវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ មគ្គាមគ្គញាណទស្សនវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ បដិបទាញាណទស្សនវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ ញាណទស្សនវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ សីលវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ កឹ បនាវុសោ ចិត្តវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ



ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃកង្ខាវិតរណៈ[1]ឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃមគ្គាមគ្គញាណទស្សនៈ[2]ឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃបដិបទាញាណទស្សនៈ[3]ឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ព្រះសារីបុត្តមានអាយុ មានថេរវាចាថា កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃសីលឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃចិត្តឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ កាលបើ

---

១-២-៣ បរិសុទ្ធិទាំង ៣ ក្នុងទីនេះ បានដល់ បញ្ញាកថា តែមួយប៉ុណ្ណោះ ។

កឹ នុ ខោ អាវុសោ ទិដ្ឋិវិសុទ្ធត្ថំ ភគវតិ
ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ
ហិទំ អាវុសោតិ វទេសិ កឹ បនាវុសោ កង្ខាវិតរ-
ណវិសុទ្ធត្ថំ... កឹ នុ ខោ អាវុសោ មគ្គាមគ្គញាណ-
ទស្សនវិសុទ្ធត្ថំ... កឹ បនាវុសោ បដិបទាញាណ-
ទស្សនវិសុទ្ធត្ថំ... កឹ នុ ខោ អាវុសោ ញាណទស្ស-
នវិសុទ្ធត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ
សមានោ នោ ហិទំ អាវុសោតិ វទេសិ កិស្សត្ថំ ចរហាវុ-
សោ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ អនុបាទាបរិ-
និព្វានត្ថំ ខោ អាវុសោ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។
កឹ នុ ខោ អាវុសោ សីលវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ។
នោ ហិទំ អាវុសោ ។ កឹ បនាវុសោ ចិត្តវិសុទ្ធិ
អនុបាទាបរិនិព្វានន្តិ ។ នោ ហិទំ អាវុសោ ។
កឹ នុ ខោ អាវុសោ ទិដ្ឋិវិសុទ្ធិ អនុបាទាបរិនិព្វា-
នន្តិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ



ខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុង
សម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃទិដ្ឋិ លោកនិយាយថា ម្នាល
អាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃកង្ខា-
វិតរណៈឬ... ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃមគ្គាមគ្គញាណទស្សនៈឬ...
ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃបដិបទាញាណទស្សនៈឬ...កាលបើខ្ញុំសួរ
ថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់
ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ លោកនិយាយថា
ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ម្នាលអាវុសោ (បើយ៉ាងនេះ)
ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ
ដើម្បីអ្វី ។ បុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ ព្រហ្មចរិយធម៌ដែលខ្ញុំ
ប្រព្រឹត្ត ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វានទេតើ ។
ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ
នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះចិត្តវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។
ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ទិដ្ឋិវិសុទ្ធិ ជាអនុបា-
ទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ

កង្ខាវិតរណវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ មគ្គាមគ្គញាណទស្សនវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ បដិបទាញាណទស្សនវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ ញាណទស្សនវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ អញ្ញត្រ ឥមេហិ ធម្មេហិ អនុបាទាបរិនិព្វានន្តិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ សីលវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ កឹ បនាវុសោ ចិត្តវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ កិន្នុ ខោ អាវុសោ ទិដ្ឋិវិសុទ្ធិ អនុបាទាបរិនិព្វានន្តិ ។ បេ ។ កឹ បនាវុសោ កង្ខាវិតរណវិសុទ្ធិ... កិន្នុ ខោ អាវុសោ មគ្គាមគ្គញាណទស្សនវិសុទ្ធិ... កឹ អាវុសោ



ចុះកង្ខាវិតរណវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះបដិបទាញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះអនុបាទាបរិនិព្វានក្រៅអំពីធម៌ទាំងនេះឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ព្រះសារីបុត្តសួរថា កាលខ្ញុំសួរថា ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា អាវុសោ នេះមិនមែនទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះចិត្តវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ ម្នាលអាវុសោ ទិដ្ឋិវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ បេ ។ ម្នាលអាវុសោ ចុះកង្ខាវិតរណវិសុទ្ធិឬ... ម្នាលអាវុសោ ចុះមគ្គាមគ្គញាណទស្សនវិសុទ្ធិឬ ... ម្នាលអាវុសោ

បនាវុសោ បដិបទាញាណទស្សនវិសុទ្ធិ... កិន្នុ ខោ អាវុសោ ញាណទស្សនវិសុទ្ធិ អនុបាទាបរិនិព្ពានន្តិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។ កិំ បនាវុសោ អញ្ញត្រ ឥមេហិ ធម្មេហិ អនុបាទាបរិនិព្ពានន្តិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។ យថាកថំ បនាវុសោ ឥមស្ស ភាសិតស្ស អត្ថោ ទដ្ឋព្វោតិ ។

(៣៩) សីលវិសុទ្ធិំ ចេ អាវុសោ ភគវា អនុបាទាបរិនិព្ពានំ បញ្ញបេស្ស(១) សឧបាទានំយេវ(២) សមានំ អនុបាទាបរិនិព្ពានំ បញ្ញបេស្ស ។ ចិត្តវិសុទ្ធិំ ចេ អាវុសោ ភគវា អនុបាទាបរិនិព្ពានំ បញ្ញបេស្ស សឧបាទានំយេវ សមានំ អនុបាទាបរិនិព្ពានំ បញ្ញបេស្ស ។ ទិដ្ឋិវិសុទ្ធិំ ចេ អាវុសោ ភគវា អនុបាទាបរិនិព្ពានំ បញ្ញបេស្ស សឧបាទានំយេវ សមានំ អនុបាទាបរិនិព្ពានំ បញ្ញបេស្ស ។ កង្ខាវិតរណវិសុទ្ធិំ ចេ អាវុសោ ភគវា អនុបាទាបរិនិព្ពានំ បញ្ញបេស្ស

---

១ ម. បញ្ញបេយ្យ ។ ២ ឱ. ម. សឧបាទានំយេវ ។



ចុះបដិបទាញាណទស្សនវិសុទ្ធិឬ...កាលខ្ញុំសួរថា ម្នាលអាវុសោ ញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះអនុបាទាបរិនិព្វាន ក្រៅអំពីធម៌ទាំងនេះឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ ម្នាលអាវុសោ (កាលបើយ៉ាងនេះ) ចុះសេចក្ដីនៃភាសិតនេះ តើលោកយល់យ៉ាងណា ។

(៣៩) បុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្តនូវសីលវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្តនូវចិត្តវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្តនូវទិដ្ឋិវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្តនូវកង្ខាវិតរណវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា

សឧបាទានញ្ញេវ សមានំ អនុបាទាបរិនិព្វានំ បញ្ញ-
បេស្ស ។ មគ្គាមគ្គញាណទស្សនវិសុទ្ធិំ ចេ អាវុសោ
ភគវា អនុបាទាបរិនិព្វានំ បញ្ញបេស្ស សឧបាទា-
នញ្ញេវ សមានំ អនុបាទាបរិនិព្វានំ បញ្ញបេស្ស ។
បដិបទាញាណទស្សនវិសុទ្ធិំ ចេ អាវុសោ ភគវា
អនុបាទាបរិនិព្វានំ បញ្ញបេស្ស សឧបាទានញ្ញេវ
សមានំ អនុបាទាបរិនិព្វានំ បញ្ញបេស្ស ។ ញាណ-
ទស្សនវិសុទ្ធិំ ចេ អាវុសោ ភគវា អនុបាទាបរិនិព្វានំ
បញ្ញបេស្ស សឧបាទានញ្ញេវ សមានំ អនុបាទាបរិ-
និព្វានំ បញ្ញបេស្ស ។ អញ្ញត្រ ចេ អាវុសោ
ឥមេហិ ធម្មេហិ អនុបាទាបរិនិព្វានំ អភវិស្ស
បុថុជ្ជនោ បរិនិព្វាយេយ្យ បុថុជ្ជនោ ហិ អាវុសោ
អញ្ញត្រ ឥមេហិ ធម្មេហិ ។ តេនហាវុសោ ឧបមន្តេ
ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស
អត្ថំ អាជានន្តិ ។



បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ
បើព្រះមានព្រះភាគបញ្ញត្ត នូវមគ្គាមគ្គញាណទស្សនវិសុទ្ធិថា ជាអនុ-
បាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបា-
ទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគ បញ្ញត្ត
នូវបដិបទាញាណទស្សនវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះ
ថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុ-
សោ បើព្រះមានព្រះភាគ បញ្ញត្តនូវញាណទស្សនវិសុទ្ធិថា ជាអនុបាទា-
បរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិ-
និព្វានទៅវិញ ។ ម្នាលអាវុសោ បើអនុបាទាបរិនិព្វាន ក្រៅអំពីធម៌
ទាំងនេះហើយ បុថុជ្ជន ក៏នឹងបរិនិព្វានបាន ម្នាលអាវុសោ ព្រោះ
បុថុជ្ជន ក្រៅអំពីធម៌ទាំងនេះឯង ។ ម្នាលអាវុសោ បើដូច្នោះ ខ្ញុំនឹង
ធ្វើសេចក្តីឧបមាដល់លោក បុរស ជាអ្នកប្រាជ្ញពួកខ្លះ ក្នុងលោកនេះ
គង់ដឹងច្បាស់នូវសេចក្តីនៃភាសិត ដោយសេចក្តីឧបមាបាន ។

(៣៦) សេយ្យថាបិ កស្សប រញ្ញោ បសេនទិស្ស កោសលស្ស សាវត្ថិយំ បដិវសន្តស្ស សាកេតេ កិញ្ចិទេវ អច្ចាយិកំ ករណីយំ ឧប្បជ្ជេយ្យ តស្ស អន្តរា ច សាវត្ថឹ អន្តរា ច សាកេតំ សត្ត រថវិនីតានិ ឧបដ្ឋបេយ្យុំ អថខោ កស្សប រាជា បសេនទិ កោសលោ សាវត្ថិយា និក្ខមិត្វា អន្តេបុរទ្វារេ(១) បឋមំ រថវិនីតំ អភិរុហេយ្យ បឋមេន រថវិនីតេន ទុតិយំ រថវិនីតំ បាបុណេយ្យ បឋមំ រថវិនីតំ វិស្សជ្ជេយ្យ ទុតិយំ រថវិនីតំ អភិរុហេយ្យ ទុតិយេន រថវិនីតេន តតិយំ រថវិនីតំ បាបុណេយ្យ ទុតិយំ រថវិនីតំ វិស្សជ្ជេយ្យ តតិយំ រថវិនីតំ អភិរុហេយ្យ តតិយេន រថវិនីតេន ចតុត្ថំ រថវិនីតំ បាបុណេយ្យ តតិយំ រថវិនីតំ វិស្សជ្ជេយ្យ ចតុត្ថំ រថវិនីតំ អភិរុហេយ្យ ចតុត្ថេន រថវិនីតេន បញ្ចមំ រថវិនីតំ បាបុណេយ្យ ចតុត្ថំ រថវិនីតំ វិស្សជ្ជេយ្យ បញ្ចមំ រថវិនីតំ អភិរុហេយ្យ បញ្ចមេន រថវិនីតេន ឆដ្ឋំ រថវិនីតំ បាបុណេយ្យ បញ្ចមំ រថវិនីតំ វិស្សជ្ជេយ្យ

១ ម. អន្តេបុរទ្វារា ។



(៣៦) ម្នាលកស្សប ដូចជា ព្រះបាទបសេនទិកោសល ទ្រង់នៅគ្រប់គ្រងក្រុងសាវត្ថី មានកិច្ចនីមួយ ដែលត្រូវធ្វើជាប្រញាប់ប្រញាល់ កើតឡើងក្នុងក្រុងសាកេត ជនទាំងឡាយ ដែលនៅក្រុងចន្លោះក្រុងសាវត្ថី និងក្រុងសាកេត គប្បីរៀបចំ នូវរថព្រះទីនាំងតាំង ៧ ថ្វាយព្រះបាទបសេនទិកោសលនោះរួចហើយ ម្នាលកស្សប ទើបព្រះបាទបសេនទិ-កោសល ទ្រង់ស្តេចចេញអំពីក្រុងសាវត្ថី ឡើងព្រះទីនាំងទី ១ ទៀបទ្វារព្រះរាជវាំងខាងក្នុង ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ១ ក៏បានដល់នូវរថព្រះទីនាំងទី ២ ហើយលះបង់រថព្រះទីនាំងទី ១ ឡើងគង់រថព្រះទីនាំងទី ២ ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ២ ក៏បានដល់រថព្រះទីនាំងទី ៣ ទ្រង់លះបង់រថព្រះទីនាំងទី ២ រួចឡើងគង់រថព្រះទីនាំងទី ៣ ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ៣ ក៏បានដល់រថព្រះទីនាំងទី ៤ ទ្រង់លះបង់រថព្រះទីនាំងទី ៣ ក៏ឡើងគង់រថព្រះទីនាំងទី ៤ ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ៤ ក៏បានដល់រថព្រះទីនាំងទី ៥ ទ្រង់លះបង់រថព្រះទីនាំងទី ៤ រួចឡើងគង់រថព្រះទីនាំងទី ៥ ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ៥ ក៏បានដល់រថព្រះទីនាំងទី ៦ ទ្រង់លះបង់រថព្រះទីនាំងទី៥

ឆដ្ឋំ រថវិនីតំ អភិរុហេយ្យ ឆដ្ឋេន រថវិនីតេន សត្តមំ រថវិនីតំ បាបុណេយ្យ ឆដ្ឋំ រថវិនីតំ វិស្សជ្ជេយ្យ សត្តមំ រថវិនីតំ អភិរុហេយ្យ សត្តមេន រថវិនីតេន សាកេតំ អនុបាបុណេយ្យ អន្តេបុរទ្វារំ តមេនំ អន្តេបុរទ្វារគតំ សមានំ មិត្តាមច្ចា ញាតិសាលោហិតា ឯវំ បុច្ឆេយ្យុំ ឥមិនា ត្វំ មហារាជ រថវិនីតេន សាវត្ថិយា សាកេតំ អនុប្បត្តោ អន្តេបុរទ្វារន្តិ ឯវំ បុដ្ឋោ អាវុសោ រាជា បសេនទិ កោសលោ កថំ ព្យាករមានោ សម្មា ព្យាករមានោ ព្យាករេយ្យាតិ ។ ឯវំ បុដ្ឋោ អាវុសោ រាជា បសេនទិ កោសលោ ឯវំ ព្យាករមានោ សម្មា ព្យាករមានោ ព្យាករេយ្យ ឥធ មេ សាវត្ថិយំ បដិវសន្តស្ស សាកេតេ កិញ្ចិទេវ អច្ចាយិកំ ករណីយំ ឧប្បជ្ជិ តស្ស មេ អន្តរា ច សាវត្ថឹ អន្តរា ច សាកេតំ សត្ត រថវិនីតានិ ឧបដ្ឋបេសុំ អថ ខ្វាហំ សាវត្ថិយា និក្ខមិត្វា អន្តេបុរទ្វារេ បឋមំ រថវិនីតំ អភិរុហឹ(១) បឋមេន រថវិនីតេន

១ ម. អភិរូហឹ ។



រួចឡើងគង់លើរថព្រះទីនាំងទី ៦ ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ៦ ក៏បានដល់រថព្រះទីនាំងទី ៧ ទ្រង់លះបង់រថព្រះទីនាំងទី ៦ រួចឡើងគង់លើរថព្រះទីនាំងទី ៧ ទ្រង់ស្ដេចដោយរថព្រះទីនាំងទី ៧ ក៏បានដល់ទៅក្រុងសាកេត ទ្រង់ប្រថាប់នៅត្រង់ទ្វារខាងក្នុងព្រះរាជវាំង ពួកមិត្រអមាត្យញាតិសាលោហិត នាំគ្នាក្រាបបង្គំទូលសួរព្រះអង្គ ក្នុងកាលដែលស្ដេចដល់ទ្វារខាងក្នុងព្រះរាជវាំងនោះ យ៉ាងនេះថា បពិត្រមហារាជ ព្រះអង្គស្ដេចចេញពីក្រុងសាវត្ថី ដោយរថព្រះទីនាំងតែមួយនេះ ដល់មកទ្វារខាងក្នុងព្រះរាជវាំងនៃក្រុងសាកេតតែម្ដងឬ ម្នាលអាវុសោ (បើគេសួរយ៉ាងនេះ) ព្រះបាទបសេនទិកោសល ទ្រង់ដោះស្រាយដូចម្ដេច ទើបឈ្មោះថាដោះស្រាយដោយប្រពៃ ។ ម្នាលអាវុសោ ព្រះបាទបសេនទិកោសល កាលបើដោះស្រាយយ៉ាងនេះ ឈ្មោះថាដោះស្រាយដោយប្រពៃថា យើងនៅអាស្រ័យក្រុងសាវត្ថី (ឯណោះទេ) តែមានកិច្ចខ្លះយ៉ាងប្រញាប់ កើតឡើងក្នុងក្រុងសាកេតនេះ ក៏បណ្ដាជនក្នុងចន្លោះក្រុងសាវត្ថីនិងក្រុងសាកេតបានរៀបចំរថ ៧ ឲ្យយើង ទើបយើងចេញមកពីក្រុងសាវត្ថី បានឡើងជិះរថទី ១ ត្រង់ទ្វារខាងក្នុងព្រះរាជវាំង មកដោយរថទី ១ ក៏បានដល់

ទុតិយំ រថវិនីតំ បាបុណេយ្យ បឋមំ រថវិនីតំ វិស្សជ្ជេយ្យ ទុតិយំ រថវិនីតំ អភិរុហេយ្យ ទុតិយេន រថវិនីតេន តតិយំ រថវិនីតំ បាបុណេយ្យ ទុតិយំ រថវិនីតំ វិស្សជ្ជេយ្យ តតិយំ រថវិនីតំ អភិរុហេយ្យ តតិយេន រថវិនីតេន ចតុត្ថំ រថវិនីតំ បាបុណេយ្យ តតិយំ រថវិនីតំ វិស្សជ្ជេយ្យ ចតុត្ថំ រថវិនីតំ អភិរុហេយ្យ ចតុត្ថេន រថវិនីតេន បញ្ចមំ រថវិនីតំ បាបុណេយ្យ ចតុត្ថំ រថវិនីតំ វិស្សជ្ជេយ្យ បញ្ចមំ រថវិនីតំ អភិរុហេយ្យ បញ្ចមេន រថវិនីតេន ឆដ្ឋំ រថវិនីតំ បាបុណេយ្យ បញ្ចមំ រថវិនីតំ វិស្សជ្ជេយ្យ ឆដ្ឋំ រថវិនីតំ អភិរុហេយ្យ ឆដ្ឋេន រថវិនីតេន សត្តមំ រថវិនីតំ បាបុណេយ្យ ឆដ្ឋំ រថវិនីតំ វិស្សជ្ជេយ្យ សត្តមំ រថវិនីតំ អភិរុហេយ្យ សត្តមេន រថវិនីតេន សាកេតំ អនុប្បត្តោ អន្តេបុរទ្វារេ ឯវំ ព្យាករមានោ ខោ អាវុសោ រាជា បសេនទិ កោ-សលោ សម្មា ព្យាករមានោ ព្យាករេយ្យាតិ ឯវមេវ ខោ អាវុសោ សីលវិសុទ្ធិ យាវទេវ ចិត្តវិសុទ្ធត្ថា ចិត្តវិសុទ្ធិ យាវទេវ ទិដ្ឋិវិសុទ្ធត្ថា ទិដ្ឋិវិសុទ្ធិ យាវទេវ



រថទី ២ ក៏លះបង់រថទី ១ ហើយឡើងជិះរថទី ២ មកដោយរថទី ២ ក៏បានដល់រថទី ៣ លះបង់រថទី ២ ហើយឡើងជិះរថទី ៣ មកដោយរថទី ៣ ក៏បានដល់រថទី ៤ លះបង់រថទី ៣ ហើយឡើងជិះរថទី ៤ មកដោយរថទី ៤ ក៏បានដល់រថទី ៥ លះបង់រថទី ៤ ហើយឡើងជិះរថទី ៥ មកដោយរថទី ៥ ក៏បានដល់រថទី ៦ លះបង់រថទី ៥ ឡើងជិះរថទី ៦ មកដោយរថទី ៦ ក៏បានដល់រថទី ៧ លះបង់រថទី ៦ ឡើងជិះរថទី ៧ មកដោយរថទី ៧ ទើបបានដល់មកក្រុងសាកេត ត្រង់ទ្វារខាងក្នុងព្រះរាជ-វាំងនេះ ម្នាលអាវុសោ ព្រះបាទបសេនទិកោសល កាលបើដោះស្រាយយ៉ាងនេះ ទើបឈ្មោះថាដោះស្រាយដោយប្រពៃ មានឧបមាដូចម្ដេចមិញ ម្នាលអាវុសោ ឯសីលវិសុទ្ធិ មានប្រយោជន៍ត្រឹមតែចិត្តវិសុទ្ធិ ចិត្តវិសុទ្ធិ មានប្រយោជន៍ត្រឹមតែទិដ្ឋិវិសុទ្ធិ ទិដ្ឋិវិសុទ្ធិមានប្រយោជន៍ត្រឹមតែ

កង្ខាវិតរណវិសុទ្ធត្ថា កង្ខាវិតរណវិសុទ្ធិ យាវទេវ មគ្គាមគ្គញាណទស្សនវិសុទ្ធត្ថា មគ្គាមគ្គញាណទស្សនវិសុទ្ធិ យាវទេវ បដិបទាញាណទស្សនវិសុទ្ធត្ថា បដិបទាញាណទស្សនវិសុទ្ធិ យាវទេវ ញាណទស្សនវិសុទ្ធត្ថា ញាណទស្សនវិសុទ្ធិ យាវទេវ អនុបាទាបរិនិព្វានត្ថា អនុបាទាបរិនិព្វានត្ថំ ខោ អាវុសោ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។

(៣៧) ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ បុណ្ណំ មន្តាណីបុត្តំ ឯតទវោច កោ នាមោ អាយស្មា កថញ្ច បនាយស្មន្តំ សព្រហ្មចារី ជានន្តីតិ ។ បុណ្ណោតិ ខោ មេ អាវុសោ នាមំ មន្តាណីបុត្តោតិ ច បន មំ សព្រហ្មចារី ជានន្តីតិ ។ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យថាតំ សុតវតា សាវកេន សម្មទេវ សត្ថុ សាសនំ អាជានន្តេន ឯវមេវំ អាយស្មតា បុណ្ណេន មន្តាណីបុត្តេន គម្ភីរា គម្ភីរា បញ្ហា(១) អនុមស្ស អនុមស្ស ព្យាកតា

១ ម. ម. បញ្ហា ។



កង្ខាវិតរណវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មានប្រយោជន៍ត្រឹមតែមគ្គាមគ្គញាណទស្សនវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ មានប្រយោជន៍ត្រឹមតែបដិបទាញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ មានប្រយោជន៍ត្រឹមតែញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ មានប្រយោជន៍ត្រឹមតែអនុបាទាបរិនិព្វាន ម្នាលអាវុសោ ព្រហ្មចរិយធម៌ ដែលខ្ញុំប្រព្រឹត្តក្នុងសម្នាក់ព្រះមានព្រះភាគ (នេះ) ដើម្បីអនុបាទាបរិនិព្វាន តែម្យ៉ាងប៉ុណ្ណោះ សេចក្ដីនេះ ក៏មានឧបមេយ្យដូច្នេះឯង ។

(៣៧) កាលបើបុណ្ណមន្តាណីបុត្ត មានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្ត មានអាយុ បានសួរបុណ្ណមន្តាណីបុត្ត មានអាយុយ៉ាងនេះថា លោកមានអាយុឈ្មោះអ្វី ពួកសព្រហ្មចារី ស្គាល់ឈ្មោះលោកមានអាយុថាដូចម្ដេច ។ ព្រះបុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ ខ្ញុំឈ្មោះបុណ្ណៈ តែពួកសព្រហ្មចារីស្គាល់ឈ្មោះខ្ញុំថា មន្តាណីបុត្ត ។ ព្រះសារីបុត្ត មានថេរវាទតបវិញថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ត្រង់ការណ៍ដែលសាវ័ក ជាអ្នកចេះដឹង យល់នូវពាក្យប្រៀនប្រដៅ របស់ព្រះសាស្ដាដោយប្រពៃ ដូចជាព្រះបុណ្ណមន្តាណីបុត្ត មានអាយុ ពិចារណារឿយៗ (នូវកថាវត្ថុ តាំង១០) ហើយដោះស្រាយប្រស្នា ដ៏ជ្រាលជ្រៅៗ យ៉ាងនោះ

លាភា សព្រហ្មចារីនំ សុលទ្ធំ(១) សព្រហ្មចារីនំ យេ អា-
យស្មន្តំ បុណ្ណំ មន្តាណីបុត្តំ លភន្តិ ទស្សនាយ លភន្តិ
បយិរុបាសនាយ ចេលណ្ឌុកេន(២) ចេបិ សព្រហ្មចារី
អាយស្មន្តំ មន្តាណីបុត្តំ មុទ្ធនា បរិហរន្តា លភេយ្យុំ
ទស្សនាយ លភេយ្យុំ បយិរុបាសនាយ តេសម្បិ
លាភា តេសម្បិ សុលទ្ធំ អម្ហាកម្បិ លាភា អម្ហាកម្បិ
សុលទ្ធំ យេ មយំ អាយស្មន្តំ បុណ្ណំ មន្តាណីបុត្តំ
លភាម ទស្សនាយ លភាម បយិរុបាសនាយាតិ ។

(៣៨) ឯវំ វុត្តេ អាយស្មា បុណ្ណោ មន្តាណីបុត្តោ
អាយស្មន្តំ សារីបុត្តំ ឯតទវោច កោ នាមោ អា-
យស្មា កថញ្ច បនាយស្មន្តំ សព្រហ្មចារី ជា-
នន្តីតិ ។ ឧបតិស្សោតិ ខោ មេ អាវុសោ នាមំ

១ ឱ. ម. សុលទ្ធលាភា ។ ២ ឱ. ម. ចេលណ្ឌកេន ។



ឈ្មោះថាជាលាភ របស់ពួកសព្រហ្មចារី ទាំងជាតិជាមនុស្សក៏ឈ្មោះថា
ពួកសព្រហ្មចារីបានល្អហើយ ត្រង់ដែលពួកសព្រហ្មចារីបុគ្គល បាន
ឃើញបានចូលទៅអង្គុយជិត នូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ទោះ
បីពួកសព្រហ្មចារី ថែរក្សាដោយធ្វើកន្ទេលសំពត់លើក្បាល ហើយឲ្យ
ព្រះបុណ្ណមន្តាណីបុត្តមានអាយុ អង្គុយលើនោះ គប្បីបានឃើញ បាន
ចូលទៅអង្គុយជិត នូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ឈ្មោះថាជាលាភ
របស់ពួកសព្រហ្មចារីទាំងនោះផង ជាតិជាមនុស្សក៏ឈ្មោះថាពួកសព្រហ្ម-
ចារីទាំងនោះ បានល្អហើយផង ឈ្មោះថាជាលាភ របស់យើងផង ជាតិ
ជាមនុស្ស ក៏ឈ្មោះថាយើងបានដោយល្អផង ត្រង់ដែលពួកយើងបាន
ឃើញ បានចូលមកអង្គុយជិត នូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ។

(៣៨) កាលបើព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះបុណ្ណមន្តា-
ណីបុត្តមានអាយុ បានសួរព្រះសារីបុត្តមានអាយុយ៉ាងនេះថា ចុះលោក
មានអាយុ ឈ្មោះអ្វី ពួកសព្រហ្មចារី ស្គាល់ឈ្មោះលោកមានអាយុ
ថាដូចម្តេច ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំឈ្មោះឧបតិស្ស:

សារីបុត្តោតិ ច បន មំ សព្រហ្មចារី ជានន្តីតិ ។ សត្ថុកប្បេន វត កិរ ភោ សាវកេន សទ្ធិំ មន្តយមានា ន ជានិម្ហ អាយស្មា សារីបុត្តោតិ សចេ ហិ មយំ ជានេយ្យាម អាយស្មា សារីបុត្តោតិ ឯត្តកម្បិ នោ នប្បដិភាសេយ្យ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យថាតំ សុតវតា សាវកេន សម្មទេវ សត្ថុ សាសនំ អាជានន្តេន ឯវមេវំ អាយស្មតា សារីបុត្តេន គម្ភីរា គម្ភីរា បញ្ហា អនុមស្ស អនុមស្ស បុច្ឆិតា លាភា សព្រហ្មចារីនំ សុលទ្ធំ សព្រហ្មចារីនំ យេ អាយស្មន្តំ សារីបុត្តំ លភន្តិ ទស្សនាយ លភន្តិ បយិរុបាសនាយ ចេលណ្ឌុកេន ចេបិ សព្រហ្មចារី អាយស្មន្តំ សារីបុត្តំ មុទ្ធនា បរិហរន្តា



តែពួកសព្រហ្មចារី ស្គាល់ឈ្មោះខ្ញុំថា សារីបុត្ត ។ ព្រះបុណ្ណមន្តានីបុត្ត មានថេរដីកាថា ឲុត្តាហើយ យើងបានប្រឹក្សាជាមួយនឹងសាវ័ក ដែលដូចស្មើនឹងព្រះសាស្តាដែរតើ តែអត់ដឹងថាលោកមានអាយុ ឈ្មោះសារីបុត្តសោះ ប្រសិនបើយើងដឹងថា លោកមានអាយុឈ្មោះសារីបុត្តពិតហើយ ពាក្យឆ្លើយនូវមានប្រមាណប៉ុណ្ណេះ ប្រហែលជាយើង ឆ្លើយមិនច្បាស់ណាស់ទេ ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ត្រង់ការណ៍ដែលសាវ័កជាអ្នកចេះដឹង យល់នូវពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាដោយប្រពៃ ដូចជាព្រះសារីបុត្តមានអាយុ បានពិចារណារឿយៗ ហើយសាកសួរប្រស្នា ដ៏ជ្រាលជ្រៅ ៗ យ៉ាងនេះ ឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារី ជាតិជាមនុស្សក៏ឈ្មោះថាពួកសព្រហ្មចារីបានល្អហើយ ត្រង់ដែលពួកសព្រហ្មចារីបានឃើញ បានចូលទៅអង្គុយជិត នូវព្រះសារីបុត្តមានអាយុ ទោះបីពួកសព្រហ្មចារី ថែរក្សាដោយធ្វើរន្ទោលសំពត់លើក្បាល ហើយឲ្យព្រះសារីបុត្តមានអាយុ អង្គុយលើនោះ

លភេយ្យំ ទស្សនាយ លភេយ្យំ បយិរុបាសនាយ តេសម្បិ លាភា តេសម្បិ សុលទ្ធំ អម្ហាកម្បិ លាភា អម្ហាកម្បិ សុលទ្ធំ យេ មយំ អាយស្មន្តំ សារីបុត្តំ លភាម ទស្សនាយ លភាម បយិរុបាសនាយាតិ ។ ឥតិហ តេ ឧភោបិ មហានាគា អញ្ញមញ្ញស្ស សុភាសិតំ សមនុមោទិំសូតិ ។

រថវិនីតសុត្តំ ចតុត្ថំ និដ្ឋិតំ ។





គប្បីបានឃើញ បានចូលទៅអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារីទាំងនោះផង ជាតិជាមនុស្សក៏ឈ្មោះថាពួកសព្រហ្មចារីទាំងនោះបានល្អហើយផង ឈ្មោះថាជាលាភរបស់យើងផង ជាតិជាមនុស្ស ក៏ឈ្មោះថាយើងបានល្អហើយផង ត្រង់ដែលយើងបានឃើញ បានចូលមកអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ។ ព្រះមហានាគទាំងពីរអង្គនោះ បានអនុមោទនាត្រេកអរនឹងភាសិតនៃគ្នានឹងគ្នា ដូចបានរៀបរាប់មកនេះឯង ។

ចប់ រថវិនីតសូត្រ ទី ៤ ។

## បញ្ចមំ និវាបសុត្តំ

(៣៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ន ភិក្ខវេ នេវាបិកោ និវាបំ និវបតិ មិគជាតានំ ឥមំ មេ និវាបំ និវុត្តំ មិគជាតា បរិភុញ្ជន្តា ទីឃាយុកា វណ្ណវន្តោ ចិរំ ទីឃមទ្ធានំ យាបេន្តូតិ ។ ឯវញ្ច ខោ ភិក្ខវេ នេវាបិកោ និវាបំ និវបតិ មិគជាតានំ ឥមំ មេ និវាបំ និវុត្តំ មិគជាតា អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជិស្សន្តិ អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជមានា មទំ អាបជ្ជិស្សន្តិ មត្តា សមានា បមាទំ អាបជ្ជិស្សន្តិ បមត្តា សមានា យថាកាមករណីយា ភវិស្សន្តិ ឥមស្មឹ និវាបេតិ ។

## និវាបសូត្រ ទី ៥

(៣៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ នេវាបិកជន (ជនអ្នកដាំដំណាំ) មិនមែនដាំដំណាំជាចំណីដើម្បីពួកម្រឹគ ដោយគិតថា ពួកម្រឹគចូរទំពាស៊ីនូវដំណាំដែលអាត្មាអញដាំហើយនេះ ជាសត្វមានអាយុវែង មានសម្បុរល្អ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានយូរអង្វែងចុះ ដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេវាបិកជន ដាំនូវដំណាំដើម្បីពួកម្រឹគ ដោយគិតយ៉ាងនេះវិញថា ពួកម្រឹគនឹងចូលមកលុកលុយដំណាំដែលអាត្មាអញដាំហើយនេះ ក៏មុខជានឹងភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះចូលមកលុកលុយ ភ្លេចខ្លួន ស៊ីនូវភោជនទាំងឡាយហើយ នឹងដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ នឹងដល់នូវសេចក្តីប្រមាទ លុះបានសេចក្តីប្រមាទហើយ ជាសត្វគួរអាត្មាអញនឹងធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំនេះ ។

(៤០) តត្រ ភិក្ខវេ បឋមា មិគជាតា អមុំ និវាបំ និវុត្តំ នេវាបិកស្ស អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជឹសុ តេ តត្ថ អនុបខជ្ជ មុច្ឆិតា ភុញ្ជមានា មទំ អាបជ្ជឹសុ មត្តា សមានា បមាទំ អាបជ្ជឹសុ បមត្តា សមានា យថាកាមករណីយា អហេសុំ នេវាបិកស្ស អមុស្មឹ និវាបេ ឯវញ្ហិ តេ ភិក្ខវេ បឋមា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា ។

(៤១) តត្រ ភិក្ខវេ ទុតិយា មិគជាតា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា មិគជាតា អមុំ និវាបំ និវុត្តំ នេវាបិកស្ស អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជឹសុ តេ តត្ថ អនុបខជ្ជ មុច្ឆិតា ភុញ្ជមានា មទំ អាបជ្ជឹសុ មត្តា សមានា បមាទំ អាបជ្ជឹសុ បមត្តា សមានា យថាកាមករណីយា អហេសុំ នេវាបិកស្ស អមុស្មឹ និវាបេ ឯវញ្ហិ តេ បឋមា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា យន្នូន មយំ



(៤០) ម្នាលភិក្ខុទាំងឡាយ បណ្ដាសត្វម្រឹគទាំងនោះ ពួកសត្វម្រឹគទី ១ ចូលទៅលុកលុយដំណាំ ដែលនេវាបិកជន ដាំឯណោះហើយ ក៏ក្តួចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះចូលទៅលុកលុយក្តួចខ្លួនគន់ដំណាំនោះហើយស៊ី ក៏ដល់នូវសេចក្ដីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្ដីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជន នឹងធ្វើតាមសេចក្ដីប្រាថ្នាបាន ព្រោះដំណាំឯណោះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ ទាំងនោះ ទើបមិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនទេ ។

(៤១) ម្នាលភិក្ខុទាំងឡាយ បណ្ដាម្រឹគទាំងនោះ ពួកម្រឹគទី ២ គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ចូលទៅលុកលុយដំណាំដែលនេវាបិកជន ដាំឯណោះហើយ ក៏ក្តួចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះ ចូលទៅលុកលុយក្តួចខ្លួនគន់ដំណាំនោះ ហើយស៊ីនូវភោជនទាំងឡាយ ហើយដល់នូវសេចក្ដីស្រវឹង លុះស្រវឹងហើយក៏ដល់នូវសេចក្ដីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជននឹងធ្វើតាមសេចក្ដីប្រាថ្នាបាន ព្រោះដំណាំឯណោះ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ នោះនឹងមិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនទេ បើដូច្នោះគួរតែយើងទាំងឡាយ

សព្វសោ និវាបភោជនា បដិវិរមេយ្យាម ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា(១) វិហរេយ្យាមាតិ ។ តេ សព្វសោ និវាបភោជនា បដិវិរមឹសុ ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរឹសុ ។ តេសំ គិម្ហានំ បច្ឆិមេ មាសេ តិណោទកសង្ខយេ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ ។ តេសំ អធិមត្តកសិមានំ(២) បត្តកាយានំ ពលវីរិយំ បរិហាយិ ពលវីរិយេ បរិហីនេ តមេវ និវាបំ និវុត្តំ នេវាបិកស្ស បច្ចាគមឹសុ ។ តេ តត្ថ អនុបក្ខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជឹសុ ។ តេ តត្ថ អនុបក្ខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជមានា មទំ អាបជ្ជឹសុ មត្តា សមានា បមាទំ អាបជ្ជឹសុ បមត្តា សមានា យថាកាមករណីយា អហេសុំ នេវាបិកស្ស អមុស្មឹ និវាបេ ឯវញ្ហិ តេ ភិក្ខវេ ទុតិយាបិ មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា ។

១ ម. អជ្ឈោគាហិត្វា ។ ២ អធិមត្តកសិមានប្បត្តិ ។



វៀរកុំស៊ីដំណាំទាំងអស់ ទីទៃវៀរចាកការស៊ីដោយសេចក្ដីភិតភ័យហើយ គួរចូលទៅកាន់ព្រៃជ្រៅ នៅតាមសប្បាយវិញ លុះពួកម្រឹគទាំងនោះគិតដូច្នោះ ហើយក៏នាំគ្នាវៀរចាកនិវាបភោជន (ដំណាំជានុយ) ទាំងអស់ វៀរចាកការស៊ីដោយសេចក្ដីភិតភ័យ ក៏ចូលទៅកាន់ព្រៃជ្រៅហើយនៅ ។ លុះដល់ខែជាទីបំផុតនៃគិម្ហរដូវ មានស្មៅនិងទឹកអស់ហើយ កាយរបស់ពួកម្រឹគទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះម្រឹគទាំងនោះមានកាយដល់នូវភាពស្គាំងស្គមហើយ កម្លាំងកាយនិងសេចក្ដីព្យាយាមក៏សាបសូន្យទៅ កាលបើកម្លាំងកាយនិងសេចក្ដីព្យាយាមសាបសូន្យហើយ ពួកម្រឹគក៏នាំគ្នាត្រឡប់មករកដំណាំ ដែលនេវាបិកដាំនោះវិញ ទើបពួកម្រឹគទាំងនោះ ចូលទៅលុកលុយក្នុងដំណាំនោះ ហើយក្ដូចខ្ទួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះ ចូលទៅលុកលុយក្នុងដំណាំនោះ ហើយក្ដូចខ្ទួនស៊ីនូវភោជនទាំងឡាយ ក៏ដល់នូវសេចក្ដីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្ដីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជនធ្វើតាមសេចក្ដីប្រាថ្នាបាន ព្រោះដំណាំឯណោះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ នោះ និងមិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនឡើយ ។

(៤២) តត្រ ភិក្ខវេ តតិយា មិគជាតា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា មិគជាតា អមុំ និវាបំ និវុត្តំ នេវាបិកស្ស ។ បេ ។ ឯវញ្ហិ តេ បឋមា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា យេបិ តេ ទុតិយា មិគជាតា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា មិគជាតា អមុំ និវាបំ និវុត្តំ នេវាបិកស្ស ។ បេ ។ ឯវញ្ហិ តេ បឋមា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា យន្នូន មយំ សព្វសោ និវាបភោជនា បដិវិរមេយ្យាម ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរេយ្យាមាតិ តេ សព្វសោ និវាបភោជនា បដិវិរមឹសុ ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរឹសុ តេសំ គិម្ហានំ បច្ឆិមេ មាសេ តិណោទកសង្ខយេ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ តេសំ អធិមត្តកសិមានំ បត្តកាយានំ ពលវីរិយំ បរិហាយិ ពលវីរិយេ បរិហីនេ





(៤២) ម្នាលភិក្ខុទាំងឡាយ បណ្តាម្រឹគទាំងនោះ ពួកម្រឹគទី ៣ គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា (ចូលទៅលុកលុយ) នូវចំណី ដែលនេសាទបិទដាក់ឯណោះ ។ បេ ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ នោះ មិនរួចអំពីឫទ្ធានុភាពរបស់នេសាទបិទដាក់ទៅហើយ ឯពួកម្រឹគទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា (ចូលទៅលុកលុយ) នូវចំណី ដែលនេសាទបិទដាក់ឯណោះ ។ បេ ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ នោះ ក៏មិនរួចអំពីឫទ្ធានុភាព របស់នេសាទបិទដាក់ទៅហើយ បើដូច្នោះគួរតែយើងទាំងឡាយ វៀរចាកនិវាបភោជនទាំងអស់ វៀរចាកការបរិភោគ ដោយសេចក្តីភ័យ ហើយចូលទៅកាន់ព្រៃជ្រៅ នៅតាមសប្បាយ ពួកម្រឹគនោះគិតដូច្នោះហើយ ក៏វៀរចាកនិវាបភោជនទាំងអស់ វៀរចាកការបរិភោគ ដោយសេចក្តីភ័យ ហើយចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ លុះដល់ខែជាទីបំផុតនៃគិម្ហរដូវដែលមានស្មៅនិងទឹកអស់ហើយ កាយរបស់ពួកម្រឹគទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះពួកម្រឹគទាំងនោះ មានកាយដល់នូវភាពស្គាំងស្គមហើយ កម្លាំងកាយ និងកម្លាំងព្យាយាម ក៏សាបសូន្យទៅ កាលបើកម្លាំងកាយ និងសេចក្តីព្យាយាមសាបសូន្យហើយ

តមេវ និវាបំ និវុត្តំ នេវាបិកស្ស បច្ចាគមឹសុ តេ តត្រ(១) អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជឹសុ តេ តត្រ(២) អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជមានា មទំ អាបជ្ជឹសុ មត្តា សមានា បមាទំ អាបជ្ជឹសុ បមត្តា សមានា យថាកាមករណីយា អហេសុំ នេវាបិកស្ស អមុស្មឹ និវាបេ ឯវញ្ហិ តេ ទុតិយាបិ មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា យន្នូន មយំ អមុំ និវាបំ និវុត្តំ នេវាបិកស្ស ឧបនិស្សាយ អាសយំ កប្បេយ្យាម តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ នេវាបិកស្ស អននុបខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជិស្សាម អននុបខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជិស្សាម អមត្តា សមានា ន បមាទំ អាបជ្ជិស្សាម អប្បមត្តា សមានា ន យថាកាមករណីយា ភវិស្សាម នេវាបិកស្ស អមុស្មឹ និវាបេតិ ។

១- ២- ឱ. ម. តត្ថ ។





ពួកម្រឹគទាំងនោះ ក៏ត្រឡប់មកកាន់ដំណាំ ដែលនាយនេវាបិកដាក់ហើយនោះវិញ ពួកម្រឹគទាំងនោះ ក៏ចូលទៅលុកលុយកន្លែងដំណាំនោះភ្លេចខ្លួនស៊ីភោជនទាំងឡាយ លុះម្រឹគទាំងនោះចូលទៅលុកលុយកន្លែងដំណាំនោះភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ ក៏ដល់នូវសេចក្ដីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្ដីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជនធ្វើតាមសេចក្ដីប្រាថ្នាបាន ព្រោះដំណាំឯណោះ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ នោះ ក៏មិនរួចអំពីឫទ្ធានុភាព របស់នេវាបិកជនទៅហើយ បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅអាស្រ័យដំណាំ ដែលនេវាបិកជនដាំឯណោះ ហើយសម្រេចទីនៅ (ឮដ៏ខាងក្រៅ) លុះសម្រេចទីនៅក្នុងទីនោះហើយ ពួកយើងនឹងមិនចូលទៅលុកលុយដំណាំ ដែលនេវាបិកជនគេដាំឯណោះ ភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះមិនចូលទៅលុកលុយ មិនភ្លេចខ្លួន ត្រាច់តែស៊ីនូវភោជនទាំងឡាយ នឹងមិនដល់នូវសេចក្ដីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់នូវសេចក្ដីប្រមាទ លុះមិនប្រមាទហើយ ជាសត្វដែលនេវាបិកជនធ្វើតាមសេចក្ដីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះ ។

តេ អមុំ និវាបំ និវុត្តំ នេវាបិកស្ស ឧបនិស្សាយ អាសយំ កប្បយឹសុ តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ នេវាបិកស្ស អននុប្បខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជឹសុ តេ តត្រ(១) អននុប្បខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជឹសុ អមត្តា សមានា ន បមាទំ អាបជ្ជឹសុ អប្បមត្តា សមានា ន យថាកាមករណីយា អហេសុំ នេវាបិកស្ស អមុស្មឹ និវាបេ ។ តត្រ ភិក្ខវេ នេវាបិកស្ស ច នេវាបិកបរិសាយ ច ឯតទហោសិ អបិស្សុ(២) នាមិមេ តតិយា មិគជាតា កេដុភិនោ ឥទ្ធិមន្តស្សុ នាមិមេ តតិយា មិគជាតា បរជនា ឥមញ្ច នាម និវាបំ និវុត្តំ បរិភុញ្ជន្តិ ន ច នេសំ ជានាម អាគតឹ វា គតឹ វា យន្នូន មយំ ឥមំ និវាបំ និវុត្តំ មហតីហិ ទណ្ឌវាគុរាហិ(៣) សមន្តា សប្បទេសំ អនុបរិវារេយ្យាម អប្បេវ នាម តតិយានំ មិគជាតានំ អាសយំ បស្សេយ្យាម យត្ថ(៤) គាហំ គច្ឆេយ្យុន្តិ ។

---

១ ឱ. ម តត្ថ ។ ២ ឱ. សឋស្សុ ។ ៣ ឱ. ម. ទណ្ឌវាករាហិ ។ ៤ ឱ. ម. យត្ថ តេ ។



ពួកម្រឹគទី ៣ នោះ ក៏ចូលទៅអាស្រ័យនិវាបៈ ដែលនាយនេវាបិកដាក់ទុកនៅទីនោះ ហើយសម្រេចទីនៅ (ក្នុងទីក្រោល) លុះសម្រេចទីនៅក្នុងទីនោះហើយ ក៏មិនចូលទៅលុកលុយចំណីដែលនាយនេវាបិកដាក់ឲ្យនោះ មិនភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះ មិនចូលទៅលុកលុយភ្លេចខ្លួន ក្នុងចំណីនោះ គ្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាសត្វគួរនេវាបិកធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះចំណី ឯណោះទេ ។ ម្នាលភិក្ខុទាំងឡាយ គ្រាសម័យនោះ នេវាបិកផង ទាំងបរិស័ទរបស់នេវាបិកផង មានសេចក្តីត្រិះរិះដូច្នេះថា អើ ពួកម្រឹគទី ៣ ទាំងនេះជាសត្វមានកលមាយា ដូចជាមានឫទ្ធិ ពួកម្រឹគទី ៣ នេះ ជាសត្វដទៃ (អំពីពួកម្រឹគទី ១ ទី ២) មកស៊ីចំណីដែលគេដាំហើយនេះឯង យើងទាំងឡាយមិនដឹងដំណើរមកនិងដំណើរទៅរបស់វាទាំងនោះ បើដូច្នោះមានតែយើងទាំងឡាយធ្វើរបងព័ទ្ធចំណីដែលយើងទាំងឡាយដាំហើយនេះ ព្រមទាំងប្រទេសជុំវិញ ដោយកំណាត់ឈើធំបង្កាត់ទាំងឡាយធំ ៗ គង់យើងទាំងឡាយនឹងឃើញនូវទីអាស្រ័យរបស់ពួកម្រឹគទី ៣ ទីដែលចាប់ម្រឹគទាំងនោះ ត្រង់កន្លែងដែលវានៅឲ្យបាន ។

តេ អមុំ និវាបំ និវុត្តំ មហតិយា ទណ្ឌវាគុរាយ សមន្តា សប្បទេសំ អនុបរិវារេសុំ ។ អទ្ទសាសុំ(១) ខោ ភិក្ខវេ នេវាបិកោ ច នេវាបិកបរិសា ច តតិយានំ មិគជាតានំ អាសយំ យត្ថ តេ គាហំ អគមំសុ ។ ឯវញ្ហិ តេ ភិក្ខវេ តតិយាបិ មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា ។

(៤៣) តត្រ ភិក្ខវេ ចតុត្ថា មិគជាតា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា មិគជាតា ។បេ។ ឯវញ្ហិ តេ បឋមា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា យេបិ តេ ទុតិយា មិគជាតា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា មិគជាតា ។បេ។ ឯវញ្ហិ តេ បឋមា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា យន្នូន មយំ ។បេ។ ឯវញ្ហិ តេ ទុតិយា មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា

១ ម. អទ្ទសំសុ ។





ជនទាំងឡាយនោះ ទាំងគ្នាធ្វើរបងព័ទ្ធជុំវិញ ដែលក្រឡូងធំហើយវែងណាស់ ព្រមទាំងប្រទេសជុំវិញ ដោយកំណាត់ឈើនិងបង្គោលទាំងឡាយធំ ៗ ម្នាលភិក្ខុទាំងឡាយ នេវាបិកជនក្តី បរិស័ទរបស់នេវាបិកជនក្តី បាន ឃើញទីនៅរបស់ពួកម្រឹគទី ៣ នោះហើយ ក៏ចាប់ពួកម្រឹគទាំងនោះ ត្រង់កន្លែងដែលវាទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ៣ នោះ មិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនឡើយ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកម្រឹគទាំងនោះ ម្រឹគទី ៤ គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះ មិនរួចអំពីឫទ្ធានុភាព របស់នេវាបិកជនទៅហើយឯពួកម្រឹគទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះមិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះគួរតែយើងទាំងឡាយ ។បេ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ នោះ មិនរួចអំពីឫទ្ធានុភាព របស់នេវាបិកជនទៅហើយ

យេបិ តេ តតិយា មិគជាតា ឯវំ សមចិន្តេសុំ យេ
ខោ តេ បឋមា មិគជាតា ។ បេ ។ ឯវញ្ហិ តេ បឋមា
មិគជាតា ន បរិមុច្ចិំសុ នេវាបិកស្ស ឥទ្ធានុភាវា យេបិ
តេ ទុតិយា មិគជាតា ឯវំ សមចិន្តេសុំ យេ ខោ តេ
បឋមា មិគជាតា ។ បេ ។ ឯវញ្ហិ តេ បឋមា
មិគជាតា ន បរិមុច្ចិំសុ នេវាបិកស្ស ឥទ្ធានុភាវា
យន្នូន មយំ ។ បេ ។ ឯវញ្ហិ តេ ទុតិយា
មិគជាតា ន បរិមុច្ចិំសុ នេវាបិកស្ស ឥទ្ធានុភាវា
យន្នូន មយំ អមុំ និវាបំ និវុត្តំ នេវាបិកស្ស ឧប-
និស្សាយ អាសយំ កប្បេយ្យាម តត្រាសយំ កប្បេត្វា
អមុំ និវាបំ និវុត្តំ នេវាបិកស្ស អននុបខជ្ជ អមុច្ឆិតា
ភោជនានិ ភុញ្ជិស្សាម អននុបខជ្ជ អមុច្ឆិតា ភោជ-
នានិ ភុញ្ជមានា ន មទំ អាបជ្ជិស្សាម អមត្តា សមា-
នា ន បមាទំ អាបជ្ជិស្សាម អប្បមត្តា សមានា ន
យថាកាមករណីយា ភវិស្សាម នេវាបិកស្ស អមុស្មឹ
និវាបេតិ តេ អមុំ និវាបំ និវុត្តំ នេវាបិកស្ស ឧប-
និស្សាយ អាសយំ កប្បេសុំ តត្រាសយំ កប្បេត្វា





ឯពួកម្រឹគទី ៣ ណា គិតព្រមគ្នា យ៉ាងនេះថា ពួកម្រឹគទី ១ ណា
។ បេ ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះ មិនរួចអំពីឫទ្ធានុភាព
របស់នេវាបិកជនទៅហើយ ឯពួកម្រឹគទី ២ ណា គិតព្រមគ្នាយ៉ាងនេះ
ថា ពួកម្រឹគទី ១ ណា ។ បេ ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១
នោះ មិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះគួរតែ
យើងទាំងឡាយ ។ បេ ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ ទាំងនោះ
មិនរួចអំពីឫទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះមានតែយើង
ទាំងឡាយ គប្បីចូលទៅអាស្រ័យចំណី ដែលនេវាបិកជនដាំឯណោះ
ហើយសម្រេចទីទៅ លុះសម្រេចទីទៅក្នុងទីនោះហើយ ពួកយើងនឹង
កុំចូលទៅលុកលុយចំណី ដែលនេវាបិកជនដាំឯណោះ កុំភ្លេចខ្លួន
ស៊ីនូវភោជនទាំងឡាយ លុះមិនចូលមកលុកលុយ មិនភ្លេចខ្លួន គ្រាន់
តែស៊ីនូវភោជនទាំងឡាយ ក៏នឹងមិនដល់នូវសេចក្ដីស្រវឹង លុះមិនស្រ-
វឹងហើយ នឹងមិនដល់នូវសេចក្ដីប្រមាទ លុះមិនប្រមាទហើយ នឹងជា
សត្វគួរនេវាបិកជន ធ្វើតាមសេចក្ដីប្រាថ្នាមិនបាន ព្រោះចំណីឯណោះ
ឡើយ ទើបពួកម្រឹគទី ៣ នោះ ចូលទៅអាស្រ័យចំណីដែលនេវាបិក-
ជនដាំឯណោះ ហើយសម្រេចទីទៅ លុះសម្រេចទីទៅក្នុងទីនោះហើយ

អមុំ និវាបំ និវុត្តំ នេវាបិកស្ស អននុបខជ្ជ អមុច្ឆិតា ភោជនំ ភុញ្ជឹសុ តេ តត្ថ អននុបខជ្ជ អមុច្ឆិតា ភោជនំ ភុញ្ជមានា ន មទំ អាបជ្ជឹសុ អមត្តា សមានា នប្បមាទំ អាបជ្ជឹសុ អប្បមត្តា សមានា ន យថាកាមករណីយា អហេសុំ នេវាបិកស្ស អមុស្មឹ និវាបេ ។ តត្រ នេវាបិកស្ស ច នេវាបិកបរិសាយ ច ឯតទហោសិ សឋស្សុនា មេ តតិយា មិគជាតា កេរាដិកា ឥទ្ធិមន្តស្សុនា មេ តតិយា មិគជាតា បរជនា ។ បេ ។ អន្វេសុំ ខោ នេវាបិកោ ច នេវាបិកបរិសា ច តតិយានំ មិគជាតានំ អាសយំ យត្ថ តេ គាហំ អគមំសុ ឯវញ្ហិ តេ តតិយាបិ មិគជាតា ន បរិមុច្ចឹសុ នេវាបិកស្ស ឥទ្ធានុភាវា ។ យន្នូន មយំ យត្ថ អគតិ នេវាបិកស្ស ច នេវាបិកបរិសាយ ច តត្រាសយំ កប្បេយ្យាម តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ នេវាបិកស្ស អននុបខជ្ជ អមុច្ឆិតា ភោជនំ ភុញ្ជមានា



ក៏មិនចូលទៅលុកលុយចំណី ដែលនេវាបិកដាក់ឯណោះ មិនភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជនទាំងឡាយ ពួកម្រឹគទី ៣ នោះ មិនចូលទៅលុកលុយក្នុងចំណីនោះ មិនភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាសត្វគួរនេវាបិកធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះចំណីឯណោះឡើយ ។ ក្នុងសម័យនោះ នេវាបិកនិងបរិស័ទរបស់នេវាបិក មានសេចក្តីត្រិះរិះដូច្នេះថា ពើក ពួកម្រឹគទី ៣ នេះ មានកលមាយាសាក្យហើយ ដូចជាសត្វមានឫទ្ធិ ពួកម្រឹគទី ៣ នេះជាសត្វដទៃ ក្រៅអំពីម្រឹគទី ១ និងម្រឹគទី ២ ។ បេ ។ លុះនេវាបិកនិងពួកបរិស័ទរបស់នេវាបិក បានឃើញទីនៅនៃពួកម្រឹគទី ៣ ហើយ ក៏ចូលទៅចាប់ម្រឹគទាំងនោះ ត្រង់ទីដែលវាទៅ កាលបើយ៉ាងនេះ ពួកម្រឹគទី ៣ នោះ មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកនោះទៅហើយ បើដូច្នោះទីត្រង់ណាដែលមិនមែនជាវិស័យ របស់នេវាបិកនិងនេវាបិកបរិស័ទ គួរយើងទាំងឡាយសម្រេចនូវទីនៅត្រង់កន្លែងនោះ លុះសម្រេចទីនៅត្រង់ទីនោះហើយ ក៏ចូលទៅលុកលុយចំណីដែលនេវាបិកដាក់ឯណោះ កុំភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជន

ន មទំ អាបជ្ជិស្សាម អមត្តា សមានា ន បមាទំ អា-
បជ្ជិស្សាម អប្បមត្តា សមានា ន យថាកាមករណី-
យា ភវិស្សាម នេវាបិកស្ស អមុស្មឹ និវាបេតិ ។ តេ
យត្ថ អគតិ នេវាបិកស្ស ច នេវាបិកបរិសាយ ច
តត្រាសយំ កប្បយឹសុ តត្រាសយំ កប្បេត្វា អមុំ
និវាបំ និវុត្តំ នេវាបិកស្ស អននុបខជ្ជ អមុច្ឆិតា
ភោជនានិ ភុញ្ជឹសុ តេ តត្ថ អននុបខជ្ជ អមុច្ឆិតា
ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជឹសុ អមត្តា
សមានា ន បមាទំ អាបជ្ជឹសុ អប្បមត្តា សមានា
ន យថាកាមករណីយា អហេសុំ នេវាបិកស្ស
អមុស្មឹ និវាបេ ។ តត្រ ភិក្ខវេ នេវាបិកស្ស ច
នេវាបិកបរិសាយ ច ឯតទហោសិ សឋាស្សុ នាមិមេ
ចតុត្ថា មិគជាតា កេដុភិនោ ឥទ្ធិមន្តស្សុ នាមិមេ
ចតុត្ថា មិគជាតា បរជនា ឥមញ្ច នាម និវាបំ
និវុត្តំ បរិភុញ្ជន្តិ ន ច នេសំ ជានាម អាគតឹ វា
គតឹ វា យន្នូន មយំ ឥមំ និវាបំ និវុត្តំ មហតីហិ
ទណ្ឌវាករាហិ សមន្តា សប្បទេសំ អនុបរិវារេយ្យាម



ទាំងឡាយ ទើងមិនដល់នូវសេចក្តីស្រើប លុះមិនស្រើបហើយ ទើងមិន
ដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ទើងជាសត្វគួរនេវាបិកជន
ធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំងណោះ ៗ ទើបពួកម្រឹគ
ទាំងនោះសម្រេចទីនៅ ត្រង់ទីដែលមិនមែនជាវិស័យ របស់នេវាបិកជន
និងនេវាបិកបរិស័ទនោះ លុះសម្រេចនូវទីអាស្រ័យក្នុងទីនោះហើយ ក៏
មិនចូលទៅលុកលុយដំណាំ ដែលនេវាបិកជនដាំងណោះ មិនភ្លេចខ្លួន
ត្រាន់តែស៊ីនូវភោជនទាំងឡាយ លុះម្រឹគទាំងនោះមិនចូលទៅលុកលុយ
មិនភ្លេចខ្លួនក្នុងដំណាំនោះហើយ ត្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏មិន
ដល់នូវសេចក្តីស្រើប លុះមិនស្រើបហើយ ក៏មិនដល់នូវសេចក្តីប្រមាទ
លុះមិនប្រមាទហើយ ជាសត្វគួរនេវាបិកជនធ្វើតាមសេចក្តីប្រាថ្នាមិនបាន
ព្រោះដំណាំងណោះ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ នេវា-
បិកជននិងនេវាបិកបរិស័ទមានសេចក្តីត្រិះរិះដូច្នេះថា ពួកម្រឹគ ទី ៤
នេះ មានកលមាយាសាក្យហើយ ដូចជាសត្វមានឫទ្ធិ ពួកម្រឹគ ទី ៤
នេះ ជាសត្វផ្សេងពីពួកម្រឹគ ទី ១ ទី ២ ទី ៣ នោះ តែងស៊ីនូវដំណាំ
ដែលយើងទាំងឡាយដាំហើយនេះ ឯយើងទាំងឡាយមិនដឹងនូវដំណើរ
មកនិងដំណើរទៅរបស់ពួកវា បើដូច្នោះមានតែយើងទាំងឡាយធ្វើរបងព័ទ្ធ
ដំណាំដែលយើងដាំហើយនេះ ព្រមទាំងប្រទេសជុំវិញ ដោយតំណាក់

អប្បេវ នាម ចតុត្ថានំ មិគជាតានំ អាសយំ បស្សេយ្យាម យត្ថ តេ គាហំ គច្ឆេយ្យុន្តិ តេ អមុំ និវាបំ និវុត្តំ មហតីហិ ទណ្ឌវាករាហិ សមន្តា សប្បទេសំ អនុបរិវារេសុំ ។ នេវ ខោ ភិក្ខវេ អទ្ទសំសុ នេវាបិកោ ច នេវាបិកបរិសា ច ចតុត្ថានំ មិគជាតានំ អាសយំ យត្ថ តេ គាហំ គច្ឆេយ្យុំ ។ អថ ខោ ភិក្ខវេ នេវាបិកស្ស ច នេវាបិកបរិសាយ ច ឯតទហោសិ សចេ ខោ មយំ ចតុត្ថេ មិគជាតេ ឃដ្ដេស្សាម តេ ឃដ្ដិតា អញ្ញេ ឃដ្ដេស្សន្តិ ឯវំ អយំ និវាបោ និវុត្តោ សព្វសោ មិគជាតេហិ បរិមុច្ចិស្សតិ យន្នូន មយំ ចតុត្ថេ មិគជាតេ អជ្ឈុបេក្ខេយ្យាមាតិ ។ អជ្ឈុបេក្ខិំសុ ខោ ភិក្ខវេ នេវាបិកោ ច នេវាបិកបរិសា ច ចតុត្ថេ មិគជាតេ ឯវញ្ហិ តេ ភិក្ខវេ ចតុត្ថា មិគជាតា បរិមុច្ចិំសុ នេវាបិកស្ស ឥទ្ធានុភាវា ។





ឈើនិងបន្លាក់តាំងឡាយធំ ៗ ដោយគិតថា ក្រែងពួកយើង គួរនឹងឃើញនូវទីនៅរបស់ពួកម្រឹគទី ៤ ពួកម្រឹគទាំងនោះ គប្បីចូលទៅកាន់ទីត្រូវចាប់បានហ្ន៎ (លុះគិតដូច្នេះហើយ) ជនទាំងឡាយនោះក៏ធ្វើរបងព័ទ្ធដំណាំដែលខ្លួនដាំឯណោះ ព្រមទាំងប្រទេសជុំវិញ ដោយកំណាត់ឈើនិងបន្លាក់តាំងឡាយធំ ៗ ។ ម្នាលភិក្ខុទាំងឡាយ នេវាបិកជនក្តី នេវាបិកបរិស័ទក្តី មិនបានឃើញទីអាស្រ័យរបស់ពួកម្រឹគទី ៤ ទេ ក៏នាំគ្នាទៅរកចាប់ម្រឹគទាំងនោះ ត្រង់កន្លែងដែលគេនៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ នេវាបិកជននិងនេវាបិកបរិស័ទ មានសេចក្តីត្រិះរិះដូច្នេះថា ប្រសិនបើ យើងទាំងឡាយ សម្លាប់នូវពួកម្រឹគទី ៤ ហើយ អ្នកទាំងឡាយដទៃមុខជានឹងសម្លាប់នូវម្រឹគដែលយើងសម្លាប់នោះដែរ កាលបើយ៉ាងនេះ ពួកម្រឹគមុខជានឹងបោះបង់ចោលនូវដំណាំដែលយើងទាំងឡាយដាំហើយនេះ ដោយប្រការទាំងពួង បើដូច្នោះមានតែយើងទាំងឡាយធ្វើព្រងើយកន្តើយនឹងពួកម្រឹគទី ៤ ។ ម្នាលភិក្ខុទាំងឡាយ នេវាបិកជនក្តី នេវាបិកបរិស័ទក្តី ក៏ធ្វើព្រងើយកន្តើយនឹងពួកម្រឹគទី ៤ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកម្រឹគទី ៤ នោះ រួចផុតពីឫទ្ធានុភាពរបស់នេវាបិកជនបាន ។

(៤៤) ឧបមា ខោ មេ អយំ ភិក្ខវេ កតា អត្ថស្ស វិញ្ញាបនាយ អយញ្ចេវេត្ថ អត្ថោ ។ និវាបោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ និវាបិកោតិ ខោ ភិក្ខវេ មារស្សេតំ បាបិមតោ អធិវចនំ ។ និវាបិកបរិសាតិ ខោ ភិក្ខវេ មារបរិសាយេតំ អធិវចនំ ។ មិគជាតាតិ ខោ ភិក្ខវេ សមណព្រាហ្មណានមេតំ អធិវចនំ ។

(៤៥) តត្រ ភិក្ខវេ បឋមា សមណព្រាហ្មណា អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជិំសុ តេ តត្ថ អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជមានា មទំ អាបជ្ជិំសុ មត្តា សមានា បមាទំ អាបជ្ជិំសុ បមត្តា សមានា យថាកាមករណីយា អហេសុំ មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេ ឯវញ្ហិ តេ ភិក្ខវេ





(៤៤) ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះឯង តថាគតធ្វើ ដើម្បីញ៉ាំងសេចក្តីឲ្យច្បាស់លាស់ ។ សេចក្តីក្នុងរឿងឧបមានុ៎ះ ដូចតទៅនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ចំណី នុ៎ះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា នេវាបិកជន (អ្នកដាក់ចំណី) នុ៎ះ ជាឈ្មោះនៃមារដែលមានចិត្តអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ពួកនេវាបិកបរិស័ទ នុ៎ះ ជាឈ្មោះរបស់បរិស័ទនៃមារ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ពួកម្រឹគ នុ៎ះ ជាឈ្មោះនៃសមណៈនិងព្រាហ្មណ៍ទាំងឡាយ ។

(៤៥) ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកទី ១ លុកលុយចំណី ដែលមារដាក់ហើយឯណោះ និងលោកាមិសៈ (អាមិសៈក្នុងលោក) ទាំងឡាយឯណោះ ភ្លេចខ្លួន បរិភោគភោជនទាំងឡាយ កាលពួកសមណព្រាហ្មណ៍ទាំងនោះ លុកលុយក្នុងចំណី និងអាមិសៈក្នុងលោកនោះហើយ ភ្លេចខ្លួនបរិភោគភោជនទាំងឡាយ ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះចំណីឯណោះផង ព្រោះលោកាមិសៈឯណោះផង ម្នាលភិក្ខុ

បឋមា សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា ។ សេយ្យថាបិ តេ ភិក្ខវេ បឋមា មិគជាតា ឯវមេវ អហំ ឥមេ បឋមេ សមណព្រាហ្មណេ វទាមិ ។

[២៦] តត្រ ភិក្ខវេ ទុតិយា សមណព្រាហ្មណា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា សមណព្រាហ្មណា អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជិំសុ តេ តត្ថ អនុបខជ្ជ មុច្ឆិតា ភោជនានិ ភុញ្ជមានា មទំ អាបជ្ជិំសុ មត្តា សមានា បមាទំ អាបជ្ជិំសុ បមត្តា សមានា យថាកាមករណីយា អហេសុំ មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេ ឯវញ្ហិ តេ បឋមា សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា យន្នូន មយំ សព្វសោ និវាបភោជនា លោកាមិសា បដិវិរមេយ្យាម ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរេយ្យាមាតិ តេ



ទាំងឡាយ កាលបើយ៉ាងនេះ សមណៈនិងព្រាហ្មណ៍ពួកទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ១ នោះ មានសេចក្ដីឧបមាយ៉ាងណា តថាគតពោលនូវសមណព្រាហ្មណ៍ទាំងឡាយទី ១ នេះ ថា មានឧបមេយ្យដូច្នោះដែរ ។

(២៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកទី ២ គិតព្រមគ្នាយ៉ាងនេះថា សមណៈនិងព្រាហ្មណ៍ពួកទី ១ ណា លុកលុយចំណីដែលមារដាំហើយឯណោះ និងលោកាមិសៈឯណោះ ភ្លេចខ្លួនបរិភោគភោជនទាំងឡាយ កាលសមណព្រាហ្មណ៍ទាំងនោះ លុកលុយក្នុងចំណី និងលោកាមិសៈនោះ ភ្លេចខ្លួនបរិភោគនូវភោជនទាំងឡាយ ហើយដល់នូវសេចក្ដីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្ដីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្ដីប្រាថ្នាបាន ព្រោះចំណីឯណោះផង ព្រោះលោកាមិសៈឯណោះផង កាលបើយ៉ាងនេះ សមណៈនិងព្រាហ្មណ៍ពួកទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទៅហើយ បើដូច្នោះមានតែយើងទាំងឡាយវៀរចាកនិវាបភោជននិងលោកាមិសៈចេញ ដោយប្រការទាំងពួង វៀរចាកការបរិភោគ ព្រោះសេចក្ដីខ្លាចចេញ ហើយចូលទៅកាន់ព្រៃជ្រៅនៅតាម

សព្វសោ និវាបភោជនា លោកាមិសា បដិវិរមឹសុ តេ សព្វសោ និវាបភោជនា លោកាមិសា បដិវិរតា(១) ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរឹសុ តេ តត្ថ សាកភក្ខាបិ អហេសុំ សាមាកភក្ខាបិ អហេសុំ និវារភក្ខាបិ អហេសុំ ទទ្ទុលភក្ខាបិ អហេសុំ ហដភក្ខាបិ អហេសុំ កណភក្ខាបិ អហេសុំ អាចាមភក្ខាបិ អហេសុំ បិញ្ញាកភក្ខាបិ អហេសុំ តិណភក្ខាបិ អហេសុំ គោមយភក្ខាបិ អហេសុំ វនមូលផលាហារា យាបេសុំ បវត្តផលភោជី តេសំ គិម្ហានំ បច្ឆិមេ មាសេ តិណោទកសង្ខយេ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ តេសំ អធិមត្តកសិមានំ បត្តកាយានំ ពលវីរិយំ បរិហាយិ ពលវីរិយេ បរិហីនេ ចេតោវិមុត្តិ បរិហាយិ ចេតោវិមុត្តិយា បរិហីនាយ តមេវ និវាបំ និវត្តំ មារស្ស បច្ចាគមឹសុ តានិ ច លោកាមិសានិ

១ ឱ. ម. តេ សព្វសោ និវាបភោជនា លោកាមិសា បដិវិរតាតិ ឥទំ បាឋំ ន ទិស្សតិ ។



សប្បាយ លុះសមណព្រាហ្មណ៍ទាំងនោះ គិតឃើញដូច្នេះហើយ ក៏វៀរចាកនិវាបភោជនគឺលោកាមិសៈ ដោយប្រការទាំងពួង ពួកសមណព្រាហ្មណ៍ទាំងនោះ បានវៀរចាកនិវាបភោជនគឺលោកាមិសៈដោយប្រការទាំងពួង ទាំងវៀរចាកបរិភោគ ព្រោះសេចក្តីខ្លាចហើយ ចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ ពួកសមណព្រាហ្មណ៍ទាំងនោះមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្រូយជាអាហារខ្លះ មានកម្ទេច (ចំនៀរស្បែក) ជាអាហារខ្លះ មានបន្លែសាកយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើនិងផ្លែឈើក្នុងព្រៃជាអាហារខ្លះ មានផ្លែឈើដែលជ្រុះឯងជាភោជនខ្លះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងដីព្រៃជ្រៅនោះ លុះដល់ខែជាទីបំផុតនៃគិម្ហរដូវ មានស្មៅនិងទឹកអស់ហើយ កាយរបស់សមណព្រាហ្មណ៍ទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះមានកាយដល់នូវភាពស្គាំងស្គមហើយ កម្លាំងនិងសេចក្តីព្យាយាម ក៏សាបសូន្យទៅ កាលបើកម្លាំងនិងសេចក្តីព្យាយាមសាបសូន្យហើយ ចេតោវិមុត្តិក៏សាបសូន្យទៅដែរ កាលបើចេតោវិមុត្តិសាបសូន្យហើយ ពួកសមណព្រាហ្មណ៍ទាំងនោះត្រឡប់មកកាន់ដំណាំ ដែលមារដាំហើយនោះវិញផង មកកាន់លោកាមិសៈទាំងឡាយ

តេ តត្ថ អនុបក្ខជ្ជ មុច្ឆិតា ភោជនំ ភុញ្ជឹសុ តេ តត្ថ អនុបក្ខជ្ជ មុច្ឆិតា ភោជនំ ភុញ្ជមានា មទំ អាបជ្ជឹសុ មត្តា សមានា បមាទំ អាបជ្ជឹសុ បមត្តា សមានា យថាកាមករណីយា អហេសុំ មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេ ឯវញ្ហិ តេ ភិក្ខវេ ទុតិយាបិ សមណព្រាហ្មណា ន បរិមុច្ចឹសុ មារស្ស ឥទ្ធានុភាវា ។ សេយ្យថាបិ តេ ភិក្ខវេ ទុតិយា មិគជាតា តថូបមេ អហំ ឥមេ ទុតិយេ សមណព្រាហ្មណេ វទាមិ ។

(២៧) តត្រ ភិក្ខវេ តតិយា សមណព្រាហ្មណា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា សមណ-ព្រាហ្មណា ។ បេ ។ ឯវញ្ហិ តេ បឋមា សមណ-ព្រាហ្មណា ន បរិមុច្ចឹសុ មារស្ស ឥទ្ធានុភាវា យេបិ តេ ទុតិយា សមណព្រាហ្មណា ឯវំ សម-ចិន្តេសុំ យេ ខោ តេ បឋមា សមណព្រាហ្មណា ។ បេ ។ ឯវញ្ហិ តេ បឋមា សមណព្រាហ្មណា



នោះផង ពួកសមណព្រាហ្មណ៍ទាំងនោះ បានលុកលុយចូលទៅកាន់និវាបនិងលោកាមិសៈនោះហើយ ស្រវឹងបរិភោគភោជនទាំងឡាយ កាលសមណព្រាហ្មណ៍ទាំងនោះ លុកលុយស្រវឹងចូលទៅកាន់និវាបលោកាមិសៈនោះ បរិភោគភោជន ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ក្នុងនិវាបឯណោះផង ក្នុងលោកាមិសៈឯណោះផង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ សមណព្រាហ្មណ៍ពួកទី ២ នោះ មិនរួចអំពីឫទ្ធានុភាពនៃមារទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ២ នោះ មានសេចក្តីឧបមាដូចម្តេចមិញ តថាគត ពោលនូវសមណព្រា-ហ្មណ៍ទាំងឡាយទី ២ នេះ ថា មានឧបមេយ្យដូច្នោះដែរ ។

(២៧) ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ទី ៣ គិតគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។ បេ ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឫទ្ធានុភាពរបស់មារទៅហើយ ទាំងពួកសមណព្រាហ្មណ៍ទី ២ ណា គិតព្រមគ្នា យ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។ បេ ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិន

ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា យន្នូន មយំ សព្វសោ និវាបភោជនា លោកាមិសា បដិវិរមេយ្យាម ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរេយ្យាមាតិ តេ សព្វសោ និវាបភោជនា លោកាមិសា បដិវិរមិំសុ ភយភោគា បដិវិរតា អរញ្ញាយតនានិ អជ្ឈោគាហេត្វា វិហរិំសុ តេ តត្ថ សាកភក្ខាបិ អហេសុំ ។ បេ ។ បវត្តផលភោជី តេសំ គិម្ហានំ បច្ឆិមេ មាសេ តិណោទកសង្ខយេ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ តេសំ អធិមត្តកសិមានំ បត្តកាយានំ ពលវីរិយំ បរិហាយិ ពលវីរិយេ បរិហីនេ ចេតោវិមុត្តិ បរិហាយិ ចេតោវិមុត្តិយា បរិហីនាយ តមេវ និវាបំ និវុត្តំ មារស្ស បច្ចាគមិំសុ



រួចអំពីឫទ្ធានុភាពរបស់មារទៅហើយ បើដូច្នេះ មានតែយើងទាំងឡាយ គប្បីវៀរចាកនិវាបភោជន និងលោកាមិសៈចេញ ដោយប្រការទាំងពួង ជាអ្នកវៀរចាកការបរិភោគ ព្រោះសេចក្តីខ្លាច ហើយចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ លុះសមណព្រាហ្មណ៍ទី ២ ទាំងនោះ គិតដូច្នេះហើយ ក៏វៀរចាកនិវាបភោជន និងលោកាមិសៈចេញ ដោយសព្វគ្រប់ វៀរចាកការបរិភោគ ព្រោះសេចក្តីខ្លាច ហើយចូលទៅកាន់ព្រៃជ្រៅ នៅតាមសប្បាយ ពួកសមណព្រាហ្មណ៍ ទាំងនោះ មានបន្លែស្រស់ជាភក្សាហារខ្លះ ។បេ។ មានផ្លែឈើដែលជ្រុះឯង ជាភោជនខ្លះ ក្នុងព្រៃនោះ លុះដល់ខែជាខាងចុងនៃគិម្ហរដូវ មានស្មៅនិងទឹកអស់ហើយ កាយរបស់សមណព្រាហ្មណ៍ទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះសមណព្រាហ្មណ៍ទាំងនោះ មានកាយដល់នូវភាពស្គាំងស្គមក្រៃពេកហើយ កម្លាំងនិងសេចក្តីព្យាយាមក៏សាបសូន្យទៅ កាលបើកម្លាំងនិងសេចក្តីព្យាយាមសាបសូន្យហើយ ចេតោវិមុត្តិក៏សាបសូន្យដែរ កាលបើចេតោវិមុត្តិសាបសូន្យហើយ ពួកសមណៈព្រាហ្មណ៍ទី ២ នោះ ក៏ត្រឡប់មកកាន់ចំណីដែលមារដាំហើយនោះផង

តានិ ច លោកាមិសានិ តេ តត្ថ អនុបខជ្ជ មុច្ឆិតា
ភោជនានិ ភុញ្ជិំសុ តេ តត្ថ អនុបខជ្ជ មុច្ឆិតា
ភោជនានិ ភុញ្ជមានា មទំ អាបជ្ជិំសុ មត្តា សមានា
បមាទំ អាបជ្ជិំសុ បមត្តា សមានា យថាកាមករ-
ណីយា អហេសុំ មារស្ស អមុស្មឹ និវាបេ អមុស្មឹ
ច លោកាមិសេ ឯវញ្ហិ តេ ទុតិយាបិ សមណ-
ព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា
យន្នូន មយំ អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច
លោកាមិសានិ ឧបនិស្សាយ អាសយំ កប្បេយ្យាម
តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ មារស្ស អមូនិ
ច លោកាមិសានិ អននុបខជ្ជ អមុច្ឆិតា ភោជនានិ
ភុញ្ជិស្សាម អននុបខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជ-
មានា ន មទំ អាបជ្ជិស្សាម អមត្តា សមានា
ន បមាទំ អាបជ្ជិស្សាម អប្បមត្តា សមានា



ក្រឡប់មកកាន់លោកាមិសៈទាំងឡាយនោះផង ពួកសមណព្រាហ្មណ៍ទាំងនោះ លុះលុយក្នុងចំណី និងលោកាមិសៈនោះ ភ្លេចខ្លួនបរិភោគនូវភោជនទាំងឡាយ កាលពួកសមណព្រាហ្មណ៍ទាំងនោះ លុះលុយក្នុងចំណីនោះ ភ្លេចខ្លួនបរិភោគនូវភោជនទាំងឡាយ ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះចំណីឯណោះផង ព្រោះលោកាមិសៈឯណោះផង កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ២ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយនៅអាស្រ័យនឹងចំណីដែលមារដាំហើយឯណោះផង អាស្រ័យនឹងលោកាមិសៈឯណោះផង ហើយគប្បីសម្រេចទីនៅអាស្រ័យ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ យើងកុំលុះលុយភ្លេចខ្លួននឹងចំណី ដែលមារដាំហើយនោះផង នឹងលោកាមិសៈឯណោះផង គ្រាន់តែបរិភោគភោជនទាំងឡាយ កាលបើយើងមិនលុះលុយ មិនភ្លេចខ្លួន គ្រាន់តែបរិភោគភោជន ក៏នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏នឹងមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ

ន យថាកាមករណីយា ភវិស្សាម មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេតិ ។ តេ អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ ឧបនិស្សាយ អាសយំ កប្បយឹសុ ។ តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ អននុបក្ខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជឹសុ អមត្តា សមានា ន បមាទំ អាបជ្ជឹសុ អប្បមត្តា សមានា ន យថាកាមករណីយា អហេសុំ មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេ ។ អបិច ខោ ឯវំទិដ្ឋិកា អហេសុំ សស្សតោ លោកោ ឥតិបិ អសស្សតោ លោកោ ឥតិបិ អន្តវា លោកោ ឥតិបិ អនន្តវា លោកោ ឥតិបិ តំ ជីវំ តំ សរីរំ ឥតិបិ អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិបិ ហោតិ តថាគតោ បរម្មរណា ឥតិបិ ន ហោតិ តថាគតោ



នឹងជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ។ លុះពួកសមណព្រាហ្មណ៍ ទី ៣ នោះ គិតដូច្នេះហើយ ក៏ចូលទៅអាស្រ័យដំណាំ ដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ ហើយសម្រេចទីនៅអាស្រ័យ ។ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ ក៏មិនបានលុកលុយ មិនបានភ្លេចខ្លួននឹងដំណាំ ដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ មិនភ្លេចខ្លួន គ្រាន់តែបរិភោគភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ។ មួយវិញទៀត ពួកសមណព្រាហ្មណ៍ ទី ៣ មានសេចក្តីយល់យ៉ាងនេះថា លោកទៀង ដូច្នេះខ្លះ លោកមិនទៀងដូច្នេះខ្លះ លោកមានទីបំផុត ដូច្នេះខ្លះ លោកមិនមានទីបំផុត ដូច្នេះខ្លះ ជីវិតនោះគឺសរីរៈនោះ ដូច្នេះខ្លះ ជីវិតក៏ដទៃ សរីរៈក៏ដទៃ ដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់មិនកើតទៀត ដូច្នេះខ្លះ សត្វទៅ

បរម្មរណា ឥតិបិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥតិបិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥតិបិ ឯវញ្ហិ តេ ភិក្ខវេ តតិយាបិ សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា ។ សេយ្យថាបិ តេ ភិក្ខវេ តតិយា មិគជាតា តថូបមេ អហំ ឥមេ តតិយេ សមណព្រាហ្មណេ វទាមិ ។

(៤៨) តត្រ ភិក្ខវេ ចតុត្ថា សមណព្រាហ្មណា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា សមណព្រាហ្មណា ។បេ។ ឯវញ្ហិ តេ បឋមា សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា យេបិ តេ ទុតិយា សមណព្រាហ្មណា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា សមណព្រាហ្មណា ។បេ។ ឯវញ្ហិ តេ បឋមា សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា យន្នូន មយំ ។បេ។ ឯវញ្ហិ តេ ទុតិយា សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា យេបិ តេ តតិយា សមណព្រាហ្មណា ឯវំ សមចិន្តេសុំ



ខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតក៏មាន មិនមែនជាមិនកើតទៀតក៏មាន ដូច្នេះខ្លះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ៣ នោះ មិនរួចអំពីឫទ្ធានុភាពនៃមារទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ៣ នោះ មានឧបមាដូចម្តេចមិញ តថាគតពោលនូវសមណព្រាហ្មណ៍ទី ៣ នេះថា មានឧបមេយ្យដូច្នោះដែរ ។

(៤៨) ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ទី ៤ គិតគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឫទ្ធានុភាពនៃមារទៅហើយ ពួកសមណព្រាហ្មណ៍ទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឫទ្ធានុភាពនៃមារទៅហើយ បើដូច្នោះមានតែយើងទាំងឡាយ ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ២ នោះ មិនរួចអំពីឫទ្ធានុភាពនៃមារទៅហើយ ពួកសមណព្រាហ្មណ៍ទី ៣ ណា គិតព្រមគ្នាយ៉ាងនេះថា

យេ ខោ តេ បឋមា សមណព្រាហ្មណា ។ បេ ។
ឯវញ្ហិ តេ បឋមា សមណព្រាហ្មណា ន បរិមុច្ចិំសុ
មារស្ស ឥទ្ធានុភាវា យេបិ តេ ទុតិយា សមណ-
ព្រាហ្មណា ឯវំ សមចិន្តេសុំ យេ ខោ តេ បឋមា
សមណព្រាហ្មណា ។ បេ ។ ឯវញ្ហិ តេ បឋមា
សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធា-
នុភាវា យន្នូន មយំ ។ បេ ។ ឯវញ្ហិ តេ ទុតិយាបិ
សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធា-
នុភាវា យន្នូន មយំ អមុំ និវាបំ និវុត្តំ មារស្ស
អមូនិ ច លោកាមិសានិ ឧបនិស្សាយ អាសយំ
កប្បេយ្យាម តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ
មារស្ស អមូនិ ច លោកាមិសានិ ។ បេ ។ អននុប្បវិស្ស
អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជិស្សាម
អមត្តា សមានា ន បមាទំ អាបជ្ជិស្សាម អប្បមត្តា
សមានា ន យថាកាមករណីយា ភវិស្សាម មារស្ស
អមុស្មិំ និវាបេ អមុស្មិំ ច លោកាមិសេតិ តេ



ពួកសមណព្រាហ្មណ៍ទី ១ ណា ។ បេ ។ កាលបើយ៉ាងនេះហើយ
ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាព នៃមារទៅហើយ
ពួកសមណព្រាហ្មណ៍ទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកសមណ-
ព្រាហ្មណ៍ទី ១ ណា ។ បេ ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្ម-
ណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាព នៃមារទៅហើយ បើដូច្នោះមានតែ
យើងទាំងឡាយ ។ បេ ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍
ទី ២ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទៅហើយ បើដូច្នោះមានតែ
យើងទាំងឡាយ ចូលទៅអាស្រ័យដំណាំ ដែលមារដាំហើយឯណោះ
និងលោកាមិសៈទាំងឡាយឯណោះ ហើយគប្បីសម្រេចនៅអាស្រ័យ
លុះសម្រេចនៅអាស្រ័យ ក្នុងទីនោះហើយ យើងកុំលុកលុយ កុំភ្លេច
ខ្លួននឹងដំណាំ ដែលមារដាំហើយឯណោះផង និងលោកាមិសៈ ទាំង-
ឡាយឯណោះផង ។ បេ ។ កាលបើយើងមិនលុកលុយ មិនភ្លេចខ្លួន
គ្រាន់តែបរិភោគភោជនទាំងឡាយ ទើបមិនដល់ នូវសេចក្តីស្រវឹង លុះ
មិនស្រវឹងហើយ ទើបមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ
ទើបជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង
ព្រោះលោកាមិសៈឯណោះផង លុះសមណព្រាហ្មណ៍ទាំងនោះ គិត

អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ ឧប-និស្សាយ អាសយំ កប្បយិំសុ តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ អនជ្ឈោបន្នា អមុច្ឆិតា ភោជនានិ ភុញ្ជិំសុ តេ តត្ថ អនជ្ឈោបន្នា អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជិំសុ អមត្តា សមានា ន បមាទំ អាបជ្ជិំសុ អប្បមត្តា សមានា ន យថាកាមករណីយា អហេសុំ មារស្ស អមុស្មិំ និវាបេ អមុស្មិំ ច លោកាមិសេ ។ អបិច ខោ ឯវំ ទិដ្ឋិកា អហេសុំ សស្សតោ លោកោ ឥតិបិ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥតិបិ ឯវញ្ហិ តេ តតិយាបិ សមណព្រាហ្មណា ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា យន្នូន មយំ យត្ថ អគតិ មារស្ស ច មារបរិសាយ ច តត្រាសយំ កប្បេយ្យាម តត្រាសយំ កប្បេត្វា



ដូច្នេះហើយ ក៏ចូលទៅអាស្រ័យដំណាំដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ ហើយសម្រេចទីនៅអាស្រ័យ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ មិនលុកលុយ មិនភ្លេចខ្លួននឹងដំណាំដែលមារដាំហើយឯណោះផង និងលោកាមិសៈទាំងឡាយឯណោះផង គ្រាន់តែបរិភោគភោជនទាំងឡាយ កាលសមណព្រាហ្មណ៍ទី ៣ ទាំងនោះ មិនបានលុកលុយ មិនបានភ្លេចខ្លួនក្នុងដំណាំនោះហើយ គ្រាន់តែបរិភោគភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ។ តែសមណព្រាហ្មណ៍ទី ៣ ទាំងនោះ មានសេចក្តីយល់ឃើញយ៉ាងនេះថា លោកទៀងដូច្នេះខ្លះ ។បេ។ សត្វខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតក៏មាន មិនមែនមិនកើតទៀតក៏មានដូច្នេះខ្លះ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ៣ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទៅហើយ បើដូច្នោះមានតែ យើងទាំងឡាយសម្រេចទីនៅអាស្រ័យត្រង់ទីដែលមិនមែនជាដំណើរនៃមារ និងបរិស័ទរបស់មារ លុះសម្រេចទី

អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ អននុប្បខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជិស្សាម អននុប្បខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជិស្សាម អមត្តា សមានា ន បមាទំ អាបជ្ជិស្សាម អប្បមត្តា សមានា ន យថាកាមករណីយា ភវិស្សាម មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេតិ តេ យត្ថ អគតិ មារស្ស ច មារបរិសាយ ច តត្រាសយំ កប្បយឹសុ តត្រាសយំ កប្បេត្វា អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ អននុប្បខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជឹសុ តេ តត្ថ អននុប្បខជ្ជ អមុច្ឆិតា ភោជនានិ ភុញ្ជមានា ន មទំ អាបជ្ជឹសុ អមត្តា សមានា ន បមាទំ អាបជ្ជឹសុ អប្បមត្តា សមានា ន យថាកាមករណីយា អហេសុំ មារស្ស អមុស្មឹ និវាបេ អមុស្មឹ ច លោកាមិសេ ឯវញ្ហិ តេ ភិក្ខវេ ចតុត្ថា សមណព្រាហ្មណា បរិមុច្ចឹសុ



នៅអាស្រ័យក្នុងទីនោះហើយ យើងកុំលុកលុយចំណី ដែលមារដាក់ហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ មិនភ្លេចខ្លួន គ្រាន់តែបរិភោគ នូវភោជនទាំងឡាយ កាលបើយើងមិនលុកលុយ មិនភ្លេចខ្លួន គ្រាន់តែបរិភោគនូវភោជនទាំងឡាយ នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់ នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ នឹងជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះចំណីឯណោះផង ព្រោះលោកាមិសៈឯណោះផង ទើបពួកសមណព្រាហ្មណ៍ទាំងនោះសម្រេចទីនៅអាស្រ័យ ត្រង់ទីដែលមិនមែនជាដំណើរនៃមារនិងបរិស័ទរបស់មារ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ ក៏មិនបានលុកលុយចំណីដែលមារដាក់ហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ មិនភ្លេចខ្លួន គ្រាន់តែបរិភោគនូវភោជនទាំងឡាយ កាលពួកសមណព្រាហ្មណ៍ទាំងនោះ មិនលុកលុយ មិនភ្លេចខ្លួនក្នុងចំណី និងលោកាមិសៈនោះហើយ គ្រាន់តែបរិភោគនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះចំណីឯណោះផង ព្រោះលោកាមិសៈឯណោះផង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ ទី ៤ នោះ ទើបរួច

មារស្ស អនាបាថគតា ។ សេយ្យថាបិ តេ ភិក្ខវេ ចតុត្ថា មិគជាតា តថូបមេ អហំ ឥមេ ចតុត្ថេ សមណព្រាហ្មណេ វទាមិ ។

(៤៩) កតញ្ច ភិក្ខវេ អគតិ មារស្ស ច មារបរិសាយ ច ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។បេ។ តតិយំ ឈានំ ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ



អំពីឥទ្ធានុភាពនៃមារបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ៤ នោះ មានសេចក្ដីឧបមាដូចម្ដេចមិញ តថាគតពោលពួកសមណព្រាហ្មណ៍ទី ៤ នេះ ថាមានឧបមេយ្យដូច្នោះដែរ ។

(៤៩) ម្នាលភិក្ខុទាំងឡាយ ចុះទីដែលមិនមែនជាដំណើររបស់មារនិងបរិស័ទនៃមារ ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ និងបីតិសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ចាកនីវរណ៍ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុធ្វើមារឲ្យខ្វាក់ បំបែកភ្នែក មិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមកមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុនោះព្រោះចូលទៅរម្ងាប់នូវវិតក្កៈវិចារៈរួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ក៏ញ៉ាំងចិត្តជាសមាធិឲ្យចម្រើនឡើង គ្មានវិតក្កៈវិចារៈទេ មានតែបីតិនិងសុខៈកើតអំពីសមាធិ ។បេ។ ហើយក៏បានចូលកាន់តតិយជ្ឈាន ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុ

អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ



បានធ្វើមារឲ្យខ្វាក់ បំបែកភ្នែកមិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមកគេមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា ព្រោះដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុបានធ្វើនូវមារឲ្យខ្វាក់ បំបែកភ្នែកមិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមកគេមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លង នូវអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ក៏ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត)ថា វិញ្ញាណ មិនមានទីបំផុតដូច្នេះ ។ បេ ។ ភិក្ខុ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចមិនមានដូច្នេះ ។ បេ ។ ភិក្ខុព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ

សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស មូលបណ្ណាសកំ

សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ តិណ្ណោ លោកេ វិសត្តិកន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

និវាបសុត្តំ បឋមំ និដ្ឋិតំ ។

---



សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក

ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់សញ្ញាវេទយិតនិរោធ (រលត់សញ្ញានិងវេទនា) ទើបអាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់ទៅ ព្រោះឃើញ (នូវអរិយសច្ច) ដោយមគ្គបញ្ញា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុបានធ្វើមារឲ្យខ្វាក់ បំបាត់ភ្នែកមិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមកមកមិនឃើញ ជាអ្នកឆ្លងនូវតណ្ហាដែលជំពាក់នៅក្នុងលោក ។ លុះព្រះមានព្រះភាគ សំដែងនិវាបសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្ដីពេញចិត្ត ត្រេកអរហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ និវាបសូត្រ ទី ១ ។

---

## ៦. បាសរាសិសុត្តំ(១)

(៩០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារា-មេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អថខោ សម្ពហុលា ភិក្ខូ យេន អាយស្មា អានន្ទោ តេនុប-សង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោចុំ ចិរស្សុតា នោ អាវុសោ អានន្ទ ភគវតោ សម្មុខា ធម្មី កថា សាធុ មយំ អាវុសោ អានន្ទ លភេយ្យាម ភគវតោ សម្មុខា ធម្មឹ(២) កថំ សវណាយាតិ ។ តេន-ហាយស្មន្តោ យេន រម្មកស្ស ព្រាហ្មណស្ស អស្សមោ តេនុបសង្កមថ អប្បេវ នាម លភេយ្យាថ ភគវតោ សម្មុខា ធម្មឹ កថំ សវណាយាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោ-សុំ ។ អថខោ ភគវា សាវត្ថិយំ បិណ្ឌាយ ចរិត្វា

១ ឱ. អរិយបរិយេសនសុត្តំ ឥតិបិ ។ ២ ឱ. ធម្មីកថំ ។

## ព្រះបាសរាសិសូត្រ ទី ៦

(៩០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះ-ភាគទ្រង់សម្រេចព្រះឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លំដាប់នោះឯង ពួកភិក្ខុច្រើនរូបចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះអានន្ទយ៉ាងនេះថា ម្នាលអានន្ទមានអាយុ យើងទាំងឡាយខានស្តាប់ធម្មីកថា ចំពោះព្រះភក្ត្រព្រះមានព្រះភាគអស់យូរហើយ ម្នាលអាវុសោអានន្ទ សូមឲ្យយើងទាំង-ឡាយ បានស្តាប់ធម្មីកថា ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគផង ។ ព្រះអានន្ទឆ្លើយតបថា លោកមានអាយុទាំងឡាយ បើដូច្នោះ ចូរលោកទាំង-ឡាយចូលទៅកាន់អាស្រម របស់រម្មកព្រាហ្មណ៍ ទើបលោកទាំងឡាយនឹងបានស្តាប់ធម្មីកថា ចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ។ ភិក្ខុទាំងនោះ ក៏ទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ គ្រានោះ ព្រះមានព្រះភាគ ស្តេចទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះ

បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន បុព្វារាមោ មិគារមាតុ បាសាទោ តេនុបសង្កមិស្សាម ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មតា អានន្ទេន សទ្ធឹ យេន បុព្វារាមោ មិគារមាតុ បាសាទោ តេនុបសង្កមិ ទិវាវិហារាយ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន បុព្វកោដ្ឋកោ តេនុបសង្កមិស្សាម គត្តានិ បរិសិញ្ចិតុំ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មតា អានន្ទេន សទ្ធឹ យេន បុព្វកោដ្ឋកោ



ត្រឡប់មកអំពីបិណ្ឌបាត ធ្វើភត្តកិច្ចស្រេចហើយ ក្នុងវេលាក្រោយភត្ត ទើបត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅកាន់ប្រាសាទ របស់មិគារមាតា ក្នុងបុព្វារាម ដើម្បីសំរាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ គ្រានោះឯង ព្រះមានព្រះភាគព្រមទាំងព្រះអានន្ទមានអាយុចូលទៅកាន់ប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ដើម្បីទៅសំរាក ក្នុងវេលាថ្ងៃ ។ លុះព្រះមានព្រះភាគ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅកាន់បន្ទប់ទឹកក្នុងទិសខាងកើតដើម្បីស្រោចស្រប់[១]កាយ ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគព្រមទាំងព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់បន្ទប់ទឹកក្នុងទិស

---

១ អ្នកផុសទាត់ខ្លួន ដោយលម្អិតនិងដីក្ដី ដោយឫសឈើមានសណ្ឋានដូចជើងកន្ត្រៃក្ដី ឈ្មោះថាអ្នកងូត ។ អ្នកដែលមិនធ្វើដូច្នោះគ្រាន់តែងូតតាមប្រក្រតីឈ្មោះថា អ្នកស្រោចស្រប់ ។ ឯសរីរៈរបស់ព្រះមានព្រះភាគមិនបានប្រឡាក់ដោយធូលីដែលគួរនឹងផុសចេញដូច្នោះទេ ព្រះអង្គគ្រាន់តែចុះទៅកាន់ទឹកដើម្បីនឹងរក្សាព្រះអង្គឲ្យស្រួលតាមរដូវប៉ុណ្ណោះ ។ អដ្ឋកថា ។

តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ បុព្វកោដ្ឋកេ គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិ គត្តានិ បុព្វាបយមានោ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ រម្មកស្ស ព្រាហ្មណស្ស អស្សមោ អវិទូរេ រមណីយោ ភន្តេ រម្មកស្ស ព្រាហ្មណស្ស អស្សមោ បាសាទិកោ ភន្តេ រម្មកស្ស ព្រាហ្មណស្ស អស្សមោ សាធុ ភន្តេ ភគវា យេន រម្មកស្ស ព្រាហ្មណស្ស អស្សមោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា យេន រម្មកស្ស ព្រាហ្មណស្ស អស្សមោ តេនុបសង្កមិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ រម្មកស្ស ព្រាហ្មណស្ស អស្សមេ ធម្មិយា កថាយ សន្និសិន្នា ហោន្តិ ។ អថខោ ភគវា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ កថាបរិយោសានំ អាគមយមានោ ។





ខាងកើត ដើម្បីស្រោចស្រប់កាយទាំងឡាយ លុះស្រោចស្រប់កាយក្នុងបុព្វកោដ្ឋកខាងកើតរួចហើយ ទើបស្ដេចឡើងមកទ្រង់ចីវរតែមួយ ទ្រង់ឋិតសំដិលព្រះកាយឲ្យស្ងួត ។ គ្រានោះ ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អាស្រមរបស់រម្មកព្រាហ្មណ៍នេះ មិនឆ្ងាយប៉ុន្មានទេ បពិត្រព្រះអង្គដ៏ចម្រើន អាស្រមរបស់រម្មកព្រាហ្មណ៍គួរជាទីត្រេកអរ បពិត្រព្រះអង្គដ៏ចម្រើន អាស្រមរបស់រម្មកព្រាហ្មណ៍គួរជាទីជ្រះថ្លា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អាស្រ័យសេចក្ដីអនុគ្រោះ ចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ ទើបព្រះមានព្រះភាគស្ដេចចូលទៅ កាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ។ គាប់ជួនសម័យនោះឯង ពួកភិក្ខុច្រើនរូបកំពុងអង្គុយប្រជុំគ្នាដោយធម្មីកថា ក្នុងអាស្រមរបស់រម្មកព្រាហ្មណ៍ ។ ទើបព្រះមានព្រះភាគទ្រង់ឋិតនៅក្បែរខ្លោងទ្វារខាងក្រៅ រង់ចាំឲ្យចប់ពាក្យនិយាយ ។

[៨១] អថខោ ភគវា កថាបរិយោសានំ វិទិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេសិ ។ វិវរឹសុ ខោ តេ ភិក្ខូ ភគវតោ ទ្វារំ ។ អថខោ ភគវា រម្មកស្ស ព្រាហ្មណស្ស អស្សមំ បវិសិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយនុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរា កថា វិប្បកតាតិ ។ ភគវន្តមេវ ខោ នោ ភន្តេ អារព្ភ ធម្មី កថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។ សាធុ ភិក្ខវេ ឯតំ ខោ ភិក្ខវេ តុម្ហាកំ បតិរូបំ កុលបុត្តានំ សទ្ធា អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ ធម្មិយា កថាយ សន្និសីទេយ្យាថ ។ សន្និបតិតានំ វោ ភិក្ខវេ ទ្វយំ ករណីយំ ធម្មី វា កថា អរិយោ វា តុណ្ហីភាវោ ។ ទ្វេមា ភិក្ខវេ បរិយេសនា អនរិយា ច បរិយេសនា អរិយា ច បរិយេសនា(១) ។

១ ឱ. ម. ឥមា ច បរិយេសនា អនរិយា ច បរិយេសនាតិ ទិស្សន្តិ ។



[៨១] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ចប់ពាក្យនិយាយហើយ ក៏ក្រហែមរួចទ្រង់គោះសន្ទះទ្វារ ។ ពួកភិក្ខុទាំងនោះក៏បើកទ្វារថ្វាយព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ហើយគង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ បានត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំនិយាយពាក្យដូចម្តេចខ្លះ ចុះពាក្យជាចន្លោះ ដូចម្តេច ដែលអ្នកទាំងឡាយនិយាយគ្នាមិនទាន់ស្រេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យប្រកបដោយធម៌ ប្រារព្ធចំពោះព្រះមានព្រះភាគ ដែលយើងខ្ញុំទាំងឡាយនិយាយមិនទាន់ស្រេច ស្រាប់តែព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ល្អហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំដោយធម្មីកថានុ៎ះឯង សមគួរដល់អ្នកទាំងឡាយ ជាកុលបុត្រដែលចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដោយសទ្ធាហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នាហើយ ត្រូវធ្វើកិច្ច ២ យ៉ាង គឺ ពាក្យប្រកបដោយធម៌ ១ ភាពជាអ្នកស្ងប់ស្ងៀមនៅដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ២ ប្រការ គឺ ការស្វែងរកមិនប្រសើរ ១ ការស្វែងរកប្រសើរ ១ ។

(៥៦) កតមា ច ភិក្ខវេ អនរិយា បរិយេសនា ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ជាតិធម្មោ សមានោ ជាតិធម្មញ្ញេវ(១) បរិយេសតិ អត្តនា ជរាធម្មោ សមានោ ជរាធម្មញ្ញេវ បរិយេសតិ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មញ្ញេវ បរិយេសតិ អត្តនា មរណធម្មោ សមានោ មរណធម្មញ្ញេវ បរិយេសតិ អត្តនា សោកធម្មោ សមានោ សោកធម្មញ្ញេវ បរិយេសតិ អត្តនា សង្កិលេសធម្មោ សមានោ សង្កិលេសធម្មញ្ញេវ បរិយេសតិ ។ កិញ្ច ភិក្ខវេ ជាតិធម្មំ វទេថ ។ បុត្តភរិយំ ភិក្ខវេ ជាតិធម្មំ ទាសិទាសំ ជាតិធម្មំ អជេឡកំ ជាតិធម្មំ កុក្កុដសូករំ ជាតិធម្មំ ហត្ថិគវស្សវឡវំ ជាតិធម្មំ ជាតរូបរជតំ ជាតិធម្មំ ។ ជាតិធម្មា ហេតេ ភិក្ខវេ ឧបធយោ ឯត្ថាយំ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ(២) អត្តនា ជាតិធម្មោ សមានោ ជាតិធម្មញ្ញេវ បរិយេសតិ ។ កិញ្ច ភិក្ខវេ ជរាធម្មំ

១ ម. សព្វត្ថ ជាតិធម្មំយេវាតិ ទិស្សតិ ។ ២ ម. អជ្ឈោបន្នោ ។





(៥៦) ការស្វែងរកមិនប្រសើរតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ស្វែងរករបស់មានជាតិជាធម្មតាថែមទៀត ខ្លួនឯងជរាជាធម្មតា ស្វែងរករបស់មានជរាជាធម្មតាថែមទៀត ខ្លួនឯងមានព្យាធិជាធម្មតា ស្វែងរករបស់មានព្យាធិជាធម្មតាថែមទៀត ខ្លួនឯងមានមរណៈជាធម្មតា ស្វែងរករបស់មានមរណៈជាធម្មតាថែមទៀត ខ្លួនឯងមានសេចក្តីសោកជាធម្មតា ស្វែងរករបស់មានសេចក្តីសោកជាធម្មតាថែមទៀត ខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ស្វែងរករបស់មានសេចក្តីសៅហ្មងជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីដែលមានជាតិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថាបុត្រភរិយាមានជាតិជាធម្មតា ទាសីទាសៈមានជាតិជាធម្មតា ពពែចៀមមានជាតិជាធម្មតា មាន់ជ្រូកមានជាតិជាធម្មតា ដំរី គោ សេះ លាឈ្មោលមិនញីមានជាតិជាធម្មតា មាសប្រាក់មានជាតិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជាតិធម៌ទាំងនោះឯង ជាឧបធិ (កិលេស) បុគ្គលនេះមានចិត្តជាប់ជ្រប់ល្វឹងលើសទៅក្នុងឧបធិ (កិលេស) ទាំងនុ៎ះ ឈ្មោះថាខ្លួនឯងមានជាតិជាធម្មតា ស្វែងរករបស់មានជាតិជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីដែលមានជរា

វទេថ ។ បុត្តភរិយំ ភិក្ខវេ ជរាធម្មំ ទាសីទាសំ ជរាធម្មំ អជេឡកំ ជរាធម្មំ កុក្កុដសូករំ ជរាធម្មំ ហត្ថិគវស្សវឡវំ ជរាធម្មំ ជាតរូបរជតំ ជរាធម្មំ ។ ជរាធម្មា ហេតេ ភិក្ខវេ ឧបធយោ ឯត្ថាយំ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ(១) អត្តនា ជរាធម្មោ សមានោ ជរាធម្មញ្ញេវ បរិយេសតិ ។ កិញ្ច ភិក្ខវេ ព្យាធិធម្មំ វទេថ ។ បុត្តភរិយំ ភិក្ខវេ ព្យាធិធម្មំ ទាសីទាសំ ព្យាធិធម្មំ អជេឡកំ ព្យាធិធម្មំ កុក្កុដសូករំ ព្យាធិធម្មំ ហត្ថិគវស្សវឡវំ ព្យាធិធម្មំ ជាតរូបរជតំ ព្យាធិធម្មំ ។ ព្យាធិធម្មា ហេតេ ភិក្ខវេ ឧបធយោ ឯត្ថាយំ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មញ្ញេវ បរិយេសតិ ។ កិញ្ច ភិក្ខវេ

១ ម. ឧ. អជ្ឈោបន្នោ ។



ជរាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាបុត្រភរិយា មានជរាជាធម្មតា ទាសីទាសៈមានជរាជាធម្មតា ពពែចៀមមានជរាជាធម្មតា មាន់ជ្រូកមានជរាជាធម្មតា ដំរីគោសេះនិងលាមានជរាជាធម្មតា មាសប្រាក់មានជរាជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជរាធម៌ទាំងនោះឯង ជាឧបធិ (កិលេស) បុគ្គលនេះមានចិត្តត្រេកជ្រប់លង់ស៊ប់ទៅ ក្នុងឧបធិ (កិលេស) ទាំងនុ៎ះ ឈ្មោះថា ខ្លួនឯងមានជរាជាធម្មតា ស្វែងរករបស់មានជរាជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីដែលមានព្យាធិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាបុត្រភរិយា មានព្យាធិជាធម្មតា ទាសីទាសៈមានព្យាធិជាធម្មតា ពពែចៀមមានព្យាធិជាធម្មតា មាន់ជ្រូកមានព្យាធិជាធម្មតា ដំរីគោសេះលាឈ្មោលនិងញី មានព្យាធិជាធម្មតា មាសប្រាក់មានព្យាធិជាធម្មតា(១) ។ ម្នាលភិក្ខុទាំងឡាយ ព្យាធិធម៌ទាំងនោះឯងជាឧបធិ (កិលេស) បុគ្គលនេះមានចិត្តត្រេកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ(កិលេស)ទាំងនុ៎ះ ឈ្មោះថាខ្លួនឯងមានព្យាធិជាធម្មតា ស្វែងរករបស់មានព្យាធិជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វី

១ មាសប្រាក់លោកមិនបានសង្គ្រោះថាមានព្យាធិមរណៈមានសោកទេ ព្រោះមិនមានព្យាធិ ដូចពពួកឈើក្បាលជាដើម ប្រាកដតែសៅហ្មងដោយសង្កិលេសធម៌មានជរាជាដើម ព្រោះហេតុនោះបានជា ព្រះអង្គសង្គ្រោះក្នុងសង្កិលេសធម៌វិញ ។

មរណធម្មំ វទេថ ។ បុត្តភរិយំ ភិក្ខវេ មរណធម្មំ ទាសីទាសំ មរណធម្មំ អជេឡកំ មរណធម្មំ កុក្កុដសូករំ មរណធម្មំ ហត្ថិគវស្សវឡវំ មរណធម្មំ ជាតរូបរជតំ មរណធម្មំ ។ មរណធម្មា ហេតេ ភិក្ខវេ ឧបធយោ ឯត្ថាយំ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ អត្តនា មរណធម្មោ សមានោ មរណធម្មញ្ញេវ បរិយេសតិ ។ កិញ្ច ភិក្ខវេ សោកធម្មំ វទេថ ។ បុត្តភរិយំ ភិក្ខវេ សោកធម្មំ ទាសីទាសំ សោកធម្មំ អជេឡកំ សោកធម្មំ កុក្កុដសូករំ សោកធម្មំ ហត្ថិគវស្សវឡវំ សោកធម្មំ ជាតរូបរជតំ សោកធម្មំ ។ សោកធម្មា ហេតេ ភិក្ខវេ ឧបធយោ ឯត្ថាយំ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ អត្តនា សោកធម្មោ សមានោ សោកធម្មញ្ញេវ បរិយេសតិ ។ កិញ្ច ភិក្ខវេ សង្កិលេសធម្មំ វទេថ ។ បុត្តភរិយំ ភិក្ខវេ សង្កិលេសធម្មំ



ដែលមានមរណៈជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថា បុត្រភរិយាមានមរណៈជាធម្មតា ទាសីទាសៈមានមរណៈជាធម្មតា ពពែចៀមមានមរណៈជាធម្មតា មាន់ជ្រូកមានមរណៈជាធម្មតា ដំរីគោសេះលាឈ្មោល និងញីមានមរណៈជាធម្មតា មាសប្រាក់មានការខូចខាតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឯមរណធម៌ទាំងនោះឯង ហៅថាឧបធិ (កិលេស) បុគ្គលនេះមានចិត្តងោកជ្រប់លង់លិបទៅក្នុងឧបធិ (កិលេស) ទាំងនុ៎ះ ឈ្មោះថា ខ្លួនឯងមានមរណៈជាធម្មតា ស្វែងរករបស់មានមរណៈជាធម្មតាដែលទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីមានសោកជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថាបុត្រភរិយាមានសោកជាធម្មតា ទាសីទាសៈមានសោកជាធម្មតា ពពែចៀមមានសោកជាធម្មតា មាន់ជ្រូកមានសោកជាធម្មតា ដំរីគោសេះលាឈ្មោលនិងញីមានសោកជាធម្មតា មាសប្រាក់មានសេចក្ដីស្អុកជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឯសោកធម៌ទាំងនោះឯងហៅថាឧបធិ (កិលេស) បុគ្គលនេះមានចិត្តងោកជ្រប់លង់លិបទៅក្នុងឧបធិ (កិលេស) ទាំងនុ៎ះ ឈ្មោះថា ខ្លួនឯងមានសេចក្ដីសោកជាធម្មតា ស្វែងរករបស់មានសេចក្ដីសោកជាធម្មតាដែលទៀត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីមានសេចក្ដីសៅហ្មងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ថាបុត្រភរិយាមានសេចក្ដីសៅហ្មង

ទាសិទាសំ សង្កិលេសធម្មំ អជេឡកំ សង្កិលេសធម្មំ កុក្កុដសូករំ សង្កិលេសធម្មំ ហត្ថិគវស្សវឡវំ សង្កិលេសធម្មំ ជាតរូបរជតំ សង្កិលេសធម្មំ ។ សង្កិលេសធម្មា ហេតេ ភិក្ខវេ ឧបធយោ ឯត្ថាយំ គធិតោ មុច្ឆិតោ អជ្ឈោបន្នោ អត្តនា សង្កិលេសធម្មោ សមានោ សង្កិលេសធម្មញ្ញេវ បរិយេសតិ ។ អយំ ភិក្ខវេ អនរិយា បរិយេសនា ។

(៨៣) កតមា ច ភិក្ខវេ អរិយា បរិយេសនា ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ជាតិធម្មោ សមានោ ជាតិធម្មេ អាទីនវំ វិទិត្វា អជាតំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា ជរាធម្មោ សមានោ ជរាធម្មេ អាទីនវំ វិទិត្វា អជរំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មេ អាទីនវំ វិទិត្វា អព្យាធឹ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា មរណធម្មោ សមានោ



ជាធម្មតា ទាសីទាសៈមានសេចក្តីសៅហ្មងជាធម្មតា ពពែចៀមមានសេចក្តីសៅហ្មងជាធម្មតា មាន់ជ្រូកមានសេចក្តីសៅហ្មងជាធម្មតា ដំរីគោសេះលាឈ្មោលនិងញីមានសេចក្តីសៅហ្មងជាធម្មតា មាសប្រាក់មានសេចក្តីសៅហ្មងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឯសង្កិលេសធម៌ទាំងនុ៎ះឯង ហៅថាឧបធិ (កិលេស) បុគ្គលនេះមានចិត្តត្រេកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ (កិលេស) ទាំងនុ៎ះ ឈ្មោះថាខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ស្វែងរករបស់មានសេចក្តីសៅហ្មងជាធម្មតាដដែលទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាការស្វែងរកមិនប្រសើរ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ ឯការស្វែងរកដ៏ប្រសើរតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានជាតិ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា ដឹងច្បាស់នូវទោសក្នុងជរាធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានជរា ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា ដឹងច្បាស់នូវទោសក្នុងព្យាធិធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានព្យាធិ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានមរណៈជាធម្មតា ដឹងច្បាស់នូវទោសក្នុង

មរណធម្មេ អាទីនវំ វិទិត្វា អមតំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា សោកធម្មោ សមានោ សោកធម្មេ អាទីនវំ វិទិត្វា អសោកំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា សង្កិលេសធម្មោ សមានោ សង្កិលេសធម្មេ អាទីនវំ វិទិត្វា អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ ។ អយំ ភិក្ខវេ អរិយា បរិយេសនា ។

(៨៦) អហម្បិ សុទំ ភិក្ខវេ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោវ សមានោ អត្តនា ជាតិធម្មោ សមានោ ជាតិធម្មញ្ញេវ បរិយេសាមិ អត្តនា ជរាធម្មោ សមានោ ជរាធម្មញ្ញេវ បរិយេសាមិ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មញ្ញេវ បរិយេសាមិ អត្តនា មរណធម្មោ សមានោ មរណធម្មញ្ញេវ បរិយេសាមិ អត្តនា សោកធម្មោ សមានោ សោកធម្មញ្ញេវ បរិយេសាមិ អត្តនា សង្កិលេសធម្មោ សមានោ សង្កិលេសធម្មញ្ញេវ បរិយេសាមិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិន្នុ ខោ អហំ អត្តនា ជាតិធម្មោ



មរណធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានមរណៈឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសោកជាធម្មតា ដឹងច្បាស់នូវទោសក្នុងសោកធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានសេចក្ដីសោក ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសេចក្ដីសៅហ្មងជាធម្មតា ដឹងច្បាស់នូវទោសក្នុងសង្កិលេសធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានសង្កិលេសធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកដ៏ប្រសើរ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុនអំពីកាលជាទីត្រាស់ដឹង ដែលតថាគតនៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ ខ្លួនឯងមានជាតិជាធម្មតា ស្វែងរកនូវជាតិធម៌ថែមទៀត ខ្លួនឯងមានជរាជាធម្មតា ស្វែងរកនូវជរាធម៌ថែមទៀត ខ្លួនឯងមានព្យាធិជាធម្មតា ស្វែងរកនូវព្យាធិធម៌ថែមទៀត ខ្លួនឯងមានមរណៈជាធម្មតា ស្វែងរកនូវមរណធម៌ថែមទៀត ខ្លួនឯងមានសោកជាធម្មតា ស្វែងរកនូវសោកធម៌ថែមទៀត ខ្លួនឯងមានសេចក្ដីសៅហ្មងជាធម្មតា ស្វែងរកនូវសេចក្ដីសៅហ្មងថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្ដីត្រិះរិះយ៉ាងនេះថា ខ្លួនឯងមានជាតិជាធម្មតា ហេតុដូចម្ដេចបានជាអាត្មាអញ

សមានោ ជាតិធម្មញ្ញេវ បរិយេសាមិ អត្តនា ជរាធម្មោ សមានោ... ព្យាធិធម្មោ សមានោ... មរណធម្មោ សមានោ... សោកធម្មោ សមានោ... អត្តនា សង្កិលេសធម្មោ សមានោ សង្កិលេសធម្មញ្ញេវ បរិយេសាមិ យន្នូនាហំ អត្តនា ជាតិធម្មោ សមានោ ជាតិធម្មេ អាទីនវំ វិទិត្វា អជាតំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសេយ្យំ អត្តនា ជរាធម្មោ សមានោ ជរាធម្មេ អាទីនវំ វិទិត្វា អជរំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសេយ្យំ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មេ អាទីនវំ វិទិត្វា អព្យាធិំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសេយ្យំ អត្តនា មរណធម្មោ សមានោ មរណធម្មេ អាទីនវំ វិទិត្វា អមតំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសេយ្យំ អត្តនា សោកធម្មោ សមានោ សោកធម្មេ អាទីនវំ វិទិត្វា អសោកំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសេយ្យំ អត្តនា សង្កិលេស-



ស្វែងរកធម៌មានជាតិជាធម្មតាដែរទៀត ខ្លួនឯងមានជរាជាធម្មតា... មានព្យាធិជាធម្មតា... មានមរណៈជាធម្មតា... មានសោកជាធម្មតា... ខ្លួនឯងមានសេចក្ដីសៅហ្មងជាធម្មតា ស្វែងរកធម៌មានសេចក្ដីសៅហ្មងជាធម្មតាដែរទៀត បើដូច្នោះ គួរតែអាត្មាអញដែលខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយគប្បីស្វែងរកព្រះនិព្វានដែលមិនមានជាតិធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា ដឹងច្បាស់នូវទោសក្នុងជរាធម៌ ហើយគប្បីស្វែងរកព្រះនិព្វានដែលឥតមានជរាធម៌ មិនមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា ដឹងច្បាស់នូវទោស ក្នុងព្យាធិធម៌ ហើយគប្បីស្វែងរកព្រះនិព្វាន ដែលមិនមានព្យាធិធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានមរណៈ ជាធម្មតា ដឹងច្បាស់នូវទោសក្នុងមរណធម៌ ហើយគប្បីស្វែងរកព្រះនិព្វានដែលមិនមានមរណធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសោកជាធម្មតា ដឹងច្បាស់នូវទោស ក្នុងសោកធម៌ហើយគប្បីស្វែងរកព្រះនិព្វាន ដែលមិនមានសោកធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសេចក្ដីសៅហ្មងជាធម្មតា

ធម្មោ សមានោ សង្កិលេសធម្មេ អាទីនវំ វិទិត្វា អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសេយ្យន្តិ ។

(៨៨) សោ ខោ អហំ ភិក្ខវេ អបរេន សមយេន ទហរោវ សមានោ សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អកាមកានំ មាតាបិតូនំ អស្សុមុខានំ រុទន្តានំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជឹ សោ ឯវំ បព្វជិតោ សមានោ កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ ឥច្ឆាមហំ អាវុសោ កាលាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ វុត្តេ ភិក្ខវេ អាឡារោ កាលាមោ មំ ឯតទវោច វិហរតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិរស្សេវ សកំ អាចរិយកំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ



ដឹងច្បាស់នូវទោស ក្នុងសង្កិលេសធម៌ ហើយគប្បីស្វែងរកព្រះនិព្វាន ដែលឥតមានសង្កិលេសធម៌ ឥតមានគុណជាតដទៃប្រសើរ ជាទីក្សេមចាកយោគៈវិញ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ លុះសម័យតមក តថាគតនោះឯងនៅក្មេង មានសក់ខ្មៅស្រិលល្អ ក៏ប្រកបដោយបឋមវ័យដ៏ចម្រើន កាលដែលមាតាបិតាមិនចង់ (ឱ្យចេញបួស) មានព្រះភក្ត្រទទឹកដោយទឹកព្រះនេត្រ កំពុងទ្រង់ព្រះកន្សែង (តថាគត) ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ ចេញចាកផ្ទះទៅកាន់ផ្នួស លុះតថាគតនោះបួសយ៉ាងនេះហើយ ក៏ស្វែងរក កិំកុសល (សេចក្ដីពិតថាអ្វីជាកុសល) កាលស្វែងរកនូវសន្តិវរបទ គឺព្រះនិព្វាន ដែលជាគុណជាតដ៏ប្រសើរ ក៏បានចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ បាននិយាយនឹងអាឡារតាបស កាលាមគោត្រ យ៉ាងនេះថា ម្នាលអាវុសោកាលាមៈ ខ្ញុំចង់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគត និយាយយ៉ាងនេះហើយ អាឡារតាបស កាលាមគោត្រ ក៏បាននិយាយ នឹងតថាគតយ៉ាងនេះថា អ្នកមានអាយុ ចូរនៅចុះ ធម៌នេះ ប្រាកដដូចជាអ្នកប្រាជ្ញនោះ ជាធម៌ សម្រាប់វិញ្ញូជន ធ្វើឱ្យជាក់ច្បាស់ នូវលទ្ធិអាចារ្យ ដោយប្រាជ្ញា របស់ខ្លួន ពុំយូរប៉ុន្មាន ក៏នឹងបានសម្រេច ។

ខោ អហំ ភិក្ខវេ នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ សោ ខោ អហំ ភិក្ខវេ តាវតកេនេវ ឱដ្ឋបហតមត្តេន លបិតលាបនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជានាមិ បស្សាមីតិ ច បដិ-ជានាមិ អហញ្ចេវ អញ្ញេ ច ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ ន ខោ អាឡារោ កាលាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា អា-ឡារោ កាលាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។ អថ ខ្វាហំ ភិក្ខវេ យេន អាឡារោ កាលាមោ តេ-នុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯត-ទវោចំ កិត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេ-ទេសីតិ ។ ឯវំ វុត្តេ ភិក្ខវេ អាឡារោ កាលាមោ



ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ក៏បានរៀនធម៌នោះ ចប់មួយរំពេច មិនយូរឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ពោលនូវញាណ-វាទផង នឹងពាក្យរបស់ថេរៈ (ការប្រកាន់ខ្លួន) ផង ត្រូវថាតថាគតបាន ឃើញដូច្នេះផង ដោយគ្រាន់តែការខ្ពូរពោលបន្ទើបមាត់ ផងដោយ គ្រាន់តែការខ្ពូរពោលបែ ពោលពាក្យចប់ប៉ុណ្ណោះ មិនមែនតែតថាគត ប៉ុណ្ណោះទេ សូម្បីជនឯទៀត (ក៏គេនិយាយយ៉ាងនេះដែរ) ។ ម្នាលភិក្ខុ ទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាឡារតាបស កាលាមគោត្រ មិនប្រកាសថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួនឯង ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ តាមពិត អាឡារតាបស កាលាមគោត្រ គ្រាន់តែដឹងផងយល់ឃើញ នូវធម៌នេះ (ប៉ុណ្ណោះ) ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតបានចូល ទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ បាន សួរអាឡារតាបស កាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ អ្នកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ថ្លៃថ្លាខ្លួនឯង ហើយ បានសម្រេច ប្រកាសទុក ដោយហេតុដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើតថាគតសួរយ៉ាងនេះហើយ អាឡារតាបសកាលាមគោត្រ

អាកិញ្ចញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ វិរិយំ មយ្ហំបត្ថិ វិរិយំ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សតិ មយ្ហំបត្ថិ សតិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សមាធិ មយ្ហំបត្ថិ សមាធិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ បញ្ញា មយ្ហំបត្ថិ បញ្ញា យន្នូនាហំ យំ ធម្មំ អាឡារោ កាលាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ ភិក្ខវេ នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថខ្វាហំ ភិក្ខវេ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ ឯត្តាវតា នោ អាវុសោ កាលាម





ក៏ប្រកាសប្រាប់ នូវអាកិញ្ចញ្ញាយតនសមាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្ដីត្រិះរិះ យ៉ាងនេះថា អាឡារតាបសកាលាមគោត្រមិនមានសទ្ធាទេ តថាគតក៏មានសទ្ធា អាឡារតាបសកាលាមគោត្រ មិនមានព្យាយាមទេ តថាគតក៏មានព្យាយាម អាឡារតាបសកាលាមគោត្រ មិនមានសតិទេ តថាគតក៏មានសតិ អាឡារតាបសកាលាមគោត្រ មិនមានសមាធិទេ តថាគតក៏មានសមាធិ អាឡារតាបសកាលាមគោត្រ មិនមានបញ្ញាទេ តថាគតក៏មានបញ្ញា បើដូច្នោះគួរតែតថាគតប្រឹងប្រែង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលអាឡារតាបសកាលាមគោត្រ ប្រកាសទុកថា ខ្លួនបានសម្រេចហើយ ព្រោះធ្វើឲ្យជាក់ច្បាស់ នូវធម៌ដោយប្រាជ្ញាដ៏ខ្ពង់ខ្ពស់ខ្លួនឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏បានសម្រេច ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នោះមួយរំពេចដោយឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតចូលទៅរកអាឡារតាបសកាលាមគោត្រ (ទៀត) លុះចូលទៅដល់ហើយ ទើបសួរអាឡារតាបសកាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ

ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ ។ អហម្បិ ខោ អាវុសោ កាលាម(១) ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ បស្សាម ឥតិ យាហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ តមហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ ឥតិ យាហំ ធម្មំ ជានាមិ តំ ត្វំ ធម្មំ ជានាសិ យំ ត្វំ ធម្មំ ជានាសិ តមហំ ធម្មំ ជានាមិ ឥតិ យាទិសោ អហំ តាទិសោ

១ ម. កាលាមាតិ ន ទិស្សតិ ។



អ្នកបានសម្រេចហើយ ព្រោះបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួន ហើយប្រកាសទុកដោយហេតុតែប៉ុណ្ណេះឬ ។ អាឡារកាលាមគោត្រតបថា ម្នាលអាវុសោ ខ្ញុំបានសម្រេចព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ហើយប្រកាសទុកដោយហេតុតែប៉ុណ្ណោះឯង ។ តថាគតសួរទៀតថា ម្នាលអាវុសោកាលាមៈ ខ្ញុំឯងបានសម្រេចព្រោះបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួនដោយហេតុប៉ុណ្ណេះដែរ ។ អាឡារកាលាមគោត្រតបថា ម្នាលអាវុសោ យើងពេញចិត្តណាស់ហើយ ម្នាលអាវុសោ អត្តភាពជាមនុស្សរបស់យើងពេញជាបានល្អហើយ ព្រោះដែលយើងបានឃើញសព្រហ្មចារីបុគ្គល ប្រាកដដូចជាអ្នកមានអាយុ ព្រោះថា ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន តាំងបានសម្រេចនូវធម៌ណា ហើយប្រកាសទុក អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួន តាំងបានសម្រេចនូវធម៌នោះ ហើយនៅដោយឥរិយាបថ ៤ ដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួន តាំងបានសម្រេចនូវធម៌ណា ហើយនៅ ដោយឥរិយាបថ ៤ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួនឯង តាំងបានសម្រេចនូវធម៌នោះ ហើយប្រកាសទុកដែរ ព្រោះខ្ញុំដឹងធម៌ណា អ្នកក៏ដឹងធម៌នោះ អ្នកដឹងធម៌ណា ខ្ញុំក៏ដឹងធម៌នោះ ខ្ញុំប្រាកដយ៉ាងណា អ្នកក៏ប្រាកដយ៉ាងនោះ

ត្វំ យាទិសោ ត្វំ តាទិសោ អហំ ឯហិ ទានិ អា-វុសោ ឧភោ សន្តា ឥមំ គណំ បរិហរាមាតិ ។ ឥតិ ខោ ភិក្ខវេ អាឡារោ កាលាមោ អាចរិយោ មេ សមានោ អន្តេវាសឹ មំ សមានំ អត្តនា(១) សម-សមំ ឋបេតិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ នាយំ ធម្មោ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ យាវទេវ អាកិញ្ចញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ ភិក្ខវេ តំ ធម្មំ អនលង្ករិត្វា តស្មា(២) ធម្មា និព្វិជ្ជ អបក្កមឹ ។

(៨៦) សោ ខោ អហំ ភិក្ខវេ កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ

---
១ ម. អត្តនា ។ ២ ម. យ. តស្មា ។



អ្នកក្រោកឡើងយ៉ាងណា ខ្ញុំក៏ក្រោកឡើងយ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ ចូរអ្នកមក យើងទាំងពីរនាក់នឹងនៅគ្រប់គ្រងគណៈនេះ ។ ម្នាលភិក្ខុទាំងឡាយ អាឡារតាបសកាលាមគោត្រ ជាអាចារ្យរបស់តថាគត ក៏តាំងតថាគតជាកូនសិស្សស្មើៗ នឹងខ្លួន ទាំងបូជាតថាគតដោយការបូជាដ៏លើសលប់ ដោយហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌ (គឺសមាបត្តិទាំង ៧) នេះ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ចាកកិលេសវត្ថុ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរលត់ទុក្ខចាកកិលេស មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីដឹងដោយក្រៃលែង មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីសេចក្តីរលត់ទុក្ខ ប្រព្រឹត្តទៅបានតែត្រឹមកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង មិនបានត្រេកអរនឹងធម៌នោះឡើយ នឿយណាយហើយចាកចេញអំពីធម៌នោះ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ជាអ្នកស្វែងរកកុសល កំពុងស្វែងរក នូវសន្តិវរបទ ក៏បានចូលទៅរកឧទ្ទកតាបស រាមបុត្រ លុះចូលទៅដល់ហើយ បាននិយាយនឹងឧទ្ទកតាបសរាមបុត្រយ៉ាងនេះថា ម្នាល

ឯតទវោចំ ឥច្ឆាមហំ អាវុសោ រាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ វុត្តេ ភិក្ខវេ ឧទ្ទកោ រាមបុត្តោ មំ ឯតទវោច វិហរតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិរស្សេវ សកំ អាចរិយកំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ ភិក្ខវេ នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ អហំ ភិក្ខវេ តាវតកេនេវ ឱដ្ឋបហតមត្តកេន លបិតលាប-នមត្តកេន(១) ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជានាមិ បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ ន ខោ រាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា រាមោ ឥមំ ធម្មំ ជានំ បស្សំ វិហាសីតិ ។ អថខ្វាហំ ភិក្ខវេ យេន ឧទ្ទកោ រាមបុត្តោ តេនុប-សង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ

១ ឱ. ម. ឱដ្ឋបហតមត្តេន លបិតលាបនមត្តេន ។



អាវុសោរាមៈ ខ្ញុំចង់ប្រព្រឹត្តព្រហ្មចរិយក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតនិយាយយ៉ាងនេះហើយ ឧទ្ទករាមបុត្រ បាននិយាយនឹងតថាគតយ៉ាងនេះថា អ្នកមានអាយុចូរនៅចុះ នេះជាធម៌ប្រាកដដូចជាអ្នកប្រាជ្ញណានោះ ជាវិញ្ញូបុរស ធ្វើឲ្យជាក់ច្បាស់ នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏វិសេសរបស់ខ្លួនហើយ បានសម្រេចមិនយូរឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង បានរៀនធម៌នោះឆាប់ៗមិនយូរឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ពោលនូវញាណវាទផង នឹងច្បាស់ខ្លួនជាថេរវាទផង ប្តេជ្ញាថា តថាគតបានឃើញដូច្នេះផង ដោយគ្រាន់តែឧទ្ទករាមបុត្រពោលធ្វើបបូរមាត់ និងដោយគ្រាន់តែឧទ្ទករាមបុត្រ ពោលពាក្យទន្ទេញប៉ុណ្ណោះ មិនមែនតែតថាគតប៉ុណ្ណោះទេ ទាំងពួកជនឯទៀត (ក៏និយាយយ៉ាងនេះដែរ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ឧទ្ទករាមបុត្រមិនប្រកាសថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ នូវធម៌នេះ ដោយប្រាជ្ញាដ៏វិសេសរបស់ខ្លួនឯង ដោយគ្រាន់តែសទ្ធាប៉ុណ្ណោះ តាមពិត ឧទ្ទករាមបុត្រគ្រាន់តែបានដឹង បានឃើញធម៌នេះប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតក៏បានចូលទៅរកឧទ្ទករាមបុត្រ លុះចូលទៅដល់ហើយ បានសួរឧទ្ទករាមបុត្រ

កិត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ(១) ។ ឯវំ វុត្តេ ភិក្ខវេ ឧទ្ទកោ រាមបុត្តោ នេវសញ្ញានាសញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ ន ខោ រាមស្សេវ អហោសិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ រាមស្សេវ អហោសិ វីរិយំ ។បេ។ សតិ... សមាធិ... បញ្ញា មយ្ហំបត្ថិ បញ្ញា យន្នូនាហំ យំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ ភិក្ខវេ នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថខ្វាហំ ភិក្ខវេ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ ឯត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។

១ ម. ឧបសម្បជ្ជ វិហរាមីតិ បវេទេសីតិ ទិស្សន្តិ ។



យ៉ាងនេះថា ម្នាលអាវុសោរាមៈ អ្នកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន បានសម្រេច ហើយប្រកាសទុក ដោយហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគត សួរយ៉ាងនេះហើយ ឧទ្ទករាមបុត្រ ក៏ប្រកាស នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឧទ្ទករាមបុត្រ មិនមានសទ្ធាទេ តថាគតទើបមានសទ្ធា ឧទ្ទករាមបុត្រ មិនមានព្យាយាមទេ ។បេ។ សតិ... សមាធិ...បញ្ញាទេ តថាគតទើបមានបញ្ញា បើដូច្នោះ គួរតែតថាគតប្រឹងប្រែងដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដែលឧទ្ទករាមបុត្រប្រកាសទុកថា អាត្មាអញបានសម្រេចហើយ ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួនឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ក៏បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះឆាប់ ពុំយូរឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតចូលទៅរកឧទ្ទករាមបុត្រ(ទៀត) លុះចូលទៅដល់ហើយ បានសួរឧទ្ទករាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ អ្នកបានសម្រេច ព្រោះធ្វើឲ្យជាក់ច្បាស់ នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួន ហើយប្រកាសទុក ដោយហេតុត្រឹមប៉ុណ្ណេះឬ ។

ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ ។ អហម្បិ ខោ អាវុសោ រាម ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ បស្សាម ឥតិ យំ ធម្មំ រាមោ សយំ អ-ភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេតិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ តំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេតិ ឥតិ យំ ធម្មំ រាមោ អញ្ញាសិ តំ ត្វំ ធម្មំ ជានាសិ យំ ត្វំ ធម្មំ ជានាសិ តំ ធម្មំ រាមោ អញ្ញាសិ ឥតិ យាទិសោ រាមោ អហោសិ តាទិសោ ត្វំ(១) យាទិ-សោ ត្វំ(២) តាទិសោ រាមោ អហោសិ ឯហិ ទានិ អាវុសោ

---
១-២ ម. យ. តុវំ ។



ឧទ្ទកៈរាមបុត្តតបថា ម្នាលអាវុសោ ខ្ញុំបានសម្រេច ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួនឯង ហើយប្រកាសនូវ ដោយហេតុតែប៉ុណ្ណេះ ។ តថាគតក៏និយាយថា ម្នាលអាវុសោរាមៈ ខ្ញុំឯងបានសម្រេចព្រោះធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លាខ្លួនឯង ចំពោះធម៌នេះ ដោយហេតុប៉ុណ្ណេះដែរ ។ ឧទ្ទកៈរាមបុត្តតបថា ម្នាលអាវុសោ យើងទាំងឡាយបានលាភហើយ អត្តភាពជាមនុស្ស យើងទាំងឡាយបានល្អហើយ ត្រង់ដែលយើងបានឃើញសព្រហ្មចារីបុគ្គល ប្រាកដដូចអ្នកមានអាយុ ព្រោះថា រាមៈ បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លាចំពោះខ្លួន បានសម្រេចនូវធម៌ណា ហើយប្រកាសនូវ អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លា របស់ខ្លួន បានសម្រេចធម៌នោះ ហើយនៅដោយឥរិយាបថទាំង ៤ ដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន ហើយបានសម្រេចធម៌ណា រាមៈ ក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លា របស់ខ្លួន បានសម្រេចធម៌នោះ ហើយប្រកាសនូវដែរ រាមៈ បានដឹងធម៌ណា អ្នកក៏បានដឹងធម៌នោះ អ្នកដឹងធម៌ណា រាមៈ ក៏ដឹងធម៌នោះដែរ មួយទៀត រាមៈ ប្រាកដយ៉ាងណា អ្នកក៏ប្រាកដយ៉ាងនោះ អ្នកប្រាកដយ៉ាងណា រាមៈ ក៏ប្រាកដយ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ ចូរអ្នកមក

តុវំ(១) គណំ បរិហរាតិ ។ ឥតិ ខោ ភិក្ខវេ ឧទ្ទកោ រាមបុត្តោ សព្រហ្មចារី មេ សមានោ អាចរិយដ្ឋានេ ច មំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ នាយំ ធម្មោ និព្ពិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្ពានាយ សំវត្តតិ យាវទេវ នេវសញ្ញានាសញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ ភិក្ខវេ តំ ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្ពិជ្ជ អបក្កមឹ ។

(៤៧) សោ ខោ(២) អហំ ភិក្ខវេ កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ មគធេសុ អនុបុព្វេន ចារិកញ្ចរមានោ យេន ឧរុវេលា សេនានិគមោ(៣) តទវសរឹ ។

១ ម. តុំ ឥមំ ។ ២ យុ. សោ កឹកុសលគវេសី ។ ៣ សេនានិគមោតិបិ បាឋោ ។ សេនានិគមោ សុជាតាយ បិតាភូតស្ស សេនានិនោ គាមោតិ អត្ថោ ។



ចូរគ្រប់គ្រងនូវគណៈនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ឧទ្ទកៈរាមបុត្រជាសព្រហ្មចារីរបស់តថាគត តាំងតថាគតក្នុងទីជាអាចារ្យ ទាំងបូជាតថាគតដោយការបូជាដ៏លើសលប់ ដោយហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌ គឺ សមាបត្តិទាំង ៨ នេះ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយចាកកិលេសវដ្ត មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកិលេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងដោយក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរលត់ទុក្ខទេ ប្រព្រឹត្តទៅបានត្រឹមតែចូលទៅកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ក៏មិនបានត្រេកអរធម៌នោះឡើយ នឿយណាយហើយដើរចេញអំពីធម៌នោះ ។

(៤៧) ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ជាអ្នកស្វែងរកកឹកុសល កំពុងតែស្វែងរកសន្តិវរបទ ក៏បានត្រាច់ទៅកាន់ចារិក ក្នុងដែនមគធៈតាមលំដាប់លំដោយ សំដៅទៅកាន់ឧរុវេលា(១) សេនានិគម(២) ។

១ ឧរុ ប្រែថា ខ្សាច់ វេលា ប្រែថា គំនរខ្សាច់ ប្រែឲ្យពេញថា គំនរខ្សាច់ធំ ។ ២ និគមជាទីនៅរបស់សេនា ។ មានពាក្យពោលថា ក្នុងដំបូងមនុស្សបានតាំងលំនៅនៅក្នុងទីនោះ ហេតុនោះបានជាលោកហៅថា សេនានិគម ឬហៅថា សេនានិគ្រាម ក៏បាន ។ ការពិតថា សេនានី នេះ ជាឈ្មោះបិតានាងសុជាតា ។

តត្ថទ្ទសំ រមណីយំ ភូមិភាគំ បាសាទិកញ្ច វនសណ្ឌំ នទិញ្ច សន្ទន្តឹ សេតកំ សុបតិត្ថំ រមណីយំ សមន្តា ច គោចរគ្គាមំ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ រមណីយោ វត(១) ភូមិភាគោ បាសាទិកោ ច វនសណ្ឌោ នទី ច សន្ទតិ សេតកា សុបតិត្ថា រមណីយា សមន្តា ច គោចរគ្គាមោ អលំ វតិទំ កុលបុត្តស្ស បធានត្ថិកស្ស បធានាយាតិ ។ សោ ខោ អហំ ភិក្ខវេ តត្ថេវ និសីទឹ អលមិទំ បធានាយាតិ ។

[៨៤]. សោ ខោ អហំ ភិក្ខវេ អត្តនា ជាតិធម្មោ សមានោ ជាតិធម្មេ អាទីនវំ វិទិត្វា អជាតំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសមានោ អជាតំ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមំ អត្តនា ជរាធម្មោ សមានោ... អត្តនា ព្យាធិធម្មោ សមានោ... អត្តនា មរណធម្មោ សមានោ... អត្តនា សោកធម្មោ សមានោ... អត្តនា សង្កិលេសធម្មោ សមានោ

១ ម. យោ វត ហោ ។



គង់ទីនោះ តថាគត បានឃើញនូវផែនដី គួរឲ្យត្រេកអរ ដងព្រៃគួរឲ្យកើតជ្រះថ្លាផង ស្ទឹងមានទឹកហូរស្អាតល្អ (មិនដាច់) មានកំពង់ទឹកស្មើល្អ គួរជាទីត្រេកអរផង ទាំងគោចរគ្រាម (ស្រុកសម្រាប់បិណ្ឌបាត) ក៏មាននៅជិតផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ភូមិភាគនេះ គួរឲ្យត្រេកអរផង ដងព្រៃគួរឲ្យកើតជ្រះថ្លាផង ស្ទឹងមានទឹកហូរស្អាតល្អមិនដាច់ មានកំពង់ទឹករាបស្មើល្អ គួរជាទីត្រេកអរផង គោចរគ្រាមក៏មាននៅជិតផង ទីនេះល្មមកុលបុត្រអ្នកត្រូវការដោយសេចក្តីព្យាយាម តាំងសេចក្តីព្យាយាមហើយតើ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង បានអង្គុយក្នុងទីនោះ ដោយគិតថា ទីនេះល្មមនឹងតាំងសេចក្តីព្យាយាមបាន ។

(៨៤) ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង មានជាតិជាធម្មតា ដោយខ្លួនឯង ដឹងទោសក្នុងសង្ខារមានជាតិជាធម៌ ហើយស្វែងរកនូវព្រះនិព្វានដែលមិនមានជាតិ មិនមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ក៏បានដល់នូវព្រះនិព្វានដែលមិនមានជាតិ រកមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ មានជរាជាធម្មតាដោយខ្លួនឯង...មានព្យាធិជាធម្មតាដោយខ្លួនឯង...មានមរណៈជាធម្មតាដោយខ្លួនឯង...មានសោកជាធម្មតាដោយខ្លួនឯង... មានសេចក្តីសៅហ្មងជាធម្មតា ដោយខ្លួនឯង

សង្កិលេសធម្មេ អាទីនវំ វិទិត្វា អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសមានោ អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមំ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

(៨៩) តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ អធិគតោ ខោ ម្យាយំ ធម្មោ គម្ភីរោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ អាលយរាមា ខោ បនាយំ បជា អាលយរតា អាលយសម្មុទិតា អាលយរាមាយ ខោ(១) បជាយ អាលយរតាយ អាលយសម្មុទិតាយ ទុទ្ទសំ ឥទំ ឋានំ យទិទំ ឥទប្បច្ចយតាបដិច្ចសមុប្បាទោ

១ ម. ឧ. ខោ បន ។



ឃើញទោសក្នុងសង្កិលេសធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានសង្កិលេសធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ បានដល់នូវព្រះនិព្វានដែលមិនមានសេចក្ដីសៅហ្មង ជាទីក្សេមចាកយោគៈ ដ៏ប្រសើរបំផុត តាំងញាណ ជាគ្រឿងឃើញ គឺ សព្វញ្ញុតញ្ញាណ ក៏កើតឡើងដល់តថាគតថា វិមុត្តិរបស់តថាគតមិនកំរើក (ដោយកាត់កិលេស) នេះជាតិជាទីបំផុត (របស់តថាគត) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ធម្មដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ជ្រាលជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់ ជាធម៌ឧត្តម ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះបាន ជាធម៌ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ឯពួកសត្វនេះ សុទ្ធតែកំពុងរីករាយក្នុងអាល័យ គឺ តណ្ហា ១០៨ កំពុងត្រេកត្រអាលក្នុងអាល័យ កំពុងស្រើបស្រាលក្នុងអាល័យ (ទៅតាមទាំងឡាយនោះឡើយ) ក៏បដិច្ចសមុប្បាទធម៌ ដែលជាបច្ច័យនៃធម៌មានសង្ខារជាដើមនេះ ជាហេតុដែលសត្វទៅរីករាយក្នុងអាល័យ ទៅត្រេកត្រអាលក្នុងអាល័យ ទៅស្រើបស្រាលក្នុងអាល័យ ឃើញបានដោយកម្រ

ឥទម្បិ ខោ ឋានំ ទុទ្ទសំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ អហញ្ចេវ ខោ បន ធម្មំ ទេសេយ្យំ បរេ ច មេ ន អាជានេយ្យុំ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។ អបិស្សុ មំ ភិក្ខវេ ឥមា អនច្ឆរិយា គាថា បដិភំសុ បុព្វេ អស្សុតបុព្វា

កិច្ឆេន មេ អធិគតំ
ហលន្ទានិ បកាសិតុំ
រាគទោសបរេតេហិ
នាយំ ធម្មោ សុសម្ពុធោ
បដិសោតគាមឹ និបុណំ
គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ
តមោក្ខន្ធេន អាវុតា(១)

ឥតិហ មេ(២) ភិក្ខវេ បដិសញ្ចិក្ខតោ អប្បោ-

១ ឱ. [illegible] ។ ម. អាវដាតិ ។ [illegible]



មួយទៀត ធម៌ណាដែលរម្ងាប់នូវសង្ខារទាំងពួងជាគ្រឿងលះបង់នូវឧបធិ គឺខន្ធ និងកិលេសទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរលត់ទុក្ខ គឺព្រះនិព្វាន ធម៌នេះជាហេតុដែលសត្វឃើញបានដោយកម្រដែរ បើទុកជាតថាគតសម្ដែងធម៌ទៅ ក៏ពួកសត្វដទៃ មិនអាចដឹងច្បាស់ទាំង នូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះ សេចក្ដីលំបាក សេចក្ដីនឿយព្រួយ មុខជានឹងមានដល់តថាគត មិនខាន ។ មួយទៀត គាថាទាំងឡាយ ដែលមិនជាអស្ចារ្យណាស់ណាទេ តថាគត មិនដែលបានឮមកក្នុងកាលមុនឡើយ ក៏ភ្លឺស្វាងដល់តថាគតថា

ឥឡូវនេះតថាគតមិនគួរសម្ដែងធម៌ ដែលតថាគតបានត្រាស់
ដឹងដោយលំបាក (នោះទេ) ព្រោះពួកសត្វដែលមានរាគៈ
ទោសៈគ្របសង្កត់ មិនងាយនឹងត្រាស់ដឹងធម៌នេះបានឡើយ
ពួកសត្វដែលត្រេកត្រអាល ដោយរាគៈ ដែលគំនរងងឹត គឺ
អវិជ្ជាគ្របសង្កត់ហើយ មុខជានឹងមិនឃើញធម៌ ដែលនាំ
សត្វឲ្យដល់ព្រះនិព្វាន ជាធម៌ល្អិតខ្លាំង ជ្រាលជ្រៅ សត្វ
ឃើញបានដោយកម្រនោះទេ ។

ម្នាលភិក្ខុទាំងឡាយ កាលតថាគត ពិចារណាឃើញដោយន័យដូច្នេះ

ស្សុក្កតាយ ចិត្តំ នមតិ នោ ធម្មទេសនាយាតិ ។

(៦០) អថខោ ភិក្ខវេ ព្រហ្មុនោ សហម្បតិស្ស មម ចេតសា ចេតោបរិវិតក្កមញ្ញាយ ឯតទហោសិ នស្សតិ វត ភោ លោកោ វិនស្សតិ វត ភោ លោកោ យត្រ ហិ នាម តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស អប្បោស្សុក្កតាយ ចិត្តំ នមតិ នោ ធម្មទេសនាយាតិ ។ អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ(១) ព្រហ្មលោកេ អន្តរហិតោ មម បុរតោ បាតុរហោសិ ។ អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា យេនាហំ តេនញ្ជលិំ បណាមេត្វា មំ ឯតទវោច ទេសេតុ ភន្តេ(២) ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ សន្តិ សត្តា អប្បរជក្ខជាតិកា

១ ម. ឯវមេវ ។ ២ ម. យ. ចេតិ ៦ ទិស្សតិ ។



ហើយ ចិត្តក៏ឱនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសំដែងធម៌ឡើយ ។

(៦០) ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្ម(១) បានដឹងនូវបរិវិតក្កក្នុងចិត្ត របស់តថាគតដោយចិត្ត (របស់ខ្លួន) ហើយក៏កើតគំនិតដូច្នេះថា ឱ សត្វលោកនឹងវិនាសហើយហ្ន៎ ឱ សត្វលោកនឹងវិនាសហើយហ្ន៎ ព្រោះព្រះហឫទ័យរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ បង្អោនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនបង្អោនទៅ ដើម្បីសំដែងធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ដូចជាបុរស ដែលមានកម្លាំង លាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែល លាចេញ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះមករកតថាគតពោល នឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ សូមព្រះសុគតទ្រង់សំដែងធម៌ ព្រោះពួកសត្វដែលមាន ធូលី គឺរាគាទិក្កិលេសដ៏ស្រាលស្ដើងក្នុងភ្នែកគឺបញ្ញាគង់មាន ព្រោះហេតុ

១ កាលពីក្នុងសាសនាព្រះពុទ្ធកស្សប ព្រហ្មនេះធ្លាប់កើតជាព្រះថេរៈ ១ អង្គឈ្មោះសហកៈ បានចំរើនបឋមជ្ឈានហើយទៅកើតជាព្រហ្មមានអាយុ ១ កប្បក្នុងជាន់បឋមជ្ឈានភូមិ បានជាហៅថា សហម្បតិ ។ អដ្ឋកថា ។

អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោតិ ។ ឥទមវោច ភិក្ខវេ ព្រហ្មា សហម្បតិ ឥទំ វត្វាន(១) អថាបរំ ឯតទវោច

បាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ
អបាបុរេតំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ
សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណំ(២) ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតំ
ឧដ្ឋេហិ វីរ វិជិតសង្គាម

១ ឧ. ម. វត្វា ។ ២. ម. សោកាតិណ្ណំ ។





តែមិនបានស្តាប់ធម៌ទើបនឹងសាបសូន្យមិនខាន ពួកសត្វដែលយល់ធម៌ ក៏គង់មានដែរ ។ ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃ តទៅទៀតថា

ក្នុងកាលមុន ធម៌ដែលពួកជន អ្នកប្រកបដោយមន្ទិលបាន
គិតហើយ ជាធម៌មិនបរិសុទ្ធ ក៏កើតប្រាកដហើយក្នុងដែន
មគធៈ សូមព្រះអង្គបើកទ្វារនៃព្រះនិព្វានចុះ ពួកសត្វប្រុងចាំ
ស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិល ទ្រង់ត្រាស់
ដឹងតាម (សំអាងព្រះពុទ្ធអភិប្បាយ) ដូចជាបុរសឈរ
លើកំពូលភ្នំថ្មសុទ្ធ គ្រឡេកមើលឃើញប្រជុំជន ដោយ
ជុំវិញខ្លួន យ៉ាងណាមិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ
មានបញ្ញាចក្ខុជុំវិញ ព្រះអង្គជាអ្នកមានសេចក្តីសោកទៅ
ប្រាសហើយ ស្តេចឡើងកាន់ប្រាសាទគឺធម៌ដែលមានឧបមា
យ៉ាងនោះ ពិចារណាមើលនូវប្រជុំជន អ្នកប្រឡូកដោយ
សេចក្តីសោក ដែលជាតិជរាគ្របសង្កត់ បពិត្រព្រះអង្គ
អ្នកមានព្យាយាម អ្នកឈ្នះនូវសង្គ្រាម ហើយជានាយកនៃ

សត្ថវាហ អនណ វិចរ លោកេ

ទេសេតុ[1] ភគវា ធម្មំ អញ្ញាតារោ ភវិស្សន្តិ ។

[៦១] អថខ្វាហំ[2] ភិក្ខវេ ព្រហ្មុនោ ច អជ្ឈេសនំ វិទិត្វា សត្តេសុ ច ការុញ្ញតំ បដិច្ច ពុទ្ធចក្ខុនា លោកំ វោលោកេសឹ ។ អទ្ទសំ ខោ អហំ ភិក្ខវេ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ[3] អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ សេយ្យថាបិ នាម ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ

១ ឱ. ទេសស្សុ ។ ២ ឱ. អថខោ អហំ ។ ៣ ឯកច្ចេ ភព្វេ អភព្វេ ពោធេ- តេ ទិស្សតិ ។



ពួកសត្វ អ្នកមិនជំពាក់បំណុលគឺកាម សូមព្រះអង្គត្រាច់ទៅ សូមស្តេចទៅកាន់លោក សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ ព្រោះ ពួកសត្វ អ្នកយល់ច្បាស់នូវធម៌ គឺនឹងមានដែរ ។

(៦១) ម្នាលភិក្ខុទាំងឡាយ គ្រានោះ តថាគតដឹងច្បាស់នូវសេចក្តីអារាធនារបស់សហម្បតិព្រហ្មផង អាស្រ័យសេចក្តីករុណាចំពោះពួកសត្វផង ទើបប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគត កំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក (ខ្លះ) មានធូលីច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយក្លៀវក្លា (ខ្លះ) មានឥន្ទ្រិយទន់ (ខ្លះ) មានអាការៈល្អ (ខ្លះ) មានអាការៈអាក្រក់ (ខ្លះ) ជាសត្វដែលតថាគតគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ (ខ្លះ) ជាអ្នកឃើញនូវទោសនិងភ័យក្នុងលោកខាងមុខខ្លះ ។ ដូចជាផ្កាដែលជាកំពូកខ្លះ គឺ ព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងត្រពាំងព្រលិតក្តី ក្នុងត្រពាំងឈូកក្រហមក្តី ក្នុងត្រពាំងឈូកសក្តី ដុះក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតឡើងតាមទឹក

អន្តោនិមុគ្គពោសិតានិ(១) អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ សមោទកដ្ឋិតានិ(២) អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកំ(៣) អច្ចុគ្គម្ម តិដ្ឋន្តិ អនុបលិត្តានិ ឧទកេន ឯវមេវ ខោ អហំ ភិក្ខវេ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទសំ សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ អថខ្វាហំ ភិក្ខវេ ព្រហ្មានំ សហម្បតឹ គាថាយ អជ្ឈភាសឹ

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ

១ ឱ. ម. អន្តោនិមុគ្គបោសីនិ ។ ២ ឱ. សំវឌ្ឍានិ សមោទកំ ឋិតានិ ។ ៣ ឱ. ឧទកា ។



លិចនៅក្នុងទឹក ដែលទឹកកំពុងចិញ្ចឹមនៅឡើយ មានផ្កាឧប្បលជាតិក្តីខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ដុះក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតឡើងតាមទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាឧប្បលជាតិក្តីខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ដុះក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះខ្ពស់ឡើងផុតទឹក មិនជាប់ដោយទឹក មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលតថាគតប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក (ខ្លះ) មានធូលីច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយក្លៀវក្លា (ខ្លះ) មានឥន្ទ្រិយទន់ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការអាក្រក់ (ខ្លះ) ជាសត្វដែលតថាគតគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយក្រ (ខ្លះ) ជាអ្នកឃើញនូវទោសនិងភ័យក្នុងលោកខាងមុខខ្លះ មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះតថាគតបានពោលតបនឹងសហម្បតិព្រហ្ម ដោយគាថា ថា

ទ្វារនៃព្រះនិព្វានទាំងនោះ តថាគតបានបើកហើយ ពួក
សត្វណា មានសោតប្រសាទ ពួកសត្វនោះ ចូរបញ្ចេញ

វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។

អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ កតាវកាសោ ខោម្ហិ ភគវតា ធម្មទេសនាយាតិ មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។

(៦៤) តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កស្ស នុ ខោ អហំ បឋមំ ធម្មំ ទេសេយ្យំ កោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ អយំ ខោ អាឡារោ កាលាមោ បណ្ឌិតោ វិយត្តោ មេធាវី ទីឃរត្តំ អប្បរជក្ខជាតិកោ យន្នូនាហំ អាឡារស្ស កាលាមស្ស បឋមំ ធម្មំ ទេសេយ្យំ សោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ អថខោ មំ ភិក្ខវេ ទេវតា ឧបសង្កមិត្វា ឯតទវោច សត្តាហកាលកតោ ភន្តេ អាឡារោ កាលាមោតិ ។





សត្វចុះ ម្នាលព្រហ្ម តថាគត មានសេចក្ដីសម្គាល់ ក្នុងការនាំឲ្យលំបាកកាយ ទើបអំពា បានជាមិនសំដែងធម៌ដ៏ឧត្តមដែលតថាគតស្ទាត់ហើយ ក្នុងពួកមនុស្សទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្ម គិតថា ខ្លួនអញជាបុគ្គល ដែលព្រះមានព្រះភាគ ទ្រង់ទទួលព្រម និងសំដែងធម៌ហើយ (លុះគិតដូច្នេះហើយ) ក៏ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណ បាត់អំពីទីនោះទៅ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលអញ គួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះ ឆាប់រហ័សបានហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះទៀតថា អាឡារកាលាមគោត្រនេះ ជាបណ្ឌិត ជាអ្នកឈ្លាសវៃ មានប្រាជ្ញា មានធូលី គឺកាមកិលេស តិចក្នុងភ្នែកស្រាប់ចង់យូរហើយ បើដូច្នោះ គួរតថាគតសំដែងធម៌ប្រោស អាឡារកាលាមគោត្រ ជាមុនចុះ កាលបើនោះ នឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មានទេវតាមួយអង្គ ចូលមករកតថាគត ហើយនិយាយយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អាឡារកាលាមគោត្រ ធ្វើកាលកិរិយា ៧ ថ្ងៃហើយ ។

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ សត្តាហកាល-
កតោ អាឡារោ កាលាមោតិ ។ តស្ស មយ្ហំ ភិក្ខវេ
ឯតទហោសិ មហាជានិយោ ខោ អាឡារោ កាលាមោ
សចេ ហិ សោ ឥមំ ធម្មំ សុណេយ្យ ខិប្បមេវ
អាជានេយ្យាតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ
កស្ស នុ ខោ បឋមំ ធម្មំ ទេសេយ្យំ កោ ឥមំ ធម្មំ
ខិប្បមេវ អាជានិស្សតីតិ ។ តស្ស មយ្ហំ ភិក្ខវេ
ឯតទហោសិ អយំ ខោ ឧទ្ទកោ រាមបុត្តោ បណ្ឌិតោ
វ្យត្តោ មេធាវី ទីឃរត្តំ អប្បរជក្ខជាតិកោ យន្នូនា-
ហំ ឧទ្ទកស្ស រាមបុត្តស្ស បឋមំ ធម្មំ ទេសេយ្យំ
សោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ អថ-
ខោ មំ ភិក្ខវេ ទេវតា ឧបសង្កមិត្វា ឯតទវោច(១)
អភិទោសកាលកតោ ភន្តេ ឧទ្ទកោ រាមបុត្តោតិ ។

១ ឱ. ម. ឯតទវោចុំ ។



ចំណែកខាងញាណទស្សនៈ របស់តថាគតក៏កើតឡើងថា អាឡារតាបស-
កាលាមគោត្រធ្វើកាលកិរិយា ៧ ថ្ងៃហើយមែន ។ ម្នាលភិក្ខុទាំងឡាយ
តថាគតនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាឡារតាបសកាលាម-
គោត្រនោះ ជាបុគ្គលមានសេចក្តីវិនាសធំ ព្រោះថាបើគាត់បានស្តាប់ធម៌
នេះ សឹងជាត្រាស់ដឹងធម៌មួយរំពេចបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត
នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ នឹងសម្តែងធម៌ដល់អ្នកណា
ជាមុនគេ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាននេះ ។ ម្នាលភិក្ខុ
ទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា ឧទ្ទកតា-
បសរាមបុត្រនេះឯង ជាបណ្ឌិត ជាអ្នកឈ្លាសវៃ មានប្រាជ្ញា មានធូលីតិច
ក្នុងភ្នែកស្រាប់យូរមកហើយ បើដូច្នោះគួរតថាគត សម្តែងធម៌ប្រោស
ឧទ្ទកតាបសរាមបុត្រជាមុនចុះ តាបសនោះ នឹងត្រាស់ដឹងធម៌នោះឆាប់
រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មានទេវតាអង្គមួយ ចូល
មកគាល់តថាគត ហើយនិយាយយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឧទ្ទក-
តាបសរាមបុត្រ ធ្វើកាលកិរិយា អំពីពេលកាត់កណ្តាលអធ្រាត្រហើយ ។

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អភិទោសកា-
លកតោ ឧទ្ទកោ រាមបុត្តោតិ ។ តស្ស មយ្ហំ
ភិក្ខវេ ឯតទហោសិ មហាជានិយោ ខោ ឧទ្ទកោ
រាមបុត្តោ សចេ ហិ សោ ឥមំ ធម្មំ សុណេយ្យ
ខិប្បមេវ អាជានេយ្យាតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯត-
ទហោសិ កស្ស នុ ខោ អហំ បឋមំ ធម្មំ ទេ-
សេយ្យំ កោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។
តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ ពហុការា ខោ មេ
បញ្ចវគ្គិយា ភិក្ខូ យេ មំ បធានបហិតត្តំ ឧបដ្ឋ-
ហឹសុ យន្នូនាហំ បញ្ចវគ្គិយានំ ភិក្ខូនំ បឋមំ ធម្មំ
ទេសេយ្យន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ
កហំ នុ ខោ ឯតរហិ បញ្ចវគ្គិយា ភិក្ខូ វិហរន្តីតិ ។
អទ្ទសំ ខោ ភិក្ខវេ ទិព្វេន ចក្ខុនា វិសុទ្ធេន អ-
តិក្កន្តមានុសកេន បញ្ចវគ្គិយេ ភិក្ខូ ពារាណសិយំ
វិហរន្តេ ឥសិបតនេ មិគទាយេ ។ អថខ្វាហំ ភិក្ខវេ
ឧរុវេលាយំ យថាភិរន្តំ វិហរិត្វា យេន ពារាណសី
តេន ចារិកំ បក្កាមឹ ។





ញាណទស្សនៈរបស់តថាគត ក៏កើតឡើងថា ឧទ្ទកតាបសរាមបុត្រ ធ្វើ-
កាលកិរិយាក៏ពេលពាក់កណ្តាលអធ្រាត្រទៅហើយមែន ។ ម្នាលភិក្ខុ
ទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឧទ្ទកតាបសរាម-
បុត្រនេះ ជាបុគ្គលមានសេចក្តីខាតធំ ព្រោះថាបើគាត់បានស្តាប់ធម៌នេះ
សមជាត្រាស់ដឹងធម៌មួយរំពេចបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ
មានសេចក្តីត្រិះរិះយ៉ាងនេះថា គាត្រាអញគួរសម្តែងធម៌ ប្រោសអ្នកណា
ជាមុនបង្អស់ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបានហ្ន៎ ។ ម្នាលភិក្ខុ
ទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា បញ្ចវគ្គិយ-
ភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់តថាគត ព្រោះបានបម្រើតថាគត
ដែលកំពុងបញ្ជូនចិត្តទៅកាន់ព្យាយាម បើដូច្នោះ គួរតថាគតសម្តែងធម៌
ប្រោសបញ្ចវគ្គិយភិក្ខុជាមុនចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មាន
សេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយនៅឯណា
ហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកបញ្ចវគ្គិយភិក្ខុនៅ
ក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធ
កន្លងលើសចក្ខុរបស់មនុស្សសាមញ្ញ ។ ម្នាលភិក្ខុទាំងឡាយ គ្រា-
នោះឯង តថាគត សម្រេចនិរិយាបថក្នុងឧរុវេលាប្រទេស តាមសមគួរ
ដល់អធ្យាស្រ័យ ហើយចៀសចេញទៅកាន់ចារិកក្នុងក្រុងពារាណសី ។

[៦៣] អទ្ទសា ខោ មំ ភិក្ខវេ ឧបកោ អាជីវកោ អន្តរា ច គយំ អន្តរា ច ពោធឹ អទ្ធានមគ្គប្បដិបន្នំ ទិស្វាន មំ ឯតទវោច វិប្បសន្នានិ ខោ តេ អាវុសោ ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ កំសិ ត្វំ អាវុសោ ឧទ្ទិស្ស បព្វជិតោ កោ វា តេ សត្ថា កស្ស វា ត្វំ ធម្មំ រោចេសីតិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ ឧបកំ អាជីវកំ គាថាយ អជ្ឈភាសឹ

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ

ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ





[៦៣] ម្នាលភិក្ខុទាំងឡាយ មានអាជីវកម្នាក់ឈ្មោះឧបក: បានឃើញតថាគតកំពុងដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃគយានិងពោធិព្រឹក្ស លុះឃើញហើយ ក៏និយាយនឹងតថាគតយ៉ាងនេះថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយ របស់អ្នកថ្លាណាស់ ពណ៌សម្បុរផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា ។ ម្នាលភិក្ខុទាំងឡាយ កាលបើឧបកាជីវក សួរយ៉ាងនេះហើយ តថាគតក៏ឆ្លើយតបដោយពាក្យជាគាថា ទៅកាន់ឧបកាជីវកថា

តថាគតជាអ្នកគ្របសង្កត់នូវគ្រប់ធម៌ទាំងអស់ ត្រាស់ដឹង
នូវគ្រប់ធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុង-
គ្រប់ធម៌ទាំងអស់ បានលះបង់ នូវគ្រប់ធម៌ទាំងអស់
ហើយ មានចិត្តផុតស្រឡះ ព្រោះអស់ទៅនៃតណ្ហាហើយ
ដឹងច្បាស់នូវគ្រប់ធម៌ ដោយខ្លួនឯង ចាំបាច់ចំពោះគ្រូ
ណា តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលស្មើនឹង

សទេវកស្មិំ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ

អហញ្ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ

ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ

ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ

អន្ធីភូតស្មិំ លោកស្មឹ អាហញ្ឆឹ អមតទុន្ទុភិន្តិ ។

យថា ខោ ត្វំ អាវុសោ បដិជានាសិ អរហសិ

អនន្តជិនោតិ ។

មាទិសា វេ ជិនា ហោន្តិ

យេ បត្តា អាសវក្ខយំ

ជិតា មេ បាបកា ធម្មា

តស្មាហំ ឧបក ជិនោតិ ។





តថាគតនេះ ក្នុងលោកនេះ ព្រមទាំងទេវលោក ក៏មិនមាន
បុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះថា តថាគត
ជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត ជាអ្នកត្រាស់ដឹង
ដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់ មាន
ភ្លើងកិលេសរលត់ហើយ ឥឡូវតថាគត ទៅកាន់ក្រុងនៃពួក
ជនអ្នកកាសី ដើម្បីនឹងសំដែងធម្មចក្ក (ដោយបំណងថា)
តថាគត នឹងវាយស្គរដ៏ជាអមតនិព្វាន ចំពោះសត្វលោក
ដែលងងឹត គឺ អវិជ្ជាគ្របសង្កត់ ។

ឧបកាជីវកតបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួន យ៉ាងណា អ្នក
គួរ(នឹងបានឈ្មោះ) ថា អនន្តជិនៈ (យ៉ាងនោះឯង) ។ តថាគត
ក៏ពោលគាថាថ្លែងទៀត ថា

ជនទាំងឡាយណា បានដល់នូវធម៌ សម្រាប់ក្ស័យអាសវៈឲ្យ
អស់ទៅ ជនទាំងឡាយនោះ ឈ្មោះថា ជិនៈ (អ្នកឈ្នះ
កិលេស) ព្រោះជនដូចជាតថាគតដែរ តថាគត បានឈ្នះ
បាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ
ទើបតថាគត បានឈ្មោះថា ជិនៈ ។

ឯវំ វុត្តេ ភិក្ខវេ សោ ឧបកោ ហុវេយ្យាវុសោតិ(១) វត្វា សីសំ ឱកម្បេត្វា ឧម្មគ្គំ គហេត្វា បក្កាមិ ។

(៦៤) អថខ្វាហំ ភិក្ខវេ អនុបុព្វេន ចារិកំ ចរមានោ យេន ពារាណសី យេន ឥសិបតនំ មិគទាយោ យេន បញ្ចវគ្គិយា ភិក្ខូ តេនុបសង្កមឹ ។ អទ្ទសំសុ ខោ មំ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ ទូរតោវ អាគច្ឆន្តំ ទិស្វាន អញ្ញមញ្ញំ សណ្ឋបេសុំ អយំ ខោ(២) អាវុសោ សមណោ គោតមោ អាគច្ឆតិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ សោ នេវ អភិវាទេតព្វោ ន បច្ចុដ្ឋាតព្វោ នាស្ស បត្តចីវរំ បដិគ្គហេតព្វំ អបិច ខោ អាសនំ ឋបេតព្វំ សចេ អាកង្ខិស្សតិ និសីទិស្សតីតិ ។ យថា យថា ខោ អហំ ភិក្ខវេ ឧបសង្កមឹ(៣) តថា តថា បញ្ចវគ្គិយា ភិក្ខូ នាសក្ខឹសុ សកាយ កតិកាយ សណ្ឋាតុំ អប្បេកច្ចេ មំ បច្ចុគ្គន្ត្វា

១ ម. ហុវេយ្យាវុសោតិ ទិស្សតិ ។ ២ ម. ខោតិ ន ទិស្សតិ ។ ៣ ម. ឧបសង្កមាមិ ។



ម្នាលភិក្ខុទាំងឡាយ កាលបើតថាគត ពោលយ៉ាងនេះហើយ ឧបកាជីវកនោះ ក៏និយាយថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹងពិតមែនហើយ (ថាហើយ) ក៏ងក់ក្បាល កាន់យកផ្លូវខុស គឺ ផ្លូវបែកគ្នាចៀសចេញទៅ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគត ត្រាច់ទៅកាន់ចារិកតាមលំដាប់ ចូលទៅរកបញ្ចវគ្គិយភិក្ខុ ឯឥសិបតនមិគទាយវ័ននៅទៀបក្រុងពារាណសីនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកបញ្ចវគ្គិយភិក្ខុ បានឃើញតថាគតដើរមកអំពីចម្ងាយ លុះឃើញហើយក៏ប្តេជ្ញាគ្នាថា នេះហើយ សមណគោតម ដ៏អ្នកលោភច្រើន ឃ្លាតចាកព្យាយាម វិលត្រឡប់មកដើម្បីភាពជាអ្នកលោភច្រើន កំពុងតែដើរមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលបាត្រនិងចីវររបស់លោកទេ ប៉ុន្តែពួកយើង គួរក្រាលអាសនៈបម្រុងទុក បើលោកចង់គង់ ក៏គង់ចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ចូលទៅដោយប្រការយ៉ាងណា ៗ ពួកបញ្ចវគ្គិយភិក្ខុ ក៏មិនអាចនឹងឋិតនៅក្នុងពាក្យប្តេជ្ញារបស់ខ្លួន ដោយប្រការយ៉ាងនោះៗបានឡើយ ខ្លះក៏ក្រោកទទួលតថាគត

បត្តចីវរំ បដិគ្គហេសុំ អប្បេកច្ចេ អាសនំ បញ្ញាបេសុំ អប្បេកច្ចេ បាទោទកំ ឧបដ្ឋបេសុំ អបិច ខោ មំ នាមេន ច អាវុសោវាទេន ច សមុទាចរន្តិ ។ (១)អហំ ភិក្ខវេ បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ មា ភិក្ខវេ តថាគតំ នាមេន ច អាវុសោវាទេន ច សមុទាចរថ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ ឱទហថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ បដិបជ្ជមានា(២) ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ ឯវំ វុត្តេ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ មំ ឯតទវោចុំ

១ ម. ម. ឥត្តត្ថេ វាចំ វុត្តេតិ ទិស្សតិ ។ ២ ម. ម. តថាបដិបជ្ជមានា ។



ហើយទទួលបាត្រចីវរ ខ្លះក្រាលអាសនៈ ខ្លះតម្កល់ទឹកសម្រាប់លាងជើង ប៉ុន្តែហៅតថាគតចំពោះឈ្មោះខ្លះ ដោយពាក្យថា អាវុសោខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត បាននិយាយពាក្យនេះនឹងពួកបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំហៅតថាគតចំពោះឈ្មោះ ទាំងកុំហៅអាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគត បានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរផ្ទៀងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ តថាគតនឹងសំដែងធម៌ ពួកកុលបុត្រទាំងឡាយដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិតាមពាក្យប្រដៅ របស់តថាគតហើយ កុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតបាននិយាយយ៉ាងនេះហើយ ពួកបញ្ចវគ្គិយភិក្ខុបាននិយាយនឹងតថាគត យ៉ាងនេះថា

តាយបិ ខោ ត្វំ អាវុសោ គោតម ឥរិយាយ តាយ បដិបទាយ តាយ ទុក្ករការិកាយ នាជ្ឈគមា ឧត្តរិ-មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ កឹ បន ត្វំ ឯតរហិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពា-ហុល្លាយ អធិគមិស្សសិ ឧត្តរិមនុស្សធម្មា អលមរិយ-ញាណទស្សនវិសេសន្តិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ បញ្ច-វគ្គិយេ ភិក្ខូ ឯតទវោចំ ន ភិក្ខវេ តថាគតោ ពាហុល្លិ-កោ ន បធានវិព្ភន្តោ ន អាវត្តោ ពាហុល្លាយ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ ឱទហថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ



ម្នាលអាវុសោគោតម សូម្បីដោយសេចក្តីព្យាយាមនោះ ដោយសេចក្តីប្រតិបត្តិនោះ ដោយទុក្ករកិរិយា (ដែលបានធ្វើរួចមកហើយ) នោះ ម្តេចគង់លោកមិនបានត្រាស់ដឹង នូវគុណវិសេស គឺញាណទស្សនៈ ដ៏គួរធ្វើនូវឲ្យជាអរិយៈ ក្រៃលែងជាងមនុស្សធម៌ ចំណាន់ពេលឥឡូវនេះ លោកប្រតិបត្តិដើម្បីលោភច្រើន ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីលោភៈច្រើនហើយ នឹងត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈគួរធ្វើនូវឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ ដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ លុះពួកបញ្ចវគ្គិយភិក្ខុ និយាយយ៉ាងនេះហើយ ទើបតថាគត ពោលនឹងពួកបញ្ចវគ្គិយភិក្ខុ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគត មិនមែនប្រតិបត្តិដើម្បីលោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់មកដើម្បីលោភៈច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថា-គត បានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរប្រុងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅនូវព្រះអមតធម ដែលតថាគតត្រាស់ដឹងហើយ តថាគតនឹងសំដែងធម៌ កាលបើអ្នកទាំង-

យថានុសិដ្ឋំ បដិបជ្ជមានា ន ចិរស្សេវ យស្សត្ថា-
យ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ
តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ
អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ ទុតិ-
យម្បិ ខោ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ មំ ឯតទវោចុំ តា-
យបិ ខោ ត្វំ អាវុសោ គោតម ឥរិយាយ តាយ បដិប-
ទាយ តាយ ទុក្ករការិកាយ នាជ្ឈគមា ឧត្តរិមនុស្ស-
ធម្មា អលមរិយញាណទស្សនវិសេសំ កឹ បន ត្វំ ឯ-
តរហិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ
អធិគមិស្សសិ ឧត្តរិមនុស្សធម្មា អលមរិយញាណ-
ទស្សនវិសេសន្តិ ។ ទុតិយម្បិ ខោ អហំ ភិក្ខវេ
បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ ន ភិក្ខវេ តថាគតោ



ទាំងឡាយ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ដោយប្រពៃ ដើម្បីប្រយោ-
ជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិ តាមដែល
ពាក្យប្រដៅរបស់តថាគតហើយ កុំយូរឡើយ មុខជានឹងធ្វើឲ្យជាក់ច្បាស់
ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃ
មគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាល
ភិក្ខុទាំងឡាយ ពួកបញ្ចវគ្គិយភិក្ខុទៅតែនិយាយនឹងតថាគត ជាគម្រប់ពីរ
ដងទៀតយ៉ាងនេះថា ម្នាលអាវុសោគោតម សូម្បីដោយសេចក្តីព្យា-
យាមនោះ ដោយបដិបទានោះ ដោយទុក្ករកិរិយានោះ ម្តេចក៏លោក
មិនបានត្រាស់ដឹង នូវគុណវិសេស គឺញាណទស្សនៈ គាប់ធ្វើខ្លួនឲ្យជា
អរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ ចំណាន់បើឥឡូវនេះ លោកប្រព្រឹ-
ត្តិដើម្បីលាភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មក
ដើម្បីលាភច្រើនហើយ នឹងបានត្រាស់ដឹងគុណវិសេសគឺញាណទស្សនៈ
គាប់ធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ ដូចម្តេចបាន ។
ម្នាលភិក្ខុទាំងឡាយ តថាគតបានពោលនឹងពួកបញ្ចវគ្គិយភិក្ខុ ជាគម្រប់
ពីរដងទៀតយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិ

ពាហុល្លិកោ ។ បេ ។ ឧបសម្បជ្ជ វិហរិស្សថាតិ ។ ទុតិយម្បិ ខោ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ មំ ឯតទវោចុំ តាយបិ ខោ ត្វំ អាវុសោ គោតម ឥរិយាយ តាយ បដិបទាយ តាយ ទុក្ករការិកាយ នាជ្ឈគមា ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ កឹ បន ត្វំ ឯតរហិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ អធិគមិស្សសិ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសន្តិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ អភិជានាថ មេ នោ តុម្ហេ ភិក្ខវេ ឥតោ បុព្វេ ឯវរូបំ ភាសិតមេតន្តិ ។ នោ ហេតំ ភន្តេ ។ ន ភិក្ខវេ តថាគតោ



ដើម្បីលោភច្រើនទេ ។ បេ ។ នឹងសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកបញ្ចវគ្គិយភិក្ខុ បាននិយាយនឹងតថាគត ជាគម្រប់ពីរដងទៀត យ៉ាងនេះថា ម្នាលអាវុសោ គោតម សូម្បីដោយឥរិយាបថនោះ ដោយបដិបទានោះ ដោយទុក្ករកិរិយានោះ ម្តងលោកមិនបានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈ ដែលធ្វើនូវខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ ចំណាន់បើឥឡូវនេះ លោកប្រព្រឹត្តដើម្បីលោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីលោភច្រើនហើយ នឹងបានត្រាស់ដឹងនូវគុណវិសេសគឺញាណទស្សនៈដែលធ្វើនូវខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ ដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកបញ្ចវគ្គិយភិក្ខុ និយាយយ៉ាងនេះហើយ តថាគតបានពោលនឹងពួកបញ្ចវគ្គិយភិក្ខុយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចាំបាននូវពាក្យនេះដែលតថាគតនិយាយយ៉ាងនេះ ក្នុងកាលមុន អំពីកាលឥឡូវនេះដែរឬទេ ។ ពួកបញ្ចវគ្គិយភិក្ខុ តបថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនធ្លាប់ឮពាក្យនុ៎ះទេ ។ តថាគតក៏និយាយថែមទៀតថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនជាអ្នកលោភច្រើនទេ

ពាហុល្លិកោ ន បធានវិព្ភន្តោ ន អាវត្តោ ពាហុល្លាយ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ ឱទហថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសា-សាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា បដិបជ្ជមានា នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ អសក្ខឹ ខោ អហំ ភិក្ខវេ បញ្ចវគ្គិយេ ភិក្ខូ សញ្ញាបេតុំ ។ ទ្វេបិ សុទំ ភិក្ខវេ ភិក្ខូ ឱវទាមិ តយោ ភិក្ខូ បិណ្ឌាយ ចរន្តិ យំ តយោ ភិក្ខូ បិណ្ឌា-យ ចរិត្វា អាហរន្តិ តេន ឆព្ពគ្គា យាបេម ។ តយោបិ សុទំ ភិក្ខវេ ភិក្ខូ ឱវទាមិ ទ្វេបិ ភិក្ខូ



មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់មករកដើម្បីល្មោភច្រើនទេ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរផ្ទៀងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅ នូវព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ តថាគតនឹងសម្តែងធម៌ កុលបុត្រទាំងឡាយចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមពាក្យប្រដៅរបស់តថាគតហើយ កុំយូរឡើយមុខជានឹងធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏អាចឲ្យពួកបញ្ចវគ្គិយភិក្ខុ យល់ច្បាស់បាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតទូន្មានភិក្ខុ ២ រូប ភិក្ខុ ៣ រូបត្រាច់ទៅបិណ្ឌបាត ឯភិក្ខុ ៣ រូប ដែលត្រាច់ទៅបិណ្ឌបាត នាំយកបន្ទាប់បិណ្ឌបាតណាមក យើងទាំង ៦ នាក់ ចិញ្ចឹមជីវិតដោយសារបន្ទាប់បិណ្ឌបាតនោះ ។ តថាគតទូន្មានភិក្ខុ ៣ រូប ឯភិក្ខុ ២ រូប ក៏

បិណ្ឌាយ ចរន្តិ យំ ទ្វេ ភិក្ខូ បិណ្ឌាយ ចរិត្វា អាហរន្តិ តេន ឆព្វគ្គា យាបេម ។ អថខោ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ មយា ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អត្តនា ជាតិធម្មា សមានា ជាតិធម្មេ អាទីនវំ វិទិត្វា អជាតំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសមានា អជាតំ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមំសុ អត្តនា ជរាធម្មា សមានា ជរាធម្មេ អាទីនវំ វិទិត្វា អជរំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសមានា អជរំ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមំសុ អត្តនា ព្យាធិធម្មា សមានា ។ បេ ។ អត្តនា មរណធម្មា សមានា ... អត្តនា សោកធម្មា សមានា ... អត្តនា សង្កិលេសធម្មា សមានា សង្កិលេសធម្មេ អាទីនវំ វិទិត្វា អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសមានា អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមំសុ ។



ត្រាច់ទៅបិណ្ឌបាត ភិក្ខុ ២ រូបដែលត្រាច់ទៅបិណ្ឌបាត នាំយកចង្ហាន់បិណ្ឌបាតណាមក យើងទាំង ៦ នាក់ ក៏ចិញ្ចឹមជីវិតដោយសារចង្ហាន់បិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ពួកបញ្ចវគ្គិយភិក្ខុ កាលដែលតថាគតឲ្វាទយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានជាតិធម៌ ជាគុណជាតដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ហើយក៏បានដល់នូវព្រះនិព្វាន ដែលមិនមានជាតិធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា បានដឹងច្បាស់ នូវទោសក្នុងជរាធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានជរាធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ហើយក៏បានដល់នូវព្រះនិព្វានដែលមិនមានជរាធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា ។ បេ ។ ខ្លួនឯងមានមរណៈជាធម្មតា ... ខ្លួនឯងមានសោកជាធម្មតា ... ខ្លួនឯងមានសេចក្ដីសៅហ្មងជាធម្មតា បានដឹងច្បាស់នូវទោសក្នុងសង្កិលេសធម៌ហើយស្វែងរកនូវព្រះនិព្វាន ដែលមិនមានសង្កិលេសជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ហើយក៏បានដល់នូវព្រះនិព្វានដែលមិនមានសង្កិលេសធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ។

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ(១) វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

(២៥) បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ។បេ។ ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា .. កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។ យេ កេចិ(២) ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេ បញ្ច កាមគុណេ គធិតា មុច្ឆិតា អជ្ឈោបន្នា អនាទីនវទស្សាវិនោ អនិស្សរណបញ្ញា បរិភុញ្ជន្តិ តេ ឯវមស្សុ វេទិតព្វា អនយមាបន្នា ព្យសនមាបន្នា យថាកាមករណីយា បាបិមតោ ។

១ ម. មេសំ ។ ២ ឱ. ម. យេហិ កេចិ ។



ចំណែកញាណទស្សនៈក៏កើតឡើង ដល់បញ្ចវគ្គិយភិក្ខុទាំងឡាយនោះថា វិមុត្តិរបស់យើង មិនកម្រើក (ដោយកិលេស)ទេ នេះជាជាតិជាទីបំផុត ឥឡូវភពថ្មីទៀត ក៏មិនមានឡើយ ។

(២៥) ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការ តើដូចម្តេច គឺ រូបទាំងឡាយដែលគប្បីដឹងបានដោយចក្ខុ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរត្រេកអរ ១ សំឡេងដែលគប្បីដឹងបានដោយសោតៈ ។បេ។ ក្លិនដែលគប្បីដឹងបានដោយឃានៈ... រសដែលគប្បីដឹងបានដោយជិវ្ហា... សម្ផស្សទាំងឡាយដែលគប្បីដឹងបានដោយកាយ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯង កាមគុណមាន ៥ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ ណាមួយ ជាអ្នកមានចិត្តរឹតត្បឹត លង់លក់ ជាអ្នកមិនឃើញទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ (បច្ចវេក្ខណញ្ញាណ) តែងបរិភោគកាមគុណទាំង ៥ នេះ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ជាអ្នកត្រូវមារមានចិត្តបាបធ្វើទៅតាមសេចក្តីប្រាថ្នាបាន ។

(៦៦) សេយ្យថាបិ ភិក្ខវេ អារញ្ញកោ មិគោ ពទ្ធោ(១) បាសរាសឹ អធិសយេយ្យ សោ ឯវមស្ស វេទិតព្វោ អនយមាបន្នោ ព្យសនមាបន្នោ យថាកាមករណីយោ លុទ្ទស្ស អាគច្ឆន្តេ ច លុទ្ទេ ន យេនកាមំ បក្កមិស្សតីតិ ឯវមេវ ខោ ភិក្ខវេ យេ កេចិ សមណា វា ព្រាហ្មណា វា ឥមេ បញ្ច កាមគុណេ គធិតា មុច្ឆិតា អជ្ឈោបន្នា អនាទីនវទស្សាវិនោ អនិស្សរណបញ្ញា បរិភុញ្ជន្តិ តេ ឯវមស្សុ វេទិតព្វា អនយមាបន្នា ព្យសនមាបន្នា យថាកាមករណីយា បាបិមតោ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេ បញ្ច កាមគុណេ អគធិតា អមុច្ឆិតា អនជ្ឈោបន្នា អាទីនវទស្សាវិនោ និស្សរណបញ្ញា បរិភុញ្ជន្តិ តេ ឯវមស្សុ វេទិតព្វា ន អនយមាបន្នា ន ព្យសនមាបន្នា

១ ម. ព. ពទ្ធោ ។



(៦៦) ម្នាលភិក្ខុទាំងឡាយ ដូចជាម្រឹគនៅក្នុងព្រៃដែលជាប់ (អន្ទាក់) ហើយ គប្បីដេកសង្កត់គំនរអន្ទាក់ ម្រឹគនោះបណ្ឌិតគប្បីជ្រាប យ៉ាងនេះថា ជាសត្វដល់នូវសេចក្តីមិនចំរើន ដល់នូវសេចក្តីវិនាស ជាសត្វដែលព្រានគឺធ្វើទៅតាមសេចក្តីប្រាថ្នាបាន កាលបើព្រានដើរមកដល់ ម្រឹគនោះនឹងស្ទុះចេញទៅ តាមចំណង់ពុំបានឡើយ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តជើកជ្រប់ លង់ស៊ប់ ជាអ្នកមិនឃើញទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវកាមគុណទាំង ៥ នេះឯង សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកដល់នូវសេចក្តីមិនចំរើន ដល់នូវសេចក្តីវិនាស ជាអ្នកដែលមារមានចិត្តបាបធ្វើទៅតាមសេចក្តីប្រាថ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តមិនជើក មិនជ្រប់ មិនលង់ស៊ប់ ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ តែងបរិភោគកាមគុណទាំង ៥ នេះ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាប យ៉ាងនេះថា ជាអ្នកមិនដល់នូវសេចក្តីមិនចំរើន មិនដល់នូវសេចក្តីវិនាស

ន យថាកាមករណីយា បាបិមតោ ។ សេយ្យថាបិ ភិក្ខវេ អារញ្ញកោ មិគោ អពទ្ធោ បាសរាសឹ អធិសយេយ្យ សោ ឯវមស្ស វេទិតព្វោ ន អនយមាបន្នោ ន ព្យសនមាបន្នោ ន យថាកាមករណីយោ លុទ្ទស្ស អាគច្ឆន្តេ ច បន លុទ្ទេ យេនកាមំ បក្កមិស្សតីតិ ឯវមេវ ខោ ភិក្ខវេ យេ កេចិ សមណា វា ព្រាហ្មណា វា ឥមេ បញ្ច កាមគុណេ អគធិតា អមុច្ឆិតា អនជ្ឈោបន្នា អាទីនវទស្សាវិនោ និស្សរណបញ្ញា បរិភុញ្ជន្តិ តេ ឯវមស្សុ វេទិតព្វា ន អនយមាបន្នា ន ព្យសនមាបន្នា ន យថាកាមករណីយា បាបិមតោ ។ សេយ្យថាបិ ភិក្ខវេ អារញ្ញកោ មិគោ អរញ្ញេ បវនេ ចរមានោ វិស្សដ្ឋោ គច្ឆតិ វិស្សដ្ឋោ តិដ្ឋតិ វិស្សដ្ឋោ និសីទតិ វិស្សដ្ឋោ សេយ្យំ កប្បេតិ តំ កិស្ស ហេតុ អនាបាថគតោ ភិក្ខវេ លុទ្ទស្ស





ជាអ្នកមិនត្រូវមារមានចិត្តបាបធ្វើទៅតាមសេចក្តីប្រាថ្នាបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាម្រឹគ ដែលនៅក្នុងព្រៃ មិនជាប់ (អន្ទាក់) តែដេកសង្កត់លើគំនរអន្ទាក់ ម្រឹគនោះ បណ្ឌិត គប្បីជ្រាបយ៉ាងនេះថា ជាសត្វមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស ជាសត្វមិនត្រូវព្រានធ្វើទៅតាមសេចក្តីប្រាថ្នាបាន ទុកជាព្រានដើរមកដល់ ម្រឹគនោះនឹងស្ទុះទៅតាមសេចក្តីប្រាថ្នារបស់ខ្លួនបាន សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តមិនគ្រឿក មិនជ្រប់ មិនលង់លក់ ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ តែនៅបរិភោគកាមគុណទាំង ៥ នេះនៅឡើយ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស ជាអ្នកមិនត្រូវមារមានចិត្តបាប ធ្វើទៅតាមសេចក្តីប្រាថ្នាបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ម្រឹគដែលនៅក្នុងព្រៃ ត្រាច់ទៅក្នុងព្រៃស្តុក ព្រៃធំ តែងដើរទៅឥតរង្កៀស ឈរក៏ឥតរង្កៀស អង្គុយក៏ឥតរង្កៀស សម្រេចការដេកក៏ឥតរង្កៀស ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រឹគនោះមិនបានប្រទះនឹងព្រាន សេចក្តីនេះមានឧបមា

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុស-
លេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ
ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ
អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ
គតោ បាបិមតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិ-
ចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯ-
កោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ
ឈានំ ... តតិយំ ឈានំ ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ
វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ
អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។
បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ រូបសញ្ញានំ សម-
តិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមន-
សិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ
ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ



យ៉ាងណាមិញ ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុ-
សលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កៈ វិចារៈ
មានបីតិនិងសុខៈដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ
គេហៅថាបានធ្វើមារឲ្យខ្វាក់ បំបាត់ភ្នែកមារមិនឲ្យឃើញស្នាមជើង
ទៅកាន់ទីដែលមារមានចក្ខុបាបមើលមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ
មួយវិញទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កៈវិចារៈបានហើយ ក៏ចូលទៅកាន់ទុតិយ-
ជ្ឈាន ជាទីផូរផង់នៃសន្តាន មានការរំងាប់ចិត្តដ៏ប្រសើរ ឥតមានវិតក្កៈ
វិចារៈឡើយ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ...ចូលកាន់តតិ-
យជ្ឈាន... ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះគេហៅថាបាន
ធ្វើមារឲ្យខ្វាក់ បំបាត់ភ្នែកមារមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែល
មារមានចក្ខុបាបមើលមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត
ភិក្ខុព្រោះកន្លង នូវរូបសញ្ញា ព្រោះវិនាសទៅនៃបដិឃសញ្ញា
ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូល
កាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាស មិនមានទី
បំផុតដូច្នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ គេហៅថា បានធ្វើ

អន្តមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ បញ្ញាយ បស្ស[១] ទិស្វា អាសវា បរិក្ខីណា ហោន្តិ អយំ

១ ម. បញ្ញាយបស្ស ។



មារឲ្យខ្វាក់ បំបាត់នូវភ្នែកមារមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែលមារមានចិត្តបាបមើលមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់ នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិតនិរោធ ។ អាសវៈទាំងឡាយ របស់ភិក្ខុនោះ ក៏អស់ទៅ ព្រោះឃើញច្បាស់ (នូវអរិយសច្ចធម៌) ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ

វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។ តិណ្ណោ លោកេ វិសត្តិកំ សោ វិសដ្ឋោ គច្ឆតិ វិសដ្ឋោ តិដ្ឋតិ វិសដ្ឋោ និសីទតិ វិសដ្ឋោ សេយ្យំ កប្បេតិ តំ កិស្ស ហេតុ អនាបាថគតោ ភិក្ខវេ បាបិមតោតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

បាសរាសិសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

---



គឺជាគេហៅថាបានធ្វើមារឲ្យខ្វាក់ បំបាំងភ្នែកមារមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែលមារមានចិត្តបាបមើលមិនឃើញ ។ ភិក្ខុនោះឆ្លងនូវតណ្ហា ដែលមានការជំពាក់ផ្សាយទៅ ក្នុងលោកនេះបានហើយ ជាអ្នកដើរទៅតាមស្រួល ឈរក៏តាមស្រួល អង្គុយក៏តាមស្រួល សម្រេចនូវការដេកក៏តាមស្រួល ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) ភិក្ខុនោះមិនបានមកកាន់ផ្លូវចក្ខុ របស់មារមានចិត្តបាបទៀតឡើយ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ បាសរាសិសូត្រទី ៦

## សត្តមំ ចូឡហត្ថិបទោបមសុត្តំ

(២៧) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ជាណុស្សោណិ ព្រាហ្មណោ សព្វសេតេន វឡវាភិរថេន(១) សាវត្ថិយា និយ្យាតិ ទិវាទិវស្ស ។ អទ្ទសា ខោ ជាណុស្សោណិ ព្រាហ្មណោ បិលោតិកំ បរិព្វាជកំ ទូរតោវ អាគច្ឆន្តំ ទិស្វាន បិលោតិកំ បរិព្វាជកំ ឯតទវោច ហន្ទ កុតោ នុ ភវំ វច្ឆាយនោ អាគច្ឆតិ ទិវាទិវស្សាតិ ។ ឥតោ ហិ ខោ អហំ ភោ អាគច្ឆាមិ សមណស្ស គោតមស្ស សន្តិកាតិ ។ តំ កិំ ភវំ(២) គោតមស្ស បញ្ញាវេយ្យត្តិយំ បណ្ឌិតោ មញ្ញេតីតិ ។ កោ ចាហំ ភោ(៣) សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានិស្សាមិ សោបិ នូនស្ស តាទិសោវ យោ សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានេយ្យាតិ ។ ឧឡារាយ ខលុ ភវំ វច្ឆាយនោ សមណំ គោតមំ បសំសាយ បសំសតីតិ ។

១ ម. វឡវាភិរថេន ។ ២ ម. តំ កិំ មញ្ញតិ ភវំ វច្ឆាយនោ ។ ៣ ម. កោ ចាហំ ភោ ភោ ច ។

## ចូឡហត្ថិបទោបមសូត្រ ទី ៧

(២៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ មានព្រាហ្មណ៍ម្នាក់ ឈ្មោះជាណុស្សោណិ ជិះរថទឹមដោយសេះសសុទ្ធ ចេញអំពីក្រុងសាវត្ថី តាំងពីកំពុងថ្ងៃត្រង់ ។ ជាណុស្សោណិព្រាហ្មណ៍ បានឃើញបិលោតិកបរិព្វាជក (បរិព្វាជកអ្នកស្លៀកសំពត់ចាស់) កំពុងដើរមកអំពីចម្ងាយ លុះឃើញជាក់ហើយ ទើបសួរបិលោតិកបរិព្វាជកដូច្នេះថា លោកវច្ឆាយនៈដ៏ចម្រើន មកអំពីទីណា តាំងពីកំពុងថ្ងៃត្រង់នេះ ។ បិលោតិកបរិព្វាជកឆ្លើយថា ម្នាលអ្នកដ៏ចម្រើន អាត្មា មកអំពីសម្នាក់ព្រះសមណគោតមនុ៎ះទេតើ ។ លោកដ៏ចម្រើនជឿថា ព្រះសមណគោតមមានប្រាជ្ញានិងសេចក្ដីវាងវៃ ល្មមហៅថាជាបណ្ឌិតបានឬទេ ។ ម្នាលអ្នកដ៏ចម្រើន អាត្មាឯណានឹងដឹងនូវប្រាជ្ញានិងសេចក្ដីវាងវៃរបស់ព្រះសមណគោតមបាន បើបុគ្គលណាដឹងនូវប្រាជ្ញានិងសេចក្ដីវាងវៃរបស់ព្រះសមណគោតមបានហើយ បុគ្គលនោះឯងនឹងប្រាកដដូចជាព្រះសមណគោតមនោះដែរ ។ ម្ដេចក៏លោកវច្ឆាយនៈដ៏ចម្រើនពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏ខ្ពង់ខ្ពស់ម្ល៉េះ ។

កោ ចាហំ ភោ សមណំ គោតមំ បសំសិស្សាមិ បសត្ថបសត្ថោ វ សោ ភវំ គោតមោ សេដ្ឋោ ទេវមនុស្សានន្តិ ។ កិំ បន ភវំ វច្ឆាយនោ អត្ថវសំ បស្សមានោ សមណេ គោតមេ ឯវំ អភិប្បសន្នោ ហោតីតិ(១) ។

[២៨] កោ ចាហំ ភោ សមណេ គោតមេ ឯវំ អភិប្បសន្នោម្ហិ(២) សេយ្យថាបិ ភោ កុសលោ នាគ-វនិកោ នាគវនំ បវិសេយ្យ សោ បស្សេយ្យ នាគវនេ មហន្តំ ហត្ថិបទំ ទីឃតោ ច អាយតំ តិរិយញ្ច វិត្ថតំ ។ សោ និដ្ឋំ គច្ឆេយ្យ មហា វត ភោ នាគោតិ ឯវមេវ ខោ អហំ(៣) យតោ អទ្ទសំ សមណេ គោតមេ ចត្តារិ បទានិ អថាហំ និដ្ឋមគមំ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ

១ ម. អភិប្បសន្នោតិ ។ ២ ម. ឧ. កោ ចាហំ ភោ សមណេ គោតមេ ឯវំ អភិប្ប-សន្នោម្ហីតិ ន ទិស្សតិ ។ ៣ ម. ម អហំ ភោ ។



ម្នាលអ្នកដ៏ចម្រើន អាត្មាអញនឹងសរសើរព្រះសមណគោតម ដូចម្ដេចបាន (ព្រោះ) ព្រះសមណគោតមដ៏ចម្រើននោះ ប្រសើរជាងអ្នកដែលប្រសើរ គឺប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ លោកវច្ឆាយនៈ ដ៏ចម្រើន ឃើញនូវអំណាចនៃប្រយោជន៍ដូចម្ដេច បានជាជ្រះថ្លា ក្នុងព្រះសមណគោតមយ៉ាងនេះ ។

(២៨) បិលោតិកបរិព្វាជកទូលថា ម្នាលអ្នកដ៏ចម្រើន អាត្មាអញជ្រះថ្លាយ៉ាងនេះ ក្នុងព្រះសមណគោតម ដូចម្ដេចបាន ម្នាលអ្នកដ៏ចម្រើន ដូចជាព្រានដំរីឈ្លាស ចូលទៅកាន់ព្រៃដំរី ព្រានដំរីនោះ បានឃើញស្នាមជើងដំរីធំ ក្នុងព្រៃដំរី ខាងបណ្ដោយក៏វែង ខាងទទឹងក៏ធំ ។ ព្រានដំរីនោះ ដល់នូវសេចក្ដីសន្និដ្ឋានថា ឱហ្ន៎ ដំរីធំមែន សេចក្ដីនេះយ៉ាងណា ឯអាត្មាបានឃើញស្នាមព្រះបាទ គឺញាណ ទាំង ៤ ប្រការ របស់ព្រះសមណគោតមក្នុងវេលាណាហើយ អាត្មាក៏ចូលចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធពិត ព្រះធម៌ដែល ព្រះមានព្រះភាគត្រាស់សំដែងប្រពៃ

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ(១) ។ ឥធាហំ ភោ បស្សាមិ ឯកច្ចេ ខត្តិយបណ្ឌិតេ និបុណេ កតបរប្បវាទេ វាលវេធិរូបេ(២) តេ ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ ។ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អមុកំ នាម គាមំ វា និគមំ វា ឱសរិស្សតីតិ ។ តេ បញ្ហំ អភិសង្ខរោន្តិ ឥមំ មយំ បញ្ហំ សមណំ គោតមំ ឧបសង្កមិត្វា បុច្ឆិស្សាម ឯវញ្ចេ(៣) នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវមស្ស មយំ វាទំ អារោបេស្សាម ឯវញ្ចេបិ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវម្បិស្ស មយំ វាទំ អារោបេស្សាមាតិ ។ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អមុកំ នាម គាមំ វា និគមំ វា ឱសដោតិ(៤) តេ យេន សមណោ គោតមោ តេនុបសង្កមន្តិ ។ តេ សមណោ គោតមោ

១ កត្ថចិ ពោត្ថកេ សុប្បដិបន្នោ សាវកសង្ឃោតិ ទិស្សតិ ។ ២ ម. ឋា. ។ ៣ កត្ថចិ ពោត្ថកេ ឯវំ ចេតិ ទិស្សតិ ។ ៤ កត្ថចិ ពោត្ថកេ ឱសរិតោតិ ។



ហើយ ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិល្អហើយ ក៏យ៉ាងនោះដែរ ។ ស្នាមព្រះបាទ គឺញាណ ទាំង ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលអ្នកដ៏ចំរើន ខ្ញុំបានឃើញខត្តិយបណ្ឌិតពួកខ្លះ ក្នុងលោកនេះ មានបញ្ញាល្អិត ធ្លាប់ញាំញីវាទៈរបស់បុគ្គលដទៃបាន ប្រាកដដូចជាខ្មាន់ធ្នូបាញ់ចំសរសៃសក់ ខត្តិយបណ្ឌិតទាំងនោះហាក់ដូចជាត្រាច់ទៅទម្លាយនូវទិដ្ឋិ របស់បុគ្គលដទៃ ដោយប្រាជ្ញា (របស់ខ្លួន) ខត្តិយ-បណ្ឌិតទាំងនោះឮដំណឹងថា ព្រះសមណគោតមដ៏ចំរើន ទ្រង់កំពុង-ដំណើរមកដល់ស្រុកឬនិគមឯណោះ ។ ខត្តិយបណ្ឌិតទាំងនោះតែងប្រឹក្សាដោយគិតថា ពួកយើង នឹងចូលទៅគាល់ព្រះសមណគោតម ហើយក្រាបបង្គំទូលសួរប្រស្នានេះ បើយើងក្រាបបង្គំទូលប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណ-គោតមនោះ យ៉ាងនេះ បើយើងបានក្រាបបង្គំទូលសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមនោះ យ៉ាងនេះវិញ ។ ខត្តិយបណ្ឌិតទាំងនេះឮដំណឹងថា ព្រះសមណគោតមដ៏ចំរើន ទ្រង់កំពុងដំណើរមកដល់ស្រុកឬនិគមឯណោះ ។ ទើបខត្តិយបណ្ឌិតទាំងនោះ ចូលទៅគាល់ព្រះសមណគោតម ។ ព្រះសមណគោតម ទ្រង់ញុំាងខត្តិយបណ្ឌិតទាំងនោះ

បញ្ហាភិសង្ខតេន និដ្ឋិតានិ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អម្ហាកំ គាមំ វា និគមំ វា ឱសរិស្សតីតិ ។ តេ បញ្ហំ អភិសង្ខរោន្តិ ឥមំ មយំ បញ្ហំ សមណំ គោតមំ ឧបសង្កមិត្វា បុច្ឆិស្សាម ឯវំ ចេ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវមស្ស មយំ វាទំ អារោបេស្សាម ឯវំ ចេបិ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវម្បិស្ស មយំ វាទំ អារោបេស្សាមាតិ ។ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អម្ហាកំ គាមំ វា និគមំ វា ឱសដោតិ តេ យេន សមណោ គោតមោ តេនុបសង្កមន្តិ ។ តេ សមណោ គោតមោ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ តេ សមណេន គោតមេន ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ន ចេវ សមណំ គោតមំ បញ្ហំ បុច្ឆន្តិ កុតោស្ស វាទំ អារោបេស្សន្តិ



ខ្ញុំចិត្ត (ចុងលើទៅ) ដោយបញ្ហា សមណព្រាហ្មណ៍ តាំងអម្បាលនោះ បានឮដំណឹងថា ព្រះសមណគោតមដ៏ចំរើនមានព្រះភាគ ដំណើរមកដល់ស្រុកឬនិគមឯណោះ ។ សមណព្រាហ្មណ៍តាំងអម្បាលនោះ បន្តប្រស្នា ដោយគិតថា ពួកយើងនឹងចូលទៅគាល់ព្រះសមណគោតម ហើយទូលសួរប្រស្នានេះ បើយើងសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមនោះយ៉ាងនេះ បើយើងទូលសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតម យ៉ាងនេះ ។ សមណព្រាហ្មណ៍តាំងអម្បាលនោះ បានឮដំណឹងថា ព្រះសមណគោតមដ៏ចំរើនមានព្រះភាគ ដំណើរមកដល់ស្រុកឬនិគមឯណោះ សមណព្រាហ្មណ៍តាំងនោះ ក៏ចូលទៅគាល់ព្រះសមណគោតម ។ ព្រះសមណគោតម ទ្រង់ញ៉ាំងសមណព្រាហ្មណ៍តាំងនោះ ឲ្យយល់ឃើញ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ពួកសមណព្រាហ្មណ៍នោះ ដែលព្រះសមណគោតមទ្រង់ឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏មិនអាចនឹងទូលសួរប្រស្នា នឹងព្រះសមណគោតមបានឡើយ នឹងលើកទោសព្រះសមណគោតមដូចម្ដេចបាន ទើបនាំគ្នា

ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេ-
ជេតិ សម្បហំសេតិ តេ សមណេន គោតមេន
ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេ-
ជិតា សម្បហំសិតា ន ចេវ សមណំ គោតមំ
បញ្ហំ បុច្ឆន្តិ កុតស្ស(១) វាទំ អារោបេស្សន្តិ អញ្ញទត្ថុ(២)
សមណស្សេវ គោតមស្ស សាវកា សម្បជ្ជន្តិ ។
យទាហំ ភោ សមណេ គោតមេ ឥមំ បឋមំ បទំ
អទ្ទសំ អថាហំ និដ្ឋមគមំ សម្មាសម្ពុទ្ធោ ភគវា
ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ
សាវកសង្ឃោតិ ។ បុន ចបរាហំ ភោ បស្សាមិ
ឥធេកច្ចេ ព្រាហ្មណបណ្ឌិតេ ។បេ។ គហបតិ-
បណ្ឌិតេ ។បេ។ សមណបណ្ឌិតេ និបុណេ
កតបរប្បវាទេ វាលវេធិរូបេ តេ ភិន្ទន្តា មញ្ញេ ចរន្តិ

១ ម. កុតោស្ស ។ ២ ម. អញ្ញទត្ថុ ។



ឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ពួកខត្តិយ-
បណ្ឌិតនោះ ដែលព្រះសមណគោតមទ្រង់ឲ្យយល់ ឲ្យកាន់យក ឲ្យក្លា-
ហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏មិនសាកសួរប្រស្នានឹងព្រះ
សមណគោតមបានឡើយ នឹងលើកពាក្យព្រះសមណគោតមដូចម្ដេចបាន
ការពិតនឹងសម្រេចទៅជាសាវ័ករបស់ព្រះសមណគោតមវិញ ។ ម្នាល
អ្នកដ៏ចម្រើន ក្នុងកាលដែលខ្ញុំបានឃើញនូវស្នាមព្រះបាទទី ១ នេះ របស់
ព្រះសមណគោតមហើយ ខ្ញុំក៏ដល់ចិត្តថាព្រះមានព្រះភាគ ជាព្រះសម្មា-
សម្ពុទ្ធពិត ព្រះធម៌ដែល ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងប្រពៃហើយ
ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ ម្នាល
អ្នកដ៏ចម្រើន មួយទៀត ខ្ញុំបានឃើញព្រាហ្មណបណ្ឌិតពួកខ្លះ ក្នុងលោក
នេះ ។បេ។ គហបតិបណ្ឌិត ។បេ។ សមណបណ្ឌិតដែលមានបញ្ញា
ល្អិត ធ្លាប់ញ៉ាំញ៉ីនូវវាទៈនៃបុគ្គលដទៃបាន ប្រាកដដូចជាខ្មាន់ធ្នូបាញ់ត្រូវសរ-
សៃសក់ សមណបណ្ឌិតទាំងអម្បាលនោះ ហាក់ដូចជាត្រាច់ទៅទម្លាយ

អញ្ញទត្ថុ សមណំយេវ គោតមំ ឱកាសំ យាចន្តិ អគា-
រស្មា អនគារិយំ បព្វជ្ជាយ ។ តេ សមណោ គោតមោ
បព្វាជេតិ តេ តត្ថ បព្វជិតា សមានា(១) វូបកដ្ឋា
អប្បមត្តា អាតាបិនោ បហិតត្តា វិហរន្តា នចិរស្សេវ
យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អន-
គារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ
ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ
វិហរន្តិ ។ តេ ឯវមាហំសុ មនំ វត ភោ
អនស្សាម មនំ វត ភោ បនស្សាម មយញ្ហិ បុព្វេ
អស្សមណាវ សមានា សមណម្ហាតិ បដិជានិម្ហ
អព្រាហ្មណាវ សមានា ព្រាហ្មណម្ហាតិ បដិជានិម្ហ
អនរហន្តាវ(២) សមានា អរហន្តម្ហាតិ បដិជានិម្ហ

១ ឱ. បព្វជិតា ឯកេ ។ ២ ឱ. ម. អនរហន្តោវ ។



សូមទុកឱកាសចំពោះព្រះសមណគោតម ដើម្បីនឹងចេញចាកផ្ទះចូលទៅកាន់
ផ្នួសវិញដោយពិត ។ ព្រះសមណគោតមទ្រង់បំបួសសមណបណ្ឌិត
ទាំងនោះ សមណបណ្ឌិតទាំងនោះ លុះបួសក្នុងសំណាក់ព្រះសមណ-
គោតមនោះហើយ ក៏ចេញចាកពួកគណៈ មិនមានសេចក្តីធ្វេសប្រហែស
មានសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅ
ក្នុងកម្មដ្ឋាន កុលបុត្រទាំងឡាយដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួស
ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បាន
ត្រាស់ដឹងនូវអនុត្តរធម៌នោះ មានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញា
ខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្ត ដោយឥរិយាបថទាំង ៤ ។
សមណបណ្ឌិតទាំងនោះ និយាយសរសើរយ៉ាងនេះថា ឱហ្ន៎ ពួកយើង
មិនបានវិនាសចាកប្រយោជន៍តិចតួចឡើយ ឱហ្ន៎ ពួកយើងមិនបានវិនាស
ចាកប្រយោជន៍តិចតួចឡើយ ដ្បិតក្នុងកាលមុន ពួកយើងមិនមែនជា
សមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រាហ្មណ៍ ប្តេជ្ញាខ្លួន
ថាជាព្រាហ្មណ៍ មិនមែនជាព្រះអរហន្ត ប្តេជ្ញាខ្លួនថាជាព្រះអរហន្ត

ឥទានិ ខោស្ម(១) សមណា ឥទានិ ខោស្ម ព្រាហ្មណា ឥទានិ ខោស្ម អរហន្តោតិ ។ យទាហំ ភោ សមណ គោតម ឥមំ ចតុត្ថំ បទំ អទ្ទសំ អថាហំ និដ្ឋមគមំ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវក-សង្ឃោតិ ។ យតោ ខោ អហំ ភោ សមណ គោតម ឥមានិ ចត្តារិ បទានិ អទ្ទសំ អថាហំ និដ្ឋមគមំ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៦៨) ឯវំ វុត្តេ ជាណុស្សោណិ ព្រាហ្មណោ សព្វសេតា វឡវាភិរថា(២) ឱរោហិត្វា ឯកំសំ ឧត្តរា-សង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ

១. ខោម្ហ ។ ២. វឡវាភិរថា ។



ឥឡូវនេះ ពួកយើងបានជាសមណៈហើយ ឥឡូវនេះ ពួកយើងបានជាព្រាហ្មណ៍ហើយ ឥឡូវនេះ ពួកយើងបានជាអរហន្តហើយ ។ ម្នាលអ្នកដ៏ចម្រើន ក្នុងកាលដែលអាត្មា បានឃើញនូវស្នាមព្រះបាទជាគម្រប់ ៤ នេះ របស់ព្រះសមណគោតមហើយ អាត្មាក៏ដល់ចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងល្អហើយ ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អហើយ ។ ម្នាលអ្នកដ៏ចម្រើន ក្នុងកាលដែលអាត្មាបានឃើញនូវស្នាមព្រះបាទទាំង ៤ ប្រការនេះ របស់ព្រះសមណគោតមហើយ អាត្មាក៏ដល់ចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងល្អហើយ ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អហើយ ។

(៦៨) កាលបើបិលោតិកបរិព្វាជក ពោលយ៉ាងនេះហើយ ជាណុស្សោណិព្រាហ្មណ៍ ក៏ចុះអំពីរថដែលទឹមដោយសេះសសុទ្ធ ធ្វើសំពត់ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះទៅ ត្រង់ទីដែលព្រះមានព្រះភាគគង់នៅ បន្លឺឧទាន ៣ ដង សរសើរៈ ៗ ដូចថា សូមនមស្ការ ចំពោះព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការ ចំពោះព្រះមាន

អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អប្បេវ នាម កទាចិ ករហចិ តេន សមណេន គោតមេន សទ្ធិំ សមាគច្ឆេយ្យាម អប្បេវ នាម សិយា កោចិទេវ កថាសល្លាបោតិ ។ អថខោ ជាណុស្សោណិ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជាណុស្សោណិ ព្រាហ្មណោ យាវតកោ អហោសិ បិលោតិកេន បរិព្វាជកេន សទ្ធិំ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ ឯវំ វុត្តេ ភគវា ជាណុស្សោណិំ ព្រាហ្មណំ ឯតទវោច ន ខោ ព្រាហ្មណ ឯត្តាវតា ហត្ថិបទោបមោ វិត្ថារេន បរិបូរោ ហោតិ អបិច ព្រាហ្មណ យថា ហត្ថិបទោបមោ វិត្ថារេន បរិបូរោ ហោតិ តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។



ព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះ សូមនមស្ការ ចំពោះព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះ ធ្វើម្តេច យើងគប្បីទៅជួបព្រះសមណគោតមបានម្តងម្កាល ធ្វើម្តេច យើងគប្បីបាននិយាយឆ្លើយឆ្លងនឹងគ្នាបន្តិច ។ លំដាប់នោះ ជាណុស្សោណិព្រាហ្មណ៍ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល មួយអន្លើដោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ តាមពាក្យដែលខ្លួននិយាយឆ្លើយឆ្លង ជាមួយនឹងបិលោតិកបរិព្វាជកនោះ ដរាបដល់ចប់សព្វគ្រប់ ។ កាលជាណុស្សោណិព្រាហ្មណ៍ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថាដូច្នេះ នឹងជាណុស្សោណិព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ ឧបមាដែលឧបមាដូចស្នាមជើងដំរី មិនទាន់បរិបូណ៌ ដោយពិស្តារត្រឹមតែប៉ុណ្ណេះទេ ម្នាលព្រាហ្មណ៍ ឯឧបមាដែលមានឧបមាដូចស្នាមជើងដំរី បរិបូណ៌ដោយពិស្តារយ៉ាងណាមិញ អ្នកចូរស្តាប់នូវសេចក្តីឧបមានោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ជាណុស្សោណិព្រាហ្មណ៍ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ ។

(៧០) ភគវា ឯតទវោច សេយ្យថាបិ ព្រាហ្មណ នាគវនិកោ នាគវនំ បវិសេយ្យ សោ បស្សេយ្យ នាគវនេ មហន្តំ ហត្ថិបទំ ទីឃតោ ច អាយតំ តិរិយញ្ច វិត្ថតំ យោ ហោតិ កុសលោ នាគវនិកោ នេវ តាវ និដ្ឋំ គច្ឆតិ មហា វត ភោ នាគោតិ ។ តំ កិស្ស ហេតុ ។ សន្តិ ហិ ព្រាហ្មណ នាគវនេ វាមនិកា នាម ហត្ថិនិយោ មហាបទា តាសមេតំ បទំ អស្សាតិ ។ សោ តមនុគច្ឆតិ តមនុគច្ឆន្តោ បស្សតិ នាគវនេ មហន្តំ ហត្ថិបទំ ទីឃតោ ច អាយតំ តិរិយញ្ច វិត្ថតំ ឧច្ចា ច និសេវិតំ យោ ហោតិ កុសលោ នាគវនិកោ នេវ តាវ និដ្ឋំ គច្ឆតិ មហា វត ភោ នាគោតិ ។ តំ កិស្ស ហេតុ ។ សន្តិ ហិ ព្រាហ្មណ នាគវនេ ឧច្ចាកឡារិកា នាម(១) ហត្ថិនិយោ មហាបទា តាសមេតំ បទំ អស្សាតិ ។ សោ តមនុគច្ឆតិ

១ ម. ឧ. ឧច្ចាកឡារិកា នាម ។





(៧០) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ ដូចជាព្រានដំរីចូលទៅកាន់ព្រៃដំរី ព្រានដំរីនោះ បានឃើញស្នាមជើងដំរីធំ ក្នុងព្រៃដំរី វែងតាមបណ្តោយផង ធំតាមទទឹងផង ព្រានដំរីដែលឈ្លាស ក៏មិនទាន់ដល់ចិត្តថា ឱហ្ន៎ ដំរីធំមែន ដូច្នេះនៅឡើយ ។ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថាក្នុងព្រៃដំរី រមែងមានមេដំរី ទាំងឡាយមានខ្លួនតូច តែមានស្នាមជើងធំ ស្នាមជើងនេះ ជាស្នាមជើងមេដំរីទាំងនោះ ។ ព្រានដំរីនោះ ក៏ទៅតាមស្នាមជើងនោះ លុះទៅតាមស្នាមជើងនោះហើយ ក៏ឃើញស្នាមជើងដំរីធំ ក្នុងព្រៃដំរី វែងតាមបណ្តោយផង ធំតាមទទឹងផង មានទីក្រឡុសដ៏ខ្ពស់ផង ព្រានដំរីដែលឈ្លាសមិនទាន់ដល់ចិត្តថា ឱហ្ន៎ ដំរីធំណាស់ ដូច្នេះនៅឡើយ ។ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថាក្នុងព្រៃដំរី រមែងមានមេដំរី ទាំងឡាយឈ្មោះឧច្ចាកឡារិកា(១) មានស្នាមជើងធំ ស្នាមជើងនេះជាស្នាមជើង នៃមេដំរីទាំងនោះ ។ ព្រានដំរីនោះ ក៏ដើរទៅតាមស្នាមជើងនោះ

១ ពាក្យថា ឧច្ចាកឡារិកា នេះជាឈ្មោះនៃមេដំរី ដែលមានជើងខ្ពស់ខ្លួនជាដើមឈើច្រក់ ទាំង ២ មានធ្មេញទ្រើល ព្រោះមេដំរីនោះមានធ្មេញខ្លួយខ្ពស់ឡើង ធ្មេញខ្ពស់ជាបចុះ ធ្មេញទាំង ២ នោះ ឃ្លាតចេញពីគ្នា ក៏មិនជិតគ្នា ។ អដ្ឋកថា ។

តមនុគច្ឆន្តោ បស្សតិ នាគវនេ មហន្តំ ហត្ថិបទំ ទីឃតោ ច អាយតំ តិរិយញ្ច វិត្ថតំ ឧច្ចា ច និសេវិតំ ឧច្ចា ច ទន្តេហិ អារញ្ជិតានិ យោ ហោតិ កុសលោ នាគវនិកោ នេវ តាវ និដ្ឋំ គច្ឆតិ មហា វត ភោ នាគោតិ ។ តំ កិស្ស ហេតុ ។ សន្តិ ហិ ព្រាហ្មណ នាគវនេ ឧច្ចាកណេរុកា(១) នាម ហត្ថិនិយោ មហាបទា តាសំ បេតំ បទំ អស្សាតិ ។ សោ តមនុគច្ឆតិ តមនុគច្ឆន្តោ បស្សតិ នាគវនេ មហន្តំ ហត្ថិបទំ ទីឃតោ ច អាយតំ តិរិយញ្ច វិត្ថតំ ឧច្ចា ច និសេវិតំ ឧច្ចា ច ទន្តេហិ អារញ្ជិតានិ ឧច្ចា ច សាខាភង្គំ តញ្ច នាគំ បស្សតិ រុក្ខមូលគតំ វា អព្ភោកាសគតំ វា គច្ឆន្តំ វា ឋិតំ វា(២) និសិន្នំ វា និបន្នំ វា ។ សោ និដ្ឋំ គច្ឆតិ អយមេវ(៣) សោ មហានាគោតិ ។ ឯវមេវ ខោ ព្រាហ្មណ ឥធ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ

១ កត្ថចិ ហេដ្ឋា ឧច្ចាកាឡារិកា បាឋោ ទិស្សតិ ។ ២ ម. ទិដ្ឋំ វា ។ ៣ ម. អយំ វ ។



លុះដើរទៅតាមស្នាមជើងនោះហើយ ក៏ឃើញស្នាមជើងដំរីធំក្នុងព្រៃដំរី វែងដោយបណ្តោយផង ធំដោយទទឹងផង មានទីក្រឡុសដំរីត្រដុសផង ទាំងទីដែលបាក់ដោយភ្លុកដំរីខ្ពស់ផង ព្រានដំរី ដែលឈ្លាសមិនទាន់ចូលចិត្តថា ឱហ្ន៎ ដំរីនេះមែនទែនធំណាស់ហើយ ។ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថាក្នុងព្រៃដំរី រមែងមានមេដំរី ឈ្មោះឧច្ចាករេណុកា(១) មានស្នាមជើងធំ ស្នាមជើងនេះ ជាស្នាមជើងនៃមេដំរីទាំងនោះ ។ ព្រានដំរីនោះដើរទៅតាមស្នាមជើងនោះ លុះដើរទៅតាមស្នាមជើងនោះហើយ ក៏ឃើញស្នាមជើងដំរីធំក្នុងព្រៃដំរី វែងដោយបណ្តោយផង ធំដោយទទឹងផង មានទីក្រឡុសដំរីត្រដុសផង ទាំងស្នាមបាក់ដោយភ្លុកខ្ពស់ឆ្ងាយ ខ្ពស់ផង ទាំងមែកឈើដែលដំរីនោះកាច់ហើយក៏ខ្ពស់ផង ហើយឃើញដំរីនោះ នៅក្បែរគល់ឈើក្តី នៅក្នុងទីវាលក្តី កំពុងដើរក្តី កំពុងឈរក្តី កំពុងក្រាបចុះក្តី កំពុងដេកក្តី ។ ទើបព្រានដំរីនោះចូលចិត្តថា ដំរីនេះជាដំរីធំមែន មានខ្លួនមាឌធំម្ល៉េះមិញ ។ ម្នាលព្រាហ្មណ៍ ឧបមេយ្យដូចជាព្រះតថាគតកើតឡើងក្នុងលោកនេះ មានខ្លួនប្រាកដថា ជាបុគ្គលឆ្ងាយចាកកិលេស ត្រាស់ដឹងដោយប្រពៃចំពោះខ្លួន បរិបូណ៌ដោយវិជ្ជានិង

១ ពាក្យថា ឧច្ចាករេណុកា នេះជាឈ្មោះនៃមេដំរីដែលមានជើងខ្ពស់ដូចដើមឈើត្រង់ៗនៃ មានឈ្មោះល្បីផង ព្រោះមេដំរីនោះមានឈ្មោះតូចក្រាក់ ។ អដ្ឋកថា ។

សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណិំ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរាវាសោ រជោបថោ អព្ភោកាសោ បព្វជ្ជា



ចរណៈ មានដំណើរល្អទៅកាន់សុគតិស្ថាន ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ជាសាស្ត្រាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ ដែលមិនត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះខ្លួនឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក និងព្រហ្មលោក នូវពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះតថាគតនោះ សំដែងធម៌មានលំអបទដើម លំអបទកណ្តាល និងលំអបទចុង ប្រកបដោយអត្ថ ព្រមទាំងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌គ្រប់គ្រាន់ គហបតីក្តី កូនរបស់គហបតីក្តី ឬបុគ្គលកើតក្នុងត្រកូលណាមួយ ជាខាងក្រោយក្តី បានស្តាប់នូវធម៌នោះ លុះបុគ្គលនោះ ស្តាប់នូវធម៌នោះហើយ រមែងបានចំពោះ នូវសទ្ធាក្នុងព្រះតថាគត បុគ្គលនោះ ប្រកបដោយការបានចំពោះ នូវសទ្ធានោះហើយ រមែងពិចារណាឃើញច្បាស់ថា ការនៅគ្រប់គ្រងផ្ទះ ជាទីចង្អៀតចង្អល់ (តឹងណាស់) ជាផ្លូវហូរមកនៃធូលីគឺកិលេស បព្វជ្ជាជាទីអាកាសទំនេរច្រើន

នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។

(៩១) សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតិ ។ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី វិរតោ មេថុនា



(ព្រោះជាឱកាស ដើម្បីធ្វើកុសលតាមសប្បាយ) បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ដូចជាស័ង្ខ ដែលគេខាត់ហើយនោះបានទេ បើដូច្នោះមានតែ អាត្មាអញកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់ជ្រលក់ដោយទឹកអម្ចត់ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លុះសម័យតទៅក្រោយមក បុគ្គលនោះ ក៏លះបង់នូវគំនរភោគៈតិចក្តី លះបង់នូវគំនរភោគៈច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់នូវសំពត់ជ្រលក់ដោយទឹកអម្ចត់ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។

(៩១) លុះបុគ្គលនោះ បានបួសយ៉ាងនេះហើយ ក៏បរិបូណ៌ដោយសិក្ខាព្រមទាំងអាជីវៈនៃភិក្ខុទាំងឡាយ ជាអ្នកលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីករុណា មានសេចក្តីអនុគ្រោះសព្វសត្វដោយប្រយោជន៍ ។ លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាតែវត្ថុដែលគេឲ្យ មានអត្តភាពដ៏ស្អាត មិនមែនជាចោរ ។ លះបង់នូវអព្រហ្មចរិយធម៌ជាមិនប្រសើរ ហើយប្រព្រឹត្តតែធម៌ដ៏ប្រសើរ ចៀសឆ្ងាយ វៀរស្រឡះចាកមេថុន

គាមធម្មា ។ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ ។



ជាធម៌របស់អ្នកស្រុក ។ លះបង់មុសាវាទ វៀរស្រឡះ ចាកមុសាវាទ ពោលតែពាក្យពិត តខ្សែពាក្យពិតដោយពាក្យពិត(១) ជាអ្នកមានសម្ដីទៀងទាត់ មានពាក្យដែលគួរជឿ មិនបានពោលបញ្ឆោតសត្វលោក ។ លះបង់បិសុណវាចា វៀរស្រឡះ ចាកបិសុណវាចា គឺជាឮពាក្យអំពីសម្នាក់ជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីបំបែកពួកជនទាំងឡាយនេះ ឬឮពាក្យក្នុងសម្នាក់ជនឯណោះ ហើយមិននាំមកប្រាប់ដល់ពួកជននេះ ដើម្បីបំបែក ពួកជនទាំងឡាយឯណោះដូច្នេះ ជាអ្នកផ្សះផ្សាពួកជនទាំងឡាយដែលបែកគ្នាហើយ ឬឲ្យកម្លាំងថែមដល់ជនទាំងឡាយដែលជាមិត្តគ្នាហើយ មានសេចក្ដីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្ដីព្រមព្រៀងគ្នា រីករាយក្នុងសេចក្ដីព្រមព្រៀងគ្នា និយាយតែវាចា ដែលជាគ្រឿងធ្វើឲ្យព្រមព្រៀងគ្នា ។ លះបង់ផរុសវាចា វៀរស្រឡះ ចាកផរុសវាចា វាចាណា ដែលមិនមានទោស នាំមកនូវសេចក្ដីសុខដល់ត្រចៀក ជាពាក្យគួរស្រឡាញ់ ជាពាក្យគួរតម្កល់ទុកក្នុងហឫទ័យ ជាសម្ដីរបស់អ្នកក្រុង ដែលជាទីត្រេកអរដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកនិយាយតែវាចាមានសភាពដូច្នោះ ។

---

១ ដែលថា តខ្សែពាក្យពិតដោយពាក្យពិតនេះ គឺមិននិយាយពាក្យកុហកក្នុងចន្លោះ ។ បានសេចក្ដីថា នាំតែនិយាយពាក្យពិតរហូតទៅ ។ អដ្ឋកថា ។

សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធា-នវតឹ វាចំ ភាសិតា កាលេន សាបទេសំ បរិយន្ត-វតឹ(១) ។ សោ ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ។ ឯកភត្តិកោ ហោតិ រត្តូបរតោ វិរតោ វិកា-លភោជនា ។ នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ ហោតិ ។ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ហោតិ ។ ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ។ ជាតរូបរជតបដិគ្គហណា បដិវិរតោ ហោតិ ។ អាមកធញ្ញបដិគ្គហណា បដិវិរតោ ហោតិ ។ អាមកមំសបដិគ្គហណា បដិវិរតោ ហោតិ ។

១ ម. ម. បរិយន្តវតឹ អត្ថសំហិតន្តិ ទិស្សតិ ។



លះបង់សម្ផប្បលាបៈ វៀរស្រឡះ ចាកសម្ផប្បលាបៈ ជាអ្នកពោលនូវពាក្យតាមកាលគួរ ជាអ្នកពោលនូវពាក្យពិត ជាអ្នកពោលនូវអត្ថ (ពោលពាក្យប្រកបដោយប្រយោជន៍ ក្នុងបច្ចុប្បន្ននិងបរលោក) ជាអ្នកពោលនូវធម៌ (ពោលពាក្យប្រកបដោយលោកុត្តរធម៌) ជាអ្នកពោល នូវវិន័យ (ពោលពាក្យប្រកបដោយសំវរវិន័យ និងបហានវិន័យ) ពោលនូវពាក្យគួររក្សាទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយសេចក្តីអាង តាមកាល ជាពាក្យមានកំណត់ ។ ភិក្ខុនោះវៀរស្រឡះចាកកិរិយាផ្តិលផ្តាច់នូវពីជគាមនិងភូតគាម ។ ជាអ្នកឆាន់តែម្តងគត់ ១ ពេល វៀរស្រឡះ ចាកការបរិភោគក្នុងរាត្រី វៀរស្រឡះ ចាកការបរិភោគក្នុងវេលាខុស ។ វៀរស្រឡះ ចាកកិរិយារាំច្រៀងប្រគំនិងមើល នូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។ វៀរស្រឡះចាកកិរិយាទ្រទ្រង់និងប្រដាប់ តាក់តែង ស្អិតស្អាងដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។ វៀរស្រឡះចាកទីដេកទីអង្គុយខ្ពស់និងទីដេកទីអង្គុយដ៏ប្រសើរ ។ វៀរស្រឡះ ចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់ ។ វៀរស្រឡះចាកកិរិយាទទួលកាន់យកនូវស្រូវស្រស់ ។ វៀរស្រឡះ ចាកកិរិយាទទួលកាន់យកនូវសាច់ឆៅ ។

ឥត្ថីកុមារិកាបដិគ្គហណា បដិវិរតោ ហោតិ ។ ទាសីទា-
សបដិគ្គហណា បដិវិរតោ ហោតិ ។ អជេឡកបដិគ្គ-
ហណា បដិវិរតោ ហោតិ ។ កុក្កុដសូករបដិគ្គហណា
បដិវិរតោ ហោតិ ។ ហត្ថិគវស្សវឡវបដិគ្គហណា បដិវិ-
រតោ ហោតិ ។ ខេត្តវត្ថុបដិគ្គហណា បដិវិរតោ ហោតិ ។
ទូតេយ្យបហិណគមនានុយោគា បដិវិរតោ ហោតិ ។
កយវិក្កយា បដិវិរតោ ហោតិ ។ តុលាកូដកំស-
កូដមានកូដា បដិវិរតោ ហោតិ ។ ឧក្កោដនវញ្ច-
ននិកតិសាចិយោគា(១) បដិវិរតោ ហោតិ ។ ឆេទន-

១ ម. ឧ. ឧក្កោដនវញ្ចននិកតិសាចិយោគា ។



វៀរស្រឡះ ចាកកិរិយាទទួលស្ត្រី(១) និងកុមារី ។ វៀរស្រឡះចាក
កិរិយាទទួល ខ្ញុំស្រីនិងខ្ញុំប្រុស(២) ។ វៀរស្រឡះចាកកិរិយាទទួល
នូវពពែនិងចៀម ។ វៀរស្រឡះ ចាកកិរិយាទទួលនូវមាន់និងជ្រូក ។
វៀរស្រឡះចាកកិរិយាទទួល នូវដំរី គោ សេះ ឈ្មោលនិងញី ។
វៀរស្រឡះចាកកិរិយាទទួលនូវស្រែនិងចំការ ។ វៀរស្រឡះចាកកិរិយា
ប្រកបនូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្ដាំដល់គ្រហស្ថ និងទៅដោយ
គេបញ្ជូនពីផ្ទះមួយ ទៅផ្ទះមួយ ។ វៀរស្រឡះចាកកិរិយាលក់ទិញផ្លាស់ប្ដូរ
(របស់ផ្សេងៗ) ។ វៀរស្រឡះចាកកិរិយាកោងដោយជញ្ជីង បន្លំដោយកាក់
មាស និងកិរិយាកោងដោយរង្វាស់រង្វាល់(៣) ។ វៀរស្រឡះចាកកិរិយា
ប្រកបនូវកិរិយាកោងដោយស៊ីសំណូក បោកប្រាស់ដោយឧបាយ និងបន្លំដោយ
របស់ក្លែង(៤) ។ វៀរស្រឡះចាកកិរិយាកាត់អវយវៈមានដៃនិងជើងជាដើម

១ ស្រីក្នុងទីនេះ សំដៅយកស្ត្រីដែលមានប្ដី ស្រីក្មេងជាងនេះហៅថាកុមារី ការទទួលនូវ
ប៉ះពាល់ក្ដី ឲ្យប្រើទាំងនោះទៀតក្ដី ។ ២ ត្រង់នេះថា វៀរចាកទទួលខ្ញុំស្រីខ្ញុំប្រុសនោះ គឺ
ទទួលដោយគំរោង ដាក់ខ្លួនជាម្ចាស់ខ្លួន មិនគួរទេ បើទទួលដោយអំណាចនៃកប្បិយ-
ការក ព្រោះថាទៅជាកាលៈទេសៈ គួរ ។ អដ្ឋកថា ។ ៣-៤ មើលខាងសេចក្ដីដោះ
ក្នុងព្រហ្មជាលសូត្រ ទីឃនិកាយ ។

ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ សោ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ(១) បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ នាម បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោវ ឌេតិ ឯវមេវ(២) ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ

១ ម. យេន ។ ២ ម. ឯវមេវំ ។



សម្ងំ ចាប់ចិត្ត ធ្វើសេចក្ដីដឹងខ្លួន ចូលទៅក្នុងស្រុក និងកាលដែលនិយាយស្ងៀមនៅ(១) ។ ភិក្ខុនោះជាអ្នកសន្តោសដោយចីវរដែលជាគ្រឿងរក្សាខ្លួនកាយ ដោយបិណ្ឌបាតដែលជាគ្រឿងរក្សាផ្ទៃ ទីទៀសចេញទៅកាន់ទិសណា ៗ តែងកាន់យក (នូវគ្រឿងបរិក្ខារ) តែប៉ុណ្ណោះ ទៀសចេញទៅ (កាន់ទិសនោះ ៗ) ។ ដូចជាសត្វស្លាបហើរទៅកាន់ទិសណា ៗ ក៏មានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅ ដូចម្ដេចមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរដែលជាគ្រឿងរក្សាខ្លួនកាយ ដោយបិណ្ឌបាតដែលជាគ្រឿងរក្សាផ្ទៃ ទីទៀសចេញទៅកាន់ទិសណា ៗ តែងកាន់យក (នូវគ្រឿងបរិក្ខារ) ប៉ុណ្ណោះ ទៀសចេញទៅ ដូច្នោះដែរ ។ ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះហើយ ទទួលនូវសេចក្ដីសុខដែលមិនមានទោស ក្នុងសន្តានចិត្តខ្លួនបាន ។ ភិក្ខុនោះឃើញរូបដោយចក្ខុហើយ មិនកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈឡើយ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវឥន្ទ្រិយគឺចក្ខុណា ភិក្ខុនោះ ក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ

១ មើលខាងលក្ខណៈ ព្រហ្មជាលសូត្រ ទីឃនិកាយ ។

រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ សោតេន សទ្ទំ សុត្វា ... ឃានេន គន្ធំ ឃាយិត្វា ... ជិវ្ហាយ រសំ សាយិត្វា ... កាយេន ផោដ្ឋព្វំ ផុសិត្វា ... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។



គឺចក្ខុនោះ រក្សានូវឥន្ទ្រិយគឺចក្ខុ ដល់នូវសេចក្ដីសង្រួម ក្នុងឥន្ទ្រិយគឺចក្ខុ ។ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្ដាត ... ពាល់ត្រូវនូវផ្សព្វដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត មិនប្រកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈឡើយ អកុសលធម៌ដ៏លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវបុគ្គលដែលមិនបានសង្រួម នូវឥន្ទ្រិយគឺចិត្តណា ភិក្ខុនោះក៏ប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយគឺចិត្តនោះ រក្សានូវឥន្ទ្រិយគឺចិត្ត ដល់នូវសេចក្ដីសង្រួមក្នុងឥន្ទ្រិយគឺចិត្ត ។ ភិក្ខុនោះប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះហើយ ទើបទទួលនូវសុខ ដែលមិនច្រឡូកដោយកិលេស ក្នុងសន្តានចិត្ត ។ កាលភិក្ខុនោះឈានទៅមុខនិងឈានថយក្រោយ ក៏មានសេចក្ដីដឹងខ្លួន កាលក្រឡេកមើលទៅមុខនិងក្រឡេកមើលទៅទិសផ្សេងៗ ក៏មានសេចក្ដីដឹងខ្លួន កាលអន្ទ្រាក់ដៃជើងចូលនិងលាដៃជើង ក៏មានសេចក្ដីដឹងខ្លួន កាលប្រើប្រាស់នូវសង្ឃាដិបាត្រនិងចីវរ ក៏មានសេចក្ដីដឹងខ្លួន កាលបរិភោគ ផឹក ទំពាស៊ី ជញ្ជក់ភ្លក្ស ក៏មានសេចក្ដីដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ក៏មានសេចក្ដីដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់រឭក និយាយ នៅស្ងៀម ក៏មានសេចក្ដីដឹងខ្លួន ។

(៧២) សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ។ ព្យាបាទបទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទបទោសា ចិត្តំ បរិសោធេតិ ។ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ។ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ ។



[៧២]. ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិសម្បជញ្ញៈដ៏ប្រសើរនេះផង រមែងសេពនូវសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធ្លាយ ទីវាល ចង្កំនរចំបើង ។ ភិក្ខុនោះត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏អង្គុយពែនភ្នែន តម្រង់កាយត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះ (ទៅកាន់កម្មដ្ឋាន) ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា ។ លះបង់នូវព្យាបាទ គឺសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះដល់សត្វទាំងពួង ជម្រះចិត្តឲ្យស្អាតចាកព្យាបាទនិងសេចក្តីប្រទូស្ត ។ លះបង់នូវថីនមិទ្ធៈ (សេចក្តីងងុយនិងងោកងក់) មានចិត្តប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ មានសតិនិងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ ។ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ (សេចក្តីរាយមាយចិត្តនិងសេចក្តីក្តៅក្រហាយ) មានចិត្តមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ក្នុងខាងក្នុង ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ ។

វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

(៧៣) សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ(១) វុច្ចតិ ព្រាហ្មណ តថាគតបទំ ឥតិបិ តថាគតនិសេវិតំ ឥតិបិ តថាគតារញ្ជិតំ ឥតិបិ ។ ន ត្វេវ តាវ អរិយសាវកោ និដ្ឋំ គច្ឆតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។ បុន ចបរំ ព្រាហ្មណ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

១ ឱ. ម. ឥទម្បិ ។



លះបង់នូវវិចិកិច្ឆា គឺសេចក្ដីងឿងឆ្ងល់ ឆ្លងផុតចាកវិចិកិច្ឆា អស់សេចក្ដីសង្ស័យក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

(៧៣) ភិក្ខុនោះលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើបញ្ញាឲ្យមានកម្លាំងថយ ហើយស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីវិវេកជាអារម្មណ៍ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលព្រាហ្មណ៍ នេះ ក៏ហៅថា ស្នាមជើងរបស់ព្រះតថាគតខ្លះ ជាទីត្រដុសរបស់ព្រះតថាគតខ្លះ ជាស្នាមដែលជាន់ដោយភ្លុករបស់ព្រះតថាគតខ្លះ ។ មិនទាន់ដល់នូវការសន្និដ្ឋានឡើយ ព្រោះអរិយសាវកនៅតែនឹកក្នុងចិត្តថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងប្រពៃហើយ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ ជាអ្នកប្រតិបត្តិប្រពៃហើយ ។ ម្នាលព្រាហ្មណ៍ ប្រការដទៃទៀត លុះភិក្ខុរម្ងាប់វិតក្កៈនិងវិចារៈរួចហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ញុំាងចិត្តជាសមាធិឲ្យខ្ពង់ខ្ពស់ឡើង មិនមានវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិប៉ុណ្ណោះ ។ បេ ។ ក៏បានដល់នូវតតិយជ្ឈាន...នូវចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

ឥទំ វុច្ចតិ ព្រាហ្មណ តថាគតបទំ ឥតិបិ តថាគតនិសេវិតំ ឥតិបិ តថាគតារញ្ជិតំ ឥតិបិ ។ ន ត្វេវ តាវ អរិយសាវកោ និដ្ឋំ គច្ឆតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៣៤) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ(១) អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ឥទម្បិ វុច្ចតិ ព្រាហ្មណ តថាគតបទំ ឥតិបិ តថាគតនិសេវិតំ ឥតិបិ តថាគតារញ្ជិតំ ឥតិបិ ។ ន ត្វេវ តាវ

១ ម. សោ អ ។



ម្នាលព្រាហ្មណ៍ នេះតថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះ ជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ជាស្នាមចាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ មិនទាន់ដល់ប៉ុណ្ណោះឡើយ ព្រះអរិយសាវ័កតែងចូលចិត្តថា ព្រះមានព្រះភាគ ជាសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងប្រពៃហើយ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។

(៣៤) កាលបើចិត្តតាំងនឹងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ ព្រោះដល់នូវអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះបង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះរឭកនូវបុព្វេនិវាសជាច្រើនប្រការ គឺ រលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ ភិក្ខុនោះរលឹកបាននូវបុព្វេនិវាសានុស្សតិជាច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស យ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ នេះឯងតថាគតហៅថា ស្នាមជើងនៃព្រះតថាគតដូច្នេះខ្លះ ជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ជាជាស្នាមចាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ មិនតែប៉ុណ្ណោះឡើយ

អរិយសាវកោ និដ្ឋំ គច្ឆតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៧៨) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ ឥទម្បិ វុច្ចតិ ព្រាហ្មណ តថាគតបទំ ឥតិបិ តថាគតនិសេវិតំ ឥតិបិ តថាគតារញ្ជិតំ ឥតិបិ ។ នត្វេវ តាវ អរិយសាវកោ និដ្ឋំ គច្ឆតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។



ព្រះអរិយសាវកក៏នៅតែមិនចូលចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងល្អប្រពៃហើយ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អប្រពៃហើយ ។

[៧៨] កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងនឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណនៃសត្វទាំងឡាយ ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួន ។ ម្នាលព្រាហ្មណ៍ នេះឯង ក៏ជាគេហៅថា ស្នាមជើងរបស់ព្រះតថាគតខ្លះ ជាទីត្រដុសរបស់ព្រះតថាគតខ្លះ ជាដំណាងកាត់ដោយភ្លុក របស់ព្រះតថាគតខ្លះ ។ មិនតែប៉ុណ្ណោះឡើយ ព្រះអរិយសាវកក៏នៅតែមិនចូលចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងល្អប្រពៃហើយ ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អប្រពៃហើយ ។

[ ៧៦ ] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥទម្បិ វុច្ចតិ ព្រាហ្មណ តថាគតបទំ ឥតិបិ តថាគតនិសេវិតំ ឥតិបិ តថាគតារញ្ជិតំ ឥតិបិ ។ ន ត្វេវ តាវ អរិយសាវកោ និដ្ឋង្គតោ ហោតិ ។ អបិច ខោ និដ្ឋំ គច្ឆតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ



[ ៧៦ ] កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់ការងារកម្ម ជាចិត្តនឹងនឹង មិនញាប់ញ័រទៅតាមលោកធម៌យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្ត ទៅដើម្បីអាសវក្ខយញ្ញាណ ។ ភិក្ខុនោះក៏ដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ។ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ ។ ម្នាលព្រាហ្មណ៍ នេះឯងក៏ហៅថា ស្នាមជើងរបស់ព្រះតថាគតខ្លះៗ ជាទីក្រេចក្រាបរបស់ព្រះតថាគតខ្លះៗ ជាស្នាមពាល់ដោយភ្លុក របស់ព្រះតថាគតខ្លះៗ ។ ព្រះអរិយសាវកនោះគង់មិនត្រឹមតែចូលចិត្តដោយហេតុ មានប្រមាណប៉ុណ្ណេះៗ ។ មួយទៀត ព្រះអរិយសាវកតែងចូលចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ

កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឥទម្បិ វុច្ចតិ ព្រាហ្មណ តថាគតបទំ ឥតិបិ តថាគតនិសេវិតំ ឥតិបិ តថាគតារញ្ជិតំ ឥតិបិ ។ ឯត្តាវតា ខោ ព្រាហ្មណ អរិយសាវកោ និដ្ឋង្គតោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។ ឯត្តាវតា ខោ ព្រាហ្មណ ហត្ថិបទោបមោ វិត្ថារេន បរិបូរោ ហោតិ ។



ចិត្តក៏ផុតស្រឡះចាកកាមាសវៈ (គ្រឿងត្រាំគឺកាម) ផង ចិត្តក៏ផុតស្រឡះចាកភវាសវៈ (គ្រឿងត្រាំគឺភព) ផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈ (គ្រឿងត្រាំគឺអវិជ្ជា) ផង កាលបើចិត្តផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ភិក្ខុនោះក៏ដឹងច្បាស់ថា កំណើតអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញ បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច មគ្គញាណក៏បានធ្វើស្រេចហើយ ករណីយកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលព្រាហ្មណ៍ នេះឯង តថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះថា ជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះថា ជាស្នាមពាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ ម្នាលព្រាហ្មណ៍ ព្រះអរិយសាវ័ក តែងដល់ចិត្តដោយហេតុមានប្រមាណប៉ុណ្ណេះថា ។ ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងប្រពៃហើយ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិប្រពៃហើយ ។ ម្នាលព្រាហ្មណ៍ ធម៌ដែលមានឧបមា ដូចស្នាមជើងដំរី ពេញបរិបូណ៌ដោយពិស្តារ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

[៣៧] ឯវំ វុត្តេ ជាណុស្សោណិ ព្រាហ្មណោ ភ-
គវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ
គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា
ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អា-
ចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុ-
មន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន
អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវ-
ន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧ-
បាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុ-
បេតំ សរណំ គតន្តិ ។

ចូឡហត្ថិបទោបមសុត្តំ សត្តមំ និដ្ឋិតំ ។

---





(៣៧) កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ
ជាណុស្សោណិព្រាហ្មណ៍ បានក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា
បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់
ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយដោយ
អនេកបរិយាយយ៉ាងនេះ ទុកដូចជា គេផ្ងាររបស់ដែលផ្កាប់ ឬបើក
បង្ហាញរបស់ដែលគេបិទ ពុំនោះសោតដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំ
នោះសោត ដូចជាគេទ្រោលប្រទីបកន្លងប្រេងក្នុងទីងងឹតដោយគិតថា បុរសអ្នកមាន
ចក្ខុ នឹងឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះករុណានោះ សូមដល់នូវព្រះ
គោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូម
ព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណគមន៍
ស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

ចប់ ចូឡហត្ថិបទោបមសូត្រ ទី៧ ។

# អដ្ឋមំ មហាហត្ថិបទោបមសុត្តំ

[៣៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច សេយ្យថាបិ អាវុសោ យានិ កានិចិ ជង្គលានំ(១) បាណានំ បទជាតានិ សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន ឯវមេវ ខោ អាវុសោ យេ កេចិ កុសលា ធម្មា សព្វេ តេ ចតូសុ អរិយសច្ចេសុ សង្គហំ គច្ឆន្តិ កតមេសុ ចតូសុ ទុក្ខេ អរិយសច្ចេ ទុក្ខសមុទយេ អរិយសច្ចេ ទុក្ខនិរោធេ អរិយសច្ចេ ទុក្ខនិរោធគាមិនិយា បដិបទាយ អរិយសច្ចេ ។

---

១ ម. ជង្គលានំ ។

# មហាហត្ថិបទោបមសូត្រ ទី ៨

[៣៨] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មានអាយុ ។ ភិក្ខុទាំងអម្បាលនោះ បានទទួលស្ដាប់ថាពិត នៃព្រះសារីបុត្តមានអាយុថា បពិត្រលោកមានអាយុ ។ ព្រះសារីបុត្តមានអាយុ មានថេរដីកាដូច្នេះថា ម្នាលអ្នកទាំងឡាយមានអាយុ ស្នាមជើងនៃសត្វទាំងឡាយណាមួយ របស់ពួកសត្វដែលទៅលើផែនដី ស្នាមជើងទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរី ប្រាកដថាប្រសើរជាងស្នាមជើង នៃសត្វទាំងអម្បាលនោះ ព្រោះស្នាមជើងដំរីនោះ ជាស្នាមជើងធំ ដូចម្ដេចមិញ ម្នាលអ្នកទាំងឡាយមានអាយុ កុសលធម៌ទាំងឡាយណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្គ្រោះចូលក្នុងអរិយសច្ចទាំង ៤ ដូច្នោះឯង អរិយសច្ចទាំង ៤ តើដូចម្ដេចខ្លះ គឺ ទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

[៧៩] កតមញ្ចាវុសោ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណំ(១) ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា(២) ទុក្ខា ។ កតមេ ចាវុសោ បញ្ចុបាទានក្ខន្ធា សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ កតមោ ចាវុសោ រូបុបាទានក្ខន្ធោ ចត្តារិ ច មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ(៣) ។ កតមេ ចាវុសោ ចត្តារោ មហាភូតា បថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

[៨០] កតមា ចាវុសោ បថវីធាតុ ។ បថវីធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ចាវុសោ អជ្ឈត្តិកា បថវីធាតុ ។ យំ អជ្ឈត្តំ

១ ម. មរណម្បិ ។ ២ ឱ. បញ្ចុបាទានក្ខន្ធាបិ ។ ៣ ឱ. ម. ឧបាទារូបំ ។



[៧៩] ម្នាលអ្នកទាំងឡាយ មានអាយុ ទុក្ខអរិយសច្ច តើដូចម្តេចខ្លះ ជាតិគឺសេចក្តីកើតជាទុក្ខ ១ ជរាគឺសេចក្តីគ្រាំគ្រាជាទុក្ខ ១ មរណៈគឺសេចក្តីស្លាប់ជាទុក្ខ ១ សោកៈគឺសេចក្តីរីងស្ងួតជាទុក្ខ ១ បរិទេវៈគឺសេចក្តីខ្សឹកខ្សួលជាទុក្ខ ១ ទុក្ខៈគឺសេចក្តីលំបាកកាយជាទុក្ខ ១ ទោមនស្សៈគឺសេចក្តីអាក់អន់ចិត្តជាទុក្ខ ១ ឧបាយាសៈគឺសេចក្តីតានតឹងចិត្តជាទុក្ខ ១ បុគ្គលប្រាថ្នានូវរបស់ណាមិនបាន របស់នោះនាំមកនូវទុក្ខ ១ ដោយសេចក្តីបង្រួញ ឧបាទានក្ខន្ធទាំង ៥ ពិតជាទុក្ខ ១ ។ ម្នាលអ្នកទាំងឡាយមានអាយុ ឧបាទានក្ខន្ធទាំងឡាយ ៥ តើដូចម្តេចខ្លះ គឺរូបដែលជាឧបាទានក្ខន្ធ ១ វេទនាដែលជាឧបាទានក្ខន្ធ ១ សញ្ញាដែលជាឧបាទានក្ខន្ធ ១ សង្ខារដែលជាឧបាទានក្ខន្ធ ១ វិញ្ញាណដែលជាឧបាទានក្ខន្ធ ១ ។ ម្នាលអ្នកទាំងឡាយមានអាយុ រូបដែលជាឧបាទានក្ខន្ធ តើដូចម្តេចខ្លះ គឺមហាភូតរូប ៤ និងឧបាទាយរូប គឺរូបដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ។ ម្នាលអ្នកទាំងឡាយមានអាយុ មហាភូតរូបទាំង ៤ ដូចម្តេចខ្លះ គឺបថវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។

[៨០] ម្នាលអ្នកទាំងឡាយ មានអាយុ បថវីធាតុ តើដូចម្តេច ។ គឺបថវីធាតុខាងក្នុងក៏មាន បថវីធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ បថវីធាតុខាងក្នុង តើដូចម្តេច ។ ធាតុណា ដ៏ខាងក្នុង

បច្ចត្តំ កក្ខឡំ ខរិគតំ ឧបាទិន្នំ សេយ្យថីទំ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារុ អដ្ឋិ អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ កក្ខឡំ ខរិគតំ ឧបាទិន្នំ អយំ វុច្ចតាវុសោ អជ្ឈត្តិកា បថវីធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា បថវីធាតុ យា ច ពាហិរា បថវីធាតុ បថវីធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា បថវីធាតុយា និព្ពិន្ទតិ បថវីធាតុយា ចិត្តំ វិរាជេតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ ពាហិរា អាបោធាតុ បកុប្បតិ អន្តរហិតា តស្មិំ សមយេ ពាហិរា បថវីធាតុ ហោតិ ។ តស្សា ហិ នាម អាវុសោ ពាហិរាយ បថវីធាតុយា តាវ មហល្លិកាយ



គួរសម្រេចថាខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ដែលវិញ្ញាណចូលទៅកាន់យក គឺសក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង តម្រងនោម បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ឬក៏ធាតុឯទៀតណាមួយ ជាខាងក្នុង គួរសម្រេចថាខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកមានអាយុ នេះហៅថា បឋវីធាតុខាងក្នុង ។ បឋវីធាតុខាងក្នុងណាក្តី បឋវីធាតុខាងក្រៅណាក្តី ធាតុទាំងពីរនុ៎ះ ឈ្មោះថាបឋវីធាតុតែម្យ៉ាង ។ គប្បីឃើញបឋវីធាតុនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា ធាតុនោះមិនមែនជារបស់អញ នោះមិនមែនជាអាត្មាអញ នោះមិនមែនខ្លួនរបស់អញ ។ លុះឃើញបឋវីធាតុនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះហើយ តែងនឿយណាយក្នុងបឋវីធាតុ ធ្វើចិត្តឲ្យទុញទ្រាន់ក្នុងបឋវីធាតុ ។ ម្នាលអ្នកមានអាយុ អាបោធាតុខាងក្រៅ រមែងកំរើកក្នុងសម័យណា បឋវីធាតុខាងក្រៅ ក៏រលាយទៅក្នុងសម័យនោះ ។ ម្នាលអ្នកមានអាយុ ឥឡូវបឋវីធាតុខាងក្រៅនោះ ជារបស់ធំដល់ម្ល៉េះ

អនិច្ចតា បញ្ញាយិស្សតិ ខយធម្មតា បញ្ញាយិស្សតិ វយ-
ធម្មតា បញ្ញាយិស្សតិ វិបរិណាមធម្មតា បញ្ញាយិស្សតិ ។
កឹ បនិមស្ស មត្តដ្ឋកស្ស កាយស្ស តណ្ហុបាទិន្នស្ស
អហន្តិ វា មមន្តិ វា អស្មីតិ វា អថខ្វស្ស នោ
តេវេត្ថ ហោតិ ។ តញ្ចេ អាវុសោ ភិក្ខុំ បរេ អក្កោសន្តិ
បរិភាសន្តិ រោសេន្តិ វិហេសេន្តិ ។ សោ ឯវំ
បជានាតិ ឧប្បន្នា ខោ មេ អយំ សោតសម្ផស្សជា
ទុក្ខា វេទនា សា ច ខោ បដិច្ច នោ អប្បដិច្ច
កឹ បដិច្ច ផស្សំ បដិច្ច ។ សោបិ ខោ ផស្សោ[១]
អនិច្ចោតិ បស្សតិ វេទនា អនិច្ចាតិ បស្សតិ សញ្ញា
អនិច្ចាតិ បស្សតិ សង្ខារា អនិច្ចាតិ បស្សតិ
វិញ្ញាណំ អនិច្ចន្តិ បស្សតិ តស្ស ធាតារម្មណមេវ
ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ[២] ។

១ ឱ. ម. សោ ផស្សោ ។ ២ ម. ឱ. អធិមុច្ចតិ ។



ម្តេចក៏នឹងមានសភាពមិនទៀង ជាធម្មតា ក៏នឹងមានសភាពអស់ទៅ ជា
ធម្មតា ក៏នឹងមានសភាពសូន្យទៅ ជាធម្មតា ក៏នឹងមានសភាពប្រែប្រួល
ជាធម្មតា ។ ចំណែករាងកាយ ដែលតាំងនៅបន្តិចបន្តួចនេះ ភិក្ខុនឹង
ប្រកាន់ ដោយតណ្ហាថាអញ ថារបស់អញ ថាអញមាន ដូចម្តេចបាន
(ការស្មើតិចតួចនេះហើយ) សេចក្តីប្រកាន់ ដោយអំណាចតណ្ហា មានះ
ទិដ្ឋិ ក្នុងបរិយាយជាកាយនិងក្នុងខន្ធ របស់ភិក្ខុនោះ មិនមានឡើយ ។
ម្នាលអ្នកទាំងឡាយ មានអាយុ បើជនទាំងឡាយដទៃ ជេរ ប្រទេច
គំរាមគំហែង បៀតបៀន ភិក្ខុនោះ ។ ភិក្ខុនោះ តែងដឹងយ៉ាងនេះថា
ទុក្ខវេទនាកើតអំពីសោតសម្ផស្សនេះ កើតឡើងដល់អាត្មាអញហើយតែ
វេទនានោះអាស្រ័យហេតុ ពុំមែនមិនអាស្រ័យហេតុទេ អាស្រ័យ
ហេតុអ្វី គឺអាស្រ័យផស្សៈ ។ ភិក្ខុនោះឯង ឃើញថាផស្សៈមិនទៀង
ឃើញថាវេទនាក៏មិនទៀង ឃើញថាសញ្ញាក៏មិនទៀង ឃើញថាសង្ខារ
ទាំងឡាយក៏មិនទៀង ឃើញថាវិញ្ញាណក៏មិនទៀង ចិត្តរបស់ភិក្ខុនោះ ក៏
ស្ទុះស្ទាជ្រះថ្លា ឋិតនៅព្រម ស៊ប់ស្ងួននៅក្នុងអារម្មណ៍គឺធាតុនោះឯង

តញ្ចេ អាវុសោ ភិក្ខុំ បរេ អនិដ្ឋេហិ អកន្តេហិ អមនាបេហិ សមុទាចរន្តិ បាណិសម្ផស្សេនបិ លេឌ្ឌុសម្ផស្សេនបិ ទណ្ឌសម្ផស្សេនបិ សត្ថសម្ផស្សេនបិ ។ សោ ឯវំ បជានាតិ តថាភូតោ ខោ អយំ កាយោ យថាភូតស្មឹ កាយេ បាណិសម្ផស្សាបិ កមន្តិ លេឌ្ឌុសម្ផស្សាបិ កមន្តិ ទណ្ឌសម្ផស្សាបិ កមន្តិ សត្ថសម្ផស្សាបិ កមន្តិ ។ វុត្តំ ខោ បនេតំ ភគវតា កកចូបមេ(១) ឱវាទេ ឧភតោទណ្ឌកេន ចេបិ ភិក្ខវេ កកចេន ចោរា ឱចរកា អង្គមង្គានិ ឱក្កន្តេយ្យុំ តត្រាបិ(២) យោ មនោ បទោសេយ្យ ន មេ សោ តេន សាសនករោ ។ អារទ្ធំ ខោ បន មេ វីរិយំ ភវិស្សតិ អសល្លីនំ ឧបដ្ឋិតា សតិ អសម្មុដ្ឋា(៣) បស្សទ្ធោ កាយោ អសារទ្ធោ

១ ម. កកចូបមោវាទេតិ ទិស្សតិ ។ ២ ម. តត្រាបិ ។ ៣ ម. អសម្មុដ្ឋាតិ ទិស្សតិ ។



ម្នាលអ្នកទាំងឡាយមានអាយុ បើជនដទៃទាំងឡាយ បៀតបៀនភិក្ខុនោះ ដោយសម្ផស្សដៃក្តី ដោយសម្ផស្សដុំដីក្តី ដោយសម្ផស្សដំបងក្តី ដោយសម្ផស្សគ្រឿងសស្ត្រាក្តី ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ។ ភិក្ខុនោះ ក៏ដឹងច្បាស់យ៉ាងនេះថា កាយនេះឯង ជាធម្មជាតិសម្រាប់ទីសម្ផស្សដៃខ្លះ សម្រាប់ទីសម្ផស្សដុំដីខ្លះ សម្រាប់ទីសម្ផស្សដំបងខ្លះ សម្រាប់ទីសម្ផស្ស គ្រឿងសស្ត្រាខ្លះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ ទុកក្នុងឱវាទ ដែលមានឧបមាដូចរណារ ថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើចោរទាំងឡាយ ជាអ្នកធ្វើអំពើថោកទាប គប្បីអារនូវអវយវៈតូច ធំ ទាំងឡាយ ដោយរណារដែលមានដងទាំងពីរខាង ភិក្ខុណាមួយ បានចិត្ត (មិនអត់ធន់) ប្រទូស្តព្រោះដំណើរ ដែលចោរអារនោះ ភិក្ខុនោះ ឈ្មោះថាមិនធ្វើតាមពាក្យប្រដៅរបស់តថាគត ដោយហេតុដែលមិនអត់ធន់នោះ ។ ភិក្ខុនោះគិតថា សេចក្តីព្យាយាមដែលអាត្មាផ្តើមប្រារព្ធហើយ មិនធូរថយឡើយ សតិ ដែលអាត្មាតម្កល់ទុកខ្ជាប់ហើយ មិនភ្លេចភាំងឡើយ កាយដែលស្ងប់ស្ងាត់ហើយ មិនរសាប់រសល់ឡើយ

សមាហិតំ ចិត្តំ ឯកគ្គំ កាមំ ទានិ ឥមស្មឹ កាយេ
បាណិប្បហារាបិ កមន្តុ លេឌ្ឌុប្បហារាបិ កមន្តុ
ទណ្ឌប្បហារាបិ កមន្តុ សត្ថប្បហារាបិ កមន្តុ
ករីយតិ ហិទំ ពុទ្ធានំ សាសនន្តិ ។ តស្ស
ចេ អាវុសោ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ
ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា
កុសលនិស្សិតា ន សណ្ឋាតិ ។ សោ តេន
សំវិជ្ជតិ សំវេគំ អាបជ្ជតិ អលាភា វត មេ ន វត
មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ
យស្ស មេ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ
អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា



ចិត្តដែលតម្កល់ទុកនឹងហើយ ជាចិត្តមានអារម្មណ៍តែមួយ ឥឡូវនេះ គេរ
សម្ផស្សដៃក្តី សម្ផស្សដុំដីក្តី សម្ផស្សដំបងក្តី សម្ផស្សគ្រឿង
សស្ត្រាក្តី ត្រង់កាយនេះ (ក៏ដោយ) ចុះ អញនៅតែធ្វើតាមពុទ្ធសា-
សនានេះ ។ ម្នាលអាវុសោទាំងឡាយ មានអាយុ កាលបើភិក្ខុនោះរលឹកឃើញ
ព្រះពុទ្ធយ៉ាងនេះ រលឹកឃើញព្រះធម៌យ៉ាងនេះ រលឹកឃើញព្រះសង្ឃយ៉ាងនេះ
ហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល(១)ក៏មិនតាំងនៅនឹងបាន ។
ភិក្ខុនោះក៏តក់ស្លុត ដល់នូវសេចក្តីសង្វេគដោយពាក្យថា ឱ! យើង
ជាមនុស្សឥតលាភ ឱ! យើងជាមនុស្សមិនមានលាភ ឱ! អត្តភាព
ជាមនុស្ស យើងបានដោយក្រ ឱ! អត្តភាពជាមនុស្ស យើងមិន
មែនបានដោយងាយទេ ព្រោះដែលអាត្មាអញ រលឹកឃើញព្រះពុទ្ធយ៉ាងនេះ
រលឹកឃើញព្រះធម៌យ៉ាងនេះ រលឹក ឃើញព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខា

---

១ ត្រង់នេះលោកដៅ ឧបេក្ខាអាស្រ័យនូវកុសល បានដល់វីរិយស្សុបេក្ខា និងឆឡង្គុបេក្ខា ទាំង ២
នេះ ។ ឯឆឡង្គុបេក្ខា ១ នេះ ជាឈ្មោះព្រះខីណាស្រពលោកទាំងឡាយ មិនកោយមនុស្ស ក្នុង
អារម្មណ៍ទាំង៦ ដែលជាអារម្មណ៍ល្អ ។ ក៏ក្នុងទីនេះ សំដៅយកឧបេក្ខាក្នុងឆឡង្គុបេក្ខា ដែល
ព្រះខីណាស្រពតាំងនៅដោយអាស្រ័យនូវសេចក្តីព្យាយាម និងសម្រេចដោយការនេះ ។ អដ្ឋកថា ។

កុសលនិស្សិតា ន សណ្ឋាតិ ។ សេយ្យថាបិ អាវុសោ សុណិសា សសុរំ(១) ទិស្វា សំវិជ្ជតិ សំវេគំ អាបជ្ជតិ ឯវមេវ ខោ អាវុសោ តស្ស ចេ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា ន សណ្ឋាតិ ។ សោ តេន សំវិជ្ជតិ សំវេគំ អាបជ្ជតិ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យស្ស មេ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា ន សណ្ឋាតីតិ ។ តស្ស ចេ អាវុសោ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ ។ សោ តេន អត្តមនោ ហោតិ ។ ឯត្តាវតាបិ ខោ អាវុសោ ភិក្ខុនោ ពហុកតំ ហោតិ ។

---

១ ឱ. ម. សស្សុំ ។



ដែលអាស្រ័យនឹងកុសល គឺមិនតាំងនៅនឹងបាន ។ ម្នាលអ្នកទាំងឡាយមានអាយុ ដូចស្ត្រីជាកូនប្រសា ឃើញឪពុកក្មេកហើយ ក៏តក់ស្លុតដល់នូវសេចក្តីព្រួយបារម្ភ ដូចម្តេចមិញ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះ រលឹកនូវព្រះពុទ្ធយ៉ាងនេះ រលឹកនូវព្រះធម៌យ៉ាងនេះ រលឹកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល គឺមិនតាំងនៅនឹងបាន ដូច្នោះឯង ។ ភិក្ខុនោះក៏តក់ស្លុត ដល់នូវសេចក្តីសង្វេគ ដោយហេតុនេះថា ឱហ្ន៎ អាត្មាអញជាមនុស្សឥតលាភ ឱហ្ន៎ អាត្មាអញជាមនុស្សខ្វែងលាភ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញបានដោយក្រ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញមិនបានដោយងាយទេ ព្រោះដែលកាលអាត្មាអញ រលឹកនូវព្រះពុទ្ធយ៉ាងនេះ រលឹកនូវព្រះធម៌យ៉ាងនេះ រលឹកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខា ដែលអាស្រ័យនឹងកុសល គឺមិនតាំងនៅបាន ។ ម្នាលអ្នកទាំងឡាយ មានអាយុ បើភិក្ខុនោះ រលឹកនូវព្រះពុទ្ធយ៉ាងនេះ រលឹកនូវព្រះធម៌យ៉ាងនេះ រលឹកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល គឺតាំងនៅបាន ។ ភិក្ខុនោះ មានចិត្តត្រេកអរដោយហេតុនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ពាក្យប្រដៅរបស់ព្រះមានព្រះភាគ ឈ្មោះថា ភិក្ខុនោះធ្វើច្រើនៗហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

[៨១] កតមា ចាវុសោ អាបោធាតុ ។ អាបោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ចាវុសោ អជ្ឈត្តិកា អាបោធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ អាបោ អាបោគតំ ឧបាទិន្នំ សេយ្យថីទំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ អាបោ អាបោគតំ ឧបាទិន្នំ អយំ វុច្ចតាវុសោ អជ្ឈត្តិកា អាបោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា អាបោធាតុ យា ច ពាហិរា អាបោធាតុ អាបោធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាបោធាតុយា និព្វិន្ទតិ អាបោធាតុយា ចិត្តំ វិរាជេតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ ពាហិរា អាបោធាតុ



[៨១] ម្នាលអ្នកទាំងឡាយមានអាយុ អាបោធាតុតើដូចម្តេច ។ អាបោធាតុខាងក្នុងក៏មាន អាបោធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ អាបោធាតុខាងក្នុង ដូចម្តេចខ្លះ ។ ធាតុណាដែលជាខាងក្នុង ដែលអាស្រ័យខ្លួន ជាទឹក ឬមានសភាពប្រហែលនឹងទឹក ដែលវិញ្ញាណចូលទៅកាន់យក គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ឬក៏ធាតុដទៃណាមួយជាខាងក្នុង អាស្រ័យខ្លួន ជាទឹក ឬមានសភាពប្រហែលនឹងទឹក ដែលវិញ្ញាណ ចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា អាបោធាតុខាងក្នុង ។ ក៏អាបោធាតុខាងក្នុងណាក្តី អាបោធាតុ ខាងក្រៅណាក្តី ធាតុទាំងពីរនេះ ឈ្មោះថា អាបោធាតុ តែមួយយ៉ាង ។ គប្បី ឃើញអាបោធាតុនោះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះឯង មិនមែនជារបស់អញ នេះក៏មិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះភិក្ខុនោះ ឃើញអាបោធាតុ ដ៏ពិតនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះ ហើយ តែងនឿយណាយក្នុងអាបោធាតុ ញុំាងចិត្តឲ្យធុញ ក្នុងអាបោធាតុ ។ ម្នាលអ្នកទាំងឡាយមានអាយុ ជួនកាលអាបោធាតុខាងក្រៅ

បកុប្បតិ សា គាមម្បិ វហតិ និគមម្បិ វហតិ នគរម្បិ វហតិ ជនបទម្បិ វហតិ ជនបទបទេសម្បិ វហតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ មហាសមុទ្ទេ យោជនសតិកានិបិ ឧទកានិ ឱគ្គច្ឆន្តិ ទ្វិយោជនសតិកានិបិ ឧទកានិ ឱគ្គច្ឆន្តិ តិយោជនសតិកា-និបិ ឧទកានិ ឱគ្គច្ឆន្តិ ចតុយោជនសតិកានិបិ ឧទកានិ ឱគ្គច្ឆន្តិ បញ្ចយោជនសតិកានិបិ ឧទកានិ ឱគ្គច្ឆន្តិ ឆយោជនសតិកានិបិ ឧទកានិ ឱគ្គច្ឆន្តិ សត្តយោជនសតិកានិបិ ឧទកានិ ឱគ្គច្ឆន្តិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ មហាសមុទ្ទេ សត្តតាលម្បិ ឧទកំ សណ្ឋាតិ ឆតាលម្បិ ឧទកំ សណ្ឋាតិ បញ្ចតាលម្បិ ឧទកំ សណ្ឋាតិ ចតុត្តាលម្បិ ឧទកំ សណ្ឋាតិ តិតាលម្បិ ឧទកំ សណ្ឋាតិ ទ្វិតាលម្បិ ឧទកំ សណ្ឋាតិ តាលមត្តម្បិ ឧទកំ សណ្ឋាតិ ។ ហោតិ ខោ សោ អាវុសោ សមយោ



ហៀរផង់ឡើងហើយ អាបោធាតុនោះ ក៏លិចស្រុកខ្លះ លិចនិគមខ្លះ លិចនគរខ្លះ លិចជនបទខ្លះ លិចជនបទនិងប្រទេសខ្លះ ។ ម្នាលអ្នកដ៏មានអាយុ ជួនកាលទឹកក្នុងមហាសមុទ្រមានជម្រៅ ១០០ យោជន៍ រីងទៅក៏មាន ទឹកមានជម្រៅ ២០០ យោជន៍ រីងទៅក៏មាន ទឹកមានជម្រៅ ៣០០ យោជន៍ រីងទៅក៏មាន ទឹកមានជម្រៅ ៤០០ យោជន៍ រីងទៅក៏មាន ទឹកមានជម្រៅ ៥០០ យោជន៍ រីងទៅក៏មាន ទឹកមានជម្រៅ ៦០០ យោជន៍ រីងទៅក៏មាន ទឹកមានជម្រៅ ៧០០ យោជន៍ រីងទៅក៏មាន ។ ម្នាលអ្នកដ៏មានអាយុ ជួនកាលទឹកមានជម្រៅ ៧ ដើមត្នោត ដក់នៅក្នុងមហាសមុទ្រខ្លះ ទឹកមានជម្រៅ ៦ ដើមត្នោតដក់នៅខ្លះ ទឹកមានជម្រៅ ៥ ដើមត្នោតដក់នៅខ្លះ ទឹកមានជម្រៅ ៤ ដើមត្នោតដក់នៅខ្លះ ទឹកមានជម្រៅ ៣ ដើមត្នោតដក់នៅខ្លះ ទឹកមានជម្រៅ ២ ដើមត្នោតដក់នៅខ្លះ ទឹកមានជម្រៅ ១ ដើមត្នោតដក់នៅខ្លះ ។ ម្នាលអ្នកដ៏មានអាយុ ជួនកាល

យំ មហាសមុទ្ទេ សត្តបោរិសម្បិ ឧទកំ សណ្ឋាតិ ឆប្បោរិសម្បិ ឧទកំ សណ្ឋាតិ បញ្ចបោរិសម្បិ ឧទកំ សណ្ឋាតិ ចតុប្បោរិសម្បិ ឧទកំ សណ្ឋាតិ តិបោរិសម្បិ ឧទកំ សណ្ឋាតិ ទ្វិបោរិសម្បិ ឧទកំ សណ្ឋាតិ បោរិសមត្តម្បិ ឧទកំ សណ្ឋាតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ មហាសមុទ្ទេ អឌ្ឍបោរិសម្បិ ឧទកំ សណ្ឋាតិ កដិមត្តម្បិ ឧទកំ សណ្ឋាតិ ជណ្ណុមត្តម្បិ ឧទកំ សណ្ឋាតិ គោប្ផកមត្តម្បិ(១) ឧទកំ សណ្ឋាតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ មហាសមុទ្ទេ អង្គុលិបព្វតេមនមត្តម្បិ ឧទកំ ន ហោតិ ។ តស្សា ហិ នាម អាវុសោ ពាហិរាយ អាបោធាតុយា តាវ មហល្លិកាយ អនិច្ចតា បញ្ញាយិស្សតិ ខយធម្មតា បញ្ញាយិស្សតិ វយធម្មតា បញ្ញាយិស្សតិ វិបរិណាមធម្មតា បញ្ញាយិស្សតិ ។ កិំ បនិមស្ស មត្តដ្ឋកស្ស កាយស្ស តណ្ហុបាទិន្នស្ស អហន្តិ វា មមន្តិ វា

១. ម. គោប្ផមត្តម្បិ ។ ឱ. គោប្ផកមត្តម្បិ ។





ទឹកមានជម្រៅ ៧ ជំហាមនុស្ស ដក់នៅក្នុងមហាសមុទ្រខ្លះ ទឹកមានជម្រៅ ៦ ជំហាមនុស្សដក់នៅខ្លះ ទឹកមានជម្រៅ ៥ ជំហាមនុស្សដក់នៅខ្លះ ទឹកមានជម្រៅ ៤ ជំហាមនុស្សដក់នៅខ្លះ ទឹកមានជម្រៅ ៣ ជំហាមនុស្សដក់នៅខ្លះ ទឹកមានជម្រៅ ២ ជំហាមនុស្សដក់នៅខ្លះ ទឹកមានជម្រៅ ១ ជំហាមនុស្សដក់នៅខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ជួនកាលទឹកមានជម្រៅពាក់កណ្តាលជំហាមនុស្សដក់នៅ ក្នុងមហាសមុទ្រខ្លះ ទឹកមានប្រមាណត្រឹមចង្កេះដក់នៅខ្លះ ទឹកមានប្រមាណត្រឹមជង្គង់ដក់នៅខ្លះ ទឹកមានប្រមាណត្រឹមកែងជើងដក់នៅខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ជួនកាលទឹកគ្រាន់តែសើមថ្នាំងម្រាមដៃ (ដក់នៅ) ក្នុងមហាសមុទ្រក៏មិនមានឡើយក៏មានដែរ ។ ម្នាលអ្នកទាំងឡាយមានអាយុ សូម្បីអាបោធាតុខាងក្រៅនោះ ជារបស់ធំលើសលុប គង់មានសភាពមិនទៀងជាធម្មតា គង់មានសភាពអស់ទៅជាធម្មតា គង់មានសភាពសូន្យទៅជាធម្មតា គង់មានសភាពប្រែប្រួលទៅជាធម្មតា ។ ចំណង់បើកាយ ដែលតាំងនៅបន្តិចបន្តិចនេះ កុំគួរនឹងប្រកាន់ ដោយតណ្ហាថាអញ ជារបស់អញ ជាអញ

អស្មីតិ វា អថ ខ្វាស្ស នោ តេវេត្ថ ហោតិ ។ តស្ស ចេ អាវុសោ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ ។ សោ តេន អត្តមនោ ហោតិ ។ ឯត្តាវតាបិ ខោ អាវុសោ ភិក្ខុនោ ពហុកតំ ហោតិ ។

[៨៤] កតមា ចាវុសោ តេជោធាតុ ។ តេជោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ចាវុសោ អជ្ឈត្តិកា តេជោធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ តេជោ តេជោគតំ ឧបាទិន្នំ សេយ្យថីទំ យេន ច សន្តប្បតិ យេន ច ជីរតិ[១] យេន ច បរិឌយ្ហតិ យេន ច អសិតបីតខាយិតសាយិតំ សម្មាបរិណាមំ គច្ឆតិ យំ វា

១ ម. ជីរយតិ ។ ឱ. ជីយតិ ។



មានខ្លួនតែមួយចំអាម (កាលបើគិតដូច្នេះហើយ) សេចក្តីប្រកាន់ដោយតណ្ហា ថាអញ ថារបស់អញ ថាអញមាន ក្នុងកាយនេះ របស់ភិក្ខុនោះ មិនមានឡើយ ។ ម្នាលអ្នកមានអាយុ កាលបើភិក្ខុនោះ រលឹកឃើញព្រះពុទ្ធយ៉ាងនេះ រលឹកឃើញព្រះធម៌យ៉ាងនេះ រលឹកឃើញព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យកុសល តាំងនៅនឹងបាន ។ ភិក្ខុនោះ មានចិត្តត្រេកអរដោយឧបេក្ខានោះ ។ ម្នាលអ្នកមានអាយុ ភិក្ខុនោះឈ្មោះថា ធ្វើតាមពាក្យប្រដៅ របស់ព្រះមានព្រះភាគច្រើនហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

(៨៤) ម្នាលអ្នកមានអាយុ តេជោធាតុដូចម្តេច ។ តេជោធាតុខាងក្នុងក៏មាន តេជោធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកមានអាយុ តេជោធាតុខាងក្នុង តើដូចម្តេច ។ ពាក្យណា ជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាភ្លើង ឬមានសភាពប្រហែលនឹងភ្លើង ដែលវិញ្ញាណចូលទៅកាន់យក គឺតេជោធាតុ ដែលញុំាងកាយឲ្យក្តៅសព្វ ១ តេជោធាតុដែលធ្វើកាយឲ្យគ្រាំគ្រា ១ តេជោធាតុដែលដុតកាយឲ្យក្រហល់ក្រហាយ ១ តេជោធាតុសម្រាប់ដុតរំលាយវត្ថុដែលបានស៊ី ផឹក ទំពាស៊ី ជញ្ជក់ភ្លក្ស ឲ្យប្រែប្រួលទៅដោយប្រពៃ ១

បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ តេជោ តេជោគតំ ឧបាទិន្នំ អយំ វុច្ចតាវុសោ អជ្ឈត្តិកា តេជោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា តេជោធាតុ យា ច ពាហិរា តេជោធាតុ តេជោធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា តេជោធាតុយា និព្វិន្ទតិ តេជោធាតុយា ចិត្តំ វិរាជេតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ ពាហិរា តេជោធាតុ បកុប្បតិ សា គាមម្បិ ទហតិ និគមម្បិ ទហតិ នគរម្បិ ទហតិ ជនបទម្បិ ទហតិ ជនបទប្បទេសម្បិ ទហតិ ។ សា ហរិតន្តំ វា បន្ថន្តំ វា សេលន្តំ វា ឧទកន្តំ វា រមណីយំ វា ភូមិភាគំ អាគម្ម អនាហារា និព្វាយតិ ។ ហោតិ ខោ សោ អាវុសោ សមយោ





មួយទៀត ធាតុភ្លើងណាមួយ ជាខាងក្នុង ដែលអាស្រ័យខ្លួនខ្ញុំ ជាភ្លើង ឬពួកសភាពប្រព្រឹត្តទៅជាភ្លើង ដែលវិញ្ញាណ ចូលទៅកាន់យក ម្នាលអ្នកទាំងឡាយ មានអាយុ នេះហៅថា តេជោធាតុខាងក្នុង ។ តេជោធាតុខាងក្នុងណាក្តី តេជោធាតុខាងក្រៅណាក្តី ធាតុទាំងពីរនេះ ឈ្មោះថា តេជោធាតុតែមួយយ៉ាង ។ គប្បីឃើញតេជោធាតុនោះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះឯង មិនមែនជារបស់អញ នោះក៏មិនមែនជាអញ នោះមិនមែនខ្លួនរបស់អញ ។ លុះគប្បីឃើញតេជោធាតុនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះហើយ តែងនឿយណាយក្នុងតេជោធាតុ ធ្វើចិត្តឲ្យនឿយណាយក្នុងតេជោធាតុ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលតេជោធាតុខាងក្រៅកម្រើកឡើង តេជោធាតុនោះ តែងឆេះស្រុកខ្លះ ឆេះនិគមខ្លះ ឆេះនគរខ្លះ ឆេះជនបទខ្លះ ឆេះជនបទនិងប្រទេសខ្លះ ។ តេជោធាតុនោះ ទោះឆេះស្មៅស្រស់ខ្លះ ឆេះផ្លូវខ្លះ ថ្មខ្លះ ទឹកខ្លះ ឬផ្ទៃផែនដីជាទីរមណីយដ្ឋាន (ដែលគ្មានស្មៅ)ខ្លះ ឥតមានគ្រឿងឆេះទៅទៀត ក៏រលត់ទៅឯង ។ ម្នាលអ្នកទាំងឡាយមានអាយុ

យំ កុក្កុដបត្តេនបិ ណ្ហារុទទ្ទុលេនបិ(១) អគ្គិំ គវេ-សន្តិ ។ តស្សា ហិ នាម អាវុសោ ពាហិរាយ តេជោធាតុយា តាវ មហល្លិកាយ អនិច្ចតា បញ្ញាយិស្សតិ ខយធម្មតា បញ្ញាយិស្សតិ វយធម្មតា បញ្ញាយិស្សតិ វិបរិណាមធម្មតា បញ្ញាយិស្សតិ ។ កិំ បនិមស្ស មត្តដ្ឋកស្ស កាយស្ស តណ្ហុបា-ទិន្នស្ស អហន្តិ វា មមន្តិ វា អស្មីតិ វា អថ ខ្វស្ស នោ តេវេត្ថ ហោតិ ។ តស្ស ចេ អាវុសោ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ ។ សោ តេន អត្តមនោ ហោតិ ។ ឯត្តាវតាបិ ខោ សោ អាវុសោ ភិក្ខុនោ ពហុកតំ ហោតិ ។

១ ម. នហារុទទ្ទុលេនបិ ។ ឱ. ណ្ហារុទទ្ទុលេនបិ ។



ជួនកាលដល់នូវទីទូលាយ ពួកជនស្វែងរកភ្លើងដោយស្លាបមាន់ខ្លះ ដោយការកូតសរសៃស្បែកខ្លះ ។ ម្នាលអ្នកដ៏មានអាយុ សូម្បីតេជោធាតុខាងក្រៅនោះដ៏ធំលើសលុប នឹងមានសភាពមិនទៀងដ៏ជាក់ច្បាស់ នឹងមានសភាពអស់ទៅជាធម្មតា នឹងមានសភាពសូន្យទៅជាធម្មតា នឹងមានសភាពប្រែប្រួលទៅជាធម្មតា ។ ចំណង់បើកាយដែលតាំងនៅបន្តិចបន្តួចនេះ ដែលគេប្រកាន់ដោយតណ្ហាថា អញ ថា របស់អញ ថា អញមាន ដូចម្តេចបាន (កាលបើគិតដូច្នោះហើយ) សេចក្តីប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ក្នុងតេជោធាតុខាងក្នុងនោះ របស់ភិក្ខុនោះ មិនមានឡើយ ។ ម្នាលអ្នកដ៏មានអាយុ កាលបើភិក្ខុនោះ រលឹកឃើញព្រះពុទ្ធយ៉ាងនេះ រលឹកឃើញព្រះធម៌យ៉ាងនេះ រលឹកឃើញព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏តាំងនៅនឹងបាន ។ ភិក្ខុនោះ មានចិត្តត្រេកអរ ដោយហេតុនោះ ។ ម្នាលអ្នកដ៏មានអាយុ ភិក្ខុនោះឈ្មោះថា ធ្វើតាមពាក្យប្រដៅ របស់ព្រះមានព្រះភាគច្រើន ៗ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

[៨៣] កតមា ចាវុសោ វាយោធាតុ ។ វាយោ-
ធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា
ចាវុសោ អជ្ឈត្តិកា វាយោធាតុ ។ យំ អជ្ឈត្តំ
បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ សេយ្យថីទំ ឧទ្ធង្គមា
វាតា អធោគមា វាតា កុច្ឆិសយា វាតា កោដ្ឋសយា
វាតា អង្គមង្គានុសារិនោ វាតា អស្សាសោ បស្សាសោ
ឥតិ វា យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ
វាយោ វាយោគតំ ឧបាទិន្នំ អយំ វុច្ចតាវុសោ អជ្ឈត្តិកា
វាយោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា វាយោ-
ធាតុ យា ច ពាហិរា វាយោធាតុ វាយោធាតុរេវេសា ។
តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ
យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ
សម្មប្បញ្ញាយ ទិស្វា វាយោធាតុយា និព្ពិន្ទតិ



(៨៣) ម្នាលអ្នកដ៏មានអាយុ វាយោធាតុ តើដូចម្តេច ។ វាយោធាតុខាងក្នុងក៏មាន វាយោធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកដ៏មានអាយុ វាយោធាតុខាងក្នុង តើដូចម្តេច ។ ធាតុណាជាខាងក្នុង ដែលអាស្រ័យខ្លួន ជាខ្យល់ ឬមានសភាពទៅតាមនឹងខ្យល់ ដែលវិញ្ញាណក្ខន្ធកាន់យក គឺខ្យល់បក់ឡើងលើ ១ ខ្យល់បក់ចុះក្រោម(១) ១ ខ្យល់បក់នៅក្នុងផ្ទៃខាងក្រៅពោះវៀន ១ ខ្យល់បក់ក្នុងពោះវៀន ១ ខ្យល់បក់សព្វសព៌ាង្គកាយ(២) ១ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ១ មួយទៀត វាយោធាតុទាំងឡាយណានីមួយ ជាខាងក្នុង អាស្រ័យខ្លួន ជាខ្យល់ ឬមានសភាពទៅតាមនឹងខ្យល់ ដែលវិញ្ញាណក្ខន្ធកាន់យក ម្នាលអ្នកដ៏មានអាយុ នេះហៅថា វាយោធាតុខាងក្នុង ។ វាយោធាតុខាងក្នុងណាក្តី វាយោធាតុខាងក្រៅណាក្តី ធាតុទាំងពីរនោះ ឈ្មោះថា វាយោធាតុតែមួយយ៉ាង ។ ភិក្ខុគួរឃើញវាយោធាតុនោះ ដោយប្រាជ្ញាប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះក៏មិនមែនជាអញ នោះមិនមែនជាខ្លួនរបស់អញ ។ លុះភិក្ខុនោះឃើញវាយោធាតុនុ៎ះ ដោយប្រាជ្ញាប្រពៃ តាមពិតយ៉ាងនេះហើយ ក៏នឿយណាយក្នុងវាយោធាតុ

---

១ បានដល់ខ្យល់ដែលបក់ចេញទៅទ្វារធំនិងបង្ហោរជាដើម ។ ២ បានដល់ខ្យល់ដែលបក់ក្នុងបណ្តាអង្គតូចនិងអង្គធំទាំងឡាយជាដើម ។ អដ្ឋកថា ។

វាយោធាតុយា ចិត្តំ វិរាជេតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ ពាហិរា វាយោធាតុ បកុប្បតិ សា គាមម្បិ វហតិ និគមម្បិ វហតិ នគរម្បិ វហតិ ជនបទម្បិ វហតិ ជនបទប្បទេសម្បិ វហតិ ។ ហោតិ ខោ សោ អាវុសោ សមយោ យំ គិម្ហានំ បច្ឆិមេ មាសេ តាលវណ្ដេនបិ វិធូបនេនបិ វាតំ បរិយេសន្តិ ឱស្សវនេបិ តិណានិ ន ឥញ្ជន្តិ(១) ។ តស្សា ហិ នាម អាវុសោ ពាហិរាយ វាយោធាតុយា តាវ មហល្លិកាយ អនិច្ចតា បញ្ញាយិស្សតិ ខយធម្មតា បញ្ញាយិស្សតិ វយធម្មតា បញ្ញាយិស្សតិ វិបរិណាមធម្មតា បញ្ញាយិស្សតិ ។ កឹ បនិមស្ស មត្តដ្ឋកស្ស កាយស្ស តណ្ហុបាទិន្នស្ស អហន្តិ វា មមន្តិ វា អស្មីតិ វា អថខ្វស្ស នោតេវេត្ថ ហោតិ ។ តញ្ចេ អាវុសោ ភិក្ខុំ បរេ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ ។ សោ ឯវំ បជានាតិ ឧប្បន្នា ខោ មេ អយំ សោតសម្ផស្សជា ទុក្ខា វេទនា

១ ម. ប. ន ឥញ្ជន្តិ ។



ធ្វើចិត្តឲ្យធុញទ្រាន់ក្នុងវាយោធាតុ ។ នែអ្នកទាំងឡាយមានអាយុ ជួនកាលវាយោធាតុខាងក្រៅកម្រើកឡើង វាយោធាតុនោះបក់លម្អិតស្រុកខ្លះ បក់លម្អិតនិគមខ្លះ បក់លម្អិតនគរខ្លះ បក់លម្អិតជនបទខ្លះ បក់លម្អិតជនបទប្រទេសខ្លះ ។ ម្នាលអ្នកទាំងឡាយ មានអាយុ ជួនកាលដល់ខែជាទីបំផុតនៃគិម្ហរដូវ ជនទាំងឡាយ តែងស្វែងរកខ្យល់ដោយផ្លិតស្លឹកត្នោតខ្លះ ដោយផ្លិតសម្រាប់បក់ភ្លើងខ្លះ សូម្បីតែស្មៅក្នុងសំយាបផ្ទះ ក៏មិនកម្រើកញាប់ញ័រ ។ ម្នាលអ្នកទាំងឡាយ មានអាយុ សូម្បីវាយោធាតុខាងក្រៅនោះ ដ៏ធំធេង គង់មានសភាពមិនទៀងជាធម្មតា គង់មានសភាពអស់ទៅជាធម្មតា គង់មានសភាពសូន្យទៅជាធម្មតា គង់មានសភាពប្រែប្រួលទៅជាធម្មតា ។ ចំណង់បើកាយដែលតាំងនៅបន្តិចបន្តួចនេះ គឺកាយដែលប្រកាន់ដោយតណ្ហាថាអញ ថារបស់អញ ថាអញមានដូចម្ដេចខ្លះ (កាលបើគិតដូច្នេះហើយ) សេចក្ដីប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ក្នុងវាយោធាតុខាងក្នុងនោះ របស់ភិក្ខុនោះ មិនមានឡើយ ។ ម្នាលអ្នកទាំងឡាយ មានអាយុ បើជនទាំងឡាយដទៃជេរប្រទេច ញាំញី បៀតបៀនភិក្ខុនោះ ។ ភិក្ខុនោះ តែងដឹងយ៉ាងនេះថា ទុក្ខវេទនាកើតអំពីសម្ផស្សនេះ កើតឡើងហើយដល់អាត្មាអញហើ

សោ ច ខោ បដិច្ច នោ អប្បដិច្ច កឹ បដិច្ច ផស្សំ បដិច្ច ។ សោ ច ខោ ផស្សោ អនិច្ចោតិ បស្សតិ វេទនា អនិច្ចាតិ បស្សតិ សញ្ញា អនិច្ចាតិ បស្សតិ សង្ខារា អនិច្ចាតិ បស្សតិ វិញ្ញាណំ អនិច្ចន្តិ បស្សតិ តស្ស ធាតារម្មណមេវ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ(១) ។ តញ្ចេ អាវុសោ ភិក្ខុំ បរេ អនិដ្ឋេហិ អកន្តេហិ អមនាបេហិ សមុទាចរន្តិ បាណិសម្ផស្សេនបិ លេឌ្ឌុសម្ផស្សេនបិ ទណ្ឌសម្ផស្សេនបិ សត្ថសម្ផស្សេនបិ ។ សោ ឯវំ បជានាតិ តថាភូតោ ខោ អយំ កាយោ យថាភូតស្មឹ កាយេ បាណិសម្ផស្សាបិ កមន្តិ លេឌ្ឌុសម្ផស្សាបិ កមន្តិ ទណ្ឌសម្ផស្សាបិ កមន្តិ សត្ថសម្ផស្សាបិ កមន្តិ ។ វុត្តំ ខោ បនេតំ ភគវតា កកចូបមោវាទេ ឧភតោទណ្ឌកេន ចេបិ ភិក្ខវេ ចោរា ឱចរកា អង្គមង្គានិ ឱក្កន្តេយ្យុំ តត្រាបិ យោ មនោ បទោសេយ្យ ន មេ សោ តេន សាសនករោតិ ។ អារទ្ធំ ខោ បន មេ វីរិយំ ភវិស្សតិ

១ ម. ម. អធិមុច្ចតិ ។



គឺវេទនានោះឯង អាស្រ័យហេតុ ឬមិនអាស្រ័យហេតុទេ អាស្រ័យហេតុអ្វី គឺអាស្រ័យផស្សៈ ។ ភិក្ខុនោះឯងឃើញថា ផស្សៈមិនទៀង ឃើញថា វេទនាមិនទៀង ឃើញថា សញ្ញាមិនទៀង ឃើញថា សង្ខារទាំងឡាយមិនទៀង ឃើញថា វិញ្ញាណមិនទៀង ចិត្តរបស់ភិក្ខុនោះ ក៏ស្ទុះស្ទា ជ្រះថ្លា ឋិតនៅព្រម ស៊ប់ស្ងួននៅ ក្នុងអារម្មណ៍គឺធាតុនោះឯង ។ ម្នាលអ្នកទាំងឡាយ មានអាយុ បើជនទាំងឡាយដទៃ បៀតបៀនភិក្ខុនោះ ដោយសម្ផស្សដៃក្តី សម្ផស្សដុំដីក្តី សម្ផស្សដំបងក្តី សម្ផស្សគ្រឿងសស្ត្រាក្តី ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ ភិក្ខុនោះ ក៏ដឹងច្បាស់យ៉ាងនេះថា កាយនេះឯង ជាសភាពសម្រាប់ដើសម្ផស្សដៃខ្លះ សម្ផស្សដុំដីខ្លះ សម្ផស្សដំបងខ្លះ សម្ផស្សសស្ត្រាខ្លះ ។ ព្រោះហេតុនោះដូចនេះ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ ក្នុងកកចូបមោវាទ ដែលប្រៀបដោយរណារថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកចោរ ជាអ្នកធ្វើអំពើថោកទាប គប្បីអារ អវយវៈតូចធំទាំងឡាយ (របស់ភិក្ខុនោះ) ដោយរណារ ដែលមានដងទាំងពីរខាង ភិក្ខុណា ធ្វើចិត្តប្រទូស្ត (មិនអត់ធន់) ក្នុងដំណើរដែលពួកចោរអារនោះ ភិក្ខុនោះ ឈ្មោះថា មិនធ្វើតាមពាក្យប្រដៅរបស់តថាគត ដោយហេតុដែលមិនអត់ធន់នោះ ។ ភិក្ខុនោះគិតថា សេចក្តីព្យាយាមដែលអាត្មាប្រារព្ធហើយ

អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ កាមំ ទានិ ឥមស្មឹ កាយេ បាណិសម្ផស្សាបិ កមន្តុ លេឌ្ឌុសម្ផស្សាបិ កមន្តុ ទណ្ឌសម្ផស្សាបិ កមន្តុ សត្ថសម្ផស្សាបិ កមន្តុ ករីយតិ ហិទំ ពុទ្ធានំ សាសនន្តិ ។ តស្ស ចេ អាវុសោ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា ន សណ្ឋាតិ ។ សោ តេន សំវិជ្ជតិ សំវេគំ អាបជ្ជតិ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យស្ស មេ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា ន សណ្ឋាតីតិ ។ សេយ្យថាបិ អាវុសោ សុណិសា សសុរំ ទិស្វា សំវិជ្ជតិ សំវេគំ អាបជ្ជតិ



នឹងមិនធូរថយឡើយ សតិ ដែលអាត្មាអញតាំងទុកហើយ នឹងមិនភ្លេចភ្លាត់ឡើយ កាយដែលស្ងប់ស្ងាត់ហើយ នឹងមិនរសាប់រសល់ឡើយ ចិត្តដែលតម្កល់នឹងហើយ នឹងមានអារម្មណ៍មួយតែមួយ ឥឡូវនេះ ការសម្ផស្សដៃក្ដី សម្ផស្សដុំដីក្ដី សម្ផស្សដំបងក្ដី សម្ផស្សគ្រឿងសស្ត្រាក្ដី ចូរតែកាយនេះ (គឺគ្រប់ទាំងខ្លួន) ឯអាត្មាអញ គឺនៅតែធ្វើតាមពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយមិនលែង ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះ រលឹកឃើញព្រះពុទ្ធយ៉ាងនេះ រលឹកឃើញព្រះធម៌យ៉ាងនេះ រលឹកឃើញព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល មិនតាំងនៅនឹងបាន ភិក្ខុនោះតែងតក់ស្លុត ដល់នូវសេចក្ដីសង្វេគដោយហេតុនោះថា ឱហ្ន៎ អាត្មាអញជាមនុស្សឥតលាភ ឱហ្ន៎ អាត្មាអញជាមនុស្សមិនមានលាភ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញបានដោយក្រ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញ មិនមែនបានដោយងាយ ។ ព្រោះដែលអាត្មាអញរលឹកឃើញព្រះពុទ្ធយ៉ាងនេះ រលឹកឃើញព្រះធម៌យ៉ាងនេះ រលឹកឃើញព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខា ដែលអាស្រ័យនឹងកុសលមិនតាំងនៅនឹងបាន ។ ម្នាលអ្នកទាំងឡាយមានអាយុ ដូចស្រីជាកូនប្រសា ឃើញឪពុកក្មេកហើយ ក៏ភ្ញាក់ឡើង ដល់នូវសេចក្ដីសង្វេគ

ឯវមេវ ខោ អាវុសោ តស្ស ចេ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា ន សណ្ឋាតិ ។ សោ តេន សំវិជ្ជតិ សំវេគំ អាបជ្ជតិ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យស្ស មេ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា ន សណ្ឋាតីតិ ។ តស្ស ចេ អាវុសោ ភិក្ខុនោ ឯវំ ពុទ្ធំ អនុស្សរតោ ឯវំ ធម្មំ អនុស្សរតោ ឯវំ សង្ឃំ អនុស្សរតោ ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ ។ សោ តេន អត្តមនោ ហោតិ ។ ឯត្តាវតាបិ ខោ អាវុសោ ភិក្ខុនោ ពហុកតំ ហោតិ ។



ដូចម្ដេចមិញ ម្នាលអ្នកទាំងឡាយមានអាយុ កាលភិក្ខុនោះរលឹកនូវព្រះពុទ្ធយ៉ាងនេះ រលឹកនូវព្រះធម៌យ៉ាងនេះ រលឹកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខា ដែលអាស្រ័យនឹងកុសល ក៏មិនបានតាំងនៅនឹងថ្លោះឯង ។ ភិក្ខុនោះរំភើបតក់ស្លុត ដល់នូវសេចក្ដីសង្វេគដោយហេតុនោះថា ឱហ្ន៎ អាត្មាអញជាមនុស្សឥតលាភ ឱហ្ន៎ អាត្មាអញជាមនុស្សមិនមានលាភ អត្តភាពជាមនុស្ស អាត្មាអញបានដោយកម្រ អត្តភាពជាមនុស្ស អាត្មាអញមិនមែនបានដោយងាយទេ ព្រោះថាដែលអាត្មាអញរលឹកនូវព្រះពុទ្ធយ៉ាងនេះ រលឹកនូវព្រះធម៌យ៉ាងនេះ រលឹកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខា ដែលអាស្រ័យនឹងកុសល មិនបានតាំងនៅនឹងបាន ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះ រលឹកនូវព្រះពុទ្ធយ៉ាងនេះ រលឹកនូវព្រះធម៌យ៉ាងនេះ រលឹកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខា ដែលអាស្រ័យនឹងកុសល រមែងតាំងនៅនឹងបាន ។ ភិក្ខុនោះ មានចិត្តត្រេកអរដោយហេតុនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ភិក្ខុនោះ ឈ្មោះថាធ្វើតាមពាក្យប្រដៅរបស់ព្រះមានព្រះភាគច្រើន ។ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[៩៤] សេយ្យថាបិ អាវុសោ កដ្ឋញ្ច បដិច្ច វល្លិញ្ច បដិច្ច មត្តិកញ្ច បដិច្ច តិណញ្ច បដិច្ច អាកាសោ បរិវារិតោ អគារន្ត្វេវ(១) សង្ខ្យំ គច្ឆតិ ឯវមេវ ខោ អាវុសោ អដ្ឋិញ្ច បដិច្ច ន្ហារុញ្ច បដិច្ច មំសញ្ច បដិច្ច ចម្មញ្ច បដិច្ច អាកាសោ បរិវារិតោ រូបន្ត្វេវ សង្ខ្យំ គច្ឆតិ ។ អជ្ឈត្តិកញ្ចេ(២) អាវុសោ ចក្ខុំ អបរិភិន្នំ ហោតិ ពាហិរា ច រូបា ន អាបាថំ អាគច្ឆន្តិ នោ ច តជ្ជោ សមន្នាហារោ ហោតិ នេវ តាវ តជ្ជស្ស វិញ្ញាណភាគស្ស បាតុភាវោ ហោតិ ។ អជ្ឈត្តិកញ្ចេ អាវុសោ ចក្ខុំ អបរិភិន្នំ ហោតិ ពាហិរា ច រូបា អាបាថំ អាគច្ឆន្តិ នោ ច តជ្ជោ សមន្នាហារោ ហោតិ នេវ តាវ តជ្ជស្ស វិញ្ញាណភាគស្ស បាតុភាវោ ហោតិ ។ យតោ ច ខោ អាវុសោ អជ្ឈត្តិកញ្ចេវ ចក្ខុំ អបរិភិន្នំ ហោតិ ពាហិរា ច រូបា អាបាថំ អាគច្ឆន្តិ

១ ម. អគារន្ត្វេវ ។ ឱ. អគារំត្វេវ ។ ២ ម. អជ្ឈត្តិកញ្ចេវ ។



[៩៤] ម្នាលអ្នកទាំងឡាយមានអាយុ អាកាសគឺទីវាលដែលគេអាស្រ័យគ្រឿងឈើខ្លះ អាស្រ័យវល្លិ៍សម្រាប់ចងខ្លះ អាស្រ័យដីសម្រាប់លាបខ្លះ អាស្រ័យស្បូវប្រក់ខ្លះ ផ្គុំជាមួយគ្នាហើយ ក៏រាប់ហៅថាផ្ទះបាន យ៉ាងណាមិញ ម្នាលអ្នកទាំងឡាយមានអាយុ អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថារូបបាន ដូច្នោះឯង ។ ម្នាលអ្នកទាំងឡាយមានអាយុ បើចក្ខុខាងក្នុងមិនសាបសូន្យទេ តែរូបទាំងឡាយខាងក្រៅ មិនបានមកកាន់គន្លងចក្ខុផង ការពិចារណាអារម្មណ៍ ដែលកើតអំពីចក្ខុនិងរូបនោះ មិនមានផង ចំណែកនៃវិញ្ញាណ ដែលកើតអំពីចក្ខុនិងរូបនោះ ក៏មិនទាន់កើតប្រាកដនៅឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ បើចក្ខុខាងក្នុងមិនសាបសូន្យទេ ហើយរូបទាំងឡាយខាងក្រៅ បានមកកាន់គន្លងចក្ខុ តែការពិចារណាអារម្មណ៍ ដែលកើតអំពីចក្ខុនិងរូបនោះ មិនមាន ចំណែកនៃវិញ្ញាណ ដែលកើតអំពីចក្ខុនិងរូបនោះ ក៏មិនទាន់កើតប្រាកដនៅឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលណាបើចក្ខុខាងក្នុងមិនសាបសូន្យផង រូបទាំងឡាយខាងក្រៅ មកកាន់គន្លងចក្ខុផង

តជ្ជោ ច សមន្នាហារោ ហោតិ ។ ឯវំ តជ្ជស្ស វិញ្ញាណភាគស្ស បាតុភាវោ ហោតិ ។ យំ តថាភូតស្ស រូបំ តំ រូបូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ យា តថាភូតស្ស វេទនា សា វេទនូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ យា តថាភូតស្ស សញ្ញា សា សញ្ញូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ យេ តថាភូតស្ស សង្ខារា តេ សង្ខារូបាទានក្ខន្ធេ សង្គហំ គច្ឆន្តិ ។ យំ តថាភូតស្ស វិញ្ញាណំ តំ វិញ្ញាណូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេសំ(១) បញ្ចន្នំ ឧបាទានក្ខន្ធានំ សង្គហោ សន្និបាតោ សមវាយោ ហោតិ ។ វុត្តំ ខោ បនេតំ ភគវតា យោ បដិច្ចសមុប្បាទំ បស្សតិ សោ ធម្មំ បស្សតិ យោ ធម្មំ បស្សតិ សោ បដិច្ចសមុប្បាទំ បស្សតីតិ ។

---

១ ម. កិរមេសំ ។ ឱ. កិរ ឥមេសំ ។



ការពិចារណា អារម្មណ៍ដែលកើតអំពីចក្ខុនិងរូបនោះ ក៏កើតមានផង ។ ចំណែកនៃវិញ្ញាណ ដែលកើតអំពីចក្ខុនិងរូបនោះ ទើបកើតប្រាកដឡើង ដោយប្រការដូច្នេះ ។ រូបណា ដែលកើតជាមួយនឹងចក្ខុវិញ្ញាណ រូបនោះ សង្គ្រោះចូលក្នុងរូបូបាទានក្ខន្ធ ។ វេទនាណា ដែលកើតជាមួយនឹងចក្ខុវិញ្ញាណ វេទនានោះ សង្គ្រោះចូលក្នុងវេទនូបាទានក្ខន្ធ ។ សញ្ញាណា ដែលកើតជាមួយនឹងចក្ខុវិញ្ញាណ សញ្ញានោះ សង្គ្រោះចូលក្នុងសញ្ញូបាទានក្ខន្ធ ។ សង្ខារទាំងឡាយណា ដែលកើតជាមួយនឹងចក្ខុវិញ្ញាណ សង្ខារទាំងឡាយនោះ សង្គ្រោះចូលក្នុងសង្ខារូបាទានក្ខន្ធ ។ វិញ្ញាណណា ដែលកើតជាមួយនឹងចក្ខុ វិញ្ញាណនោះ សង្គ្រោះចូលក្នុងវិញ្ញាណូបាទានក្ខន្ធ ។ ភិក្ខុនោះតែងដឹងច្បាស់ យ៉ាងនេះថា ការសង្គ្រោះ គឺប្រមូលប្រជុំនូវឧបាទានក្ខន្ធទាំង៥ នេះ យ៉ាងនេះឯង ។ មួយវិញទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលណា ឃើញបដិច្ចសមុប្បាទ (សេចក្តីកើតឡើង ព្រោះអាស្រ័យហេតុ) បុគ្គលនោះ ឈ្មោះថា ឃើញធម៌ បុគ្គលណា ឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញបដិច្ចសមុប្បាទ (គឺសេចក្តីកើតឡើង ព្រោះអាស្រ័យហេតុ) ។

បដិច្ចសមុប្បន្នា ខោ បនិមេ យទិទំ បញ្ចុបាទា-
នក្ខន្ធា ។ យោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឆន្ទោ
អាលយោ អនុនយោ អជ្ឈោសានំ សោ ទុក្ខសមុទ-
យោ ។ យោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឆន្ទ-
រាគវិនយោ ឆន្ទរាគប្បហានំ សោ ទុក្ខនិរោធោតិ(១) ។
ឯត្តាវតាបិ ខោ អាវុសោ ភិក្ខុនោ ពហុកតំ ហោតិ ។
អជ្ឈត្តិកញ្ចេ អាវុសោ សោតំ អបរិភិន្នំ ហោតិ...
ឃានំ អបរិភិន្នំ ហោតិ... ជិវ្ហា អបរិភិន្នា ហោ-
តិ... កាយោ អបរិភិន្នោ ហោតិ... អជ្ឈត្តិកោ
ចេ អាវុសោ មនោ អបរិភិន្នោ ហោតិ ពាហិរា
ច ធម្មា ន អាបាថំ អាគច្ឆន្តិ នោ ច តជ្ជោ
សមន្នាហារោ ហោតិ នេវ តាវ តជ្ជស្ស វិញ្ញា-
ណភាគស្ស បាតុភាវោ ហោតិ ។ អជ្ឈត្តិកោ ចេ
អាវុសោ មនោ អបរិភិន្នោ ហោតិ ពាហិរា ច ធម្មា

១ ម. ប. ឥតិសទ្ទោ នត្ថិ ។



ឧបាទានក្ខន្ធទាំង៥ណា ដែលមាននៅ ឧបាទានក្ខន្ធទាំង៥នេះឯង កើត
ឡើងព្រមព្រោះអាស្រ័យហេតុ សេចក្តីពេញចិត្ត សេចក្តីអាល័យ សេចក្តី
ត្រេកអរចំពោះសេចក្តីជ្រប់ចុះ ក្នុងឧបាទានក្ខន្ធទាំង៥នេះណា សេចក្តីពេញ
ចិត្តជាដើមនោះ ឈ្មោះថាទុក្ខសមុទយៈ (ហេតុនាំឲ្យកើតឡើងនៃទុក្ខ)
ការកំចាត់បង់នូវតម្រេកដោយអំណាចនៃឆន្ទៈ ពីការលះបង់នូវតម្រេក
ដោយអំណាចនៃឆន្ទៈណា ក្នុងឧបាទានក្ខន្ធទាំង៥នេះ ការកំចាត់
បង់នូវតម្រេកជាដើមនោះ ឈ្មោះថា ទុក្ខនិរោធ ។ ម្នាលអ្នកដ៏ទាំងឡាយ
មានអាយុ ពាក្យប្រដៅរបស់ព្រះមានព្រះភាគ ឈ្មោះថា ភិក្ខុធ្វើ
ច្រើនហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ ម្នាលអ្នកដ៏-
ទាំងឡាយ មានអាយុ បើសោតប្បសាទខាងក្នុងមិនសាបសូន្យ ។ ។ ឃាន-
ប្បសាទមិនសាបសូន្យ... ជិវ្ហាប្បសាទមិនសាបសូន្យ ។ កាយប្បសាទមិន
សាបសូន្យ ។ ។ ម្នាលអ្នកដ៏ទាំងឡាយមានអាយុ បើចិត្តខាងក្នុង មិនសាប
សូន្យទេ តែធម្មារម្មណ៍ទាំងឡាយខាងក្រៅ មិនបានមកកាន់គន្លងចិត្ត
ផង ការពិចារណាអារម្មណ៍ ដែលកើតអំពីចិត្តនិងធម្មារម្មណ៍នោះ ក៏មិន
មានទាំងផង ចំណែកនៃវិញ្ញាណ ដែលកើតអំពីចិត្តនិងធម្មារម្មណ៍នោះ
ក៏មិនទាន់កើតប្រាកដឡើងឡើយ ។ ម្នាលអ្នកដ៏ទាំងឡាយ មានអាយុ
បើចិត្តខាងក្នុង មិនសាបសូន្យផង ធម្មារម្មណ៍ទាំងឡាយខាងក្រៅ

អាបាថំ អាគច្ឆន្តិ នោ ច តជ្ជោ សមន្នាហារោ ហោតិ នេវ តាវ តជ្ជស្ស វិញ្ញាណភាគស្ស បាតុភាវោ ហោតិ ។ យតោ ច ខោ អាវុសោ អជ្ឈត្តិកោ ចេវ មនោ អបរិភិន្នោ ហោតិ ពាហិរា ច ធម្មា អាបាថំ អាគច្ឆន្តិ តជ្ជោ ច សមន្នាហារោ ហោតិ ។ ឯវំ តជ្ជស្ស វិញ្ញាណភាគស្ស បាតុភាវោ ហោតិ ។ យំ តថាភូតស្ស រូបំ តំ រូបូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ យា តថាភូតស្ស វេទនា សា វេទនូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ យា តថាភូតស្ស សញ្ញា សា សញ្ញូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ យេ តថាភូតស្ស សង្ខារា តេ សង្ខារូបាទានក្ខន្ធេ សង្គហំ គច្ឆន្តិ ។ យំ តថាភូតស្ស វិញ្ញាណំ តំ វិញ្ញាណូបាទានក្ខន្ធេ សង្គហំ គច្ឆតិ ។ សោ ឯវំ បជានាតិ ឯវំ កិរិមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សង្គហោ សន្និបាតោ សមវាយោ ហោតិ(១) ។ វុត្តំ ខោ បនេតំ ភគវតា យោ បដិច្ចសមុប្បាទំ បស្សតិ សោ ធម្មំ បស្សតិ

១ ម. ឱ. ហោតីតិ ។



ក៏បានមកកាន់គន្លងនៃចិត្តផង តែការពិចារណាអារម្មណ៍ ដែលកើតអំពីចិត្តនិងធម្មារម្មណ៍នោះមិនមាន ចំណែកនៃវិញ្ញាណ ដែលកើតអំពីចិត្តនិងធម្មារម្មណ៍នោះ ក៏នៅមិនទាន់ប្រាកដ ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលណាបើចិត្តខាងក្នុង មិនសាបសូន្យផង ធម្មារម្មណ៍ទាំងឡាយខាងក្រៅ បានមកកាន់គន្លងនៃចិត្តផង ការពិចារណាអារម្មណ៍ដែលកើតអំពីចិត្តនិងធម្មារម្មណ៍នោះ ក៏មានផង ។ ចំណែកនៃវិញ្ញាណ ដែលកើតអំពីចិត្តនិងធម្មារម្មណ៍នោះ រមែងកើតប្រាកដឡើងបាន យ៉ាងនេះឯង ។ រូបណា ដែលកើតជាមួយនឹងមនោវិញ្ញាណ រូបនោះ សង្គ្រោះចូលក្នុងរូបូបាទានក្ខន្ធ ។ វេទនាណា ដែលកើតជាមួយនឹងមនោវិញ្ញាណ វេទនានោះ សង្គ្រោះចូល ក្នុងវេទនូបាទានក្ខន្ធ ។ សញ្ញាណា ដែលកើតជាមួយនឹងមនោវិញ្ញាណ សញ្ញានោះ សង្គ្រោះចូលក្នុងសញ្ញូបាទានក្ខន្ធ ។ សង្ខារទាំងឡាយណា ដែលកើតជាមួយនឹងមនោវិញ្ញាណ សង្ខារទាំងឡាយនោះ សង្គ្រោះចូលក្នុងសង្ខារូបាទានក្ខន្ធ ។ វិញ្ញាណណា ដែលកើតជាមួយនឹងចិត្តៈ វិញ្ញាណនោះ សង្គ្រោះចូលក្នុងវិញ្ញាណូបាទានក្ខន្ធ ។ ភិក្ខុនោះតែងដឹងច្បាស់យ៉ាងនេះថា ការសង្គ្រោះ គឺប្រជុំប្រមូលនូវឧបាទានក្ខន្ធទាំង ៥ នេះ យ៉ាងនេះឯង ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលណាឃើញបដិច្ចសមុប្បាទ បុគ្គលនោះឈ្មោះថាឃើញធម៌

យោ ធម្មំ បស្សតិ សោ បដិច្ចសមុប្បាទំ បស្សតីតិ ។
បដិច្ចសមុប្បន្នា ខោ បនិមេ យទិទំ បញ្ចុបាទានក្ខន្ធា
យោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឆន្ទោ
អាលយោ អនុនយោ អជ្ឈោសានំ សោ ទុក្ខសមុ-
ទយោ យោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ
ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ សោ ទុក្ខនិរោធោតិ ។
ឯត្តាវតាបិ ខោ អាវុសោ ភិក្ខុនោ ពហុកតំ ហោ-
តីតិ ។ ឥទមវោច អាយស្មា សារីបុត្តោ អត្តមនា តេ
ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

មហាហត្ថិបទោបមសុត្តំ អដ្ឋមំ និដ្ឋិតំ ។



បុគ្គលណា ឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញបដិច្ចសមុប្បាទ ។
ឧបាទានក្ខន្ធទាំង ៥ ណា ដែលមាននៅ ឧបាទានក្ខន្ធទាំង ៥ នេះឯង
កើតឡើងព្រម ព្រោះអាស្រ័យហេតុ សេចក្តីពេញចិត្ត សេចក្តីអាល័យ
សេចក្តីត្រេកអរ និងសេចក្តីជ្រប់ចុះណា ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ
សេចក្តីពេញចិត្តជាដើមនោះ ឈ្មោះថា ទុក្ខសមុទ័យ ការកម្ចាត់បង់នូវ
តម្រេកដោយអំណាចតណ្ហា និងការលះបង់តម្រេក ដោយអំណាចតណ្ហា
ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ការកំចាត់បង់នូវតម្រេកជាដើមនោះ ឈ្មោះ
ថាទុក្ខនិរោធ ។ ម្នាលអ្នកទាំងឡាយមានអាយុ ពាក្យប្រដៅរបស់ព្រះ
មានព្រះភាគ ឈ្មោះថា ភិក្ខុនោះធ្វើច្រើន ១ ហើយ ដោយហេតុមាន
ប្រមាណប៉ុណ្ណោះឯង ។ លុះព្រះសារីបុត្រ មានអាយុ សម្តែងនូវ
មហាហត្ថិបទោបមសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្ត
ត្រេកអរ រីករាយហើយ ចំពោះភាសិត របស់ព្រះសារីបុត្រមានអាយុ
ដោយប្រការដូច្នេះ ។

ចប់មហាហត្ថិបទោបមសូត្រ ទី ៨ ។

# នវមំ មហាសារោបមសុត្តំ

[៤៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អចិរបក្កន្តេ ទេវទត្តេ តត្រ ខោ ភគវា ទេវទត្តំ អារព្ភ ភិក្ខូ អាមន្តេសិ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ(១) ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ លាភី សក្ការសិលោកវា

១ កត្ថចិ បោត្ថកេ ជរាមរណេន សោកេហិ... ឧបាយាសេហីតិ ទិស្សតិ ។

# មហាសារោបមសូត្រ ទី ៩

[៤៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ កាលដែលទេវទត្តចៀសចេញទៅ មិនយូរប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ហៅភិក្ខុទាំងឡាយ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងសាសនានេះ មានកុលបុត្រពួកខ្លះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខប្រើតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុត នៃគំនរទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះក៏មានសេចក្តីពេញចិត្ត មានតម្រិះដ៏បរិបូណ៌ ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះថា អាត្មាអញជាអ្នកបានលាភសក្ការៈ និងសេចក្តី

ឥមេ បនញ្ញេ ភិក្ខូ អប្បញ្ញាតា អប្បេសក្ខាតិ ។ សោ តេន លាភសក្ការសិលោកេន មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ អតិក្កម្ម បបដិកំ សាខាបលាសំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ ន អញ្ញាសិ សាខាបលាសំ តថាហាយំ(១) ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ អតិក្កម្ម បបដិកំ សាខាបលាសំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ

១ ម. តថាយំ ។



សរសើរ បំពោកភិក្ខុទាំងឡាយឯទៀត ។ នេះ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះ យសស័ក្តិ ។ កុលបុត្រនោះ តែងស្រវឹង ភ្លេច ដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ លុះប្រមាទហើយ តែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស អ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ឋិតនៅ (ជាការមុខ) ក៏រំលងខ្លឹម ស្រាយ សំបក ក្រមរ ហើយកាត់យកតែមែកនិងស្លឹកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា ៖ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ មែកនិងស្លឹកទេតើ ហេតុដូច្នោះ បានជាបុរសដ៏ចម្រើននេះ ត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំ មានខ្លឹមឋិតនៅ (ជាការមុខ) ក៏រំលងខ្លឹម ស្រាយ សំបក ក្រមរ ហើយកាត់យកតែមែកនិងស្លឹកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការនេះណា

យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ លាភី សក្ការសិលោកវា ឥមេ បនញ្ញេ ភិក្ខូ អប្បញ្ញាតា អប្បេសក្ខាតិ ។ សោ តេន លាភសក្ការសិលោកេន មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។



ដែលបុរសនោះត្រូវធ្វើ ដោយខ្លឹមឈើនោះ ការនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា កុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខប៉ះពាល់ហើយ ធ្វើម្តេចហ្ន៎ ទីបំផុតនៃកងទុក្ខទាំងអស់នេះ ប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ ក៏មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯងបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះថា អាត្មាអញជាអ្នកមានលាភសក្ការៈ និងសេចក្តីសរសើរ ចំណែកភិក្ខុទាំងឡាយដទៃនេះ មិនមានគេស្គាល់ឈ្មោះ យសស័ក្តិតិច ។ កុលបុត្រនោះ រមែងស្រវឹង ភ្លេច ដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។

អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សាខាបលាសំ អគ្គហេសិ ព្រហ្មចរិយស្ស តេន ច វោសានំ អាបាទិ ។

(៨៦) ឥធ បន ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ



ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា ប្រកាន់យកនូវមែក និងស្លឹក របស់ព្រហ្មចរិយៈ ហើយដល់ នូវការធ្វេសប្រហែសសេចក្តីព្យាយាម ដោយហេតុនោះ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រខ្លះទៀត ចេញចាកផ្ទះដោយសទ្ធា ចូលទៅកាន់ផ្នួសដោយគិតថា អាត្មាអញជាអ្នកធ្លាក់ចុះក្នុងជាតិ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ ធម៌ក្តី ឬវិធីបំផុតនៃកងទុក្ខទាំងអស់នេះ នឹងប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ ក៏មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ មិនស្រវឹង មិនភ្លើត មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបំពេញនូវសីលសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសីលសម្បទានោះ ។ កុលបុត្រនោះ

តាយ សីលសម្បទាយ អត្តានុក្កំសេតិ បរំ
វម្ភេតិ អហមស្មិ សីលវា កល្យាណធម្មោ ឥមេ
បនញ្ញេ ភិក្ខូ ទុស្សីលា បាបធម្មាតិ ។ សោ តាយ
សីលសម្បទាយ មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ
បមត្តោ សមានោ ទុក្ខំ វិហរតិ ។ សេយ្យថាបិ
ភិក្ខវេ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ
ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ
អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ
បបដិកំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ
មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ
វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន
អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ
បបដិកំ ន អញ្ញាសិ សាខាបលាសំ តថាហយំ ភវំ
បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ
ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ



រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា
អាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកភិក្ខុទាំងឡាយដទៃ ៗ
នេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ ភិក្ខុនោះ រមែងស្រវឹង
វង្វេង ដល់នូវសេចក្ដីប្រមាទ ដោយសីលសម្បទានោះ លុះប្រមាទហើយ
រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស អ្នកត្រូវការដោយ
ខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំ
មានខ្លឹមឋិតនៅ (ចំពោះមុខ) ហើយ ក៏រំលងខ្លឹម ស្រាយ សំបក ហើយ
កេះយកតែស្រកែក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមាន
ចក្ខុ បានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា ៖ បុរសដ៏ចំរើន
នេះមិនស្គាល់ខ្លឹម ស្រាយ សំបក ស្រកែក មែកនិងស្លឹកទេតើ ហេតុដូច្នោះ
បានជាបុរសដ៏ចំរើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ
ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ)

អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ បប្បដិកំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេយ្យាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ



ហើយ ក៏រំលងខ្លឹម ស្រាយ សំបក ហើយកេះយកតែស្រមោក សម្គាល់ថា ខ្លឹម ហើយទៀសចេញទៅ ការងារណា ដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើនោះ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ (សេចក្តីនេះមានឧបមាយ៉ាងណា) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា កុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះដោយសទ្ធា ចូលទៅកាន់ផ្នួសដោយគិតថា អាត្មាអញ ជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុត នៃគំនរទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ មិនស្រវឹង មិនភ្លើន មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ

សីលសម្បទំ អារាធេតិ ។ សោ តាយ សីល-សម្បទាយ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ សីលវា កល្យាណធម្មោ ឥមេ បនញ្ញេ ភិក្ខូ ទុស្សីលា បាបធម្មាតិ ។ សោ តាយ សីលសម្បទាយ មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ បបដិកំ អគ្គហេសិ ព្រហ្មចរិយស្ស តេន ច វោសានំ អាបាទិ ។

(៨៧) ឥធ បន ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។



រមែងញុំាងនូវសីលសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ ដោយសីលសម្បទានោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា អាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកភិក្ខុពួកដទៃ ឯទៀត នេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ កុលបុត្រនោះ ក៏ស្រវឹងភ្លេចខ្លួន ដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា ជាអ្នកកាន់យកនូវស្រកា របស់ព្រហ្មចរិយៈ ហើយដល់នូវការបញ្ចប់ដោយសេចក្តីល្ងាយ ដោយហេតុនោះ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ កុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា និងថា អាត្មាអញ ជាអ្នកត្រូវជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើដូចម្តេច នឹងធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះឲ្យប្រាកដឡើងបាន ។ កុលបុត្រនោះ លុះបួសហើយនោះហើយ ក៏ញុំាងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។

សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សីលសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ សមាហិតោ ឯកគ្គចិត្តោ ឥមេ បនញ្ញេ ភិក្ខូ អសមាហិតា វិព្ភន្តចិត្តាតិ ។ សោ តាយ សមាធិសម្បទាយ មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។



កុលបុត្រនោះរមែងមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនបានលើកតម្កើងខ្លួនឯង មិនបានបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះទេ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះឡើយ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ កុលបុត្រនោះលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះថា អាត្មាអញជាអ្នកមានចិត្តតាំងមាំ មានចិត្តប្រកបក្នុងអារម្មណ៍តែមួយ ចំណែកភិក្ខុទាំងឡាយដទៃ ៗ នេះ មិនមានចិត្តតាំងមាំ មានចិត្តវិលវល់ ។ កុលបុត្រនោះតែងស្រវឹង វង្វេង ដល់នូវសេចក្តីប្រមាទព្រោះសមាធិសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។

សេយ្យថាបិ ភិក្ខវេ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ តចំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ ន អញ្ញាសិ សាខាបលាសំ តថាហាយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ តចំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវទុក្ខទោមនស្សុបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម



ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹម រំលងស្រាយ ហើយស្ទុះយកតែសំបកមកសម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុឃើញបុរសនោះហើយនិយាយយ៉ាងនេះថា ៖ បុរសដ៏ចម្រើននេះមិនស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ មែក ស្លឹកទេតើ ព្រោះហេតុនោះ បុរសដ៏ចម្រើននេះ អ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹមរំលងស្រាយ ហើយស្ទុះយកតែសំបកមកសម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការធ្វើកិច្ចណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើនោះ ការធ្វើនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ (សេចក្ដីនេះ ឧបមាយ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាកុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ព្រោះជា អ្នកទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើដូចម្ដេចនឹង

ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ នប្បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សីលសម្បទាយ ន មជ្ជតិ នប្បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ សមាហិតោ



ធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេច មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេច មិនដល់នូវសេចក្តីប្រមាទព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ កុលបុត្រនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃព្រោះសមាធិសម្បទានោះថា អាត្មាអញ ជាអ្នកមានចិត្តខ្ជាប់ខ្ជួន

ឯកគ្គចិត្តោ ឥមេ បនញ្ញេ ភិក្ខូ អសមាហិតា វិព្ភន្តចិត្តាតិ ។ សោ តាយ សមាធិសម្បទាយ មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ គណ្ឌំ អគ្គហេសិ ព្រហ្មចរិយស្ស តេន ច វោសានំ អាបាទិ ។

(៨៨) ឥធ បន ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ



មានចិត្តប្រព្រឹត្តទៅ ក្នុងអារម្មណ៍តែមួយ ចំណែកភិក្ខុទាំងឡាយដទៃ ៗ នេះ ជាអ្នកមានចិត្តមិនតាំងខ្ជាប់ខ្ជួន មានចិត្តរវើរវាយ ។ កុលបុត្រនោះ ក៏ស្រវឹង ភ្លេចខ្លួន ដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានកាន់យកនូវស្លឹកនៃព្រហ្មចរិយៈ ហើយដល់នូវការបញ្ចប់ដោយសេចក្តីព្យាយាម ដោយហេតុនោះ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត កុលបុត្រពួកខ្លះ ក្នុងសាសនានេះ បានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះចូលសាងផ្នួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ មិនមានសេចក្តីពេញចិត្ត

ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោ-
កេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន
លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមា-
ទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារា-
ធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ
នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីល-
សម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ
តាយ សីលសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមា-
ទំ អាបជ្ជតិ អប្បមត្តោ សមានោ សមាធិសម្បទំ អា-
រាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ
ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ
សមាធិសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។
សោ តាយ សមាធិសម្បទាយ ន មជ្ជតិ ន បមជ្ជតិ
ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ ញាណទស្ស-
នំ អារាធេតិ ។ សោ តេន ញាណទស្សនេន អត្តម-
នោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តេន ញាណ-
ទស្សនេន អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ



មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈនិងសេចក្ដីសរសើរនោះ ។
កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទះបង្អាប់អ្នកដទៃ ព្រោះលាភ-
សក្ការៈនិងសេចក្ដីសរសើរនោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេច មិន
ដល់នូវសេចក្ដីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្ដីសរសើរនោះ លុះ
មិនប្រមាទហើយ រមែងញុំាងនូវសីលសម្បទា ។ កុលបុត្រនោះមាន
សេចក្ដីពេញចិត្តដោយសីលសម្បទានោះ តែថា មិនមានតម្រិះបរិបូណ៌
ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្ទះបង្អាប់អ្នកដទៃ
ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេច មិន
ដល់នូវសេចក្ដីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ
រមែងញុំាងនូវសមាធិសម្បទា ។ កុលបុត្រនោះ មានសេចក្ដីពេញចិត្ត
ដោយសមាធិសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុល-
បុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទះបង្អាប់អ្នកដទៃ ព្រោះសមាធិ-
សម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេច មិនដល់នូវសេចក្ដី
ប្រមាទព្រោះសមាធិសម្បទានោះ លុះមិនប្រមាទហើយ រមែងញុំាងនូវ
ញាណទស្សនៈ[១] ។ កុលបុត្រនោះមានសេចក្ដីពេញចិត្ត មានតម្រិះ
បរិបូណ៌ដោយញាណទស្សនៈនោះ ។ កុលបុត្រនោះ រមែងលើកតម្កើង
ខ្លួនឯង បន្ទះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះថា អាត្មាអញ

១ បានដល់ ទិព្វចក្ខុ ។

ជានំ បស្សំ វិហរាមិ ឥមេ បនញ្ញេ ភិក្ខូ អជានំ អបស្សំ វិហរន្តីតិ ។ សោ តេន ញាណទស្សនេន មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ ផេគ្គុំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ ន អញ្ញាសិ សាខាបលាសំ តថា ហយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ ផេគ្គុំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ កុលបុត្តោ សទ្ធា



បានស្គាល់ បានឃើញ (នូវប្រណីត) ចំណែកភិក្ខុទាំងឡាយដទៃទៀត ។ នេះ មិនបានស្គាល់ មិនបានឃើញ (នូវប្រណីត) ទេ ។ កុលបុត្រនោះ កើតស្រើប វង្វេង ដល់នូវសេចក្ដីប្រមាទ ព្រោះញាណទស្សនៈនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលដើមឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) កំលងខ្លឹម ហើយកាត់យកតែស្រាយមកសំគាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះមិនស្គាល់ខ្លឹម ស្រាយ សំបក ក្រប មែកនិងស្លឹកទេ ព្រោះហេតុនោះ បានជាបុរសដ៏ចម្រើននេះ អ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលដើមឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) កំលងខ្លឹម ហើយកាត់យកតែស្រាយមកសំគាល់ថាខ្លឹម ហើយចៀសចេញទៅ ការគិតណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការគិតនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ (សេចក្ដីនេះ ឧបមាយ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចកុលបុត្រពួកខ្លះ ក្នុងសាសនា

អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សីលសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ



នេះ ព្រោះចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកធ្លាក់ក្នុងជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎នឹងធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ មិនស្រវឹង មិនភ្លើន មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងញុំាងនូវសីលសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត ដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លើន មិនដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែង

សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សមាធិសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ ញាណទស្សនំ អារាធេតិ ។ សោ តេន ញាណទស្សនេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តេន ញាណទស្សនេន អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ ជានំ បស្សំ វិហរាមិ ឥមេ បនញ្ញេ ភិក្ខូ អជានំ អបស្សំ វិហរន្តីតិ ។ សោ តេន ញាណទស្សនេន មជ្ជតិ បមជ្ជតិ បមាទំ អាបជ្ជតិ បមត្តោ សមានោ ទុក្ខំ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ផេគ្គុំ អគ្គហេសិ ព្រហ្មចរិយស្ស តេន ច វោសានំ អាបាទេតិ ។

[៥៥] ឥធ បន ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេ-



បាននូវសមាធិសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្ត ដោយសមាធិសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេច មិនដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ ដោយញាណទស្សនៈនោះ ។ កុលបុត្រនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះថា អាត្មាអញបានដឹង បានឃើញ (រូបល្អិត) ចំណែកភិក្ខុទាំងឡាយដទៃនេះ មិនបានដឹង មិនបានឃើញ (រូបល្អិត) ទេ ។ កុលបុត្រនោះ តែងស្រវឹង ភ្លេច ដល់នូវសេចក្តីប្រមាទ ព្រោះញាណទស្សនៈនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា បានកាន់យកតែស្រាយរបស់ព្រហ្មចរិយៈ ហើយដល់នូវការបញ្ចប់នូវសេចក្តីព្យាយាមដោយហេតុនោះ ។

(៥៥) ម្នាលភិក្ខុទាំងឡាយ មួយទៀត កុលបុត្រពួកខ្លះក្នុងលោកនេះ បានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល

ទុក្ខទោមនស្សុបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សីលសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ នោ ច ខោ



សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខប្រាកដហើយ ធ្វើដូចម្តេចហ្ន៎ ដំណើរធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះ នឹងប្រាកដបាន ។ កុលបុត្រនោះលុះបួសយ៉ាងនេះហើយ ក៏បានញ៉ាំងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេចខ្លួន មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះពេញចិត្តដោយសីលសម្បទានោះ តែថាមិនទាន់មានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេចខ្លួន មិនដល់នូវសេចក្តីប្រមាទព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះពេញចិត្ត ដោយសមាធិសម្បទានោះ តែថា មិនទាន់

បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សមាធិសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ ញាណទស្សនំ អារាធេតិ ។ សោ តេន ញាណទស្សនេន អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តេន ញាណទស្សនេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តេន ញាណទស្សនេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សមយវិមោក្ខំ អារាធេតិ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ សោ ភិក្ខុ តាយ សមយវិមុត្តិយា បរិហាយេថាតិ(១) ។ សេយ្យថាបិ ភិក្ខវេ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ សារំយេវ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ ជានមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ អញ្ញាសិ វតាយំ ភវំ បុរិសោ

១ ម. ឥតិសទ្ទោ ន ទិស្សតិ ។



តម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ កុលបុត្រនោះ មិនស្រវឹង មិនភ្លេចភ្លាំង មិនដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះ ពេញចិត្តដោយញាណទស្សនៈនោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លេចភ្លាំង មិនដល់នូវសេចក្តីប្រមាទ ព្រោះញាណទស្សនៈនោះ លុះមិនប្រមាទហើយ រមែងបាននូវសមយវិមោក្ខ(១) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះនឹងសាបសូន្យចាកសមយវិមុត្តិនោះ ដោយហេតុណា ហេតុនុ៎ះមិនមែនមាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) កាត់យកតែខ្លឹមមក ដឹងថាខ្លឹមពិតហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា ៖ បុរសដ៏ចម្រើននេះ

១ ប្រែថា ធម៌ដែលរួចចាកបច្ចនីកធម៌ក្នុងសម័យនីមួយៗ តាមការកំណត់វេលា បានដល់ លោកិយសមាបត្តិ ។

សារំ អញ្ញាសិ ផេគ្គុំ អញ្ញាសិ តចំ អញ្ញាសិ បបដិកំ អញ្ញាសិ សាខាបលាសំ តថាហាយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ សារញ្ញេវ ឆេត្វា អាទាយ បក្កន្តោ សារន្តិ ជានមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ អនុភវិស្សតីតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិបរិទេវេហិទុក្ខេហិទោមនស្សេហិឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។



ស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ មែកនិងស្លឹកប្រាកដ ព្រោះហេតុនោះបានជាបុរសដ៏ចំរើននេះ ត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏ចាំរើសយកតែខ្លឹមម្យ៉ាង ដឹងថាជាខ្លឹមពិត ហើយចៀសចេញទៅ ការកិច្ចណា ដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើ ការកិច្ចនោះ នឹងសម្រេចប្រយោជន៍ដល់បុរសនោះពិត (សេចក្តីនេះមានឧបមាយ៉ាងណា) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាកុលបុត្រពួកខ្លះ ក្នុងសាសនានេះ បានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា ដោយគិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើទីបំផុតនៃគំនរទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះលុះបួសយ៉ាងនេះហើយ បានញ៉ាំងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះហើយ ។ កុលបុត្រនោះមិនលើកដំកើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។

សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សីលសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សោ តាយ សមាធិសម្បទាយ ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ ញាណទស្សនំ អារាធេតិ ។ សោ តេន ញាណទស្សនេន អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តេន ញាណទស្សនេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។



កុលបុត្រនោះមិនស្រវឹង មិនភ្លើន មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះ មិនស្រវឹង មិនភ្លើន មិនដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះពេញចិត្តដោយសមាធិសម្បទានោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនភ្លើន មិនដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះពេញចិត្តដោយញាណទស្សនៈនោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះ ។

សោ តេន ញាណទស្សនេន ន មជ្ជតិ ន បមជ្ជតិ ន បមាទំ អាបជ្ជតិ អប្បមត្តោ សមានោ អសមយវិមោក្ខំ អារាធេតិ ។ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ សោ ភិក្ខុ តាយ អសមយវិមុត្តិយា បរិហាយេថាតិ ។

(៤០) ឥតិ ខោ ភិក្ខវេ នយិទំ ព្រហ្មចរិយំ លាភសក្ការសិលោកានិសំសំ ន សីលសម្បទានិសំសំ ន សមាធិសម្បទានិសំសំ ន ញាណទស្សនានិសំសំ យា ច ខោ អយំ ភិក្ខវេ អកុប្បា ចេតោវិមុត្តិ ឯតទត្ថមិទំ ភិក្ខវេ ព្រហ្មចរិយំ ឯតំ សារំ ឯតំ បរិយោសានន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាសារោបមសុត្តំ នវមំ និដ្ឋិតំ ។

---



កុលបុត្រនោះមិនស្រវឹង មិនភ្លេចស្មារតី មិនដល់នូវសេចក្តីប្រមាទ ព្រោះញាណទស្សនៈនោះ លុះមិនប្រមាទហើយ រមែងបាននូវសមយវិមោក្ខ (ធម៌ដែលរួចចាកកិលេសឥតមានកំណត់កាលវេលា បានដល់លោកុត្តរធម៌) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសាបសូន្យចាកអសមយវិមុត្តិនោះ ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ។

(៤០) ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មិនមែនមានលាភសក្ការៈនិងសេចក្តីសរសើរជាអានិសង្ស មិនមែនមានសីលសម្បទាជាអានិសង្ស មិនមែនមានសមាធិសម្បទាជាអានិសង្ស មិនមែនមានញាណទស្សនៈជាអានិសង្សប៉ុណ្ណោះទេ ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិ ការរួចចាកកិលេសនៃចិត្តគឺអរហត្តផល ជាធម្មជាតមិនកម្រើកណា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មានអរហត្តផលនុ៎ះជាប្រយោជន៍ មានអរហត្តផលនុ៎ះ ជាខ្លឹម មានអរហត្តផលនុ៎ះ ជាទីបំផុត ។ ព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត បានត្រេកអរហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាសារោបមសូត្រ ទី ៩ ។

## ទសមំ ចូឡសារោបមសុត្តំ

[៨១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ បិង្គលកោច្ឆោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បិង្គលកោច្ឆោ ព្រាហ្មណោ ភគវន្តំ ឯតទវោច យេមេ ភោ គោតម សមណព្រាហ្មណា សង្ឃិនោ គណិនោ គណាចរិយា ញាតា យសស្សិនោ តិត្ថករា សាធុសម្មតា ពហុជនស្ស សេយ្យថីទំ បូរណោ កស្សបោ មក្ខលិ គោសាលោ អជិតោ កេសកម្ពលោ(១) បកុធោ កច្ចាយនោ សញ្ជយោ វេលដ្ឋបុត្តោ(២) និគណ្ឋោ នាដបុត្តោ សព្វេតេ សកាយ បដិញ្ញាយ អព្ភញ្ញិំសុ(៣) សព្វេវ ន អព្ភញ្ញិំសុ ឧទាហុ ឯកច្ចេ អព្ភញ្ញិំសុ

១ ម. កេសកម្ពលី ។ ២ ម. ឧ. វេលដ្ឋបុត្តោ ។ ៣ ម. ឧ. អព្ភញ្ញំសុ ។

## ចូឡសារោបមសូត្រ ទី ១០

(៨១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រាហ្មណ៍ឈ្មោះបិង្គលកោច្ឆៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ ហើយបញ្ចប់ពាក្យដែលគួរឲ្យកើតសេចក្តីរីករាយ គួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ឈ្មោះបិង្គលកោច្ឆៈអង្គុយក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន សមណព្រាហ្មណ៍ទាំងឡាយណា មានពួក មានគណៈ ជាអាចារ្យនៃគណៈ មានកេរ្តិ៍ឈ្មោះយសស័ក្តិ ធ្វើលទ្ធិជាកំពង់ ដែលច្រើននាក់បានសន្មតថាជាមនុស្សត្រឹមត្រូវ គឺបូរណកស្សប ១ មក្ខលិគោសាល ១ អជិតកេសកម្ពល ១ បកុធកច្ចាយនៈ ១ សញ្ជយវេលដ្ឋបុត្ត ១ និគន្ថនាដបុត្ត ១ សមណព្រាហ្មណ៍ទាំងអស់នោះបានត្រាស់ដឹងដូចពាក្យប្តេជ្ញារបស់ខ្លួន ឬមិនបានត្រាស់ដឹងទាំងអស់គ្នា ឬថាត្រាស់ដឹងខ្លះ

ឯកាហេ ន អគ្គិញ្ញស្សតិ ។ អស់ ព្រាហ្មណ តិដ្ឋតេត់

សព្វេ តេ សមណា បដិញ្ញាយ អគ្គិញ្ញស្ស សព្វេ

ន អគ្គិញ្ញស្ស ឧទាហុ ឯកច្ចេ អគ្គិញ្ញស្ស ឯកច្ចេ

ន អគ្គិញ្ញស្សតិ ឆម្មំ តេ[១] ព្រាហ្មណ តេសស្សបូម៌

ត់ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាម៌-

តិ ។ ឯវំ ភោតិ ខោ ពិន្ទុលភោជោ ព្រាហ្មណោ

ភគវតោ បច្ចស្សោសិ ។

(៨២) ភគវា ឯតទវោច សេយ្យថាបិ ព្រាហ្មណ

បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរ-

មានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ

សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ អតិក្កម្ម

បបដិកំ សាខាបលាសំ ឆេត្វា អាទាយ បក្កមេយ្យ

សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា

ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ

១ ម. អគ្គញ្ញស្ស ឲ្យត្ថេ ។



មិនបានត្រាស់ដឹងខ្លះ ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ កុំនិយាយ

ឡើយ ពាក្យថា សមណព្រាហ្មណ៍ទាំងអស់នោះបានត្រាស់ដឹង ដូច

ពាក្យប្ដេជ្ញារបស់ខ្លួន ឬមិនបានត្រាស់ដឹងទាំងអស់គ្នា ឬថាត្រាស់ដឹង

ខ្លះ មិនបានត្រាស់ដឹងខ្លះ ដូច្នេះនេះឡើយ តថាគតសំដែង ម្នាលព្រាហ្មណ៍

តថាគតនឹងសំដែងធម៌ដល់អ្នកវិញ ចូរអ្នកប្រុងស្ដាប់ធម៌នោះ ចូរធ្វើទុក

ក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ ពិន្ទុលភោជព្រាហ្មណ៍ទទួលព្រះ

ពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា- ព្រះសមណៈដ៏ចម្រើន ។

[៨២] ព្រះមានព្រះភាគបានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាល

ព្រាហ្មណ៍ ប្រៀបដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ

ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ)

រំលងខ្លឹម ស្រាយ សំបក ក្រមរ ហើយកាត់យកមែកនិងស្លឹកមក

សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុ បានឃើញ

បុរសនោះហើយនិយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម

ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ ន អញ្ញាសិ សាខាបលាសំ តថា ហាយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ អតិក្កម្ម បបដិកំ សាខាបលាសំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ សេយ្យថាបិ វា បន ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ បបដិកំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ





ស្រាយ សំបក ក្រមរ មែកនិងស្លឹកទេ ហេតុនោះបានជាបុរសដ៏ចំរើននេះជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងនូវខ្លឹម ស្រាយ សំបក ក្រមរ ហើយកាត់យកតែមែកនិងស្លឹកមក សំគាល់ថាខ្លឹម ហើយចៀសចេញទៅ កាកិច្ចណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ កាកិច្ចនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងនូវខ្លឹម ស្រាយ សំបក ហើយកេះយកតែក្រមរមក សំគាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុ បានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា បុរសដ៏ចំរើននេះមិនស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ

ន អញ្ញាសិ សាខាបលាសំ តថាហយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ បបដិកំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ សេយ្យថាបិ វា បន ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ តចំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ ន អញ្ញាសិ សាខាបលាសំ តថាហយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ



មែកនិងស្លឹកទេតើ ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹម ស្រាយ សំបក ហើយកាត់យកតែក្រមរមក សម្គាល់ថា ខ្លឹម ហើយចៀសចេញទៅ ការណ៍ណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការណ៍នោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ មួយទៀតដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹម ស្រាយ ហើយកាត់យកតែសំបកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ៖ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ មែកនិងស្លឹកទេតើ ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ

សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ តចំ ឆេត្វា អាទាយ បក្កាមេយ្យ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតិ។ សេយ្យថាបិ ភ បេ ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ ផេគ្គុំ ឆេត្វា អាទាយ បក្កាមេយ្យ សារន្តិ មញ្ញមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ ន វតាយំ ភវំ បុរិសោ អញ្ញាសិ សារំ ន អញ្ញាសិ ផេគ្គុំ ន អញ្ញាសិ តចំ ន អញ្ញាសិ បបដិកំ ន អញ្ញាសិ សាខាបលាសំ តថាហាយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ ផេគ្គុំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ សេយ្យថាបិ ភ បេ ព្រាហ្មណ បុរិសោ





(ចំពោះមុខ) គឺលះនូវខ្លឹម ស្រាយ ហើយស្មានយកតែសំបកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ គឺនឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ពុំនោះសោត ដូចបុរសត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) គឺលះនូវខ្លឹម ហើយកាប់យកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ៗ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ ស្លឹកនិងមែកឈើទេតើ ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) គឺលះខ្លឹម ហើយកាប់យកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ពុំនោះសោត ដូចបុរស

សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ សារញ្ញេវ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ ជានមានោ ។ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ អញ្ញាសិ វតាយំ ភវំ បុរិសោ សារំ អញ្ញាសិ ផេគ្គុំ អញ្ញាសិ តចំ អញ្ញាសិ បបដិកំ អញ្ញាសិ សាខាបលាសំ តថាហយំ ភវំ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ សារញ្ញេវ ឆេត្វា អាទាយ បក្កន្តោ សារន្តិ ជានមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ អនុភវិស្សតីតិ ។

(៤៣) ឯវមេវ ខោ ព្រាហ្មណ ឥធេកច្ចោ បុគ្គលោ[១] សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ

១. ឱ. ម. បុគ្គលោ ។





អ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលនោះដើមឈើធំមានខ្លឹម ឋិតនៅ (ដុះតាំងនៅ) ក៏កាប់យកតែខ្លឹមមក ស្គាល់ថាខ្លឹមពិតហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះស្គាល់ខ្លឹម ស្រាយ សំបកក្រៅ មែកនិងស្លឹកមែន ព្រោះថាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលដើមឈើធំមានខ្លឹមឋិតនៅ (ដុះតាំងនៅ) គឺកាប់យកតែខ្លឹមមក ស្គាល់ច្បាស់ថាខ្លឹម ហើយចៀសចេញទៅ កិច្ចណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ កិច្ចនោះនឹងសម្រេចប្រយោជន៍ដល់បុរសនោះ ។

(៤៣) ម្នាលព្រាហ្មណ៍ សេចក្តីដែលពោលមកហើយនេះ ក៏ដូចគ្នានឹងបុគ្គលពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា ដោយគិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ

ទុក្ខាបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខ-ក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិ-និព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ លាភី សក្ការសិលោកវា ឥមេ បនញ្ញេ ភិក្ខូ អប្បញ្ញាតា អប្បេសក្ខាតិ ។ លាភសក្ការ-សិលោកេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយា-យ ន ឆន្ទំ ជនេតិ ន វាយមតិ ឱលីនវុត្តិកោ ច ហោតិ សាថលិកោ[១] ។ សេយ្យថាបិ សោ ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេ-សនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ អតិក្កម្ម បបដិកំ សាខាបលាសំ ឆេត្វា អាទាយ

១ ឱ. ម. សាថិលិកោ ។



មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់ នេះឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរ-សើរនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះថា អាត្មាអញជាអ្នកមានលាភសក្ការៈនិងសេចក្តីសរសើរ ចំណែកភិក្ខុទាំងឡាយដទៃ ៗ នេះ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះយសសក្តិ ។ ធម៌ទាំងឡាយដទៃណា ដែលជាធម៌ដ៏ប្រសើរលើសលប់និងថ្លៃថ្លា ជាងលាភសក្ការៈនិងសេចក្តីសរសើរ កុលបុត្រនោះមិនបានញុំាងឆន្ទៈឲ្យកើតឡើង មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹម ស្រាយ សំបក ក្រមរ ហើយកាត់យកតែមែកនិងស្លឹកយក

បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ តថូបមាហំ ព្រាហ្មណ ឥមំ បុគ្គលំ វទាមិ ។

[៩៤] ឥធ បន ព្រាហ្មណ ឯកច្ចោ បុគ្គលោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ លាភសក្ការសិលោកេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ



សម្គាល់ថាខ្លឹម ហើយយកចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ គឺនឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

(៩៤) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះចូលកាន់ផ្នួស ដោយសទ្ធា ដោយគិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា ជាអ្នកមានទុក្ខគ្របសង្កត់ហើយ មានទុក្ខនៅខាងមុខ ធ្វើដូចម្តេច នឹងធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ បុគ្គលនោះលុះបួសយ៉ាងនេះហើយ រមែងញុំាងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ បុគ្គលនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់និងថ្លៃថ្លាជាងលាភសក្ការៈនិងសេចក្តីសរសើរ បុគ្គលនោះរមែងញុំាងឆន្ទៈឲ្យកើតឡើង រមែងព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានសេចក្តីប្រព្រឹត្តមិនរួញរា

អសាថិលិកោ ។ សោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ សីលវា កល្យាណធម្មោ ឥមេ បនញ្ញេ ភិក្ខូ ទុស្សីលា បាបធម្មាតិ ។ សីលសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ន ឆន្ទំ ជនេតិ ន វាយមតិ ឱលីនវុត្តិកោ ច ហោតិ សាថិលិកោ ។ សេយ្យថាបិ សោ ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ អតិក្កម្ម តចំ បបដិកំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ តថូបមាហំ ព្រាហ្មណ ឥមំ បុគ្គលំ វទាមិ ។



ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបំពេញនូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសីលសម្បទានោះ ។ បុគ្គលនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា គឺអាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកភិក្ខុពួកដទៃក្រៅពីនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុបនិងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹម ស្រាយ សំបក ហើយគេយកតែក្រមរមក សំគាល់ជាខ្លឹម ហើយចៀរចេញទៅ ការកិច្ចណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការកិច្ចនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគត ពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

[៤៩] ឥធ បន ព្រាហ្មណ ឯកច្ចោ ។បេ។ អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ លាភសក្ការសិលោកេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ សោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សីលសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ



(៤៩) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងសាសនានេះ ។បេ។ គប្បីធ្វើនូវទីបំផុតនៃទុក្ខប្រាកដបាន ។ បុគ្គលនោះលុះបួសរួចយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ បុគ្គលនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះឡើយ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់និងថ្លៃថ្លា ជាងលាភសក្ការៈនិងសេចក្តីសរសើរ បុគ្គលនោះតែងញុំាងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះតែងបំពេញនូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះតែងញុំាងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា

អសាថិលិកោ ។ សោ សមាធិសម្បទំ អាគមេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ សមាហិតោ ឯកគ្គចិត្តោ ឥមេ បនញ្ញេ ភិក្ខូ អសមាហិតា វិព្ភន្តចិត្តាតិ ។ សមាធិសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ន ឆន្ទំ ជនេតិ ន វាយមតិ ឱលីនវុត្តិកោ ច ហោតិ សាថិលិកោ ។ សេយ្យថាបិ សោ ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ អតិក្កម្ម ផេគ្គុំ តចំ ឆេត្វា អាទាយ បក្កន្តោ សារន្តិ មញ្ញមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ តថូបមាហំ ព្រាហ្មណ ឥមំ បុគ្គលំ វទាមិ ។



ប្រព្រឹត្តមិនធូរថយទេ ។ បុគ្គលនោះ រមែងបាននូវសមាធិសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ បុគ្គលនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះថា អាត្មាអញ ជាអ្នកមានចិត្តតាំងខ្ជាប់ខ្ជួន មានចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ ឯភិក្ខុទាំងឡាយដទៃ ៗ នេះ មិនមានចិត្តតាំងខ្ជាប់ខ្ជួន មានចិត្តរវេរវាយ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ជាងសមាធិសម្បទា បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ទាំងនោះទេ ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយទេ ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលឃើញឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) គឺរំលងខ្លឹម ស្រាយ ហើយស្ទុះយកតែសំបកឈើ សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះនឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

(៤២) ឥធ បន ព្រាហ្មណ ឯកច្ចោ បុគ្គលោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន ។ បេ ។ អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។ សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ លាភសក្ការសិលោកេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថលិកោ ។ សោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ



(៤២) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈគ្របសង្កត់ហើយ ។ បេ ។ ធ្វើទីបំផុតនៃទុក្ខប្រាកដបាន ។ បុគ្គលនោះលុះបួសហើយយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើតឡើង ។ បុគ្គលនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈនិងសេចក្តីសរសើរនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏ប្រសើរលើសលុបនិងថ្លៃថ្លាជាងលាភសក្ការៈនិងសេចក្តីសរសើរ បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងសម្រេចនូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត ដោយសីលសម្បទានោះ តែមិនមែន

បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សីលសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ សោ សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សមាធិសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ សោ ញាណទស្សនំ អារាធេតិ ។ សោ តេន ញាណទស្សនេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ សោ តេន ញាណទស្សនេន អត្តានុក្កំសេតិ បរំ វម្ភេតិ អហមស្មិ ជានំ បស្សំ វិហរាមិ ឥមេ បនញ្ញេ ភិក្ខូ អជានំ



តម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ផង ដ៏ឧត្តមផង ជាងសីលសម្បទា បុគ្គលនោះរមែងញុំាងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបានសម្រេចសមាធិសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត ដោយសមាធិសម្បទានោះ តែមិនទាន តម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ផង ដ៏ឧត្តមផង ជាងសមាធិសម្បទា បុគ្គលនោះរមែងញុំាងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបានសម្រេចញាណទស្សនៈ ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយញាណទស្សនៈនោះ ។ បុគ្គលនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះថា អាត្មាអញជាអ្នកដឹងផង បានឃើញ (ប្រាកដ) ចំណែកភិក្ខុទាំងឡាយដទៃ ៗ នេះ ជាអ្នកមិនដឹង មិន

អប្បេសក្ខា វិហរន្តីតិ ។ ញាណទស្សនេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ ន វាយមតិ ឱលីនវុត្តិកោ ច ហោតិ សាថិលិកោ ។ សេយ្យថាបិ សោ ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ សារំ ផេគ្គុំ ឆេត្វា អាទាយ បក្កមេយ្យ សារន្តិ មញ្ញមានោ យថាស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ នានុភវិស្សតីតិ ។ តថូបមាហំ ព្រាហ្មណ ឥមំ បុគ្គលំ វទាមិ ។

(៤៧) ឥធ បន ព្រាហ្មណ ឯកច្ចោ បុគ្គលោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវ នាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ លាភសក្ការសិលោកំ អភិនិព្វត្តេតិ ។



ឃើញ (ប្រាកដ) ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ផង ថ្លៃថ្លាជាងញាណទស្សនៈ បុគ្គលនោះមិនញ៉ាំងឆន្ទៈឲ្យកើត មិនព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹមឋិតនៅ (ដំណោះមុខ) គឺរំលងខ្លឹម ហើយកាប់យកស្រាយមក សំគាល់ថាខ្លឹម ហើយទៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះក៏មិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះ ថាដូចជាបុរសនោះដែរ ។

(៤៧) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ បុគ្គលនោះលុះបួសរួចហើយ ក៏ញ៉ាំងលាភសក្ការៈនិងសេចក្តីសរសើរឲ្យកើត ។

សោ តេន លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ លាភសក្ការសិលោកេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ សោ សីលសម្បទំ អារាធេតិ ។ សោ តាយ សីលសម្បទាយ អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សីលសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សីលសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ សោ សមាធិសម្បទំ អារាធេតិ ។ សោ តាយ សមាធិសម្បទាយ អត្តមនោ ហោតិ



បុគ្គលនោះមិនមានសេចក្ដីពេញចិត្ត មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈនិងសេចក្ដីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ដោយលាភសក្ការៈនិងសេចក្ដីសរសើរនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏ប្រសើរលើសលប់និងថ្លៃថ្លា ជាងលាភសក្ការៈនិងសេចក្ដីសរសើរ បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើតឡើង ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្ដីពេញចិត្ត ដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏ប្រសើរលប់ជាងសីលសម្បទានោះ បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសមាធិសម្បទា ។ បុគ្គលនោះមានសេចក្ដីពេញចិត្តដោយសមាធិសម្បទានោះ

នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តាយ សមាធិសម្បទាយ ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ សមាធិសម្បទាយ ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ សោ ញាណទស្សនំ អារាធេតិ ។ សោ តេន ញាណទស្សនេន អត្តមនោ ហោតិ នោ ច ខោ បរិបុណ្ណសង្កប្បោ ។ សោ តេន ញាណទស្សនេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ ញាណទស្សនេន ច យេ អញ្ញេ ធម្មា ឧត្តរិតរា ច បណីតតរា ច តេសំ ធម្មានំ សច្ឆិកិរិយាយ ឆន្ទំ ជនេតិ វាយមតិ អនោលីនវុត្តិកោ ច ហោតិ អសាថិលិកោ ។ កតមេ ច ព្រាហ្មណ ធម្មា ញាណទស្សនេន ឧត្តរិតរា ច បណីតតរា ។ ឥធ ព្រាហ្មណ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ



តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់និងថ្លៃថ្លា ជាងសមាធិសម្បទា បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវញាណទស្សនៈ ។ បុគ្គលនោះមានសេចក្តីពេញចិត្តដោយញាណទស្សនៈនោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់និងថ្លៃថ្លា ជាងញាណទស្សនៈ បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយដូចម្តេច ដែលជាធម៌ដ៏លើសលប់និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយ

សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយម្បិ ខោ ព្រាហ្មណ ធម្មោ ញាណទស្សនេន ឧត្តរិតរោ ច បណីតតរោ ច ។ បុន ចបរំ ព្រាហ្មណ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយម្បិ ខោ ព្រាហ្មណ ធម្មោ ញាណទស្សនេន ឧត្តរិតរោ ច បណីតតរោ ច ។ បុន ចបរំ ព្រាហ្មណ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា



បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ។ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កៈវិចារៈរួចហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ ។ បេ ។ តតិយជ្ឈាន ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ។ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់និងថ្លៃថ្លា ជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយទៀត ភិក្ខុ ព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា(១) ព្រោះអស់ទៅនៃបដិឃសញ្ញា(២) ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា(៣) ដោយ

---

១ រូបសញ្ញា សេចក្តីសម្គាល់ក្នុងរូប សំដៅក្នុងទីនេះសំដៅយករូបាវចរជ្ឈាន១៥ អារម្មណ៍របស់រូបាវចរជ្ឈានទាំងនោះផង ។ ២ បដិឃសញ្ញា សេចក្តីសម្គាល់កើតឡើងដោយការប៉ះពាល់នៃចក្ខុប៉ះពាល់នឹងរូប ត្រចៀកប៉ះពាល់នឹងសំឡេងជាដើម ។ ៣ នានត្តសញ្ញា សញ្ញាផ្សេងៗ គ្នា ឯសញ្ញាដែលផ្សេងៗគ្នានោះមាន ៤៤ គឺ កាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១ ។

អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧប-
សម្បជ្ជ វិហរតិ ។ អយម្បិ ខោ ព្រាហ្មណ ធម្មោ
ញាណទស្សនេន ឧត្តរិតរោ ច បណីតតរោ ច ។
បុន ចបរំ ព្រាហ្មណ ភិក្ខុ សព្វសោ អាកាសា-
នញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញា-
ណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ
វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អា-
កិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ
អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញា-
យតនំ ឧបសម្បជ្ជ វិហរតិ ។ អយម្បិ ខោ ព្រាហ្មណ
ធម្មោ ញាណទស្សនេន ឧត្តរិតរោ ច បណីតតរោ
ច ។ បុន ចបរំ ព្រាហ្មណ ភិក្ខុ សព្វសោ នេវសញ្ញា-
នាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ
ឧបសម្បជ្ជ វិហរតិ ។ បញ្ញាយ ចស្ស ទិស្វា អាសវា
បរិក្ខីណា ហោន្តិ ។ អយម្បិ ខោ ព្រាហ្មណ ធម្មោ
ញាណទស្សនេន ឧត្តរិតរោ ច បណីតតរោ ច ។



ប្រការទាំងពួង ចូលដល់អាកាសានញ្ចាយតនជ្ឈាន ដោយការពិចារ-
ណាថា អាកាសមិនមានទីបំផុតដូច្នេះ ។ ម្នាលព្រាហ្មណ៍ ធម៌នេះ
ឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្លា ជាងញាណទស្សនៈ ។ ម្នាល
ព្រាហ្មណ៍ មួយវិញទៀត ភិក្ខុ ព្រោះប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយត-
នជ្ឈានដោយប្រការទាំងពួង ចូលដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយ
ការពិចារណាថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។ បេ ។ ព្រោះប្រ-
ព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ចូលដល់នូវ
អាកិញ្ចញ្ញាយតនជ្ឈាន ដោយការពិចារណាថា អ្វីបន្តិចតួចមិនមាន
ដូច្នេះ ។ បេ ។ ព្រោះប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយ
ប្រការទាំងពួង ចូលដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាល
ព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្លា ជាងញាណ-
ទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយវិញទៀត ភិក្ខុ ព្រោះប្រព្រឹត្តកន្លង
នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ចូលដល់នូវ
សញ្ញាវេទយិតនិរោធ(១) ។ អាសវៈទាំងឡាយរបស់ភិក្ខុនោះរមែងអស់ទៅ
មិនមានសេសសល់ ព្រោះបានឃើញច្បាស់ដោយបញ្ញា ។ ម្នាលព្រាហ្មណ៍
ធម៌នេះឯង ជាធម៌ដ៏លើសលប់និងថ្លៃថ្លាជាងញាណទស្សនៈ ។

១ សេចក្តីរលត់នូវសញ្ញានិងវេទនា ។

ឥមេ ខោ ព្រាហ្មណ ធម្មា ញាណទស្សនេន ឧត្តរិតរា ច បណីតតរា ច ។ សេយ្យថាបិ សោ ព្រាហ្មណ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ សារញ្ញេវ អាទាយ បក្កមេយ្យ សារន្តិ ជានមានោ យញ្ចស្ស សារេន សារករណីយំ តញ្ចស្ស អត្ថំ អនុភវិស្សតីតិ ។ តថូបមាហំ ព្រាហ្មណ ឥមំ បុគ្គលំ វទាមិ ។

[៥៥] ឥតិ ខោ ព្រាហ្មណ នយិទំ ព្រហ្មចរិយំ លាភសក្ការសិលោកានិសំសំ ន សីលសម្បទានិសំសំ ន សមាធិសម្បទានិសំសំ ន ញាណទស្សនានិសំសំ យា ច ខោ អយំ ព្រាហ្មណ អកុប្បា ចេតោវិមុត្តិ ឯតទត្ថមិទំ ព្រាហ្មណ ព្រហ្មចរិយំ ឯតំ សារំ ឯតំ បរិយោសានន្តិ ។ ឯវំ វុត្តេ បិង្គលកោច្ឆោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម



ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយនេះឯង ជាធម៌ដ៏លើសលប់ផង ដ៏ថ្លៃថ្លាផង នៃញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការ ដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹមឋិតនៅ (ដុះការមុខ) ក៏ចាំងយកតែខ្លឹមមក ដឹងច្បាស់ថាខ្លឹម ហើយចៀសចេញទៅ ការធ្វើណា ដែលបុរសនោះត្រូវការធ្វើដោយខ្លឹមឈើ ការធ្វើនោះក៏នឹងសម្រេចប្រយោជន៍ដល់បុរសនោះ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះ ថាដូចជាបុរសនោះដែរ ។

[៥៥] ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះមិនមែនមានត្រឹមតែលាភសក្ការៈនិងសេចក្តីសរសើរ ជាអានិសង្ស មិនមែនមានត្រឹមតែសីលសម្បទាជាអានិសង្ស មិនមែនមានត្រឹមតែសមាធិសម្បទាជាអានិសង្ស មិនមែនមានត្រឹមតែញាណទស្សនៈជាអានិសង្ស ដោយប្រការដូច្នេះឯង ម្នាលព្រាហ្មណ៍ ចេតោវិមុត្តិ ការរួចចាកកិលេសនៃចិត្តដែលជាអកុប្បផល ជាគុណមិនកម្រើកណា ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះ មានអកុប្បផលនុ៎ះជាប្រយោជន៍ មានអកុប្បផលនុ៎ះជាខ្លឹម មានអកុប្បផលនុ៎ះជាទីបំផុត ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ។ បិង្គលកោច្ឆព្រាហ្មណ៍ ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតម

អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ

គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ចូឡកោកនទសុត្តំ ទសមំ និដ្ឋិតំ ។

ថេរវគ្គោ តតិយោ ។

តស្សុទ្ទានំ

[illegible]

[illegible]

[illegible]

[illegible] ។

---

ធ្វើចប់នៅថ្ងៃអាទិត្យ ៣ រោច ខែ ភទ្របទ

ឆ្នាំ ច ព.ស ២៥៥០ ត្រូវនឹងថ្ងៃទី ១០ ខែតុលា

ឆ្នាំ ២០០៦

ហាយ ចំរើន

អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ចូឡសារោបមសុត្តំ ទសមំ និដ្ឋិតំ ។

ឱបម្មវគ្គោ តតិយោ ។

តស្សុទ្ទានំ

មោលិយផគ្គុនារិដ្ឋនាមោ
អន្ធវនេ កថិបុណ្ណនិវាបោ
ភាសិកណេរុមហាគជ្ជនាមោ
សារោបមុនបច្ឆិមកោ ច ។

---



ដ៏ចម្រើន ពីរោះណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះ តរៀងទៅ ។

ចប់ ចូឡសារោបមសូត្រ ទី ១០ ។

ចប់ ឱបម្មវគ្គទី ៣ ។

## បញ្ជីរឿងនៃឱបម្មវគ្គនោះគឺប៉ុណ្ណេះ

រឿងមោលិយផគ្គុនភិក្ខុ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ ក្នុងកកចូបមសូត្រ ១ រឿងអរិដ្ឋភិក្ខុប្រកាន់មិច្ឆាទិដ្ឋិ ក្នុងអលគទ្ទូបមសូត្រ ១ រឿងកុមារកស្សបភិក្ខុនៅក្នុងអន្ធវន ក្នុងវម្មិកសូត្រ ១ រឿងបុណ្ណភិក្ខុ ក្នុងរថវិនីតសូត្រ ១ រឿងបុគ្គលដាំដំណាំ ក្នុងនិវាបសូត្រ ១ រឿងសត្វម្រឹគដេកសន្ធឹកលើគំនរអន្ទាក់ ក្នុងបាសរាសិសូត្រ ១ រឿងប្រៀបមេដំរីឈ្មោះករេណុ (មានភ្លុកក្បៀ) ក្នុងចូឡហត្ថិបទោបមសូត្រ ១ រឿងស្នាមជើងដំរី ក្នុងមហាហត្ថិបទោបមសូត្រ ១ រឿងធម៌ប្រសើរប្រៀបដូចខ្លឹមឈើ ក្នុងមហាសារោបមសូត្រ ១ រឿងបិង្គលកោច្ឆព្រាហ្មណ៍ ក្នុងចូឡសារោបមសូត្រ ១ ។

# សុត្តន្តបិដកេ

## មជ្ឈិមនិកាយស្ស មូលបណ្ណាសកំ

## ទុតិយោ ភាគោ

---

## ឱបម្មវគ្គោ

---

### បឋមំ កកចូបមសុត្តំ


| មាតិកា | អង្កេ |
| --- | --- |
| ឱបម្មវគ្គស្ស កកចូបមសុត្តេ ភិក្ខុនីសំសដ្ឋតា | ៣ |
| ឯកាសនភោជនតា | ៧ |
| តុត្តបតោទេ | ៩ |
| បញ្ច វចនបថា | ១៥ |
| អាកាសេ រូបលេខូបមា | ១៩ |
| ពិឡារភស្តូបមា | ២១ |
| កកចូបមោវាទមនសិការោ | ២៥ |


### ទុតិយំ អលគទ្ទូបមសុត្តំ


| | |
| --- | --- |
| ឱបម្មវគ្គស្ស អលគទ្ទូបមសុត្តេ អរិដ្ឋភិក្ខុវត្ថុ | ២៧ |
| អរិដ្ឋទិដ្ឋិភេទនំ | ៣១ |


# សុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសកៈ

## ទុតិយភាគ

---

## ឱបម្មវគ្គ

---

### កកចូបមសូត្រ ទី ១


| មាតិកា | លេខទំព័រ |
| --- | --- |
| ឱបម្មវគ្គ កកចូបមសូត្រ ការនៅច្រឡូកច្រឡំនឹងភិក្ខុនី | ៣ |
| ការបរិភោគភោជនតែក្នុងអាសនៈមួយ | ៧ |
| រឿងធ្លាប់មានមកហើយ | ៩ |
| គន្លងនៃពាក្យ ៥ ប្រការ | ១៥ |
| សេចក្ដីប្រៀបដោយការគូររូបក្នុងអាកាស | ១៩ |
| សេចក្ដីប្រៀបដោយសំពៀតស្បែកឆ្មា | ២១ |
| ការធ្វើទុកក្នុងចិត្តចំពោះឱវាទដែលប្រៀបដោយរណារ | ២៥ |


### អលគទ្ទូបមសូត្រ ទី ២


| | |
| --- | --- |
| ឱបម្មវគ្គ អលគទ្ទូបមសូត្រ រឿងអរិដ្ឋភិក្ខុ | ២៧ |
| ការក្រាបបង្គំទូលអំពីទិដ្ឋិរបស់អរិដ្ឋភិក្ខុ | ៣១ |

មាតិកា បិដ្ឋេ

ទុតិយវគ្គស្ស អលគទ្ទូបមសុត្តេ អរិដ្ឋភិក្ខុ កាមន្ថាបនំ . . . . . ៣៣

អរិដ្ឋភិក្ខុគរហា . . . . . . . . . . . ៣៥

ទុគ្គហិតា ធម្មា . . . . . . . . . . . ៣៩

សុគ្គហិតា ធម្មា . . . . . . . . . . . ៤៣

កុល្លូបមា ធម្មទេសនា . . . . . . . . ៤៥

ឆ ទិដ្ឋិដ្ឋានានិ . . . . . . . . . . . ៤៧

បរិតស្សនាកថា . . . . . . . . . . . ៥១

អត្តត្តនិយាភាវទិដ្ឋិនិស្សយំ . . . . . . . . ៥៥

ភិក្ខុនំ បដិបុច្ឆា . . . . . . . . . . . ៥៧

ឧក្ខិត្តបលិឃោតិអាទិកោ . . . . . . . . ៥៩

ចតុស្សច្ចប្បញ្ញត្តិ . . . . . . . . . . . ៦១

បដិបត្តិផលំ . . . . . . . . . . . ៦៧


## តតិយំ វម្មិកសុត្តំ


ទុតិយវគ្គស្ស វម្មិកសុត្តេ បណ្ណរសបញ្ហា . . . . . . . . ៧៣

បណ្ណរសបញ្ហាព្យាករណំ . . . . . . . . ៧៧





មាតិកា លេខទំព័រ

ទុតិយវគ្គ អលគទ្ទូបមសូត្រ ការស្រង់ឲ្យហៅអរិដ្ឋភិក្ខុ . . . . . ៣៣

ការស្រង់តិះដៀលអរិដ្ឋភិក្ខុ . . . . . . . . . . ៣៥

ធម៌ទាំងឡាយដែលមោឃបុរសរៀនមិនល្អ . . . . ៣៩

ធម៌ទាំងឡាយដែលកុលបុត្ររៀនល្អ . . . . . . ៤៣

ធម្មទេសនាមានឧបមាដោយក្បូន . . . . . . . ៤៥

ហេតុជាទីតាំងនៃទិដ្ឋិមាន ៦ យ៉ាង . . . . . . . ៤៧

ពោលអំពីសេចក្តីតក់ស្លុត . . . . . . . . . . ៥១

អត្តត្តនិយាភាវទិដ្ឋិនិស្ស័យ . . . . . . . . . ៥៥

ការស្រង់សាកសួរចំពោះពួកភិក្ខុ . . . . . . . . ៥៧

ភិក្ខុដែលឈ្មោះថាមានសន្ទះទ្វារកន់លើកឡើង

ហើយជាដើម . . . . . . . . . . . . . . ៥៩

បញ្ញត្តិសច្ចៈទាំង ៤ . . . . . . . . . . . . ៦១

ផលនៃសេចក្តីប្រតិបត្តិ . . . . . . . . . . . ៦៧


## វម្មិកសូត្រ ទី ៣


ទុតិយវគ្គ វម្មិកសូត្រ ប្រស្នា ១៥ យ៉ាង . . . . . . . . . ៧៣

ការស្រង់ព្យាករណ៍ប្រស្នា ១៥ យ៉ាង . . . . . . ៧៧

# ចតុត្ថំ រថវិនីតសុត្តំ


មាតិកា . . . អង្កា

ឧបម្ពត្តស្ស រថវិនីតសុត្តេ សន្តុដ្ឋិតាទិកថា . . . . . . . . ៨១

សារីបុត្តស្ស បរិកិត្តនំ . . . . . . . . . . . . ៨៣

បុណ្ណស្ស បសំសា . . . . . . . . . . . ៨៥

វុសិតព្រហ្មចរិយបញ្ហា . . . . . . . . . . ៨៧

សត្ត វិសុទ្ធិយោ . . . . . . . . . . . ៩១

សត្ត រថវិនីតោបមា . . . . . . . . . . . ៩៣

អញ្ញមញ្ញំសម្មោទនកថា . . . . . . . . . . ៩៧


# បញ្ចមំ និវាបសុត្តំ


ឧបម្ពត្តស្ស និវាបសុត្តេ បឋមទុតិយមិគជាតូបមា . . . . . ១០១

តតិយមិគជាតូបមា . . . . . . . . . . . . ១០៣

ចតុត្ថមិគជាតូបមា . . . . . . . . . . . ១០៧

បឋមសមណព្រាហ្មណា . . . . . . . . . ១១១

ទុតិយសមណព្រាហ្មណា . . . . . . . . . ១១៣




# រថវិនីតសូត្រ ទី ៤


មាតិកា . . . លេខទំព័រ

ឧបម្ពត្ត រថវិនីតសូត្រ ពោលអំពីសេចក្តីសន្តោសជាដើម . . . ៨១

សេចក្តីបរិកិត្តននៃព្រះសារីបុត្រ . . . . . . . . . . ៨៣

សេចក្តីសរសើរព្រះបុណ្ណៈ . . . . . . . . . . . ៨៥

វុសិតព្រហ្មចរិយបញ្ហា . . . . . . . . . . . ៨៧

វិសុទ្ធិទាំង ៧ . . . . . . . . . . . . . . ៩១

ឧបមាដោយរថព្រះទីនាំងទាំង ៧ . . . . . . . . ៩៣

ពាក្យរាក់ទាក់ទៅវិញទៅមក . . . . . . . . . . ៩៧


# និវាបសូត្រ ទី ៥


ឧបម្ពត្ត និវាបសូត្រ សេចក្តីប្រៀបដោយពួកម្រឹគ ទី ១ ទី ២ . . ១០១

សេចក្តីប្រៀបដោយពួកម្រឹគ ទី ៣ . . . . . . ១០៣

សេចក្តីប្រៀបដោយពួកម្រឹគ ទី ៤ . . . . . . ១០៧

សមណព្រាហ្មណ៍ពួក ទី ១ . . . . . . . . . ១១១

សមណព្រាហ្មណ៍ពួក ទី ២ . . . . . . . . . ១១៣

| មាតិកា | អង្កេ |
|---|---|
| ឧបម្មវគ្គស្ស និទានសុត្តេ តតិយសមណព្រាហ្មណា | ១១៨ |
| ចតុត្ថសមណព្រាហ្មណា | ១១៩ |
| មារមារបរិសានំ គតិ | ១២៣ |

## ឆដ្ឋំ បាសរាសិសុត្តំ

| មាតិកា | អង្កេ |
|---|---|
| ឧបម្មវគ្គស្ស បាសរាសិសុត្តេ ភគវតោ រម្មកអស្សមុបសង្កមនំ | ១២៧ |
| អនរិយបរិយេសនា | ១២៩ |
| អរិយបរិយេសនា | ១៣៣ |
| អាឡារុបសង្កមនំ | ១៣៨ |
| ឧទ្ទកុបសង្កមនំ | ១៣៩ |
| សន្តិវរបទបរិយេសនំ | ១៤៣ |
| អធិគតធម្មាវិដ្ឋនំ | ១៤៨ |
| សហម្បតិព្រហ្មជ្ឈេសនា | ១៤៧ |
| លោកំ វោលោកនំ | ១៤៩ |



| មាតិកា | លេខទំព័រ |
|---|---|
| ឧបម្មវគ្គ និទានសូត្រ សមណព្រាហ្មណ៍ពួក ទី ៣ | ១១៨ |
| សមណព្រាហ្មណ៍ពួក ទី ៤ | ១១៩ |
| ដំណើរនៃមារនិងបរិស័ទនៃមារ | ១២៣ |

## បាសរាសិសូត្រ ទី ៦

| មាតិកា | លេខទំព័រ |
|---|---|
| ឧបម្មវគ្គ បាសរាសិសូត្រ ព្រះមានព្រះភាគស្តេចចូលទៅកាន់អាស្រម របស់រម្មក ព្រាហ្មណ៍ | ១២៧ |
| ការស្វែងរកមិនប្រសើរ | ១២៩ |
| ការស្វែងរកដ៏ប្រសើរ | ១៣៣ |
| ស្តេចចូលទៅរកអាឡារតាបស | ១៣៨ |
| ស្តេចចូលទៅរកឧទ្ទកតាបស | ១៣៩ |
| ការទ្រង់ស្វែងរកសន្តិវរបទ | ១៤៣ |
| ការទ្រង់រំពឹងពីធម៌ដែលបានសម្រេចហើយ | ១៤៨ |
| ការក្រាបបង្គំទូលអារាធនានៃសហម្បតិព្រហ្ម | ១៤៧ |
| ការទ្រង់ប្រមើលមើលសត្វលោក | ១៤៩ |

មាតិកា អង្កេ

ឱបម្មវគ្គស្ស បាសរាសិសុត្តេ បឋមទេសនាវត្ថុំ . . . . . . ១៥១
ឧបកេន កថាសល្លាបោ . . . . . . . . . . ១៥៤
បញ្ចវគ្គិយធម្មទេសនា . . . . . . . . . . ១៥៧
បញ្ច កាមគុណា . . . . . . . . . . . ១៦៣
តិស្សោ មិគូបមា . . . . . . . . . . . ១៦៤
ចតុអរូបជ្ឈានំ . . . . . . . . . . . . ១៦៧

## សត្តមំ ចូឡហត្ថិបទោបមសុត្តំ

ឱបម្មវគ្គស្ស ចូឡហត្ថិបទោបមសុត្តេ ចត្តារិ បទានិ . . . . ១៧១
ជាណុស្សោណិឧទានំ . . . . . . . . . . ១៧៤
ចតុហត្ថិបទោបមា . . . . . . . . . . . ១៧៧
សិក្ខាសាជីវសមាបន្នកា . . . . . . . . . ១៨១
ចតុរូបជ្ឈានំ . . . . . . . . . . . . ១៨៧
ចុតូបបាតញាណំ . . . . . . . . . . . ១៨៩
អាសវក្ខយញាណំ . . . . . . . . . . . ១៩១



មាតិកា លេខទំព័រ

ឱបម្មវគ្គ បាសរាសិសូត្រ ការត្រិះរិះអំពីព្រះបឋមទេសនា . ១៥១
ទ្រង់មានព្រះពុទ្ធដីកាជាមួយនឹងឧបកាជីវក . . . . ១៥៤
ទ្រង់សម្តែងធម៌ដល់បញ្ចវគ្គិយភិក្ខុ . . . . . . . ១៥៧
កាមគុណ ៥ . . . . . . . . . . . . . . ១៦៣
ឧបមាដោយម្រឹគ ៣ ពួក . . . . . . . . . . ១៦៤
អរូបជ្ឈាន ៤ . . . . . . . . . . . . . ១៦៧

## ចូឡហត្ថិបទោបមសូត្រ ទី ៧

ឱបម្មវគ្គ ចូឡហត្ថិបទោបមសូត្រ ស្នាមព្រះបាទទាំង ៤ . . . ១៧១
ឧទានកថារបស់ជាណុស្សោណិព្រាហ្មណ៍ . . . . ១៧៤
ឧបមាដោយស្នាមជើងដំរីទាំង ៤ . . . . . . ១៧៧
ភាពជាអ្នកប្រកបព្រមដោយសិក្ខានិងសាជីវៈ . . . ១៨១
រូបជ្ឈាន ៤ . . . . . . . . . . . . . ១៨៧
ចុតូបបាតញាណ . . . . . . . . . . . . ១៨៩
អាសវក្ខយញាណ . . . . . . . . . . . . ១៩១

# អដ្ឋមំ មហាហត្ថិបទោបមសុត្តំ

មាតិកា | អង្កេ

ឧបមាវត្ថុស្ស មហាហត្ថិបទោបមសុត្តេ បឋវីធាតុ . . . . . ១៩៥

អាបោធាតុ . . . . . . . . . . . . . . ២០១

តេជោធាតុ . . . . . . . . . . . . . . ២០៣

វាយោធាតុ . . . . . . . . . . . . . . ២០៧

ខន្ធសង្គហោ . . . . . . . . . . . . . . ២១១

# នវមំ មហាសារោបមសុត្តំ

ឧបមាវត្ថុស្ស មហាសារោបមសុត្តេ ព្រហ្មចរិយសាខាបលាសោ ២១៧

ព្រហ្មចរិយបបដិកា . . . . . . . . . . . ២១៩

ព្រហ្មចរិយតចោ . . . . . . . . . . . ២២៣

ព្រហ្មចរិយផេគ្គុ . . . . . . . . . . . ២២៧

ព្រហ្មចរិយសារោ . . . . . . . . . . . ២៣១

ព្រហ្មចរិយបរិយោសានំ . . . . . . . . . ២៣៥



# មហាហត្ថិបទោបមសូត្រ ទី ៨

មាតិកា | លេខទំព័រ

ឧបមាវត្ថុ មហាហត្ថិបទោបមសូត្រ បឋវីធាតុ . . . . . . ១៩៥

អាបោធាតុ . . . . . . . . . . . . . . . ២០១

តេជោធាតុ . . . . . . . . . . . . . . . ២០៣

វាយោធាតុ . . . . . . . . . . . . . . . ២០៧

ខន្ធសង្គហៈ . . . . . . . . . . . . . . ២១១

# មហាសារោបមសូត្រ ទី ៩

ឧបមាវត្ថុ មហាសារោបមសូត្រ មែកនិងស្លឹកនៃព្រហ្មចរិយធម៌ . ២១៧

ក្រមរនៃព្រហ្មចរិយធម៌ . . . . . . . . . . ២១៩

សំបកនៃព្រហ្មចរិយធម៌ . . . . . . . . . ២២៣

ស្រាយនៃព្រហ្មចរិយធម៌ . . . . . . . . . . ២២៧

ខ្លឹមនៃព្រហ្មចរិយធម៌ . . . . . . . . . . ២៣១

ទីបំផុតនៃព្រហ្មចរិយធម៌ . . . . . . . . . ២៣៥

# ទសមំ ចូឡសារោបមសុត្តំ


| មាតិកា | បិដ្ឋ |
|---|---|
| ទុម្មត្តស្ស ចូឡសារោបមសុត្តំ សារត្ថុបមា . . . . . | ២៣៧ |
| បឋមបុគ្គលោ . . . . . . . . . . . . . . | ២៤១ |
| ទុតិយបុគ្គលោ . . . . . . . . . . . . . | ២៤៣ |
| តតិយបុគ្គលោ . . . . . . . . . . . . . | ២៤៥ |
| ចតុត្ថបុគ្គលោ . . . . . . . . . . . . . | ២៤៧ |
| បញ្ចមបុគ្គលោ . . . . . . . . . . . . . | ២៤៩ |
| ឧទ្ទានគាថា . . . . . . . . . . . . . . | ២៥៥ |


---



# ចូឡសារោបមសូត្រ ទី ១០


| មាតិកា | លេខទំព័រ |
|---|---|
| ទុម្មត្តិ ចូឡសារោបមសូត្រ ឧបមាដូចបុរសអ្នកត្រូវ | |
| ការរកខ្លឹមឈើ . . . . . . . . . . . . . | ២៣៧ |
| បុគ្គលទី ១ . . . . . . . . . . . . . . | ២៤១ |
| បុគ្គលទី ២ . . . . . . . . . . . . . . | ២៤៣ |
| បុគ្គលទី ៣ . . . . . . . . . . . . . . | ២៤៥ |
| បុគ្គលទី ៤ . . . . . . . . . . . . . . | ២៤៧ |
| បុគ្គលទី ៥ . . . . . . . . . . . . . . | ២៤៩ |
| ឧទ្ទានគាថា . . . . . . . . . . . . . . | ២៥៥ |

# សេចក្តីកែប្រែពាក្យ ខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ដូចម្តេ | ដូចម្តេច | ១៩ | ៦ |
| បន្សៀតបន្ទុលចិត្តបំណោះ | បន្សៀតបន្ទុលចិត្តបំណោះ ៗ | ,, | ៨ |
| បានឃើញពស់វែក ១ | បានឃើញពស់វែក ១ | ៤១ | ៧ |
| ក៏ដល់នូវភាពស្តាំនស្តម | ក៏ដល់នូវភាពស្តាំន | | |
| ក្រៃពេក | ស្តាប់ក្រៃពេក | ១០៣ | ១៥ |
| ស្ងប្បដោយសេចក្តីព្យា- | ស្ងប្បដោយសេចក្តី | | |
| យាមនោះ | ព្យាយាមនោះ | ១៥៨ | ៤ |
| ដោយបរិកម្មថា | ដោយប្រការទាំងពួង | | |
| | ហើយបរិកម្មថា | ១៦៧ | ៧ |
| ៗ មេ ៗ | ៗ បេ ៗ | ១៨៧ | ១៧ |
| សិបស្លូនទៅក្នុងកាម្មណ៍ | សិបស្លូនទៅក្នុងកាម្មណ៍ | | |
| គឺជាគុណនោះឯង | គឺជាគុណនោះឯង ៗ | ១៩៦ | ១៥ |
| ទាំង ៤ នេះ | ទាំង ៥ នេះ | ៤១៤ | ១៧ |
| មានសេចក្តី | មានសេចក្តី | ៤១៩ | ,, |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធភាសា | អវិរុទ្ធភាសា | អង្កេ | បន្ទុលេខាយំ |
|---|---|---|---|
| អគារិប្ប | អភិប្ប | ១៨៧ | ១៧ |